ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

# ឯកសារណែនាំអនុវត្ត
# ស្តីពី
# ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

## ដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់

រៀបចំដោយអគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម
គាំទ្រដោយកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងទ្រទ្រង់ជីវភាពរស់នៅ (NRM&L)
ឧបត្ថម្ភដោយ : DANIDA/DFID/NZAid

ឆ្នាំ ២០០៩

# មាតិកា


បញ្ជីពាក្យកាត់ ........ ៤

សេចក្តីផ្តើម ........ ៦

១. គោលបំណង និងយុត្តាធិការ ........ ៧

១.១ គោលបំណង ........ ៧

១.២ ខ្លឹមសារសង្ខេបនៃឯកសារណែនាំអនុវត្ត ........ ៨

២ ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ........ ៩

២.១ តើការរៀបចំផែនការជាអ្វី ? ........ ៩

២.២ និយមន័យ និងគោលបំណងនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ........ ១១

២.៣ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ........ ១២

២.៣.១ ការសំរេចលើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ........ ១៣

២.៤ ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីផ្សេងៗទៀត ........ ១៥

២.៤.១ ការធ្វើផែនការប្រើប្រាស់ដីថ្នាក់ភូមិ ........ ១៥

២.៤.២ ការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ថ្នាក់ឃុំ សង្កាត់ ........ ១៦

២.៤.៣ ការកែសម្រួលព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ........ ១៦

២.៤.៤ ការកំណត់ព្រំប្រទល់ដែនព្រៃឈើ ........ ១៦

២.៤.៥ សិទ្ធិលើដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ........ ១៧

២.៤.៦ កម្មវិធីសម្បទានដីសង្គមកិច្ច ........ ១៧

២.៤.៧ ការធ្វើអត្តសញ្ញាណកម្ម និងការគូសផែនទីដីរដ្ឋ ........ ១៨

២.៤.៨ ដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានរ៉ែ ........ ១៩

២.៤.៩ សហគមន៍ព្រៃឈើ ........ ១៩

២.៤.១០ សហគមន៍នេសាទ ........ ១៩

២.៤.១១ ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ ........ ២០

២.៥ ក្របខណ្ឌគតិយុត្តសំរាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ........ ២០

៣. ផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ........ ២២

៣.១ គណៈកម្មាធិការកសាងផែនការ និងថវិកា ឃុំ សង្កាត់ ........ ២២

៣.១.១ ជំហានទីមួយៗនៃដំណើរការរៀបចំផែនការ ........ ២៣

៣.២ ការគាំទ្រសំរាប់ការរៀបចំផែនការថ្នាក់ឃុំ សង្កាត់ ........ ២៤

៤. ទិដ្ឋភាពទូទៅនៃសកម្មភាពរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ........ ២៧



346.045
LAN
sh land use
NCDD Library
000041

៤.១ ទំនាក់ទំនងរវាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់
ជាមួយនឹងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ..... ២៧
៤.១.១ យន្តការស្ថាប័ន ..... ២៧
៤.១.២ ការអនុម័តលើសំណើរផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ..... ៣១
៤.១.៣ អ្នកចូលរួមរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ..... ៣២
៤.២ ការគ្រប់គ្រងទិន្នន័យ (Data Management) ..... ៣២
៤.៣ ទិដ្ឋភាពទូទៅនៃតួនាទី និងការទទួលខុសត្រូវក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ..... ៣២
៥. ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ..... ៣៤
ការងារ A : ការត្រៀមរៀបចំ ..... ៣៥
សកម្មភាព ០.១ : ការធ្វើអត្តសញ្ញាណកម្មដីរដ្ឋ ..... ៣៧
សកម្មភាព ០.២ : ការប្រមូលទិន្នន័យអំពីប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំ ..... ៣៩
សកម្មភាព ០.៣ : ការប្រមូលទិន្នន័យ អំពីការប្រើប្រាស់ដី និងគំរបដី ..... ៤១
សកម្មភាព ០.៤ : ការធ្វើអត្តសញ្ញាណកម្ម និងការគូសផែនទី "តំបន់រសើប" ..... ៤៣
សកម្មភាព ០.៥ : ការប្រមូលព័ត៌មានអំពីគោលបំណងអភិវឌ្ឍន៍ដែលបានមកពីផែនការអនុម័តរួច ..... ៤៥
សកម្មភាព ០.៦ : ការផលិតផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ..... ៤៦
ការងារ B: ការផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពគោលបំណង អភិវឌ្ឍន៍ ( ផអឃ ជំហាន១) ..... ៤៨
សកម្មភាព ១.១: គណៈកម្មការផែនការ
និងថវិកាធ្វើការពិនិត្យសារឡើងវិញនូវផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ..... ៥០
សកម្មភាព ១.២ : ការវិភាគ និងការគូសផែនទី បញ្ហា មូលហេតុ និង ដំណោះស្រាយ ..... ៥២
សកម្មភាព ១.៣: គណៈកម្មាធិការកសាងផែនការ និងថវិកា
ពិនិត្យសារឡើងវិញនិងធ្វើបច្ចុប្បន្នភាពបញ្ជីគោលបំណងអភិវឌ្ឍន៍ ..... ៥៤
សកម្មភាព ១.៤ : ការធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ ..... ៥៥
សកម្មភាព ១.៥ : ការរៀបចំផែនការបឋមប្រើប្រាស់ដីពេលអនាគត ..... ៥៨
ការងារ C : ការកសាងផែនទីសំរេច ( ផអឃ ជំហាន៣) ..... ៦០
សកម្មភាព ៣.១ : គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យសារឡើងវិញ
និងធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដី ..... ៦១
សកម្មភាព ៣.២ : គណៈកម្មាធិការកសាងផែនការ និងថវិកា រៀបចំផែនទីបញ្ហា មូលហេតុ
និងដំណោះស្រាយ ..... ៦៣
ការងារ D : ការគាំទ្រដល់ការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ ( កវឃ ជំហាន១) ..... ៦៥

សកម្មភាព ១.១ : គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការពិនិត្យផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សារឡើងវិញ ........ ៦៥
សកម្មភាព ១.២ : ការវិភាគ និងការគូសផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ........ ៦៩
សកម្មភាព ១.៣ : ការធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ ........ ៧១
សកម្មភាព ១.៤ : ការរៀបចំផែនការបឋមប្រើប្រាស់ដីពេលអនាគត ........ ៧៣
សកម្មភាព ១.៥ : ការជ្រើសរើសគំរោងដីធ្លីសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់ ........ ៧៥
សកម្មភាព ១.៦ : ការធ្វើបច្ចុប្បន្នភាពផែនទីគំរោង ........ ៧៦
ការងារ E : ការរៀបចំពង្រាងផែនការប្រើប្រាស់ដី( កវ័យ ជំហាន២) ........ ៧៨
សកម្មភាព ២.១ : ការរៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដើម្បីសុំការអនុម័ត ........ ៧៩
ការងារ F: ការគាំទ្រឃុំ សង្កាត់ក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ( កវ័យ ជំហាន៣) ........ ៨១
សកម្មភាព ៣.១ : ការធ្វើបទបង្ហាញអំពីសេចក្តីព្រាងផែនទីគំរោង និងផែនទីប្រើប្រាស់ដីពេលអនាគត ........ ៨២
ការងារ G : ការកសាងផែនទីសំរេចសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់ ( កវ័យ ជំហាន៤) ........ ៨៤
សកម្មភាព ៤.១: ការធ្វើបច្ចុប្បន្នភាពផែនទីគំរោង នៅទីណាដែលមានភាពសមស្រប ........ ៨៥
ការងារ H : ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ( កវ័យ ជំហាន ៥) ........ ៨៦
សកម្មភាព ៥.១ : ការលើកកំពស់សមត្ថភាពគណៈកម្មាធិការកសាងផែនការ និងថវិកា/តំណាងឃុំ សង្កាត់ ........ ៨៧

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១ : - ក្របខ័ណ្ឌច្បាប់សំរាប់រៀបចំផែនដី និងផែនការប្រើប្រាស់ដី ........ ៩១
- អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
ឧបសម្ព័ន្ធ ២ : ឃុំ សង្កាត់ដែលបានអនុវត្តការចូលរួមរៀបចំផែនការប្រើប្រាស់ដី (PLUP) ........ ១០៨
ឧបសម្ព័ន្ធ ៣: ទិដ្ឋភាពរួមនៃឃុំ សង្កាត់ដែលមានការវិភាគក្សេត្រ—បរិស្ថាន ........ ១០៩
ឧបសម្ព័ន្ធ ៤ : ការពិពណ៌នាអំពីការប្រើប្រាស់ដី/គំរបដី ( ផែនទីមាត្រដ្ឋាន) ........ ១១៦
ឧបសម្ព័ន្ធ ៥ : ការរៀបចំផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ........ ១២៦
ឧបសម្ព័ន្ធ ៦ : ការរៀបចំផែនទីបង្ហាញតំបន់មានបញ្ហាចោទ ( តំបន់រសើប) ........ ១៣១
ឧបសម្ព័ន្ធ ៧ : ការវិភាគដីសមស្រប និងជំរើសនៃការប្រើប្រាស់ដីពេលអនាគត ........ ១៣៥
ឧបសម្ព័ន្ធ ៨ : តម្រូវការទិន្នន័យសំរាប់រៀបចំផែនទីតំបន់មានបញ្ហាចោទ និង ការវិភាគដីសមស្រប ........ ១៤២
ឧបសម្ព័ន្ធ ៩ : រចនាសម្ព័ន្ធក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ........ ១៤៥
ឧបសម្ព័ន្ធ ១០: មាតិកានៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ........ ១៤៦
ឧបសម្ព័ន្ធ ១១ : ទំរង់ស្នើសុំថវិកាវិនិយោគ ........ ១៥៩
ឧបសម្ព័ន្ធ ១២ : និយមន័យនៃពាក្យមួយចំនួន ........ ១៦៣

# បញ្ជីពាក្យកាត់

| | |
|---|---|
| ក្រសួង ដ.ន.ស<br>MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>Ministry of Land Management, Urban Planning and Construction |
| មន្ទីរ ដ.ន.ស.ស<br>PDLMUPCC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត<br>Provincial Department of Land Management, Urban Planning, Construction and Cadastre |
| ការិ.ដ.ន.ស.ភ<br>DOLMUPC | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ<br>Disrtict  Office of Land Management, Urban Planning, Construction and Land Titling |
| គ.គ្រ.ដ.រ.ខ<br>PSLMC | គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត<br>Provincial State Land Management Committee |
| ក.ក.ដ.រ.ស<br>DSLWG | ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ<br>District State Land Working Group |
| គ.ស.ស.ជ<br>NSLCC | គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ<br>National Social Land Concession Committee |
| គ.ប.ដ.រ.ខ<br>PLUAC | គណៈកម្មការប្រើប្រាស់ និងបែងចែកដីថ្នាក់រាជធានី ខេត្ត<br>Provincial Land Use and Allocation Committee |
| ក.ក.ស<br>DWG | ក្រុមការងារថ្នាក់ក្រុង ស្រុក ខ័ណ្ឌ<br>District Working Group |
| ក.ស.ផ.ប.ជ<br>N-LUP Team | ក្រុមសម្របសម្រួលផែនការប្រើប្រាស់ដីថ្នាក់ជាតិ<br>National Land Use Planning Team |
| ក.ស.ផ.ប.ខ<br>P-LUP Team | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត<br>Provincial Land Use Planning Team |
| ក.ស.ផ.ប.ស្រ<br>D-LUP Team | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ<br>District Land Use Planning Team |
| ក្រុម GIS<br>GIS Team | ក្រុមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ<br>Geographic Information System Team |
| កបឃ<br>CC | ក្រុមប្រឹក្សាឃុំ សង្កាត់<br>Commune Council |
| គផថ<br>PBC | គណៈកម្មាធិការកសាងផែនការ និងថវិកា ឃុំ សង្កាត់<br>Planning and Budgeting Committee |
| ផអឃ<br>CDP | ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់<br>Commune Development Plan |
| កវឃ<br>CIP | កម្មវិធីវិនិយោគឃុំ សង្កាត់<br>Commune Investment Program |
| បមដ<br>PCS | បញ្ហា មូលហេតុ និងដំណោះស្រាយ<br>Problem Cause and Solution |

| | |
|---|---|
| ក.ស.ខ<br>PFT | ក្រុមសម្របសម្រួលថ្នាក់រាជធានី ខេត្ត<br>Provincial Facilitation Team |
| ក.ស.ស្រ<br>DFT | ក្រុមសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ<br>District Facilitation Team |
| ក.ប.អ.ស.ស<br>LASED | ការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច<br>Land Allocation for Social and Economic Development |
| UXO | គ្រាប់-អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ<br>Un-exploided Ordnance |
| ត.ក.ជ<br>IFBA | តំបន់ធ្វើកសិកម្ម និងជីវចំរុះ<br>Intergrated Farming and Biodiversity Area |
| ក.ផ្ស.ក.ក.អ<br>CAAEP | កម្មវិធីផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី<br>Cambodia Australian Agricultural Extension Program |
| គ.ជ.វ.វ<br>NCDD | គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>National Committee for the Management of Decentralization and Deconcentration Reform |
| ក.គ.ក.វ.វ<br>PSDD | កម្មវិធីគាំទ្រដល់កំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ<br>Program to Support Decentralization and Deconcentration Reform |
| ត.អ.ប.ម.ទ.ស<br>TSBR | តំបន់អភិរក្សជីវមណ្ឌលបឹងទន្លេសាប<br>Tonle Sap Biosphere Reserve |
| ត.ក.ស<br>CPA | តំបន់ការពាររបស់សហគមន៍<br>Community Protected Areas |
| ស.ដ.ស<br>ELC | សម្បទានដីសេដ្ឋកិច្ច<br>Economic Land Concession |
| ស.ព.ឈ<br>CF | សហគមន៍ព្រៃឈើ<br>Community Forestry |
| ស.គ.ន<br>CFi | សហគមន៍នេសាទ<br>Community Fishery |

# សេចក្ដីផ្ដើម

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សំដៅដល់ផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជនរបស់បុគ្គលឯកជន។ ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់នេះមានគោលបំណង :

- ផ្ដល់សមត្ថកិច្ចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានដី និង ធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាព និង កាត់បន្ថយទំនាស់ ក្នុងការប្រើប្រាស់ដីធ្លី
- គាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព និងសមធម៌
- រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- ជួយសំរេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំ សង្កាត់ ស្របតាមស្ថានភាពដីជាក់ស្ដែង និងសក្ដានុពលធម្មជាតិនៃដី
- ឆ្លើយតបចំពោះសេចក្ដីត្រូវការរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់
- ជួយការពារធនធានដី និងធនធានធម្មជាតិផ្សេងៗទៀតមិនឱ្យបាត់បង់គុណភាព និងមិនឱ្យប្រើប្រាស់ខុសទិសដៅ
- រួមចំណែកក្នុងការកំណត់ និងគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ សង្កាត់ឱ្យបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាងរដ្ឋរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ស្វែងរកការគាំទ្របច្ចេកទេសពីស្ថាប័ន អង្គភាពនានា និងពីផ្នែកឯកជន ដើម្បីបំពេញបន្ថែមចំពោះការរៀបចំកសាង ផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

ពិនិត្យជារួម ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់នេះ ជាឧបករណ៍មួយដ៏សំខាន់ដែលជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌។ ជាការពិត ដីធ្លីគឺជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ជីវភាពប្រជាពលរដ្ឋ ដូច្នេះក្រោយពេលដែលមានផែនការប្រើប្រាស់ដីនេះ អាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដីទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចថ្នាក់មូលដ្ឋានដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័ត នៅថ្នាក់ខេត្ត និងរាជធានី តាមនីតិវិធី ដូចដែលធ្លាប់អនុវត្តក្នុងការការកសាងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច កន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធចូលរួមធ្វើការសំរេច។

គំនិតផ្ដួចផ្ដើមការងារនេះ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយមានកិច្ចគាំទ្រពី DANIDA/DFID/NZAid តាំងតែពីឆ្នាំ ២០០៦មក ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិ និងទ្រទ្រង់ជីវភាពរស់នៅ ក្នុងអនុសមាសភាគរៀបចំដែនដី។

ដើម្បីឱ្យការអនុវត្តនៅមូលដ្ឋានប្រព្រឹត្តិទៅបានងាយស្រួលនោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំឯកសារណែនាំអនុវត្តស្ដីពី **ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់** ដើម្បីគាំទ្រដល់ដំណើការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ (រយៈពេលប្រាំឆ្នាំ) និងកម្មវិធីវិនិយោគឃុំ សង្កាត់ (រយៈពេលមួយឆ្នាំ) ដូចមានចែងនៅក្នុងអនុក្រឹត្យស្ដីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ សមិទ្ធិផលនៃដំណើរការរៀបចំផែនការនេះគឺ "ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់"។

# ១. គោលបំណង និងយុត្តាធិការ

## ១.១ គោលបំណង

ឯកសារណែនាំអនុវត្តស្តីពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ផ្តល់ព័ត៌មានជាលំអិតថា តើត្រូវបំពេញការងារយ៉ាងដូចម្តេចខ្លះ ដើម្បីឱ្យស៊ីសង្វាក់គ្នានឹងដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ ឯកសារណែនាំអនុវត្តនេះ មានបំណងគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីរៀបចំផែនការ និងជំរើសនានានៃការប្រើប្រាស់ដីសំរាប់ពេលអនាគត។ អ្នកប្រើប្រាស់ឯកសារណែនាំអនុវត្តនេះជាបឋមគឺ ក្រុមប្រឹក្សាឃុំ សង្កាត់ (គណៈកម្មាធិការកសាងផែនការ និងថវិកា) និងមន្ត្រីដែលទទួលភារកិច្ចគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់។ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ត្រូវដាក់ជូនក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីស្នើសុំសេចក្តីសំរេច។ ដំណើរការនៃ ការរៀបចំផែនការ នេះ ដូចមានបង្ហាញនៅក្នុងដ្យាក្រាម ១ ។ ទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំអនុវត្តនេះ គឺដូចមានបង្ហាញក្នុងប្រអប់ដែលមានស្នាមអុច១ពណ៌ក្រហមព័ទ្ធជុំវិញក្នុងដ្យាក្រាម១ ។




**ដ្យាក្រាម១** : ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ (ផបដឃ)

## ១.២ ខ្លឹមសារសង្ខេបនៃឯកសារណែនាំអនុវត្ត

ផ្នែកនេះបង្ហាញអំពីដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ តាមដំណាក់កាលនិមួយៗ :

- តើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ជាអ្វី? តើផែនការនេះមានទំនាក់ទំនងយ៉ាងណាទៅនឹងការប្រើប្រាស់ដីផ្សេងៗទៀត? ➔ សូមមើលជំពូក២
- តើមានក្របខណ្ឌគតិយុត្តណាខ្លះដែលគាំទ្រដល់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ? ➔ សូមមើលជំពូក៣
- តើមានគោលការណ៍អ្វីខ្លះ គាំទ្រដល់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់? តើការគូសផែនទី និងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ស្ថិតនៅក្នុងដំណាក់កាលណា ? ➔ សូមមើលជំពូក៣
- តើត្រូវការអ្វីខ្លះសំរាប់រៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងត្រូវប្រើផែនការនេះយ៉ាងដូចម្តេច សំរាប់កសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់? ហើយត្រូវស្នើសុំសេចក្តីសំរេចពីអាជ្ញាធរតាមលំដាប់ថ្នាក់យ៉ាងដូចម្តេច? ➔ សូមមើលជំពូក៤
- តើមានសកម្មភាពអ្វីខ្លះសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ នៅក្នុងជំហាននិមួយៗ (អ្នកណាជាអ្នកធ្វើ តាមរបៀបណា និងទទួលបានលទ្ធផលអ្វី)? ➔ សូមមើលជំពូក ៥

| គោលការណ៍ណែនាំនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ | លទ្ធផលនៃការរៀបចំផែនការប្រើប្រាសដីនៅក្នុងឃុំ សង្កាត់ |
|---|---|
| ១. កំណត់អត្តសញ្ញាណកម្មនៃការប្រើប្រាស់ដីបច្ចុប្បន្ន និងសក្តានុពលនៃដីសំរាប់អនាគត ព្រមទាំងឧបសគ្គនានាដែលអាចកើតមាន ។<br>២. គប្បីធ្វើយ៉ាងណាឱ្យសមស្របទៅតាមសមត្ថភាពរបស់ឃុំ សង្កាត់ ។<br>៣. ត្រូវផ្សារភ្ជាប់នឹងដំណើរការ និងគោលការណ៍នៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងផែនការវិនិយោគឃុំ សង្កាត់ដែលមានស្រាប់ ។<br>៤. ជួយគាំទ្រក្នុងការដោះស្រាយទំនាស់នៃការប្រើប្រាស់ដី និងផ្តល់នូវមូលដ្ឋានសំរាប់ការវិនិយោគ និងកិច្ចព្រមព្រៀង ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីនៅមូលដ្ឋាន ។<br>៥. ធ្វើសមាហរណកម្មទៅក្នុងផែនការអភិវឌ្ឍន៏ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងធ្វើជាឯកសារផែនការប្រើប្រាស់ដី ដោយឡែកសំរាប់សុំសេចក្តីសំរេចពីក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ។ | ១. ការវិភាគនូវស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ននៅក្នុងឃុំ សង្កាត់ ៖<br>○ កែសម្រួល និងធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដី (រួមមានហេដ្ឋារចនាសម្ព័ន្ធ ដីសម្បទាន តំបន់ការពារ សហគមន៍ព្រៃឈើ ។ល ។)<br>២. ការវិភាគសក្តានុពល និងឧបសគ្គនៃការប្រើប្រាស់ដី ៖<br>○ សក្តានុពល៖ដីសម្បទានសេដ្ឋកិច្ច ដីសម្បទានសង្គមកិច្ច ការកែលំអកសិកម្ម សហគមន៍នេសាទ ។ល ។<br>○ ឧបសគ្គ ៖ដីពុំមានជីជាតិ ដីមានទំនាស់ ។ល ។<br>៣. ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ (រួមមានជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត)<br>៤. ផែនការអនុវត្ត (ដែលជាចំណែកមួយនៃ ផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់) កំណត់នូវគំរោង សំរាប់ធ្វើការអភិវឌ្ឍនាពេលអនាគត និងគំរោងផ្សេងៗនៅលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន ដែលទាក់ទងទៅនឹងការលើកសំណើអនុវត្តតាមជំហាន និងតាមកាលវេលា ។ |

**ប្រអប់១:** គោលការណ៍ណែនាំ និងលទ្ធផលនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ (ផបដយ)

## ២  ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

### ២.១ តើការរៀបចំផែនការជាអ្វី ?

**ការរៀបចំផែនការ** គឺជាដំណើរការដែលអ្នកពាក់ព័ន្ធទាំងអស់រួមគ្នារៀបចំ និងព្រមព្រៀងជារួមថា តើត្រូវធ្វើការងារណាមួយយ៉ាងដូចម្តេច?។ ឧទាហរណ៍ ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ ការរៀបចំផែនការថ្នាក់មូលដ្ឋាននេះ ត្រូវអនុលោមតាម ឬ បំពេញបន្ថែមផែនការដែលមានលំដាប់ខ្ពស់ជាង។ ឧទាហរណ៍ចំពោះការរៀបចំផែនការប្រើប្រាស់ដី ផែនការថ្នាក់ឃុំ សង្កាត់ត្រូវផ្តល់ជាព័ត៌មានដល់ការធ្វើផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលផ្សារភ្ជាប់នឹងផែនការថ្នាក់រាជធានី ខេត្ត និងផែនការថ្នាក់ជាតិ (សូមមើល រូប១)។




រូប១ : ប្រព័ន្ធរៀបចំផែនការរៀបចំដែនដី

រូប១ គឺជាការផ្តួចផ្តើមបង្ហាញអំពីប្រព័ន្ធនៃការកសាងផែនការរៀបចំដែនដីតាមលំដាប់ថ្នាក់។ ផែនការថ្នាក់មូលដ្ឋានបំពេញបន្ថែមឱ្យផែនការដែលមានថ្នាក់ខ្ពស់ជាង ចំណែកផែនការដែលមានថ្នាក់ខ្ពស់ជាងមានអនុភាពលើផែនការដែលមានថ្នាក់ទាបជាង។ ឧទាហរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកំណត់តំបន់សក្តានុពលសំរាប់បង្កើតសហគមន៍ព្រៃឈើ ដូច្នេះក្នុងផែនទីប្រើប្រាស់ដីអនាគត ក៏ដូចជានៅក្នុង ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវគោរពទៅតាមការកំណត់នេះដែរ។ ចំណែកការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ ត្រូវលើកស្នើឡើងអំពីតម្រូវការថវិកា ឬស្នើការគាំទ្រពីស្ថាប័ន ជំនាញដើម្បីសំរបសំរួលការអនុវត្ត (រូប ២)។

ការប្រើប្រាស់ដីនៅជនបទមានការពាក់ព័ន្ធគ្នាទៅវិញទៅមករវាងការប្រើប្រាស់ដីសំរាប់កសិកម្ម ព្រៃឈើ នេសាទ ការអភិរក្សសត្វព្រៃ ទេសចរណ៍ ...។ ការរៀបចំផែនការនៅជនបទត្រូវតែកំណត់ឱ្យបានច្បាស់ផងដែរអំពីការរីករាលដាលនៃទីក្រុង និងឧស្សាហកម្ម ដោយកំណត់ថាតើដីតំបន់ណាដែលគួរតែបំរុងទុកប្រើប្រាស់សំរាប់វិស័យកសិកម្ម ព្រោះវិស័យនេះនៅតែមានសារៈសំខាន់ជាសារវ័ន្តសំរាប់តំបន់ជនបទ។

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

១. ត្រូវអនុវត្តតាមវិធីសាស្ត្រដែលមានលក្ខណៈចូលរួម ដោយតម្រូវឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធពីគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់នីមួយៗ ព្រមទាំងពីក្រុមសង្គមស៊ីវិលដែលមានការពាក់ព័ន្ធនឹងការងារដីធ្លី ។

២. ត្រូវស្របតាមគម្រោងផែនការអភិវឌ្ឍដែលមានជាផ្លូវការនៅថ្នាក់ឃុំ សង្កាត់ ដែលអាចជាប្រភេទនៃការអភិវឌ្ឍចម្រុះ ឬជាប្រភេទនៃការអភិវឌ្ឍដោយផ្អែកតាមប្រភពធនធានជាក់លាក់នីមួយៗ តាមទស្សនៈភូមិមួយផលិតផលមួយ ឬតាមលក្ខណៈពិសេសជាក់លាក់របស់តំបន់នីមួយៗ ។

៣. ត្រូវយកផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ។

៤. ត្រូវបើកចំហររាល់ព័ត៌មានទាំងអស់ចំពោះគ្រប់ភាគីពាក់ព័ន្ធ ។

៥. ត្រូវផ្តល់អាទិភាពខ្ពស់ដល់តម្រូវការដីនៅមូលដ្ឋាន ឃុំ សង្កាត់សាមីនាពេលបច្ចុប្បន្ន និងទៅអនាគតសម្រាប់រយៈពេលពី ១០ទៅ ១៥ឆ្នាំខាងមុខ សម្រាប់សេវានិងការប្រើប្រាស់ជាសាធារណៈសម្រាប់ការដោះស្រាយការតាំងទីលំនៅថ្មីដែលបណ្តាលមកពីគម្រោងអភិវឌ្ឍរបស់រដ្ឋ គម្រោងអភិវឌ្ឍរបស់មូលដ្ឋាន គ្រោះធម្មជាតិផ្សេងៗ ឬកំណើនប្រជាពលរដ្ឋ តាមរយៈការបម្រុងដីទុកសម្រាប់គោលដៅជាក់លាក់នីមួយៗស្របតាមបញ្ញត្តិច្បាប់ទាំងឡាយ ដូចជាការផ្តល់ដីតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចជាដើម ។

៦. ការធ្វើផែនការប្រើប្រាស់ដីមិនមែនជាការផ្តល់ដីឬបែងចែកដីជាក់ស្តែងនោះទេ ។




**រូប ២ :** ទំនាក់ទំនងរវាងដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់/កម្មវិធីវិនិយោគ ឃុំ សង្កាត់ និងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

## ២.២ និយមន័យ និងគោលបំណងនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

*ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់* គឺសំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជនរបស់បុគ្គលឯកជន (ជាដំណើរការដែលមានតម្លាភាព និងមានការចូលរួមពីប្រជាពលរដ្ឋ) ដោយប៉ាន់ប្រមាណពីសក្តានុពលដី និងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជំរើសដ៏ល្អបំផុតក្នុងការប្រើប្រាស់ដី។ គោលបំណងនៃផែនការនេះ គឺធ្វើយ៉ាងណាឱ្យការប្រើប្រាស់ដីមាននិរន្តរភាព បំពេញបានទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ការវិនិយោគ ព្រមទាំងការពារបានប្រភពធនធានសំរាប់ពេលអនាគត។

*ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់* ជួយពង្រឹងនូវយុទ្ធសាស្រ្តក្នុងការអភិវឌ្ឍឃុំ សង្កាត់ ក្រោមទម្រង់នៃកម្មវិធីវិនិយោគឃុំ សង្កាត់ និងផែនការអភិវឌ្ឍឃុំ សង្កាត់។ បន្ថែមពីលើនេះទៀត ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ជួយគាំទ្រដល់ការអភិវឌ្ឍតាមវិស័យក្នុងតំបន់នានា ដែលស្ថិតនៅក្នុងឃុំ សង្កាត់ ឬឆ្លងឃុំ សង្កាត់ ដូចជាការគ្រប់គ្រង តំបន់ការពារ និងការគ្រប់គ្រងទីជំរាលជាដើម។

*ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី* ជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកចូលរួមឯទៀត ដើម្បីពន្យល់អំពីគោលនយោបាយ និងផែនការដែលមានរួចមកហើយ។ ក្រុមសម្របសម្រួលផែនការប្រើប្រាស់ដី ក៏ជួយគាំទ្រផងដែរដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការសម្របសម្រួលដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ប្រកបដោយគុណភាពដែលធានាបាននូវការចូលរួមរបស់អ្នកភូមិយ៉ាងពេញលេញ ហើយត្រូវមានតំណាងចូលរួមគ្រប់គ្រាន់ (ជាពិសេសគឺមានតំណាងស្ត្រី និងជនជាតិដើមភាគតិច)។

**ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គប្បីសំរេចឱ្យបានដូចខាងក្រោម:**

| | *ផែនការប្រើប្រាស់ដីដែលល្អអាច ៈ* |
|---|---|
| ១. ផ្តល់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព។<br>២. គាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ប្រកបដោយចីរភាព និងសមធម៌។<br>៣. រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។<br>៤. ជួយឱ្យសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំ សង្កាត់ ស្របតាមស្ថានភាពដីជាក់ស្តែងនិងសក្តានុពលធម្មជាតិ ។<br>៥. ឆ្លើយតបចំពោះសេចក្តីត្រូវការដីរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់។<br>៦. ជួយការពារធនធានដី និងធនធានធម្មជាតិផ្សេងៗទៀតមិនឱ្យបាត់បង់គុណភាព និងមិនឱ្យប្រើប្រាស់ខុសទិសដៅ។ | ◦ ផ្តល់នូវវិធីសំរាប់ធ្វើសេចក្តីសំរេចចិត្តកាន់តែបានល្អប្រសើរ និងសមស្រប<br>◦ សម្របសម្រួលជាមួយនឹងសកម្មភាពអភិវឌ្ឍផ្សេងៗក្នុងការធ្វើសេចក្តីសំរេចចិត្តរួមគ្នា ដើម្បីធ្វើឱ្យការអភិវឌ្ឍន៍ទាំងនោះបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ជាជាងការប្រទាញប្រទង់គ្នា។<br>◦ ផ្តល់នូវទិដ្ឋភាពជាក់ស្តែងនៃស្ថានភាពបច្ចុប្បន្ន និងនិន្នាការវិវត្តរបស់វា។<br>◦ ជួយដល់សហគមន៍នូវការប៉ាន់ប្រមាណពីសំណើអភិវឌ្ឍន៍សំរាប់ពេលអនាគតឱ្យស្របទៅតាមគោលបំណងរបស់សហគមន៍ |

| | |
|---|---|
| ៧. រួមចំណែកក្នុងការកំណត់ និងគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ សង្កាត់ឱ្យបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាងរដ្ឋរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។<br>៨. ស្វែងរកការគាំទ្រផ្នែកបច្ចេកទេសពីស្ថាប័ន អង្គភាពនានា និងពីផ្នែកឯកជន ដើម្បីបំពេញបន្ថែមចំពោះការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ | ◦ ស្វែងរកជាបន្ថែមទៀតនូវជំរើសផ្សេងៗ និងផ្តល់នូវក្របខណ្ឌការងារជារួមសំរាប់ទប់ទល់នឹងស្ថានភាពផ្លាស់ប្តូរនៅក្នុងសហគមន៍ ។ |

**គោលបំណងជាចំបងនៃដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺ :**

- ◦ វិភាគស្ថានភាពបច្ចុប្បន្ននៅក្នុងឃុំ សង្កាត់អំពីការប្រើប្រាស់ដី សិទ្ធិកាន់កាប់ដី ទំនាស់ដីធ្លី ព្រមទាំងកំណត់បញ្ហា មូលហេតុ និងដំណោះស្រាយ
- ◦ ត្រួតពិនិត្យជំរើសនានានៃការប្រើប្រាស់ដីពេលអនាគតសំរាប់ឃុំ សង្កាត់ ដោយផ្អែកលើសេចក្តីត្រូវការចាំបាច់របស់ឃុំ សង្កាត់នោះ និងការវិភាគភាពសមស្របនៃដី ដើម្បីត្រៀមបំរុងសំរាប់ការប្រើប្រាស់ដីទាំងនោះសំរាប់ពេលអនាគត
- ◦ រៀបចំបង្កើតផែនការអនុវត្តមួយដែលជាមូលដ្ឋានសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់ ដោយកំណត់គំរោងអភិវឌ្ឍពេលអនាគត និងសកម្មភាពនានានៅលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន ហើយផ្សារភ្ជាប់ទៅនឹងជំហ៊ាន និងកាលវេលាអនុវត្តដែលបានគ្រោងឡើង។

## ២.៣ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ដើម្បីធ្វើឱ្យងាយស្រួលក្នុងការអនុវត្តនៅមូលដ្ឋានឃុំ សង្កាត់ គំរូស្តង់ដារមួយសំរាប់ការរៀបចំផែនការប្រើប្រាស់ដីត្រូវបានរៀបចំ ហើយគ្រាន់តែឱ្យក្រុមប្រឹក្សាឃុំ សង្កាត់បំពេញតាមគំរូស្តង់ដារនោះ។ គំរូស្តង់ដារនេះមានទម្រង់ជាផែនទីសំរេចជាក់ស្តែង និងជារបាយការណ៍ ព្រមទាំងនីតិវិធីនៃការកសាងផែនទី និងគំរូនៃការចងក្រងរបាយការណ៍ផងដែរ (សូមមើលឧបសម្ព័ន្ធ ១០)។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ រួមមានយ៉ាងហោចណាស់ក៏មានព័ត៌មាន ៦ប្រភេទ ដែលត្រូវធ្វើការប្រមូលដោយគណៈកម្មាធិការកសាងផែនការ និងថវិកា ឃុំ សង្កាត់។ ព័ត៌មានដែលត្រូវប្រមូលនេះគឺជា ទិន្នន័យ/ព័ត៌មានដែលមានស្រាប់ (រួមមាន បញ្ហា មូលហេតុ ដំណោះស្រាយ និងទិន្នន័យភូមិ) និងជាព័ត៌មានដែលផ្អែកលើចំណេះដឹងមូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់ និងភូមិ ៖

១. **ចំនួនប្រជាជន និងការប៉ាន់ស្មានចំនួនប្រជាជនសំរាប់ពេលអនាគត** : ការប្រើប្រាស់ដីគឺផ្អែកលើតម្រូវការដីរបស់ប្រជាជន ដែលចាំបាច់ត្រូវធ្វើការប៉ាន់ប្រមាណអំពីកំណើននៃប្រជាជន។

២. **ការប្រើប្រាស់ដីបច្ចុប្បន្ន** : ការប្រើប្រាស់ដីបច្ចុប្បន្នគឺផ្អែកលើប្រព័ន្ធនៃការចាត់ថ្នាក់តាមប្រភេទនៃការប្រើប្រាស់ (លំអិត និងសាមញ្ញ) រួមមានហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ សាលារៀន មណ្ឌលសុខភាព ...) និងប្រភេទនៃការប្រើប្រាស់ដី (ដីសម្បទានសេដ្ឋកិច្ច ដីសម្បទានសង្គមកិច្ច តំបន់ការពារ ។ល។)

៣. **លទ្ធភាព/សក្តានុពលរបស់ដី** : លទ្ធភាពក្នុងការជ្រើសរើសដីសំរាប់ការប្រើប្រាស់ផ្សេងៗ (ឧ.ទា ផលិតកម្ម ស្រូវ) គឺត្រូវបានកំណត់ដោយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដោយប្រើប្រាស់ចំណេះដឹងមូលដ្ឋានតាមភាពសមស្របនៃដី និង/ឬដោយប្រើប្រាស់ព័ត៌មានផ្សេងៗ ទៀតពីការវិភាគតំបន់ក្សេត្រ-បរិស្ថានឃុំ ឬការធ្វើការងារនៅទីវាលជាក់ស្តែង ឧទាហរណ៍ ការដើរពំនុះកាត់ភូមិ ឃុំ ។ល ។

៤. **ការធ្វើនិទស្សន៍នៃតម្រូវការដីពេលអនាគត** : តម្រូវការដីសំរាប់សហគមន៍នាពេលអនាគតក្នុងរយៈពេល១០ ឬ១៥ឆ្នាំខាងមុខ នឹងត្រូវបានរៀបរាប់ដោយឈរលើអាទិភាពនៃការវិភាគកិច្ចអភិវឌ្ឍដោយនិរន្តរភាព (ឧ.ទា សាលារៀន មណ្ឌលសុខភាព សហគមន៍ព្រៃឈើ/នេសាទ សម្បទានដីសង្គមកិច្ច) ។

៥. **ជំរើសក្នុងការប្រើប្រាស់ដីសំរាប់ពេលអនាគត** : ជំរើសក្នុងការប្រើប្រាស់ដីសំរាប់ពេលអនាគតត្រូវបានបង្ហាញនៅក្នុងផែនទីប្រើប្រាស់ដីពេលអនាគត ។

៦. **ផែនការអនុវត្ត** : ជំរើសក្នុងការប្រើប្រាស់ដីសំរាប់ពេលអនាគត (ដូចជា ហេដ្ឋារចនាសម្ព័ន្ធ សហគមន៍ព្រៃឈើ សហគមន៍នេសាទ ដីសម្បទានសង្គមកិច្ច) ត្រូវបានបែងចែកនៅក្នុងបណ្តុំគំរោងនានា ដោយដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ដែលត្រូវបានបង្ហាញនៅក្នុងផែនទីគំរោង ។

## ២.៣.១ ការសំរេចលើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងលើកសំណើទៅក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យ និងឯកភាព។ ក្រោយពីឯកភាពរួចហើយ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនផែនការនេះទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ (ដឹកនាំដោយអភិបាលខេត្ត) ដើម្បីធ្វើការសំរេច និងឆ្លើយតបមកវិញ។ ក្រុមការងារថ្នាក់ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋពិនិត្យមើលផែនការប្រើប្រាស់ដីនេះ ដើម្បីឱ្យមានភាពប្រាកដប្រជា (ឧ. ផែនការតាមវិស័យ និងផែនការប្រើប្រាស់ដីដទៃទៀត) និងលើបញ្ហាស្ថេរភាព សន្តិសុខ និងភាពស្របច្បាប់នៃគំរោងដែលធ្វើផែនការនៅលើដីរបស់រដ្ឋ ។

យោងទៅតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

១. ក្រុមប្រឹក្សាឃុំ សង្កាត់ លើកសំណើសុំគោលការណ៍រៀបចំផែនការប្រើប្រាស់ដីទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនសំណើសុំរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវធ្វើការសម្រេចនិងឆ្លើយតបក្នុងរយៈពេលមិនលើសពីម្ភៃមួយ (២១) ថ្ងៃ។

២. បន្ទាប់ពីមានការយល់ព្រមពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំសំណើថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណើថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃយ៉ាងយូរ ដើម្បីឱ្យគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត រៀបចំថវិកាស្របតាមបញ្ញត្តិដែលមានចែងក្នុងមាត្រា ១៩នៃអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

៣. ក្រោយពីទទួលបានការឯកភាពថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់តំណាងដោយមេឃុំ ចៅសង្កាត់ និងសមាជិកម្នាក់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលបន្ទុកការងារដី ត្រូវប្រជុំដើម្បីរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ អង្គប្រជុំត្រូវចាត់តាំងក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមានមេឃុំឬចៅសង្កាត់សាមី ចុះស្រង់ព័ត៌មានពីស្ថានភាពជាក់ស្តែងនៃការប្រើប្រាស់ដីកន្លងមក ហើយគូសលើផែនទីរដ្ឋបាលនិង/ឬផែនទី ប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ប្រសិនបើមាន។

៤. ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជុំលើកទី២ ដើម្បីពិចារណាអំពី :

- ការរៀបចំផែនការប្រើប្រាស់ដី ដោយប្រើប្រាស់ផែនទីដែលមានទិន្នន័យឬព័ត៌មានពីស្ថានភាពប្រើប្រាស់ដីជាក់ស្តែងដែលមានកន្លងមក
- ផែនការមេឬផែនការអភិវឌ្ឍឃុំ សង្កាត់ ឬផែនការអភិវឌ្ឍរបស់រដ្ឋផ្សេងទៀតដែលបានអនុម័តជាផ្លូវការរួចហើយឬមិនទាន់អនុម័ត ប្រសិនបើមាន
- ការគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ សង្កាត់នោះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព
- សេចក្តីត្រូវការដីរបស់ស្ថាប័ន អាជ្ញាធរផ្សេងៗ និងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់។

៥. ពេលបានសម្រេចធ្វើផែនការនេះរួចហើយ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសេចក្តីព្រាងផែនការនេះទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីពិនិត្យនិងកែសម្រួល។

៦. ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេលសែសិបប្រាំ(៤៥)ថ្ងៃតាមទីកន្លែងជាក់ស្តែងនូវផែនការដែលបានពិនិត្យ និងកែសម្រួលរួចហើយដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនឯកភាពនឹងទិន្នន័យ ដែលបានបិទផ្សាយជាសាធារណៈនេះមានសិទ្ធិតវ៉ាទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានីរាជធានី ខេត្ត។

៧. ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រមូលសរុបមតិសាធារណៈ ពិនិត្យ និងលើកអនុសាសន៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យ សម្រេចចុងក្រោយក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ។

៨. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ប្រជុំលើកទីពីរដើម្បីពិនិត្យមតិយោបល់សាធារណៈ និងអនុសាសន៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អាចចាត់បញ្ជូនក្រុមស៊ើបអង្កេតមួយទៅពិនិត្យនិងស្រង់យកព័ត៌មានបន្ថែមទៀត ប្រសិនបើយល់ឃើញថាជាការចាំបាច់។ ក្រុមស៊ើបអង្កេតអាចប្រើពេលវេលាមិនឱ្យហួសពីសាមសិប(៣០)ថ្ងៃទេ។

៩. ការសម្រេចលើផែនការប្រើប្រាស់ដីត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃអង្គប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដែលមានសមាជិកចូលរួមប្រជុំយ៉ាងតិចពីរភាគបី(២/៣)នៃសមាជិកទាំងអស់។ ក្រោយពីគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវបានសម្រេចរួចហើយលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវចម្លងឯកសារអំពីផែនការប្រើប្រាស់ដីនេះ ជូនគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឃុំ សង្កាត់សាមី។

១០. ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំការប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ពាក់ព័ន្ធដើម្បីត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដី និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ជារៀងរាល់ឆមាសនិងប្រចាំឆ្នាំ។

## ២.៤ ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីផ្សេងៗទៀត

មានការរៀបចំផែនការប្រើប្រាស់ដីដទៃទៀតកំពុងតែអនុវត្តនៅក្នុងប្រទេសកម្ពុជា ដែលជួយដល់ប្រជាពលរដ្ឋទទួលបានសិទ្ធិក្នុងការប្រើប្រាស់ដី ឬការបញ្ជាក់អំពីស្ថានភាពនៃការកាន់កាប់ដី ឬព័ត៌មានអំពីលទ្ធភាពនៃការប្រើប្រាស់ដី។ ប្រអប់២ បង្ហាញអំពីទិដ្ឋភាពទូទៅនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងការប្រើប្រាស់ដីផ្សេងៗទៀត។ ដំណើរការគ្រប់គ្រងដីធ្លីនៅក្នុងប្រទេសកម្ពុជា ដូចមានបង្ហាញជូនខាងក្រោមនេះ ៖

### ២.៤.១ ការធ្វើផែនការប្រើប្រាស់ដីថ្នាក់ភូមិ

ការធ្វើផែនការប្រើប្រាស់ដីនៅថ្នាក់ភូមិ ដែលត្រូវបានគេស្គាល់ថា "**ការចូលរួមរៀបចំផែនការប្រើប្រាស់ដីនៅតំបន់ជនបទ** (PLUP)" ត្រូវបានធ្វើឡើងនៅតាមតំបន់គោលដៅមួយចំនួននៅក្នុងប្រទេសកម្ពុជាតាមរយៈគំរោងនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់

មានបំណងរៀបចំផែនការប្រើប្រាស់ដីឱ្យកាន់តែច្បាស់លាស់ និងលំអិតថែមទៀតនោះ អាចស្នើសុំរៀបចំកសាង "**ការចូលរួមរៀបចំផែនការប្រើប្រាស់ដី** (PLUP)" (សូមមើលឧបសម្ព័ន្ធ២)។

## ២.៤.២ ការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ថ្នាក់ឃុំ សង្កាត់

ការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន គឺជាវិធីសាស្ត្រសំរាប់ធ្វើការវិភាគប្រព័ន្ធកសិកម្មសំរាប់ជីវភាពរស់នៅ សំរាប់រៀបចំផែនការ ព្រមទាំងកំណត់អាទិភាពនៃសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងនោះការគ្រប់គ្រងធនធានធម្មជាតិ ក៏ត្រូវបានត្រូវយកចិត្តទុកដាក់ផងដែរ។ ការវិភាគអំពីតំបន់កេ្សត្រ-បរិស្ថាន អាចផ្ដល់ឱកាសដល់ឃុំ សង្កាត់ ធ្វើការអភិវឌ្ឍ ដោយយោងទៅលើផលិតភាព និរន្តរភាព ស្ថេរភាព និងសមភាព ដែលជាលទ្ធផលនៃការវិភាគទៅតាមតំបន់នីមួយៗ។ លទ្ធផលទាំងនេះ អាចស្នើសុំពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តបាន។ ***ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់*** គួរគប្បីប្រើប្រាស់របាយការណ៍អំពីតំបន់កេ្សត្រ-បរិស្ថាន ដើម្បីយកប្រើប្រាស់សំរាប់ការវិភាគភាពសមស្របនៃដី (ការងារ A និងការងារ D)។

## ២.៤.៣ ការកែសម្រួលព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់

ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់នៅប្រទេសកម្ពុជា ត្រូវបានកំណត់ឱ្យប្រើប្រាស់រួចមកហើយ ក៏ប៉ុន្តែព្រំប្រទល់រដ្ឋបាលទាំងនេះត្រូវធ្វើការកែសម្រួលឡើងវិញតម្រូវតាមស្ថានភាពជាក់ស្តែង។ ចំពោះការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវយកព្រំប្រទល់រដ្ឋបាលដែលបានកំណត់រួចមកហើយនោះធ្វើជាមូលដ្ឋានសំរាប់ដំណើរការ។ ក្រុមសម្របសម្រួលផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ជួយគាំទ្រក្នុងការកែសម្រួលព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ឬផ្នែកណាមួយនៃព្រំប្រទល់ដែលពុំទាន់ច្បាស់លាស់នៅឡើយ ដោយធ្វើការវាស់វែង និងគូសផែនទីឡើងវិញ។

## ២.៤.៤ ការកំណត់ព្រំប្រទល់ដែនព្រៃឈើ

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកគម្របព្រៃឈើឆ្នាំ២០០២ ជាផ្លូវការ ក៏ប៉ុន្តែព្រំប្រទល់ព្រៃឈើជាក់ស្តែងនៅលើដីពុំទាន់បានកំណត់ជាក់លាក់នៅឡើយទេ។ ក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់នេះ ការវាស់វែងកំណត់ដែនព្រៃឈើ និងការធ្វើបច្ចុប្បន្នភាពនៃការប្រើប្រាស់ដីទៅតាមស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន គប្បីផ្អែកលើចំណេះដឹងមូលដ្ឋាន និងស្ថានភាពជាក់ស្តែងនៅទីនោះ។ ដោយមានការសម្របសម្រួលពីមន្ត្រីរដ្ឋបាលព្រៃឈើ ការគូសផែនទីព្រំប្រទល់ព្រៃឈើត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើទិដ្ឋភាពបច្ចេកទេស និងក្របខ័ណ្ឌគតិយុត្តដែលមានជាធរមាន។ ការគូសវាសនេះ ជូនកាលយើងអាចឃើញនូវភាពខុសគ្នារវាងគម្របព្រៃឈើដែលមានជាក់ស្តែងនៅមូលដ្ឋាន និងគម្របព្រៃឈើឆ្នាំ ២០០២។ ការកំណត់ព្រំប្រទល់ដែនព្រៃឈើនេះ ក៏ជាផ្នែក មួយនៃការគូសផែនទីដីរដ្ឋដែរ។

### ២.៤.៥ សិទ្ធិលើដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច

ច្បាប់ភូមិបាលឆ្នាំ ២០០១ បានផ្តល់សិទ្ធិដល់សហគមន៍ជនជាតិដើមភាគតិច ដោយមានការចុះបញ្ជិការដីដែលជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី ដីនោះមិនមែនមានតែដីដែលដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបំរុងចាំបាច់ក្នុងការប្តូរវេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក។

បច្ចុប្បន្ន ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងតែដំណើរការចុះបញ្ជិការសហគមន៍ជនជាតិដើមភាគតិច និងចុះបញ្ជិការដីសហគមន៍ជនជាតិដើមភាគតិច។ ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់អាចជួយគាំទ្រដល់ការកំណត់ដីសហគមន៍។ ដីសហគមន៍ត្រូវបានគូសនៅលើផែនទីប្រើប្រាស់ដី (បច្ចុប្បន្នភាព) និងនៅលើផែនទីប្រើប្រាស់ដីពេលអនាគត (*ដើម្បីជាមូលដ្ឋានសំរាប់ការស្នើសុំ*)។

### ២.៤.៦ កម្មវិធីសម្បទានដីសង្គមកិច្ច

សម្បទានដីសង្គមកិច្ច គឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់សំរាប់គោលបំណងសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសំរាប់សង់លំនៅឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

សម្បទានដីសង្គមកិច្ចថ្នាក់ឃុំ សង្កាត់ គឺការផ្ទេរដីដែលជាកម្មសិទ្ធិឯកជនរបស់រដ្ឋជូនទៅដល់ប្រជាជនក្រីក្រដែលផ្តួចផ្តើមរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ជួយគាំទ្រក្នុងការផ្តួចផ្តើមកំណត់ដីសម្បទានសង្គមកិច្ច។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចស្នើសុំដីដែលត្រៀមបំរុងសំរាប់ធ្វើជាសម្បទានដីសង្គមកិច្ច ហើយត្រៀមបំរុងដីនេះដោយដាក់បញ្ចូលទៅក្នុងផែនទីប្រើប្រាស់ដីពេលអនាគត។ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចស្នើសុំដីសំរាប់សម្បទានដីសង្គមកិច្ចទៅគណៈកម្មការប្រើប្រាស់និងបែងចែកដីថ្នាក់រាជធានី ខេត្ត (PLUAC) ឬក៏ស្នើសុំតាមរយៈផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។




<u>**ប្រអប់ ២**</u>: ទិដ្ឋភាពទូទៅនៃការប្រើប្រាស់ដីផ្សេងទៀត និងការប្រើប្រាស់ដីដែលបានលើកឡើងនៅក្នុង ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

## ២.៤.៧ ការធ្វើអត្តសញ្ញាណកម្ម និងការគូសផែនទីដីរដ្ឋ

ដីរដ្ឋ គឺសំដៅដល់ដីទាំងអស់ដែលជារបស់រដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នសាធារណៈ និងដីដែលត្រូវបានប្រគល់ឱ្យនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គលដើម្បីកាន់កាប់។ ការធ្វើអត្តសញ្ញាណកម្ម និងការគូសផែនទីដីរដ្ឋជាដំណើរការមួយដែលមានលក្ខណៈសម្របសម្រួល និងមានតម្លាភាព ត្រូវបានធ្វើឡើងដោយក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

### ២.៤.៨ ដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានរ៉ែ

**សម្បទានដីសេដ្ឋកិច្ច** សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឱ្យសម្បទានិកដើម្បីប្រើប្រាស់សំរាប់ធ្វើអាជីវកម្ម និងកសិឧស្សាហកម្ម។ ព័ត៌មានអំពីសម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**សម្បទានរ៉ែ** ត្រូវបានផ្តល់ដល់ក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនក្នុងស្រុក ដើម្បីធ្វើការសិក្សារុករក និងរហូតដល់ការធ្វើអាជីវកម្ម។ ព័ត៌មានអំពីសម្បទានរ៉ែត្រូវបានផ្តល់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ផ្ទៃដីសម្បទាន** ត្រូវបានគូសវាសនៅលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន។

### ២.៤.៩ សហគមន៍ព្រៃឈើ

**សហគមន៍ព្រៃឈើ** គឺជាសហគមន៍ដែលស្ម័គ្រចិត្តចងក្រងប្រមូលផ្តុំក្រោមកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ដើម្បីធ្វើសកម្មភាពអភិវឌ្ឍន៍ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយចីរភាពនៅក្នុងព្រៃសហគមន៍ ដោយអនុវត្តតាមច្បាប់ស្តីពីព្រៃឈើ។ សហគមន៍ព្រៃឈើ គឺមានគោលបំណងក្នុងការគ្រប់គ្រងធនធានព្រៃឈើដើម្បីដោះស្រាយតម្រូវការរបស់សហគមន៍មូលដ្ឋាន (ឧ.ទា ដើម្បីបំពេញដល់តម្រូវការសង្គម សេដ្ឋកិច្ច វប្បធម៌ និងជំនឿរបស់ប្រជាជនក្នុងពេលបច្ចុប្បន្ន និងពេលអនាគត) និងដើម្បីរក្សាបាននូវការដុះលូតលាស់ និងនិរន្តរភាពនៃព្រៃឈើ។ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ជួយកំណត់នូវផ្ទៃដីសហគមន៍ព្រៃឈើដែលបញ្ចូលការងារនេះ ទៅក្នុងការរៀបចំផែនការទូទៅ។ ផ្ទៃដីនៃសហគមន៍ព្រៃឈើត្រូវបានបង្ហាញនៅក្នុងផែនទីប្រើប្រាស់ដីបច្ចុប្បន្ន និងនៅលើផែនទីប្រើប្រាស់ដីពេលអនាគត។ រដ្ឋបាលព្រៃឈើជាស្ថាប័នគ្រប់គ្រងទិន្នន័យស្តីពីសហគមន៍ព្រៃឈើនេះ។

### ២.៤.១០ សហគមន៍នេសាទ

សហគមន៍នេសាទ គឺសំដៅដល់ក្រុមប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងភូមិមួយ ឬច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលបានយល់ព្រមសហការណ៍គ្នាចូលរួមគ្នាដោយស្ម័គ្រចិត្តក្នុងគោលបំណងចូលរួមគ្រប់គ្រងអភិរក្ស ប្រើប្រាស់ធនធានជលផលនៅតាមមូលដ្ឋានប្រកបដោយចីរភាព និងការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរស្របតាមលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនិងវិស័យជលផល។ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ជួយកំណត់កន្លែងសហគមន៍នេសាទ (ផ្ទៃដីសហគមន៍នេសាទ) គឺជាដែននេសាទរបស់រដ្ឋដែលបានព្រមព្រៀងផ្តល់សិទ្ធិជូនសហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬក្បែរដែននេសាទដើម្បីប្រើប្រាស់ជាប្រពៃណី។ ការកំណត់កន្លែងសហគមន៍នេសាទនេះនឹងបញ្ចូលទៅក្នុងការរៀបចំផែនការទូទៅ។ ទីតាំងសហគមន៍នេសាទត្រូវគូសបង្ហាញនៅក្នុងផែនទីប្រើប្រាស់ដីបច្ចុប្បន្ន និងនៅលើផែនទីប្រើប្រាស់ដីពេលអនាគត (ពេលដែលស្នើសុំដើម្បីចុះបញ្ជីការ)។

### ២.៤.១១ ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងដំណើរការចុះបញ្ជីដីធ្លី (ការផ្តល់ប័ណ្ណកម្មសិទ្ធិដី) ក្នុងគោលបំណងធ្វើឱ្យកាន់តែប្រសើរនូវសុវត្ថិភាពក្នុងការកាន់កាប់ដី សំដៅកាត់បន្ថយជំលោះដីធ្លីលើផ្នែកកម្មសិទ្ធិ និងសម្របសម្រួលការគ្រប់គ្រងដីធ្លី ការតាមដានត្រួតពិនិត្យធនធានធម្មជាតិ និងការការពារកម្មសិទ្ធិរបស់រដ្ឋ និងទប់ស្កាត់លើការធ្វើលទ្ធកម្មដីដោយខុសច្បាប់ និងការប្រមូលដីទុក។ ការផ្តល់នូវប័ណ្ណកម្មសិទ្ធិនេះគឺមានការរំពឹងទុកថា : (ក) ធ្វើឱ្យកសិករ បង្កើនការឈានទៅទទួលបាននូវឥណទានជាផ្លូវការ (ខ) ធ្វើឱ្យកាន់តែប្រសើរនូវការវិនិយោគលើវិស័យកសិកម្ម និងពាណិជ្ជកម្មនៅតាមតំបន់ជនបទ និងទីក្រុង ដែលនឹងធ្វើឱ្យកើនឡើងនូវផលិតកម្ម និងផ្តល់ឱកាសការងារ (គ) លើកកំពស់ទីផ្សារដីធ្លីឱ្យកាន់តែមានប្រសិទ្ធភាព និង (ឃ) លើកកំពស់ការប្រើប្រាស់ការចុះបញ្ជីជាផ្លូវការ ដើម្បីសំរួលដល់ការផ្លាស់ប្តូរប្រភេទដី ឬផ្ទេរដីធ្លី។ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ជួយដល់ការកំណត់តំបន់ដីដែលមិនមានសុវត្ថិភាព និងអាទិភាពនៃដំណើរការចុះបញ្ជីដីធ្លី។

## ២.៥ ក្របខណ្ឌគតិយុត្តសំរាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ក្របខណ្ឌគតិយុត្តពាក់ព័ន្ធការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដែលមានសុពលភាព មានដូចខាងក្រោម :

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ (ឆ្នាំ ២០០៨) :
  - (មាត្រា ៣៧): ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ និងកម្មវិធីវិនិយោគប្រចាំឆ្នាំនីមួយៗ។
  - (មាត្រា៣៩): ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍដែលរួមមានក្របខណ្ឌការងារសំរាប់ការអភិវឌ្ឍ ដែលបរិយាយអំពីគោលការណ៍ជាមូលដ្ឋានសំរាប់ប្រើប្រាស់ និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិនៅក្នុងដែនរបស់ខ្លួន។
- អនុក្រឹត្យស្តីពីនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ (ឆ្នាំ២០០៨) :
  - (មាត្រា ៦): ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការសិក្សានិងបង្ហាញអំពីសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ឃុំ សង្កាត់របស់ខ្លួន ផ្តល់ព័ត៌មានជាក់លាក់នានា រៀបចំកិច្ចពិភាក្សា ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ជាមួយប្រជាជនក្នុងភូមិ ដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីជាលក្ខណៈផែនការលំអិត និងជាម្ចាស់នៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់តាំងជនបង្គោលមួយ ឬច្រើនរូបឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល និងធ្វើទំនាក់ទំនងជាប្រចាំជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ លើការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ (សូមមើលឧបសម្ព័ន្ធ ១ ខ្លឹមសារនៃអនុក្រឹត្យទាំងស្រុង)។

◦ ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី (ឆ្នាំ ២០០៥) :

-(មាត្រា៦): ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកសាងគំនូសព្រាងផែនទីប្រើប្រាស់ដីក្នុងឃុំ សង្កាត់ ដោយកំណត់ដីឯកជន ដីរដ្ឋ ដីសមស្របសំរាប់សម្បទានដីសង្គមកិច្ច ឬសម្បទានដីសេដ្ឋកិច្ចដើម្បីមានមូលដ្ឋានអភិវឌ្ឍក្នុងឃុំ សង្កាត់របស់ខ្លួនស្របតាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

◦ អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្តីពីសម្បទានដីសង្គមកិច្ច

-(មាត្រា ៥): ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមលក្ខខ័ណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច។

-(មាត្រា ៩): លក្ខខណ្ឌចាំបាច់ដើម្បីធ្វើផែនការសម្បទានដីសង្គមកិច្ច រួមមាន ការពិពណ៌នាអំពីដី ដែលត្រូវបំពេញតាមនីតិវិធីនៃការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់។

ជាបន្ថែម ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ជាជំនួយស្មារតីដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបំពេញនូវភារកិច្ចរបស់ខ្លួន :

◦ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ :

-(មាត្រា ៤៣): ឃុំ សង្កាត់ មានតួនាទីទទួលខុសត្រូវក្នុងការការពារ ថែរក្សាបរិស្ថាន និងធនធានធម្មជាតិ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-(មាត្រា ៦០): ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំអនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍឃុំ សង្កាត់ ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។

-(មាត្រា ៦៤): ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង។ ផែនការអភិវឌ្ឍឃុំ សង្កាត់ ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រ និងមធ្យោបាយធានា ដើម្បីបង្ករលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល។

## ៣. ផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់

ឧបករណ៍ជាចម្បងហើយជាផ្លូវការសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការចាត់ចែងការងារអភិវឌ្ឍន៍របស់ខ្លួន គឺ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

អនុលោមទៅតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ លេខ ២៤២៣/ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧នោះ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាឧបករណ៍យុទ្ធសាស្ត្រសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់រៀបចំផែនការ និងធ្វើការសំរេចចិត្តក្នុងការអភិវឌ្ឍឃុំ សង្កាត់ ដូចមានចែងក្នុងប្រការ ២នៃប្រកាសនេះថា *"ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវប្រើជាមូលដ្ឋានសម្រាប់ណែនាំរាល់ការសម្រេចចិត្តក្នុងការងារអភិវឌ្ឍន៍ឃុំ សង្កាត់ និងសម្រេចកសាងកម្មវិធីវិនិយោគឃុំ សង្កាត់ និងការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់"*។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវតែស្របគ្នាជាមួយផែនការជាតិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច។ គោលបំណងនៃការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺដើម្បីជួយទៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកៀរគរធនធានពីខាងក្នុង និងពីខាងក្រៅសំរាប់ដោះស្រាយបញ្ហា និងដើម្បីបំរើដល់ផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ (ប្រការ ១)។ កម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវបានបង្កើតឡើងសំរាប់រយៈពេល៥ឆ្នាំ ហើយត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នភាពសារឡើងវិញរៀងរាល់ឆ្នាំ។

ក្រោយពេលរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ រួចរាល់ហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំកម្មវិធីវិនិយោគ(រយៈពេលមួយឆ្នាំ)ដែលជាមធ្យោបាយសំរាប់អនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ហើយត្រូវរៀបចំថវិកាប្រចាំឆ្នាំសំរាប់ឃុំ សង្កាត់។

### ៣.១ គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (មាត្រា ២៧) ផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ព្រមទាំងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ត្រូវបានព្រាងដោយគណៈកម្មាធិការកសាងផែនការ និងថវិកា ដែលរៀបចំចាត់តាំងឡើងដោយមេឃុំ ។ គណៈកម្មាធិការកសាងផែនការ និងថវិកាត្រូវតែប្រើប្រាស់វិធីសាស្ត្រនៃការចូលរួម ដើម្បីធានាឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនៅក្នុងមូលដ្ឋាន។

សមាសភាពនៃគណៈកម្មាធិការកសាងផែនការ និងថវិកា មានដូចខាងក្រោម :

- មេឃុំ ឬចៅសង្កាត់ (ជាប្រធាន)
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៣នាក់ ជ្រើសរើសដោយផ្អែកលើសមត្ថភាព
- តំណាងអាជ្ញាធរភូមិចំនួន០២នាក់ក្នុងមួយភូមិ ជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋពី ២-៤នាក់ (អាស្រ័យទៅតាមទំហំរបស់ឃុំ សង្កាត់) គឺជាអ្នកផ្តល់យោបល់ដែលរួមមានបុរស និងស្ត្រីដែលជ្រើសរើសដោយមេឃុំ ចៅសង្កាត់

- ស្មៀនឃុំ សង្កាត់ (ជាលេខាធិការ) ។

ក្នុងការអនុវត្តន៍ជាទូទៅ សមាសភាពនៃគណៈកម្មាធិការកសាងផែនការ និងថវិកាត្រូវបានណែនាំជាផ្លូវការថា គឺ អាស្រ័យទៅលើស្ថានភាពនៃឃុំ សង្កាត់ និងលទ្ធភាពនៃមេឃុំ ចៅសង្កាត់ ដើម្បីនឹងស្វែងរកមនុស្សឱ្យបានគ្រប់ចំនួនហើយអ្នកទាំងនោះអាចមានសមត្ថភាព មានការស្ម័គ្រចិត្ត និងមានពេលវេលាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងគ្រប់កិច្ចប្រជុំនៃគណៈកម្មាធិការកសាងផែនការ និងថវិកា ។

### ៣.១.១ ជំហាននិមួយៗនៃដំណើរការរៀបចំផែនការ

វដ្តនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ មានរយៈពេលប្រមាណពី៥ ទៅ៦ខែ ហើយឃុំ សង្កាត់តែងតែចាប់ផ្តើមធ្វើនៅខែឧសភាជារៀងរាល់ឆ្នាំ។ ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្ម វិធីវិនិយោគឃុំ សង្កាត់ (០២/០៧/២០០៧) បានធ្វើការបង្រួញផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ពី ១១ជំហានបញ្ចូលមកនៅត្រឹម ៥ ជំហាន ដូចដែលមានបង្ហាញក្នុងដ្យាក្រាម ២ និង៣។

**ជំហាននិមួយៗ ក្នុងដំណើរការនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ៈ**

<u>ជំហាន ១</u> : សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិកា។

<u>ជំហាន ២</u> : កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់។

<u>ជំហាន ៣</u> : សេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់

<u>ជំហាន ៤</u> : ការអនុម័តផែនការអភិវឌ្ឍឃុំ សង្កាត់។

<u>ជំហាន ៥</u> : ការវាយតម្លៃ អំពីការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់។




**<u>ដ្យាក្រាម ២ៈ</u>** វដ្តនៃផែនការអភិវឌ្ឍឃុំ សង្កាត់

ជំហាននិមួយៗក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ :

<u>ជំហាន ១</u> : ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ។

<u>ជំហាន ២</u> : ការរៀបចំគំរោងវិនិយោគឃុំ សង្កាត់។

<u>ជំហាន ៣</u> : សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ។

<u>ជំហាន ៤</u> : ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់។

<u>ជំហាន ៥</u> : ការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីវិនិយោគឃុំ សង្កាត់។




**<u>ដ្យាក្រាម ៣ៈ</u>** វដ្តនៃកម្មវិធីវិនិយោគឃុំ សង្កាត់

## ៣.២ ការគាំទ្រសំរាប់ការរៀបចំផែនការថ្នាក់ឃុំ សង្កាត់

ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ផ្តល់លទ្ធផលជាសេចក្តីព្រាងផែនការប្រើប្រាស់ដីរួមមាន ព័ត៌មានអំពីស្ថានភាពសង្គមកិច្ច-សេដ្ឋកិច្ចនៅក្នុងឃុំ សង្កាត់ ព័ត៌មានអំពីលទ្ធភាពដី និងជំរើសសំរាប់ការប្រើប្រាស់ដីទៅអនាគត ក៏ដូចជាគម្រោងការសំរាប់អនុវត្ត។ ជាមួយនឹងផែនទីទាំង៦ប្រភេទដូចមានរាយរាប់ក្នុងតារាង២ បង្ហាញនូវទិដ្ឋភាពទូទៅនៃសំណើក្នុងការរៀបចំជាផែនទី ដើម្បីប្រើប្រាស់ក្នុងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងដំណើរការផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

| ឈ្មោះផែនទី | បរិយាយ | មាត្រដ្ឋាន | អ្នកផលិត | ពេលវេលាផលិត | ការធ្វើបច្ចុប្បន្នភាព |
|---|---|---|---|---|---|
| ផែនទីតំបន់រសើប (ខេត្ត) | ផែនទីខេត្តមានមាត្រដ្ឋានចង្អុលបង្ហាញតំបន់ដែលតម្រូវឱ្យមានការការពារជាពិសេស។ | ពី 1:100,000 ដល់ 1:250,000 អាស្រ័យទៅលើទំហំរបស់រាជធានីខេត្ត។ | ក្រុម GIS ថ្នាក់ខេត្ត (ដោយមានព័ត៌មានទិន្នន័យផ្តល់មកពីបណ្តាមន្ទីរជំនាញ)។ | CLUP ការងារ A. មុនដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ប្រចាំឆ្នាំ។ | ក្រុម GIS ក្រោយពេលទទួលបានទិន្នន័យថ្មីដែលបានទទួលការអនុម័តរួច។ |
| ផែនទីប្រើប្រាស់ដីលំអិត | ផែនទីឃុំមានមាត្រដ្ឋានអំពីការប្រើប្រាស់ដីបច្ចុប្បន្នមាន(៦៧ប្រភេទ) | ពី 1:10,000 ដល់ 1:30,000 អាស្រ័យលើទំហំរបស់ឃុំ សង្កាត់។ | ក្រុម GIS ថ្នាក់រាជធានី ខេត្ត។ | CLUP ការងារ A. មុនដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ប្រចាំឆ្នាំ។ | ដោយក្រុម GIS កម្មវិធីវិនិយោគជំហាន១ (មាត្រដ្ឋាន) និងផែនការអភិវឌ្ឍឃុំ សង្កាត់ជំហាន១ (គំនូសព្រាង)។ |
| ផែនទីប្រើប្រាស់ដីសាមញ្ញ | ផែនទីឃុំមានមាត្រដ្ឋានអំពីការប្រើប្រាស់ដីបច្ចុប្បន្នមាន(៧ ប្រភេទជាមូលដ្ឋាន)។ | ពី 1:10,000 ដល់ 1:30,000 អាស្រ័យលើទំហំរបស់ឃុំ។ | -ក្រុម GIS ថ្នាក់រាជធានី ខេត្ត -គណៈកម្មការផែនការនិងថវិកា និង អ្នកភូមិ ពិនិត្យសារឡើងវិញនិងធ្វើបច្ចុប្បន្នភាព។ | CLUP ការងារ A. មុនដំណើរការផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ប្រចាំឆ្នាំ។ | ដោយក្រុម GIS កម្មវិធីវិនិយោគ ជំហាន១ (មាត្រដ្ឋាន) និងផែនការអភិវឌ្ឍជំហាន១(គំនូសព្រាង) |
| ផែនទី បញ្ហា មូលហេតុ និង ដំណោះ ស្រាយ | ផែនទីគំនូសព្រាងបង្ហាញពី បញ្ហា មូលហេតុ និង ដំណោះស្រាយក្នុងឃុំដែលកំណត់ដោយគណៈកម្មការផែនការ និងថវិកា និងអ្នកភូមិ។ | គូសព្រាងនៅលើផែនទីប្រើប្រាស់ដីសាមញ្ញ (ពី 1:10,000 ដល់ 1:30,000 អាស្រ័យលើទំហំរបស់ឃុំ សង្កាត់) | គណៈកម្មាធិការផែនការនិងថវិកា និងអ្នកភូមិពិនិត្យសារឡើងវិញនិងធ្វើបច្ចុប្បន្នភាព | ការងារ B. ក្នុងពេលរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ជំហាន១ | ដោយគណៈកម្មការផែនការ និងថវិកា ក្នុងខួបនៃផែនការអភិវឌ្ឍឃុំ សង្កាត់ ជំហាន៣ និងកម្មវិធីវិនិយោគ ឃុំ សង្កាត់ជំហាន១ |

| ឈ្មោះផែនទី | បរិយាយ | មាត្រដ្ឋាន | អ្នកផលិត | ពេលវេលាផលិត | ការធ្វើបច្ចុប្បន្នភាព |
|---|---|---|---|---|---|
| ផែនទីប្រើប្រាស់ដីពេលអនាគត | គំនូសព្រាងបង្ហាញតំបន់ ប្រើប្រាស់ដី និងគំរបដី រៀបចំដោយគណៈកម្មការផែនការ និងថវិកា គូសចូលកុំព្យូទ័រ ក្រោយដំណើរការផអឃ។ | គូសព្រាងនៅលើផែនទី ប្រើប្រាស់ដីសាមញ្ញ (ពី 1:10,000 ដល់ 1:30,000 អាស្រ័យលើទំហំរបស់ឃុំសង្កាត់)។ | គណៈកម្មាធិការផែនការ និងថវិកា ក្រុម GIS | ការងារ C. និង D. ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ជំហាន៣, កម្មវិធីវិនិយោគឃុំសង្កាត់ ជំហាន១។ | ធ្វើបច្ចុប្បន្នភាពរៀងរាល់ ៥ឆ្នាំម្តង (ក្រោយដំណើរការផែនការអភិវឌ្ឍន៍ឃុំ សង្កាត់) ឬញឹកញាប់ជាងនេះតាមការចាំបាច់។ |
| ផែនទីគំរោង | គំនូសព្រាងបង្ហាញទីតាំង គំរោងជាអាទិភាពរបស់ឃុំទាំង សំណើគំរោង និងគំរោង ដែលសំរេចហើយ គូសចូលកុំព្យូទ័រ ក្រោយដំណើរការផែនការអភិវឌ្ឍន៍ឃុំសង្កាត់។ | គូសព្រាងនៅលើផែនទី ប្រើប្រាស់ដីសាមញ្ញ (ពី 1:10,000 ដល់ 1:30,000 អាស្រ័យលើទំហំរបស់ឃុំ សង្កាត់)។ | គណៈកម្មាធិការផែនការ និងថវិកា ក្រុម GIS។ | ការងារ C. និង G. ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ជំហាន៣, កម្មវិធីវិនិយោគឃុំសង្កាត់ជំហាន២ និង ៤។ | ធ្វើបច្ចុប្បន្នភាពក្នុងវដ្តផែនការអភិវឌ្ឍន៍ ឃុំសង្កាត់ ក្រោយសិក្ខាសាលាសមាហរណកម្ម ថ្នាក់ស្រុក (ផែនការអភិវឌ្ឍន៍ ឃុំសង្កាត់ជំហាន ៣)។ |

**តារាង ២:** ទិដ្ឋភាពទូទៅអំពីផែនទីនៅក្នុង *ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់*

ផែនទី "**តំបន់រសើប**" រាជធានី ខេត្ត ត្រូវបានផលិតឡើងនៅថ្នាក់ខេត្ត នៅពេលចាប់ផ្តើមវដ្តនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដោយផ្អែកលើទិន្នន័យប្រព័ន្ធពត៌មានភូមិសាស្ត្ររបស់ថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្រុង។ នៅពេលដែលប្រភពធនធានមានគ្រប់គ្រាន់ ការងារនេះអាចធ្វើឡើងវិញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ (ឧទាហរណ៍ នៅពេលធ្វើផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ)។ ផែនទី "តំបន់រសើប" គឺជាផែនទីដែលបង្ហាញបណ្តាតំបន់ដែលទាមទារឱ្យមានកិច្ចការពារ ជាពិសេសសំរាប់ហេតុផលបរិស្ថាន ឬសង្គម។ ផែនទីនេះត្រូវបានប្រើប្រាស់នៅពេលវិភាគជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត (សូមមើលឧបសម្ព័ន្ធ ៦)។

ផែនទីប្រើប្រាស់ដីលំអិតត្រូវបានផលិតឡើងសំរាប់ថ្នាក់ឃុំ សង្កាត់ និងថ្នាក់រាជធានី ខេត្ត នៅពេលចាប់ផ្តើមនៃវដ្តរបស់ផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដោយផ្អែកលើទិន្នន័យប្រព័ន្ធព័ត៌មានភូមិសាស្ត្រថ្នាក់ជាតិ។ បច្ចុប្បន្នផែនទីប្រើប្រាស់ដីលំអិត មានលទ្ធភាពបង្ហាញរហូតដល់ប្រភេទនៃការប្រើប្រាស់ដី និងប្រភេទនៃធនធានធម្មជាតិចំនួន ៦៧ប្រភេទខុសៗគ្នា។ បន្ថែមពីលើនេះទៀត ផែនទីនេះបង្ហាញអំពី "តំបន់រសើប" ដែលទាមទារឱ្យមានកិច្ចការពារជាពិសេសសំរាប់កិច្ចការពារផ្នែកសង្គម និងបរិស្ថាន។

ផែនទីប្រើប្រាស់ដីសាមញ្ញបច្ចុប្បន្ន គឺផ្អែកទៅលើផែនទីប្រើប្រាស់ដីលំអិតបច្ចុប្បន្ន តែមានការបង្ហាញប្រភេទនៃការប្រើប្រាស់ដីតែចំនួន ៧ប្រភេទជាមូលដ្ឋានតែប៉ុណ្ណោះ និងបន្ថែមលើនេះគឺ "តំបន់រសើប" ដែលទាមទារឱ្យមានកិច្ចការពារជាពិសេសសំរាប់កិច្ចការពារផ្នែកសង្គម និងបរិស្ថាន។ ផែនទីប្រើប្រាស់ដីសាមញ្ញ គឺជាផែនទីមូលដ្ឋាន (ផែនទីគោល)សំរាប់គូសផែនទី ៣ប្រភេទទៀតគឺ : ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ និងផែនទីប្រើប្រាស់ដីពេលអនាគត។

ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ បង្ហាញនូវបញ្ហាដែលបានកំណត់ដោយ ឃុំ សង្កាត់ និងអ្នកភូមិ នៅអំឡុងពេលវិភាគបញ្ហា មូលហេតុ និងដំណោះស្រាយក្នុងការងារ B និង C (ជំហាន ១ និង ៣ នៃដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់) និងការងារ D (កម្មវិធីវិនិយោគឃុំ សង្កាត់ជំហាន ១)។ ផែនទីបញ្ហា មូលហេតុ និង ដំណោះស្រាយមានទំរង់ជាគំនូសព្រាងដែលគូសផ្ទាប់ជាន់ពីលើផែនទីប្រើប្រាស់ដីសាមញ្ញក្នុងពេលបច្ចុប្បន្នជាមួយនឹងសញ្ញាសំគាល់ដែលត្រូវគ្នាទៅនឹងតារាងបញ្ហា មូលហេតុ និងដំណោះស្រាយ ដែលរៀបរាប់អំពីរូបភាព ទំហំ និង មូលហេតុនៃបញ្ហានីមួយៗ។

ផែនទីគំរោងរបស់ឃុំត្រូវបានផលិតឡើងនៅថ្នាក់ឃុំ សង្កាត់ហើយបង្ហាញអំពីទីតាំងនៃគំរោងដែលបានស្នើឡើង និងគំរោងដែលបានអនុម័តហើយ។ ផែនទីគំរោងមានទម្រង់ជាគំនូសព្រាងគូសផ្ទាប់ជាន់ពីលើផែនទីប្រើប្រាស់ដីបច្ចុប្បន្នសាមញ្ញ បង្ហាញនូវបណ្តាទីតាំងនៃគំរោងដែលរួមមានព្រំប្រទល់ប៉ាន់ស្មានប្រហាក់ប្រហែល។ ផែនទីនេះ ត្រូវគូសចូលទៅក្នុងកុំព្យូទ័រដោយក្រុម GIS ថ្នាក់ខេត្តដែលនឹងបង្ហាញទីតាំងត្រឹមត្រូវ (ការងារ D កម្មវិធីវិនិយោគឃុំ សង្កាត់ជំហាន ១)។ ភាពលំអិតនៃគំរោងទាំងនេះមានបង្ហាញនៅក្នុងតារាង (ឧទាហរណ៍ ប្រវែងនៃផ្លូវ ទំហំផ្ទៃដីនៃសហគមន៍ព្រៃឈើ ។ល។) ហើយត្រូវបានភ្ជាប់ជាមួយនឹងផែនការអនុវត្ត។

ផែនទីប្រើប្រាស់ដីពេលអនាគតរបស់ឃុំ សង្កាត់ គឺជាការបង្ហាញនូវលក្ខណៈរូបសាស្រ្តនៃឃុំ សង្កាត់ ក្នុងចក្ខុវិស័យអភិវឌ្ឍន៍រយៈពេលវែង និងការលើកជាសំណើសំរាប់គោលបំណងបន្ទាន់ ដូចដែលបានរៀបចំក្នុងការងារ C (ផែនការអភិវឌ្ឍឃុំ សង្កាត់ ជំហាន៣)។ ផែនទីប្រើប្រាស់ដីពេលអនាគតមានទម្រង់ជាគំនូសព្រាងគូសផ្ទាប់ជាន់ពីលើផែនទីប្រើប្រាស់ដីសាមញ្ញក្នុងពេលបច្ចុប្បន្ន បង្ហាញនូវការលើកសំណើអាទិភាពសំរាប់គំរោងអភិវឌ្ឍន៍ឃុំ សង្កាត់ រួមមានព្រំប្រទល់ប៉ាន់ស្មានប្រហាក់ប្រហែល។ ផែនទីនេះត្រូវគូសចូលទៅក្នុងកំព្យូទ័រដោយក្រុម GIS ថ្នាក់រាជធានី ខេត្ត ដែលបង្ហាញទីតាំងត្រឹមត្រូវ (ការងារ D កម្មវិធីវិនិយោគឃុំ សង្កាត់ ជំហាន ១)។ ភាពលំអិតនៃគំរោងទាំងនេះនឹងមានបង្ហាញនៅក្នុងតារាង (ឧ.ទា ប្រវែងនៃផ្លូវ ទំហំផ្ទៃដីនៃសហគមន៍ព្រៃឈើ ។ល។) ហើយត្រូវបានភ្ជាប់ជាមួយនឹងផែនការអនុវត្ត។

## ៤. និរន្តរភាពនៃសកម្មភាពរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

### ៤.១ ទំនាក់ទំនងរវាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ជាមួយនឹងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់មានកាលវេលាស្របគ្នាទៅនឹងវដ្តនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ ហេតុនេះហើយអនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវរៀបចំឡើងសំរាប់រយៈពេលមួយដែលមានរយៈពេល៥ឆ្នាំ (ជាមួយនឹងចក្ខុវិស័យរយៈពេល ១០ ទៅ ១៥ឆ្នាំ) ហើយនឹងធ្វើការពិនិត្យសារឡើងវិញ (គំរោង និងប្រភពធនធានដែលមាន) ជាមូលដ្ឋានក្នុង ១ឆ្នាំម្តង (សូមមើលឧបសម្ព័ន្ធ)។

#### ៤.១.១ យន្តការស្ថាប័ន

ដំណើរការដែលផ្តួចផ្តើមការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺត្រូវបានធ្វើឡើងដោយក្រុមការងារចំរុះស្ថាប័នក្នុងឃុំ សង្កាត់នីមួយៗ ដែលដឹកនាំដោយមេឃុំ ចៅសង្កាត់។

ការរៀបចំស្ថាប័នសំរាប់ដំណើរការផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវរៀបចំតាមលំនាំប្រហាក់ប្រហែលទៅនឹងការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងផែនការវិនិយោគឃុំ សង្កាត់ ដូចដែលមានចែងនៅច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ឆ្នាំ២០០១) និងប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍ ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដូចជា :

- មេឃុំ ចៅសង្កាត់ មានភារកិច្ចទទួលខុសត្រូវសម្របសម្រួលក្នុងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងធ្វើការពិនិត្យ និងកែសំរួលរៀងរាល់ឆ្នាំដែលជាមូលដ្ឋានសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់ ព្រមទាំងធ្វើការដាក់ជូននូវសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធ្វើការសំរេច។

-ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវក្នុងការរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងធ្វើការកែលំអផែនការ ហើយនិងត្រួតពិនិត្យនិងវាយតម្លៃជាប្រចាំទៅលើលទ្ធផលនិងឥទ្ធិពលនៃការអនុវត្តន៍ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។ គណៈកម្មាធិការកសាងផែនការ និងថវិកា ជួយដល់មេឃុំ ចៅសង្កាត់ ក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ជាមួយនឹងការចូលរួមផ្តល់យោបល់ពីអ្នកពាក់ព័ន្ធដទៃទៀត។

-ក្រុមជនបង្គោលផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ថ្នាក់ឃុំ សង្កាត់ មានសមាសភាពពីក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធដទៃទៀតនៅថ្នាក់មូលដ្ឋាន ហើយដែលជួយគាំទ្រដោយក្រុមសម្របសម្រួលរៀបចំផែនការប្រើ

ប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ (D-LUP) អ្នកជំនាញការដទៃទៀតដូចជាក្នុងផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងកម្មវិធីផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលីជាដើម (CAAEP[១]) ។

- ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ (ចំរុះស្ថាប័ន) គួរមានចំនួនច្រើនបំផុតត្រឹម ៤នាក់ សំរាប់សម្របសម្រួលដំណើរការផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ស្ត្រី និងអ្នកដែលមានការយល់ដឹងពីជនជាតិភាគតិច គប្បីត្រូវបានលើកទឹកចិត្ត ដើម្បីចូលរួមនៅក្នុងក្រុមផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

- សមាសភាពនៃក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ (D-LUP) ប្រែប្រួលទៅតាមស្ថានភាពភូមិសាស្ត្រនៃប្រភពធនធានជាមូលដ្ឋាននៅតាមឃុំសង្កាត់នីមួយៗ តែជាតួយ៉ាងគឺអាចមានសមាជិកភាពមកពី :

- មន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលថ្នាក់ក្រុង ស្រុក ខណ្ឌ
- មន្ត្រីនៃការិយាល័យបរិស្ថានថ្នាក់ក្រុង ស្រុក ខណ្ឌ
- មន្ត្រីខណ្ឌ/សង្កាត់រដ្ឋបាលព្រៃឈើ
- មន្ត្រីខណ្ឌ/សង្កាត់រដ្ឋបាលជលផល
- មន្ត្រីការិយាល័យផ្សព្វផ្សាយកសិកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ
- មន្ត្រីការិយាល័យធនធានទឹក និងឧតុនិយមថ្នាក់ក្រុង ស្រុក ខណ្ឌ ។

ជាបន្ថែមទៅលើសមាសភាពនៃក្រុមខាងលើនេះ ឃុំ សង្កាត់អាចសុំជំនួយគាំទ្របន្ថែមក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដូចជាក្រុមសម្របសម្រួលថ្នាក់ស្រុក (DFT) ជាដើម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ប្រសិនបើមានលទ្ធភាពគួរតែផ្តួចផ្តើមរៀបចំដំណើរការកសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដោយខ្លួនឯង ដោយពុំចាំបាច់តម្រូវឱ្យមានជំនួយទាំងស្រុងពីខាងក្រៅនោះទេ ។

[១] CAAEP- Cambodia Australian Agriculture Extension Program

## ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ( ៥ជំហាននៃដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ដែលផ្សារភ្ជាប់នឹងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់)

| ការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ | លទ្ធផល | អ្នកចូលរួម | សម្ភារៈ | ជំហាននៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ |
|---|---|---|---|---|
| A. ការត្រៀមរៀបចំ | → គោលបំណងដែលបានមកពីផែនការដទៃទៀតដែលបានអនុម័តរួចហើយ<br>→ ផែនទីប្រើប្រាស់ដីឃុំ (សាមញ្ញ និងលំអិត)<br>→ ផែនទី "តំបន់រសើប" រាជធានី ខេត្ត | - ក្រុម GIS/LUP<br>- ក្រុមសម្របសម្រួលខេត្ត<br>- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ<br>- មន្ទីរជំនាញ<br>- អង្គការក្រៅរដ្ឋាភិបាល<br>- វិស័យឯកជន | - ទិន្នន័យមកពីផែនការអភិវឌ្ឍន៍ផ្សេងទៀត<br>- ផែនការអភិវឌ្ឍន៍ ដែលបានអនុម័តរួចហើយ (លំដាប់ខ្ពស់ជាង)<br>- ផែនទីតំបន់កេរ្តិ៍-បរិស្ថាន (ប្រសិនជាមាន)<br>- ទម្រង់១ (សង្ខេបនៃផែនការដែលមានស្រាប់) | |
| B. ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពគោលបំណងអភិវឌ្ឍន៍ | → ធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដីលំអិតឃុំ<br>→ ធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដីសាមញ្ញឃុំ<br>→ ធ្វើបច្ចុប្បន្នភាពផែនទី "តំបន់រសើប"<br>→ សេចក្តីព្រាងផែនទី ប.ម.ដ<br>→ បញ្ជីដំបូងរាយនូវជំរើសសំរាប់ការសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីពេលអនាគត<br>→ សេចក្តីព្រាងផែនទីគំរោង | -ក្រុមសម្របសម្រួលរាជធានី ខេត្ត និង ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ<br>-ក្រុម GIS/LUP<br>-ក្រុមសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ<br>- គណៈកម្មាធិការកសាងផែនការ និងថវិកាសមាជិកឃុំ (បុគ្គលគន្លឹះ) | -ផែនទីសាមញ្ញ<br>-ផែនទីលំអិត<br>-ផែនទីតំបន់រសើប<br>-តារាង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ១.១/១.៦<br>-គោលការណ៍ ប.ម.ដ<br>-ទិន្នន័យឃុំ<br>-ផែនទីគម្របដី ( បានធ្វើបច្ចុប្បន្នភាពរួច)<br>-ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ តារាង ១.៣ | ជំហ៊ានទី ១ |
| C. ការកសាងផែនទីសំរេច | → ធ្វើបច្ចុប្បន្នភាពផែនទី ប.ម.ដ សំរេច<br>→ ធ្វើបច្ចុប្បន្នភាពផែនទីគំរោង សំរេច<br>→ ធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដីពេល អនាគត | - គណៈកម្មាធិការកសាងផែនការ និងថវិកា ក្រុមសម្របសម្រួលផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និង ក្រុម GIS/LUP | -ផែនទីគំនូសព្រាង<br>-ផែនទីគោល<br>-សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ | ជំហ៊ានទី ៣ |

**តារាង ៣:** ទិដ្ឋភាពទូទៅនៃដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដែលផ្សារភ្ជាប់ជាមួយនឹងផែនការអភិវឌ្ឍឃុំ សង្កាត់

## ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ (ជំហានទីមួយៗនៃដំណើរការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ដែលផ្សារភ្ជាប់នឹងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់)

| ការងារផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ | លទ្ធផល | អ្នកចូលរួម | សម្ភារៈ | ជំហាននៃកម្មវិធីវិនិយោគឃុំ សង្កាត់ |
|---|---|---|---|---|
| A . ការត្រៀមរៀបចំ | - គោលបំណងដែលបានមកពីផែនការដទៃទៀត ដែលបានអនុម័តរួចហើយ<br>- ផែនទីប្រើប្រាស់ដីឃុំ (សាមញ្ញ និងលំអិត)<br>- ផែនទី "តំបន់រសើប" រាជធានី ខេត្ត | -ក្រុម GIS/LUP<br>-គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ជាតិ<br>-មន្ទីរជំនាញ | -ទិន្នន័យ/ព័ត៌មាន ពីផែនការអភិវឌ្ឍន៍ ផ្សេងទៀត<br>-ផែនទីដែលមាន ស្រាប់ (អនុម័តរួច) | |
| D. ការគាំទ្រដល់ការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ | → សេចក្តីព្រាងក្របខណ្ឌការងារសំរាប់រៀបចំផែនការប្រើប្រាស់ដីពេលអនាគត<br>→ សេចក្តីព្រាងបច្ចុប្បន្នភាពផែនទីគំរោង<br>→ ធ្វើបច្ចុប្បន្នភាពផែនទីសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី (គំនូសព្រាងមានមាត្រដ្ឋាន) / ផែនទី ប.ម.ដ<br>→ របាយការណ៍ភាពសមស្របនៃដី<br>→ ធ្វើបច្ចុប្បន្នភាពផែនទីសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីពេលអនាគត | -គណៈកម្មាធិការកសាងផែនការ និងថវិកា<br>- ក្រុម D-LUP<br>-ក្រុម GIS/LUP | -ផែនទីគំរោងពីមុនមក<br>-ឯកសារ ផអឃ<br>-ផែនទីគោល<br>-ទិន្នន័យឃុំ<br>-គោលការណ៍វាយតម្លៃភាពសមស្របនៃដី | ជំហានទី១ |
| E . រៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ | → សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ដាក់ជូនទៅក្រុមការងារថ្នាក់ ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការគ្រប់គ្រង ដីរដ្ឋ ដើម្បីអនុម័ត។ | -គណៈកម្មាធិការកសាងផែនការ និងថវិកា<br>-ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ប្រើប្រាស់ដី ក្រុង ស្រុក ខណ្ឌ<br>-ក្រុមសម្របសម្រួលក្រុង ស្រុក ខណ្ឌ<br>- ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី | -សេចក្តីព្រាងផែនទីគំរោង<br>-ទិន្នន័យឃុំ | ជំហានទី ២ |
| F. ការគាំទ្រឃុំ សង្កាត់ ក្នុង សិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ | → ឯកភាពលើជំរើសក្នុងការសម្របសម្រួលរៀបចំផែន ការប្រើប្រាស់ដីពេលអនាគតជាមួយការព្រមព្រៀងជាបណ្តោះអាសន្ន | -គណៈកម្មាធិការកសាងផែនការ និងថវិកា<br>- ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ប្រើប្រាស់ដី ក្រុង ស្រុក ខណ្ឌ | -ធ្វើបច្ចុប្បន្នភាពផែនទីគំរោង | ជំហានទី ៣ |
| G. ការកសាងផែនទីសំរេចសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់ | → ពិនិត្យកែសំរួលឡើងវិញផែនទី គំរោង (រួមទាំងជំរើសក្នុងការសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីពេលអនាគត) នៅទីណាដែលសមស្រប | - ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីក្រុង ស្រុក ខណ្ឌ<br>- ក្រុម GIS/LUP | -ផែនទីគំរោងសំរេច<br>-ផែនទី សម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីលំអិត និងសាមញ្ញ (បច្ចុប្បន្នភាពរួច)<br>-ផែនទី ប.ម.ដ. ឯកសារផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ | ជំហានទី ៤ |

| ការងារផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់ | លទ្ធផល | អ្នកចូលរួម | សម្ភារៈ | ជំហាន ករណ៍ |
|---|---|---|---|---|
| F. ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ | → ធ្វើឱ្យកាន់តែល្អនូវសមត្ថភាព ក្នុងការបង្ហាញរបស់ផែនទី ប.ម.ដ<br>→ ធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ | - ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីក្រុង ស្រុក ខណ្ឌ<br>-ក្រុម GIS/LUP<br>-គណៈកម្មាធិការកសាងផែនការ និងថវិកា | -ផែនការអនុវត្ត<br>-ផែនទីគំរោង<br>-ផែនទី ប.ម.ដ<br>-លក្ខខណ្ឌនិង សូចនាករក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | ជំហានទី ៥ |

តារាង ៤: ទិដ្ឋភាពទូទៅនៃដំណើរការផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដែលផ្សារភ្ជាប់ជាមួយនឹងកម្មវិធីវិនិយោគឃុំ សង្កាត់

## ៤.១.២ ការអនុម័តលើសំណើរផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវចុះហត្ថលេខាដោយមេឃុំ ឬចៅសង្កាត់ ហើយតាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសេចក្តីព្រាងផែនការនេះទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីពិនិត្យនិងកែសម្រួល។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេលសែសិប ប្រាំ(៤៥)ថ្ងៃ តាមទីកន្លែងជាក់ស្តែងនូវផែនការដែលបានពិនិត្យនិងកែសម្រួលរួចហើយដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ រូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនឯកភាពនឹងទិន្នន័យដែលបានបិទផ្សាយជាសាធារណៈមានសិទ្ធិតវ៉ាទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានីខេត្ត។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបូកសរុបមតិសាធារណៈ ពិនិត្យ និងលើកអនុសាសន៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យ សម្រេចចុងក្រោយក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ប្រជុំដើម្បីពិនិត្យមតិយោបល់សាធារណៈ និងអនុសាសន៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល សាមសិប(៣០)ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អាចចាត់ បញ្ជូនក្រុមស៊ើបអង្កេតមួយទៅពិនិត្យនិងស្រង់យកព័ត៌មានបន្ថែមទៀត ប្រសិនបើយល់ឃើញថាជាការចាំបាច់។ ក្រុមស៊ើបអង្កេតអាចប្រើពេលវេលាមិនឱ្យហួសពីសាមសិប(៣០)ថ្ងៃទេ។ ការសម្រេចលើផែនការប្រើប្រាស់ដីត្រូវអនុវត្ត តាមសំឡេងភាគច្រើនដាច់ខាតនៃអង្គប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដែលមានសមាជិកចូលរួម ប្រជុំយ៉ាងតិចពីរភាគបី (២ភាគ៣)នៃសមាជិកទាំងអស់។ ក្រោយពីគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវបានសម្រេចរួចហើយ លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តត្រូវចម្លងឯកសារអំពី ផែនការប្រើប្រាស់ដីនេះជូនគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឃុំ សង្កាត់សាមី។ ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំការប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដី និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ជារៀងរាល់ឆមាសនិងប្រចាំឆ្នាំ។

### ៤.១.៣ អ្នកចូលរួមរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១) គ្រប់អង្គការចាត់តាំងសង្គមស៊ីវិលអាចចូលរួមនៅក្នុងដំណើរការផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ហើយនឹងទទួលខុសត្រូវជាតំណាងសំរាប់ការពារផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដែលងាយនឹងរងគ្រោះ ដូចជា ស្ត្រី យុវជន អ្នកក្រីក្រ និងជនជាតិដើមភាគតិច ព្រមទាំងរួមចំណែកក្នុងការផ្តល់ចំណេះដឹង និងមតិយោបល់ ដើម្បីរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

## ៤.២ ការគ្រប់គ្រងទិន្នន័យ (Data Management)

នៅចុងបញ្ចប់នៃដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ផែនទីប្រើប្រាស់ដីលំអិត ផែនទីបញ្ហា មូលហេតុ ដំណោះស្រាយ និងផែនទីប្រើប្រាស់ដីពេលអនាគត ហើយត្រូវបានភ្ជាប់ជាមួយនឹងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់(សូមមើលគំរូ) ហើយនឹងដាក់ជូន ទៅដើម្បីស្នើសុំការសំរេចអនុម័ត។

ព័ត៌មានដែលប្រមូលបានក្នុងរយៈពេលដំណើរការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទាំងនេះ ត្រូវធ្វើការរក្សាទុកជាមូលដ្ឋាន ជាកម្រងទិន្នន័យ/ឯកសារ(កាលប្បវត្តិ) ហើយត្រូវតំកល់ទុកនៅសាលាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ដើម្បីប្រើប្រាស់ជាឯកសារយោងនៅវដ្តបន្ទាប់នៃដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

- ព័ត៌មានស្តីពីសង្គមកិច្ច សេដ្ឋកិច្ចនៃឃុំ សង្កាត់ និងភូមិ ទៅតាមទិដ្ឋភាពជាក់ស្តែងក្នុងពេលបច្ចុប្បន្ននេះ គប្បីមានផែនទីភ្ជាប់មកជាមួយ រួមមានផែនទីប្រើប្រាស់ដីលំអិតបច្ចុប្បន្ន ផែនទីបញ្ហា-មូលហេតុ-ដំណោះស្រាយ និងផែនទីប្រើប្រាស់ដីពេលអនាគត។
- ចំពោះក្រុង ស្រុក ខណ្ឌ ទិន្នន័យ ឬឯកសារប្រហាក់ប្រហែល គប្បីភ្ជាប់ព័ត៌មានអំពីគំរោងឆ្លងឃុំ សង្កាត់(អន្តរឃុំ សង្កាត់) រួមមានបញ្ជីរាយនាមពីគំរោងអន្តរឃុំ សង្កាត់ទាំងអស់ដែលបានអនុម័តរួច។
- ចំពោះរាជធានី ខេត្ត ទិន្នន័យ ឬឯកសារប្រហាក់ប្រហែលគប្បីភ្ជាប់ទិន្នន័យឌីជីថល (ឯកសារដែលប្រើប្រាស់ជាមួយកុំព្យូទ័រ)ដែលមានផ្ទុកនូវផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញនៃឃុំទាំងអស់នៅក្នុងរាជធានី ខេត្ត បង្ហាញនូវទីតាំងដីរដ្ឋ ***"តំបន់រសើប"*** និងផែនទីគម្របដី។

## ៤.៣ ទិដ្ឋភាពទូទៅនៃតួនាទី និងការទទួលខុសត្រូវក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

តារាងទី ៥ បង្ហាញអំពីតួនាទី និងការទទួលខុសត្រូវនៃបុគ្គល/ក្រុមនិមួយៗនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ឧបសម្ព័ន្ធ ៩ បង្ហាញអំពីរចនាសម្ព័ន្ធនៃក្រុមការងារផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ។

| ថ្នាក់ | ឈ្មោះ | ស្ថាប័ន/អាជ្ញាធរ | ការងារចំបង |
|---|---|---|---|
| ជាតិ | ក្រុមសម្របសម្រួលផែនការប្រើប្រាស់ដីថ្នាក់ជាតិ។ | អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រៀបចំក្របខ័ណ្ឌគតិយុត្ត គោលការណ៍ណែនាំសៀវភៅណែនាំអនុវត្ត គំរូស្តង់ដារ បណ្តុះបណ្តាលគ្រូបង្គោល ត្រួតពិនិត្យតាមដាននិងវាយតម្លៃ សម្របសម្រួលជាមួយបណ្តាក្រសួងពាក់ព័ន្ធ ...។ |
| ខេត្ត | គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត | សាលាខេត្ត (អភិបាលខេត្តជាប្រធាន)<br>មន្ទីរជំនាញជុំវិញខេត្ត | សំរេចអនុម័តលើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រួតពិនិត្យតាមដាន និងវាយតម្លៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ |
| | មន្ទីរជំនាញជុំវិញខេត្ត | មន្ទីរកសិកម្ម រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល មន្ទីបរិស្ថាន ... | រួមចំណែកដល់ការគូសផែនទី "តំបន់រសើប"។ |
| | អ្នកដឹកនាំក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី | ប្រជុំសម្របសម្រួលជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដី PSDD ដើម្បីត្រួតពិនិត្យតាមដាន និងវាយតម្លៃរៀបចំផែនការ និងសម្របសម្រួល និងជាអ្នកប្រមូលផែនការអភិវឌ្ឍន៍ដទៃទៀត។ |
| | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត | មន្ទីរ ដ.ន.ស.ស និងមន្ទីរពាក់ព័ន្ធ | បណ្តុះបណ្តាលអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រួតពិនិត្យសារឡើងវិញ ពិនិត្យគុណភាព។ |
| | ក្រុម GIS | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | បំលែងពីគំនូសព្រាងទៅជាមាត្រដ្ឋាន ធ្វើបច្ចុប្បន្នភាពផែនទី បណ្តុះបណ្តាលក្នុងការគូរផែនទី។ |
| | ក្រុមសម្របសម្រួលថ្នាក់រាជធានី ខេត្ត( គ្រប់គ្រងធនធានធម្មជាតិ) | មន្ទីរពាក់ព័ន្ធ | សម្របសម្រួលជាមួយក្រុមផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ |
| ស្រុក | ក្រុមការងាដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ | មន្ទីរពាក់ព័ន្ធ | អនុម័តសំរេចលើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដោះស្រាយទំនាស់ ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់។ |
| | អ្នកដឹកនាំក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល (ដ.ន.ស.ភ) | ធ្វើផែនការ និងសម្របសម្រួល ធ្វើរបាយការណ៍ ធ្វើការបកស្រាយជាមួយនឹងក្រុមផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ថ្នាក់រាជធានី ខេត្ត ដើម្បីយកផែនការដែលមានលំដាប់ខ្ពស់ជាងមកបញ្ជ្រាបចូលផែនការថ្នាក់ឃុំ សង្កាត់។ |
| | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ | ការិយាល័យ ដ.ន.ស.ភខ័ណ្ឌ/ សង្កាត់រដ្ឋបាលព្រៃឈើខ័ណ្ឌ/ សង្កាត់រដ្ឋបាលជលផលស្នាក់ការបរិស្ថាន ... | សម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ |
| | អ្នកសម្របសម្រួលថ្នាក់ក្រុងស្រុក ខណ្ឌ ( គ្រប់គ្រងធនធានធម្មជាតិ) | ការិយាល័យជុំវិញក្រុង ស្រុក ខ័ណ្ឌ | សម្របសម្រួល នឹងសហការជាមួយក្រុមការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ |
| ឃុំ | គណៈកម្មាធិការកសាងផែនការ និងថវិកា | ក្រុមប្រឹក្សាឃុំ សង្កាត់ | ជួយគាំទ្រការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ , ធានានូវដំណើរការបើកចំហរ និងមានតម្លាភាព និងធានាថាបញ្ហាជនជាតិដើមភាគតិចត្រូវបានលើកឡើងយ៉ាងសមស្រប |
| | ជនបង្គោល | ជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់ | ជួយគាំទ្រ មគ្គុទ្ទេស និងការស្នាក់នៅជាមួយនឹងក្រុមការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ថ្នាក់ក្រុង ស្រុក ខណ្ឌ/អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ។ |

**តារាង ៥:** តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

## ៥. ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ជាបន្តបន្ទាប់នេះនឹងធ្វើការពិពណ៌នាជាលំអិតអំពីទីតាំង លទ្ធផល សកម្មភាព ប្រតិបត្តិករ និងការទទួលខុសត្រូវ ព្រមទាំងតម្រូវការប្រភពធនធាននៅក្នុងបណ្តាការងារផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ជាដំបូងគឺការសង្ខេបទូទៅនៃការងារ និងដ្យាក្រាមបង្ហាញនូវលទ្ធផលផ្សេងៗ។ ក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងអស់ វាជាប្រការសំខាន់ត្រូវមានតំណាងសមស្របរបស់ស្ត្រី (ដែលយ៉ាងហោចណាស់ក៏មានការចូលរួម តាមរយៈជនបង្គោលតំណាងស្ត្រី និងកុមារ) ក្រុមជនជាតិដើមភាគតិច និងក្រុមតូចៗផ្សេងៗទៀត ដែលធានាថា យោបល់ និងទស្សនៈរបស់ពួកគេត្រូវបានបញ្ចេញនៅក្នុងអង្គប្រជុំពិនិត្យសារឡើងវិញ និងធ្វើការអនុម័ត។

**ការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់រួមមាន ៖**

ការងារ A : ការត្រៀមរៀបចំ

ការងារ B : ការផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពគោលបំណងអភិវឌ្ឍន៍

ការងារ C : ការកសាងផែនទីសំរេច

ការងារ D : ការគាំទ្រដល់ការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់

ការងារ E : ការរៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ការងារ F : ការគាំទ្រឃុំ សង្កាត់ ក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ ក្រុង ស្រុក ខណ្ឌ

ការងារ G : ការផលិតផែនទីសំរេចសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់

ការងារ H : ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

---

**សញ្ញាសំគាល់សំរាប់ដ្យាក្រាម :**


របាយការណ៍/ឯកសារ


មូលដ្ឋានទិន្នន័យ


គំនូសព្រាងផែនទី ឬផែនទីមាត្រដ្ឋាន


ការងារ (*ដីនៅក្នុងឃុំ សង្កាត់*) ឬ ជំហាន (ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់)


ការបណ្តុះបណ្តាល

| ការងារ A : ការត្រៀមរៀបចំ | |
|---|---|
| គោលបំណង | រៀបចំផែនទី "តំបន់រសើប" នៃការប្រើប្រាស់ដីក្នុងរាជធានី ខេត្ត ដើម្បីជាពត៌មានទូទៅសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រើប្រាស់ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ឬផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ រៀបចំបញ្ជីនៃគោលបំណងអភិវឌ្ឍនានា ដែលបានគ្រោងនៅក្នុងផែនការនានាដែលបានទទួលការអនុម័តរួចហើយ (សិក្សាធិការ សុខាភិបាល កសិកម្ម ការសាងសង់ផ្លូវ...) ។ |
| សកម្មភាព | **សកម្មភាព ០.១ :** ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រមូលទិន្នន័យដែលមានស្រាប់អំពីដីរដ្ឋ ពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងបណ្តាមន្ទីរជំនាញជុំវិញរាជធានី ខេត្ត ។ |
| | **សកម្មភាព ០.២:** ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រមូលនូវព័ត៌មានអំពីតំបន់ក្សេត្រ-បរិស្ថាន (ដកស្រង់ពីផែនទីតំបន់ក្សេត្រ-បរិស្ថាន)ពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ |
| | **សកម្មភាព ០.៣:** ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រមូលនូវទិន្នន័យអំពីការប្រើប្រាស់ដី/គម្របដីសំរាប់ឃុំ សង្កាត់និមួយៗពីស្ថាប័នថ្នាក់ជាតិ និងពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។ |
| | **សកម្មភាព ០.៤:** ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានីខេត្ត រៀបចំសិក្ខាសាលាដើម្បីកំណត់ "តំបន់រសើប" នៅក្នុងរាជធានី ខេត្ត ដែលតម្រូវឱ្យមានកិច្ចការពារជាពិសេសសំរាប់ការពារបរិស្ថាន និងសង្គម (ឧបសម្ព័ន្ធ ៦) |
| | **សកម្មភាព ០.៥:** ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រមូល និងវិភាគព័ត៌មានពីផែនការនានាដែលបានអនុម័តចុងក្រោយ ដូចជា ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ការចូលរួមក្នុងការធ្វើផែនការប្រើប្រាស់ដី (PLUP) ប្លង់គោល របាយការណ៍ផែនការតាមវិស័យ ... ដើម្បីកំណត់ជាគំរោងសំរាប់ពេលអនាគត។ |
| | **សកម្មភាព ០.៦ :** ដោយឈរលើមូលដ្ឋានទិន្នន័យដែលប្រមូលបានក្នុងសកម្មភាព ០.១ ដល់ ០.៤ ក្រុម GIS ថ្នាក់ខេត្ត ផលិតនូវផែនទី២ប្រភេទសំរាប់ឃុំនីមួយៗ : ១)ផែនទីប្រើប្រាស់ដីបច្ចុប្បន្នលំអិត និង ២)ផែនទីប្រើប្រាស់ដីសាមញ្ញ ដែលនឹងប្រើជាផែនទីគោលសំរាប់អនុវត្តសកម្មភាពជាបន្តបន្ទាប់។ |
| អ្នកចូលរួម | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត (ជាក្រុមសំខាន់) សម្របសម្រួលការងារទាំងនេះជាមួយនឹងក្រុមសម្របសម្រួលថ្នាក់រាជធានី ខេត្ត (ដែលជាក្រុមសម្របសម្រួលរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់) ។ ក្រុមទាំងនេះទទួលនូវការគាំទ្រផ្នែកបច្ចេកទេសពីអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញនានានឹងផ្តល់ការគាំទ្របន្ថែមទៀតដល់ដំណើរការនេះ។ |
| ទីកន្លែង | សកម្មភាពនេះ ប្រព្រឹត្តទៅនៅថ្នាក់រាជធានី ខេត្ត។ |
| រយៈពេល | រយៈសំរាប់សកម្មភាពរៀបចំនេះគឺមានរយៈពេល ១ខែ។ |
| សម្ភារៈ | ផែនទីមានស្រាប់នៃតំបន់គោលដៅសំរាប់ការរៀបចំផែនការ ព័ត៌មានរដ្ឋបាលដែលមានស្រាប់នៃតំបន់គោលដៅរៀបចំផែនការ ទិន្នន័យជាក់លាក់ដែលបានមកពីបណ្តាប្រភពដូចដែលបានលើកឡើងក្នុងសកម្មភាពខាងលើ ផែនការអភិវឌ្ឍន៍ដែលបានអនុម័តរួចហើយ (ប្លង់គោល ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។ល ។) |
| លទ្ធផល | ផែនទីប្រើប្រាស់ដីបច្ចុប្បន្នលំអិត ផែនទីប្រើប្រាស់ដីសាមញ្ញ ផែនទី"តំបន់រសើប"ថ្នាក់រាជធានី ខេត្ត បញ្ជីនៃគោលបំណងអភិវឌ្ឍន៍ដែលបានមកពីបណ្តាផែនការដែលបានអនុម័តរួចហើយ។ |


លទ្ធផលនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
ការងារ A:
ការត្រៀមរៀបចំ
ទិន្នន័យដីរដ្ឋ
បញ្ជីនៃគោលបំណងអភិវឌ្ឍន៍
ដែលបានមកពីបណ្ដាផែនការ
ដែលបានអនុម័តរួចហើយ ។
ផែនទីប្រើប្រាស់ដី
( មាត្រដ្ឋាន)
ផែនទី
"តំបន់រសើប"
ផែនទីតំបន់អេកូ-កសិកម្ម
( ទីណាដែលមាន)

## សកម្មភាព ០.១ : ការធ្វើអត្តសញ្ញាណកម្មដីរដ្ឋ

| បរិយាយ សកម្មភាព ០.១ |
|---|
| ទីកន្លែង: ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ |
| ក្រុម GIS និងក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ រាជធានី ខេត្ត ប្រមូលនូវព័ត៌មានអំពីទីតាំង និងស្ថានភាព ដីរដ្ឋនៅតាមឃុំ សង្កាត់នីមួយៗ ក្នុងខេត្ត ដោយយកទិន្នន័យពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ស្រុក និងពីមន្ទីរជំនាញជុំវិញរាជធានី ខេត្ត។ ក្រុម GIS ថ្នាក់រាជធានី ខេត្តត្រូវទិន្នន័យ និងពតិមានទាំងនេះ គូសជាផែនទីដីរដ្ឋ ។ |

**និយមន័យអំពីដីរដ្ឋ**

យោងតាមមាត្រា២ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋលេខ ១១៨ អនក្រ.បក (២០០៥) " ដីរដ្ឋ" សំដៅដល់ដីទាំងអស់ ដែលជារបស់រដ្ឋ ហើយដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័ន ថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់ឱ្យនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថា ជានីតិបុគ្គលដើម្បីកាន់កាប់ ។

**លទ្ធផល :**

យោងតាមមាត្រា ៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨ អនក្រ.បក គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ គួរតែមានទិន្នន័យដីរដ្ឋ ដូចមានបង្ហាញជាសង្ខេបនៅក្នុងតារាងខាងក្រោមនេះ។

| | |
|---|---|
| លទ្ធផល ១ | ទិន្នន័យអំពីទីតាំង និងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋដែលប្រមូលបាន |
| លទ្ធផល ២ | ទិន្នន័យអំពីការចាត់ថ្នាក់ដីរដ្ឋ ជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋដែលប្រមូលបាន |
| លទ្ធផល ៣ | ទិន្នន័យអំពីប្រភេទនៃដី និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋដែលបានប្រមូល |
| លទ្ធផល ៤ | ទិន្នន័យអំពីដីរដ្ឋទាំងអស់ រួចត្រូវប្រគល់ឱ្យក្រុម GIS ដើម្បីគូរផែនទី |

**សកម្មភាព :**

| | |
|---|---|
| សកម្មភាព ០.១.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ក្រុង ធ្វើការស្នើសុំពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីទទួលបាននូវទិន្នន័យអំពីៈ ១) ទីតាំងនិងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋ ២) ការចាត់ថ្នាក់ដីរដ្ឋជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ និង ៣) ប្រភេទនៃដី និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ ។ |
| សកម្មភាព ០.១.២ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ក្រុង ធ្វើការទំនាក់ទំនងជាមួយនឹងមន្ទីរជំនាញជុំវិញខេត្តដើម្បីទទួលយកព័ត៌មានដូចក្នុងការងារខាងលើ ។ |
| សកម្មភាព ០.១.៣ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ក្រុង ប្រមូលយកនូវគ្រប់ទិន្នន័យទាំងអស់អំពីដីរដ្ឋ សំរាប់ឃុំនីមួយៗ ហើយប្រគល់ទិន្នន័យទាំងនេះទៅអោយក្រុម GIS ថ្នាក់ រាជធានី ខេត្តដើម្បីគូរផែនទី ។ |

## ប្រតិបត្តិករ និងការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត | ប្រមូលទិន្នន័យជីវដ្ឋពីស្ថាប័នថ្នាក់រាជធានី ខេត្តដោយធ្វើការទំនាក់ទំនងជាមួយនឹងគណៈកម្មាធិការគ្រប់គ្រងជីវដ្ឋថ្នាក់រាជធានី ខេត្ត ក្រុមការងារជីវដ្ឋ និង មន្ទីរជំនាញជុំវិញរាជធានី ខេត្ត រួចប្រគល់ទិន្នន័យទាំងនោះទៅឱ្យក្រុម GIS ដើម្បីគូសផែនទីជីវដ្ឋ។ |
| គណៈកម្មាធិការគ្រប់គ្រងជីវដ្ឋរាជធានី ខេត្ត | ចែករំលែកទិន្នន័យអំពីជីវដ្ឋ ជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ រាជធានី ខេត្ត។ |
| ក្រុមការងារជីវដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ | ចែករំលែកទិន្នន័យ អំពីជីវដ្ឋ ជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត។ |
| មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងមន្ទីរជំនាញ ជុំវិញរាជធានី ខេត្ត | ចែករំលែកទិន្នន័យ អំពីជីវដ្ឋជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត។ |
| ក្រុម GIS | រៀបចំគ្រប់គ្រងទិន្នន័យ និងពត៌មានជីវដ្ឋដែលប្រមូលបាន (រៀបចំជាស្រទាប់ layer GIS) ដោយគូសជាផែនទី សំរាប់ប្រើប្រាស់ក្នុងការរៀបចំផែនការប្រើប្រាស់ ដីនៅក្នុងឃុំ សង្កាត់។ |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *តម្រូវការពេលវេលាសំរាប់បំពេញការងារទូទាំងខេត្ត នឹងកំណត់ជាក្រោយ* |
| តម្រូវការសម្ភារៈ | • មូលដ្ឋានទិន្នន័យ អំពីការគ្រប់គ្រងជីវដ្ឋ<br>• បញ្ជីការដីធ្លី (ប្រសិនជាបានចុះបញ្ជីការរួចរាល់ហើយ) |
| តម្រូវការទិន្នន័យ | ទិន្នន័យជីវដ្ឋ |
| តម្រូវការបណ្តុះបណ្តាល | គ្មាន |
| តម្រូវការផ្សេងៗទៀត | - អនុក្រឹត្យស្តីពីការគ្រប់គ្រងជីវដ្ឋ<br>- ប្រកាសស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ជីវដ្ឋ<br>- ឯកសារសម្រាប់អនុវត្តការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីនិងការធ្វើចំណាត់ដី រដ្ឋ<br>- សេចក្តីសម្រេចស្តីពីការបញ្ចូលឯកសារលក្ខណៈវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ជីវដ្ឋជា ឧបសម្ព័ន្ធរបស់ប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី ១០ ខែមិនា ឆ្នាំ២០០៦ ស្តីពី ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ជីវដ្ឋ។ |

## សកម្មភាព ១.២ : ការប្រមូលទិន្នន័យអំពីប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ

| **បរិយាយ សកម្មភាព ១.២** |
|---|
| ទីកន្លែង: ថ្នាក់រាជធានី ខេត្ត |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ធ្វើការទំនាក់ទំនងការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីប្រមូលទិន្នន័យអំពីប្រព័ន្ធក្សេត្រ-បរិស្ថាន នៅក្នុងឃុំ សង្កាត់ នីមួយៗ (សូមមើលឧបសម្ព័ន្ធ៣)។ ព័ត៌មានទាំងនេះរួមមាន ទីតាំង ព្រំប្រទល់ និងរបាយការណ៍បច្ចេកទេស (ជីវរូបសាស្ត្រ និងសង្គមកិច្ច-សេដ្ឋកិច្ច) នៃតំបន់ក្សេត្រ-បរិស្ថាននៅក្នុងឃុំ សង្កាត់ទាំងនោះ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្តក្រុង ត្រូវប្រគល់ទិន្នន័យទាំងនេះដល់ក្រុម GIS ថ្នាក់រាជធានី ខេត្តដើម្បីគូរផែនទី។ |

**ការវិភាគប្រព័ន្ធ ក្សេត្រ-បរិស្ថាន** (CAEA)

*ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន គឺជាវិធីសាស្ត្រសំរាប់ធ្វើការវិភាគប្រព័ន្ធកសិកម្មនៃការចិញ្ចឹមជីវិត និងសំរាប់ធ្វើផែនការ ព្រមទាំងអាទិភាពក្នុងការស្រាវជ្រាវ និងសកម្មភាពអភិវឌ្ឍន៍។ ការងារនេះត្រូវបានធ្វើនៅមូលដ្ឋានឃុំ សង្កាត់ ដែលជាឧបករណ៍សំរាប់ធ្វើការប៉ាន់ប្រមាណអំពីតម្រូវការ និងសំរាប់ធ្វើផែនការវិស័យកសិកម្ម និងបរិស្ថាននៃកម្មវិធីជាតិអភិវឌ្ឍន៍ជនបទកម្ពុជា។ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានដែលត្រូវបានធ្វើឡើងដោយមានការចូលរួមនិងឯកភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ ពីមន្ត្រីកសិកម្ម ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត និងមានការគាំទ្រពីផ្នែកប្រព័ន្ធកសិកម្មគ្រួសារនៃមន្ទីរកសិកម្ម។ ធ្វើការកំណត់ប្រព័ន្ធ ក្សេត្រ-បរិស្ថានសំខាន់ៗនៅក្នុងឃុំ សង្កាត់ និងស្វែងយល់ជាទូទៅអំពីមុខងាររបស់វា ដើម្បីកំណត់នូវបញ្ហាគន្លឹះ ឬបង្កើតជា ចំណោទអំពីកត្តាណាដែលធ្វើឱ្យមានផលប៉ះពាល់ដល់ដំណើរការមុខងាររបស់វា។ ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ សង្កាត់ ត្រូវបានធ្វើការពិនិត្យសារឡើងវិញច្រើនលើកច្រើនសារ ដើម្បីទទួលបាន នូវទិដ្ឋភាពជាក់ស្តែងនៃឃុំ សង្កាត់ ស្ថានភាពក្នុងការអភិវឌ្ឍន៍កសិកម្មឃុំ សង្កាត់ និងបញ្ហាថ្មីៗដែលកើតមានឡើង។ នៅពេលថ្មីៗនេះ មានការណែនាំអំពីការបង្កើនបច្ចេកទេស កសិកម្មឱ្យកាន់តែប្រសើរ ក្នុងដំណើរការនៃការត្រួតពិនិត្យឡើងវិញអំពីការវិភាគ ប្រព័ន្ធក្សេត្រ-បរិស្ថាន ហើយវាយតម្លៃ ដោយយកចិត្តទុកដាក់ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗ។*

(ប្រភព : សៀវភៅណែនាំក្នុងការវិភាគប្រព័ន្ធ ក្សេត្រ-បរិស្ថាន គំរោងផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី ២០០៥)

**លទ្ធផល**

ទិន្នន័យនៃការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ ត្រូវបង្ហាញជាស្រទាប់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS layer) នៅលើផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ហើយលទ្ធផលនៃការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានដែលត្រូវគូសក្នុងផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដូចមានបង្ហាញជាសង្ខេបខាងក្រោមនេះ :

| | |
|---|---|
| លទ្ធផល ១ | តំបន់ក្សេត្រ-បរិស្ថានសំខាន់ៗដែលមានក្នុងឃុំ សង្កាត់នីមួយៗ។ |
| លទ្ធផល ២ | អត្តសញ្ញាណកម្មនៃព្រំប្រទល់ និងចរិកលក្ខណៈនៃប្រព័ន្ធប្រើប្រាស់ដី (ប្រព័ន្ធក្សេត្រ-បរិស្ថាន) នៅក្នុងឃុំ សង្កាត់។ |
| លទ្ធផល ៣ | ទិន្នន័យអំពីប្រព័ន្ធក្សេត្រ-បរិស្ថាន ត្រូវផ្តល់ទៅឱ្យក្រុម GIS ដើម្បីគូរផែនទី។ |

### សកម្មភាព

| | |
|---|---|
| សកម្មភាព ០.២.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រមូលទិន្នន័យអំពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានពីការិយាល័យផ្សព្វផ្សាយកសិកម្មសំរាប់ឃុំ សង្កាត់នីមួយៗ (ទិន្នន័យនៃឃុំ សង្កាត់ ដែលបានវិភាគហើយ) ។ |
| សកម្មភាព ០.២.២ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាធានី ខេត្ត រៀបចំទិន្នន័យអំពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ទៅឱ្យក្រុម GIS ដើម្បីគូរផែនទី ។ |

### ប្រតិបត្តិករ និងការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត | ដឹកនាំប្រមូលទិន្នន័យអំពីប្រព័ន្ធអេកូកសិកម្ម ពីការិយាល័យផ្សព្វផ្សាយកសិកម្ម និងប្រគល់ទិន្នន័យទាំងនេះទៅឱ្យក្រុម GIS ដើម្បីគូរផែនទី ។ |
| ការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រមូលនិងគ្រប់គ្រងទិន្នន័យអំពីការវិភាគប្រព័ន្ធក្សេត្របរិស្ថាន នៅឃុំណាដែលបានធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ហើយធ្វើការចែករំលែកទិន្នន័យនេះទៅឱ្យក្រុមសម្របសម្រួលរៀបចំ ផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ក្រុង (PLUP) |
| ក្រុម GIS | ទទួលទិន្នន័យអំពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន (អាចជាទិន្នន័យ GIS) សំរាប់ការវិភាគដីសមស្រប ។ |

### តម្រូវការចនចាន

| | |
|---|---|
| តម្រូវការពេលវេលា | *ប៉ាន់ស្មានប្រហែលជា កន្លះ(១/២) ថ្ងៃ* |
| តម្រូវការសម្ភារៈ | គ្មាន |
| តម្រូវការទិន្នន័យ | ទិន្នន័យអំពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានដែលមានរក្សាទុកនៅការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មខេត្ត (ក្នុងករណីដែលបណ្តាឃុំ សង្កាត់ក្នុងរាជធានី ខេត្តត្រូវបានធ្វើការវិភាគប្រព័ន្ធ ក្សេត្រ-បរិស្ថានហើយ) ។ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ក្រុង ត្រូវការនូវការបណ្តុះបណ្តាលអំពីមូលដ្ឋានក្នុងការបកស្រាយ ការវិភាគ ក្សេត្រ-បរិស្ថាន ដើម្បីយល់បានថាទិន្នន័យណាខ្លះដែលមានការពាក់ព័ន្ធសំរាប់បញ្ចូលទៅក្នុងផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## សកម្មភាព ០.៣ : ការប្រមូលទិន្នន័យ អំពីការប្រើប្រាស់ដី និងគំរបដី

| បរិយាយ សកម្មភាព ០.៣ |
|---|
| ទីកន្លែង : ថ្នាក់រាជធានី ខេត្ត |
| ទិន្នន័យអំពីការប្រើប្រាស់ដី និងគំរបដីដែលមានស្រាប់ គឺមានស្ទើរតែទូទៅនៅគ្រប់ស្ថាប័នទាំងអស់ ជាពិសេសគឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយនិងតាមមន្ទីរជំនាញជុំវិញរាជធានី ខេត្ត ជាពិសេសមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រមូលទិន្នន័យអំពីការប្រើប្រាស់ដី និងគំរបដីទាំងអស់ពីបណ្តាប្រភពផ្សេងៗគ្នា រៀបចំទិន្នន័យទៅតាមឃុំ សង្កាត់ ហើយផ្តល់នូវព័ត៌មាននេះទៅដល់ក្រុម GIS ថ្នាក់ខេត្តដើម្បីគូរផែនទី។ |

### លទ្ធផល

| | |
|---|---|
| លទ្ធផល ១ | ទិន្នន័យអំពីការប្រើប្រាស់ដី និងគំរបដីដែលបានប្រមូលពីបណ្តាស្ថាប័ន និងបណ្តាមន្ទីរ។ |
| លទ្ធផល ២ | ទិន្នន័យអំពីការប្រើប្រាស់ដី និងគំរបដីដែលបានរៀបចំសំរាប់ឃុំ សង្កាត់នីមួយៗ។ |
| លទ្ធផល ៣ | ផ្តល់ទិន្នន័យដែលមានការពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដីនិងគំរបដីទៅឱ្យក្រុម GIS ដើម្បីគូរផែនទី។ |

### សកម្មភាព

| | |
|---|---|
| សកម្មភាព ០.៣.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រមូលទិន្នន័យអំពីការប្រើប្រាស់ដី និងគំរបដីពីបណ្តាក្រសួង និងមន្ទីរជុំវិញរាជធានី ខេត្ត។ |
| សកម្មភាព ០.៣.២ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត រៀបចំទិន្នន័យអំពីការប្រើប្រាស់ដី និងគំរបដីតាមឃុំ សង្កាត់នីមួយៗ។ |
| សកម្មភាព ០.៣.៣ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រគល់ទិន្នន័យអំពីការប្រើប្រាស់ដី និងគំរបដីទៅឱ្យក្រុម GIS ថ្នាក់រាជធានី ខេត្តដើម្បីគូរផែនទី។ |

### ប្រតិបត្តិករ និងការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត | ដឹកនាំក្នុងការប្រមូលទិន្នន័យពីថ្នាក់ខេត្ត និងថ្នាក់ជាតិៈ ធ្វើការសម្របសម្រួលជាមួយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម ស្ថាប័ននានា និងពីមន្ទីរ ជំនាញផ្សេងៗទៀត ហើយប្រគល់ទិន្នន័យទាំងនោះទៅក្រុម GISថ្នាក់រាជធានី ខេត្ត។ |
| ក្រសួង ដ.ន.ស និង ស្ថាប័ននានា | ចែករំលែកទិន្នន័យ អំពីការប្រើប្រាស់ដី និងគំរបដីជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត (P-LUP)។ |
| មន្ទីរ ដ.ន.ស.ស និង មន្ទីរជំនាញជុំវិញខេត្ត | ចែករំលែកទិន្នន័យអំពីការប្រើប្រាស់ដី និងគំរបដីជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត (P-LUP) ។ |
| ក្រុម GIS | ទទួលទិន្នន័យអំពីការប្រើប្រាស់ដី/គម្របដីពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត (P-LUP) ហើយរៀបចំទិន្នន័យទាំងនេះតាមប្រភេទផ្សេងៗ (ជា layer) ទៅលើផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *ប៉ាន់ស្មានពេលវេលា : ប្រាំថ្ងៃ (៥)* |
| តម្រូវការសម្ភារៈ | គ្មាន |
| តម្រូវការទិន្នន័យ | ទិន្នន័យអំពីការប្រើប្រាស់ដី/គំរបដី ដែលមានមូលដ្ឋានទិន្នន័យពីក្រសួង និងមន្ទីរជំនាញ |
| តម្រូវការបណ្តុះបណ្តាល | សមាជិកក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត និងក្រុមសម្របសម្រួលរាជធានី ខេត្ត ត្រូវការវគ្គបណ្តុះបណ្តាលរយៈពេលខ្លី អំពីការបកស្រាយទិន្នន័យ និងតម្រូវការទិន្នន័យដែលពាក់ព័ន្ធសំរាប់បញ្ចូលទៅក្នុងផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## សកម្មភាព ០.៤ : ការធ្វើអត្តសញ្ញាណកម្ម និងការគូសផែនទី"តំបន់រសើប"

| បរិយាយ សកម្មភាព ០.៤ |
|---|
| ទីកន្លែង: ថ្នាក់រាជធានី ខេត្ត |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ក្រុង រៀបចំសិក្ខាសាលាស្តីពីការកំណត់តំបន់រសើប ដែលមានការចូលរួមពាក់ព័ន្ធពីមន្ទីរជំនាញ ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល មេឃុំ និងក្រុមប្រឹក្សាឃុំ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ និងតំណាងនៃទីភ្នាក់ងារបច្ចេកទេសខាងក្រៅដែលធ្វើការនៅក្នុងខេត្ត ដើម្បីធ្វើអត្តសញ្ញាណកម្ម តំបន់រសើបទាក់ទងនឹងសង្គមកិច្ច និងបរិស្ថាន ដែលតម្រូវឱ្យមានការការពារផ្នែកសង្គម ឬបរិស្ថានជាពិសេសនៅក្នុងខេត្ត។ រួចហើយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ប្រគល់ព័ត៌មាននេះដល់ក្រុម GIS ថ្នាក់រាជធានី ខេត្ត ដើម្បីធ្វើការគូរផែនទី។ សកម្មភាពនេះត្រូវការនូវការគាំទ្រផ្នែកបច្ចេកទេសពីអ្នកជំនាញ GIS ម្នាក់។ សកម្មភាពនេះ គួរតែធ្វើនៅគ្រប់ខេត្តទាំងអស់ និងគួរធ្វើបច្ចុប្បន្នភាពឡើងវិញជារៀងរាល់ឆ្នាំ (ធ្វើសមាហរណកម្មតំបន់ថ្មីៗដែលបានអនុម័ត)។ និយមន័យតំបន់រសើប សូមមើលក្នុងឧបសម្ព័ន្ធទី ៦។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | អត្តសញ្ញាណកម្មតំបន់រសើប ផ្នែកសង្គម និងសេដ្ឋកិច្ច នៅតាមឃុំ សង្កាត់នីមួយៗនៅក្នុងរាជធានី ខេត្ត ជាមួយនឹងព្រំប្រទល់ប្រហាក់ប្រហែល។ |
| លទ្ធផល ២ | អត្តសញ្ញាណកម្មតំបន់រសើប ផ្នែកបរិស្ថាន នៅតាមឃុំ សង្កាត់នីមួយៗនៅក្នុងរាជធានី ខេត្ត ជាមួយនឹងព្រំប្រទល់ប្រហាក់ប្រហែល។ |
| លទ្ធផល ៣ | ទិន្នន័យអំពីតំបន់រសើបផ្តល់ទៅឱ្យក្រុម GIS រាជធានី ខេត្ត ដើម្បីគូរផែនទី។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ០.៤.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ធ្វើការអញ្ជើញតំណាងស្ថាប័នថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ព្រមទាំងតំណាងដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាលដែលមានសកម្មភាពក្នុងតំបន់គោលដៅ ដើម្បីចូលរួមសិក្ខាសាលាកំណត់តំបន់រសើប។ |
| សកម្មភាព ០.៤.២ | នៅក្នុងសិក្ខាសាលាស្តីពីការកំណត់តំបន់រសើប ធ្វើការលើកសំណើពិភាក្សា និងឯកភាពលើតំបន់រសើប ដែលមានក្នុងមូលដ្ឋានជាមួយនឹងព្រំប្រទល់ប្រហាក់ប្រហែល។ ការអនុម័តត្រូវធ្វើឡើងដោយការចុះសំរុងគ្នាជាទូទៅ។ |
| សកម្មភាព ០.៤.៣ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ធ្វើការកត់ត្រានូវតំបន់រសើប ដែលបានឯកភាពគ្នាក្នុងឃុំ សង្កាត់នីមួយៗ រួចផ្ញើទៅក្រុម GIS ថ្នាក់រាជធានី ខេត្ត ដើម្បីគូរផែនទី។ |
| សកម្មភាព ០.៤.៤ | ក្រុម GIS ថ្នាក់រាជធានី ខេត្ត ទទួលនូវទិន្នន័យទាំងអស់ពី ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត (P-LUP) ដើម្បីផលិតផែនទី "តំបន់រសើប" រាជធានី ខេត្ត។ |

## ប្រតិបត្តករ និងការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្តរៀបចំ និងដឹកនាំសិក្ខាសាលា កំណត់តំបន់រសើបរាជធានី ខេត្ត ធ្វើការកត់ត្រា នូវលទ្ធផលសំរេចចុងក្រោយ និងផ្ញើទិន្នន័យ នេះដល់ក្រុម GIS ថ្នាក់រាជធានី ខេត្តដើម្បីគូរផែនទី។ |
| តំណាងមកពីថ្នាក់ជាតិ | គួរតែត្រូវបានចូលរួមក្នុងសិក្ខាសាលានេះប្រសិនជាអាច ហើយធ្វើការលើកសំណើលើតំបន់រសើបលើផ្នែកសង្គម និងបរិស្ថាននៅក្នុងរាជធានី ខេត្ត។ |
| មន្ទីរជំនាញជុំវិញខេត្ត | ចូលរួមក្នុងសិក្ខាសាលា និងធ្វើការលើកសំណើលើតំបន់រសើប លើផ្នែកសង្គម និង បរិស្ថាននៅក្នុងរាជធានី ខេត្ត។ |
| មេឃុំ | ចូលរួមក្នុងសិក្ខាសាលា និងធ្វើការលើកសំណើ លើតំបន់រសើប លើផ្នែកសង្គម និង បរិស្ថាននៅក្នុងរាជធានី ខេត្ត។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/ ក្រុមសម្របសម្រួលក្រុង ស្រុក ខណ្ឌ | ជួយក្រុមសម្របសម្រួលរាជធានី ខេត្តក្នុងការរៀបចំសិក្ខាសាលា ចូលរួមក្នុងសិក្ខាសាលា និងធ្វើការលើកសំណើលើតំបន់រសើប លើផ្នែកសង្គម និងបរិស្ថាននៅក្នុងរាជធានី ខេត្ត។ |
| មេឃុំ និងក្រុមប្រឹក្សាឃុំ សង្កាត់ | ចូលរួមក្នុងសិក្ខាសាលា និងធ្វើការលើកសំណើអំពីតំបន់រសើប លើផ្នែកសង្គម និង បរិស្ថាននៅក្នុងរាជធានី ខេត្ត ដោយផ្អែកលើចំណេះដឹងមូលដ្ឋាននៃឃុំ និងប្រជាជនមូលដ្ឋាន។ |
| តំណាងនៃអង្គការក្រៅរដ្ឋាភិបាល | ចូលរួមក្នុងសិក្ខាសាលា និងធ្វើការលើកសំណើ លើតំបន់រសើប លើផ្នែកសង្គម និង បរិស្ថាននៅក្នុងរាជធានី ខេត្ត។ |
| តំណាងនៃអង្គការអន្តរជាតិ | ចូលរួមក្នុងសិក្ខាសាលា និងធ្វើការលើកសំណើអំពីតំបន់រសើប លើផ្នែកសង្គម និង បរិស្ថាននៅក្នុងរាជធានី ខេត្ត។ |
| ក្រុម GIS | ផលិតផែនទីផ្សេងៗដែលជាតម្រូវការសំរាប់សិក្ខាសាលាកំណត់តំបន់រសើប។ ទទួលទិន្នន័យតំបន់រសើប ហើយបញ្ចូលទៅជាទិន្នន័យស្រទាប់នៅលើផែនទីប្រើប្រាស់ដី នៅក្នុងឃុំសង្កាត់។ ធ្វើការគូសចម្លងទៅក្នុងកុំព្យូទ័រ ប្រសិនជាទិន្នន័យក្នុងកុំព្យូទ័រពុំទាន់មាន។ ផលិតផែនទី តំបន់រសើបរាជធានី ខេត្ត ជាគំរូផ្សេងៗគ្នារហូតដល់មានការឯកភាពគ្នារវាងមន្ទីរនានា (ពីព្រាងរហូតដល់សំរេច)។ |

## តម្រូវការចំបាច់

| | |
|---|---|
| តម្រូវការពេលវេលា | *ពេលវេលា ប៉ាន់ស្មាន សំរាប់សិក្ខាសាលាតំបន់រសើប: ពីរ(២) ថ្ងៃ*<br>*ពេលវេលាប៉ាន់ស្មាន សំរាប់រៀបចំផែនទីតំបន់រសើប: ពីរ(២) ថ្ងៃ*<br>*ពេលវេលាប៉ាន់ស្មាន សំរាប់គូរបញ្ចូលកុំព្យូទ័រ : ប្រាំ(៥) ថ្ងៃ(អាស្រ័យទៅលើចំនួននៃផែនទី)* |
| តម្រូវការសម្ភារៈ | ផែនទីលំអិត (GIS) នៃខេត្តដែលប្រើប្រាស់ជាគោលសំរាប់ការកំណត់តំបន់រសើប។ |
| តម្រូវការទិន្នន័យ | ផែនទីលំអិត (GIS) នៃទិន្នន័យរាជធានី ខេត្ត |
| តម្រូវការបណ្តុះបណ្តាល | គ្មាន |
| តម្រូវការផ្សេងៗទៀតដើម្បីអនុវត្តក្នុងសកម្មភាពនេះ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត នឹងធ្វើការចែកជូនដល់អ្នកតំណាងទាំងអស់នូវនិយមន័យ និងឧទាហរណ៍នៃតំបន់រសើបផ្នែកសង្គម និងបរិស្ថាន។ ដើម្បីជាការណែនាំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរផលិតនូវសំភារៈផ្សព្វផ្សាយឱ្យយល់ពីនិយមន័យ និងឧទាហរណ៍នៃតំបន់រសើបផ្អែកលើតម្រូវការនៃកិច្ចការពារ (សូមមើលឧបសម្ព័ន្ធ ៦)។ |

## សកម្មភាព ០.៥ : ការប្រមូលព័ត៌មានអំពីគោលបំណងអភិវឌ្ឍន៍ដែលបានមកពីផែនការអនុម័តរួច

| **បរិយាយ សកម្មភាព ០.៥** |
|---|
| ទីកន្លែង: ថ្នាក់រាជធានី ខេត្ត |
| ផែនការពីបណ្ដាមន្ទីរជំនាញ (ផែនការតាមវិស័យ ផែនការប្រើប្រាស់ដី និងផែនការអភិវឌ្ឍន៍) ត្រូវបានប្រមូល និងវិភាគអំពីគោលបំណងអភិវឌ្ឍន៍នានាសំរាប់ឃុំ សង្កាត់ ។ |

### លទ្ធផល

ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ត្រូវរៀបចំចងក្រងគោលបំណងអភិវឌ្ឍនានាដែលបានកំណត់នៅក្នុងឯកសារផ្សេងៗគ្នា ។ គោលបំណងទាំងនេះត្រូវធ្វើការបង្ហាញនៅក្នុងទម្រង់មួយ ដែលរួមមានទាំងប្រភពនៃឯកសារ ។ ទម្រង់នេះនឹងត្រូវប្រើប្រាស់ដើម្បីវិភាគថាតើកិច្ចអភិវឌ្ឍន៍នេះនឹងធ្វើឡើងនៅ ទីណា ។

| | |
|---|---|
| លទ្ធផល ១ | ទិដ្ឋភាពទូទៅនៃឯកសារនានាដែលបានអនុម័តរួច ដោយរៀបចំជាបញ្ជី (ទម្រង់១) ។ |

### សកម្មភាព

| | |
|---|---|
| សកម្មភាព ០.៥.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ រាជធានី ខេត្ត ធ្វើការប្រមូលឯកសារពាក់ព័ន្ធពីមន្ទីរជំនាញជុំវិញខេត្ត រួចហើយរៀបចំចងក្រងជាបញ្ជីឈ្មោះគម្រោងទាំងនោះ (ឈ្មោះ កាលបរិច្ឆេទ មាតិកា) ។ |

### ប្រតិបត្តិករ និងការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ។ | ប្រគល់ផែនទីប្រើប្រាស់ដីសាមញ្ញ និងលំអិតដែលបានទទួលពីក្រុម GIS ជូនដល់ក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅនីមួយៗ ចំនួន ១ច្បាប់នៅពេលចាប់ផ្ដើមដំណើរការធ្វើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ |

### តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *១ សប្ដាហ៍ (អាទិត្យ) សំរាប់ការប្រមូល និងវិភាគឯកសារ* |
| តម្រូវការសម្ភារៈ | ផែនការទាំងឡាយដែលបានអនុម័តរួច (ការចូលរួមក្នុងការធ្វើផែនការប្រើប្រាស់ដី ផែនការអភិវឌ្ឍន៍ខេត្ត ផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ) ផែនការតាមវិស័យ (ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម) និងការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានផងដែរ ។ |
| តម្រូវការទិន្នន័យ | ធ្វើការគូរបញ្ចូលទិន្នន័យ GIS ទៅក្នុងកុំព្យូទ័រនូវគំរោងទាំងឡាយដែលបានអនុម័តរួច |
| តម្រូវការបណ្ដុះបណ្ដាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ត្រូវការបណ្ដុះបណ្ដាលរយៈពេលខ្លីអំពីក្របខណ្ឌការងារនៃការរៀបចំដែនដី និងអំពីផែនការដែលបានអនុម័តរួច ព្រមទាំងអំពីការប្រើប្រាស់ផែនការទាំងនោះយ៉ាងដូចម្ដេច ។ |
| តម្រូវការផ្សេងៗទៀត | ទម្រង់ ១: បញ្ជីនៃគោលបំណងអភិវឌ្ឍន៍ |

## សកម្មភាព ០.៦ : ការផលិតផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

| បរិយាយ សកម្មភាព ០.៦ |
|---|
| ទីកន្លែង: ថ្នាក់រាជធានី ខេត្ត |
| បន្ទាប់ពីក្រុម GIS ថ្នាក់រាជធានី ខេត្តទទួលបាន និងរៀបចំទិន្នន័យមូលដ្ឋានទាំងអស់ពីសកម្មភាព០.១ដល់០.៤ហើយនោះ គេត្រូវប្រើទិន្នន័យទាំងនេះផលិតផែនទីជាពីរប្រភេទសំរាប់ឃុំនីមួយៗ គឺផលិតផែនទីប្រើប្រាស់ដីលំអិត និងផែនទីប្រើប្រាស់ដីសាមញ្ញឃុំ សង្កាត់។ ក្រុម GIS ថ្នាក់រាជធានី ខេត្ត ប្រគល់ផែនទីទាំងពីរប្រភេទនេះចំនួនមួយច្បាប់ៗទៅឃុំសង្កាត់នីមួយៗ មុនចាប់ផ្តើមដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ប្រចាំឆ្នាំ។ |

### លទ្ធផល

ក្រុម GIS ផលិតផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ជាពីរប្រភេទគឺ : ផែនទីប្រើប្រាស់ដីលំអិត និងផែនទីប្រើប្រាស់ដីសាមញ្ញ។ ផែនទីប្រើប្រាស់ដីលំអិតត្រូវបានផលិតដើម្បីប្រើប្រាស់ជាឯកសារយោង ហើយមិនតម្រូវឱ្យធ្វើការប្រែទេនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់/កម្មវិធីវិនិយោគឃុំ សង្កាត់ និងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ផែនទីនេះត្រូវធ្វើបច្ចុប្បន្នភាពជាថ្មី នៅពេលចាប់ផ្តើមវដ្តនៃការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ប្រចាំឆ្នាំតែប៉ុណ្ណោះ។ ផែនទីប្រើប្រាស់ដីសាមញ្ញបង្ហាញអំពីចំណាត់ថ្នាក់នៃការប្រើប្រាស់ដីជាមូលដ្ឋានតែប្រាំពីរប្រភេទប៉ុណ្ណោះ ដូច្នេះផែនទីនេះមានការងាយស្រួលអាន ហើយត្រូវប្រើប្រាស់ធ្វើជាផែនទីគោលសំរាប់រៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងគូសគំនូសព្រាងជាន់ពីលើ។

| | |
|---|---|
| លទ្ធផល ១ | ផែនទីប្រើប្រាស់ដីបច្ចុប្បន្នលំអិតបោះពុម្ពនៅលើក្រដាស A0 ធ្វើការបង្ហាញនូវៈ ព្រំប្រទល់ឃុំបច្ចុប្បន្ន លំអិតនៃប្រភេទនៃការប្រើប្រាស់ដី (អាចមានលទ្ធភាពបង្ហាញរហូតដល់ ៦៧ ប្រភេទនៃការប្រើប្រាស់ដី និងគំរបដី។ |
| លទ្ធផល ២ | ផែនទីប្រើប្រាស់ដីសាមញ្ញ(បច្ចុប្បន្ន) បោះពុម្ពនៅលើក្រដាស A0 ធ្វើការបង្ហាញអំពីព្រំប្រទល់ឃុំ សង្កាត់បច្ចុប្បន្ន ប្រភេទនៃការប្រើប្រាស់ដីសាមញ្ញ (ប្រភេទមូលដ្ឋានចំនួន៧ ប្រភេទនៃការប្រើប្រាស់ដី និងគំរបដី)។ |
| លទ្ធផល ៣ | ផែនទីប្រើប្រាស់ដីលំអិត និងផែនទីប្រើប្រាស់ដីសាមញ្ញ ដែលបោះពុម្ពលើក្រដាស A0 ចំនួន ១ច្បាប់ៗ ហើយត្រូវបានបែងចែកជូនតាមឃុំ សង្កាត់នីមួយៗនៅក្នុងរាជធានី ខេត្ត។ |

### សកម្មភាព

| | |
|---|---|
| សកម្មភាព ០.៦.១ | ក្រុម GIS ថ្នាក់រាជធានី ខេត្តរៀបចំនូវគ្រប់ទិន្នន័យនៃការប្រើប្រាស់ដី និងគំរបដីទាំងអស់ដែល ទទួលបានពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត និងក្រុមសម្របសម្រួលថ្នាក់រាជធានី ខេត្ត តាមឃុំនីមួយៗ |

| | |
|---|---|
| | រួចហើយធ្វើការបញ្ចូលទៅក្នុងកុំព្យូទ័រ។ |
| សកម្មភាព ០.៦.២ | ក្រុម GIS ថ្នាក់រាជធានី ខេត្ត បោះពុម្ពចេញនូវផែនទីចំនួន ១ច្បាប់ៗ នូវផែនទីលំអិត និងសាមញ្ញ សំរាប់ឃុំ សង្កាត់នីមួយៗ លើក្រដាសខ្នាត A0។ |
| សកម្មភាព ០.៦.៣ | ក្រុម GIS ថ្នាក់រាជធានី ខេត្ត ធ្វើការបែងចែកផែនទីលំអិត និងសាមញ្ញ ដែលបានបោះពុម្ពលើក្រដាស ខ្នាត A0 ដល់ឃុំនីមួយៗក្នុងខេត្ត នៅពេលចាប់ផ្តើមដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងផែនការវិនិយោគឃុំ សង្កាត់ ព្រមទាំងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។ |

## ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| ក្រុម GIS ថ្នាក់រាជធានី ខេត្ត | ទទួល ប្រមូល និងបញ្ចូលទិន្នន័យដែលទទួលបានពីលទ្ធផលនៃសកម្មភាពពី ០.១ ដល់ ០.៤ ទៅក្នុងមូលដ្ឋានទិន្នន័យ (database) នៃការប្រើប្រាស់ដី និងគំរបដី ហើយធ្វើការបោះពុម្ពចេញជាផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ សំរាប់ឃុំ សង្កាត់នីមួយៗនៅក្នុងខេត្ត។ |
| ក្រុមសម្របសម្រួលរៀបចំ | ទទួលពីក្រុម GIS នូវផែនទីប្រើប្រាស់ដីសាមញ្ញ និងលំអិត ហើយធ្វើការចែកជូនទៅដល់ឃុំ សង្កាត់នីមួយៗ នៅពេលចាប់ផ្តើមដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ |
| មេឃុំ ចៅសង្កាត់ | ទទួលពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត /ក្រុមសម្របសម្រួលរាជធានី ខេត្ត នូវផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ នៅពេលចាប់ផ្តើមដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *១ សប្តាហ៍* |
| តម្រូវការសម្ភារៈ | សំភារៈសំរាប់ការងារ GIS |
| តម្រូវការទិន្នន័យ | ទិន្នន័យ GIS លំអិតអំពីការប្រើប្រាស់ដី សំរាប់ឃុំ សង្កាត់នីមួយៗនៅក្នុងរាជធានី ខេត្ត។ |
| តម្រូវការបណ្តុះបណ្តាល | ក្រុម GIS រាជធានី ខេត្តនីមួយៗត្រូវការបណ្តុះបណ្តាលដើម្បីការគូសផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ជាប្រចាំឆ្នាំដូចខាងក្រោម :<br>○ ប្រមូល វិភាគ និងបញ្ចូលទិន្នន័យទៅក្នុង GIS<br>○ បោះពុម្ពនូវផែនទីប្រើប្រាស់ដីសំរាប់គ្រប់ឃុំ សង្កាត់<br>○ ធ្វើបច្ចុប្បន្នភាព និងធ្វើការបោះពុម្ពសារឡើងវិញជាទៀងទាត់ នៅពេលដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

| ការងារ B: ការផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពគោលបំណង អភិវឌ្ឍន៍ (ជំហាន ជំហាន១) | |
|---|---|
| គោលបំណង | ធ្វើឱ្យគណៈកម្មាធិការកសាងផែនការ និងថវិកា និងសមាជិកឃុំ សង្កាត់ មានការយល់ដឹងច្បាស់អំពីការប្រើប្រាស់ផែនទីព្រមទាំងលើកកំពស់ និងចែករំលែកការយល់ដឹងអំពីស្ថានភាពនៃការប្រើប្រាស់ដីក្នុង ឃុំ សង្កាត់ ហើយមានលទ្ធភាពកសាងផែនការបឋមនៃការប្រើប្រាស់ដី ។ |
| សកម្មភាព | **សកម្មភាព ១.១** : គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការពិនិត្យផែនទីប្រើប្រាស់ដីនៅក្នុង ឃុំ សង្កាត់សារឡើងវិញ ។<br>**សកម្មភាព ១.២** : គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការវិភាគទិន្នាការ និងផ្តល់មតិយោបល់ ដើម្បីបង្កើតផែនទី បញ្ហា មូលហេតុ និងដំណោះស្រាយ ។<br>**សកម្មភាព ១.៣** : គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការពិនិត្យសារឡើងវិញ និង ធ្វើបច្ចុប្បន្នភាពបញ្ជីគោលបំណងអភិវឌ្ឍន៍ ដែលបានមកពីផែនការដែលបានអនុម័តរួច ។<br>**សកម្មភាព ១.៤** : ឃុំ សង្កាត់ធ្វើការវិភាគទៅលើមូលដ្ឋានទូទៅនៃការវិភាគដីសមស្រប ។<br>**សកម្មភាព ១.៥** : រៀបចំផែនការបឋមសំរាប់ជំរើសក្នុងការប្រើប្រាស់ដីធ្លី ។ |
| អ្នកចូលរួម | - គណៈកម្មាធិការកសាងផែនការ និងថវិកា និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអញ្ជើញចូលរួមជាបុគ្គលគន្លឹះក្នុងការផ្តល់ព័ត៌មាន ដើម្បីផ្តល់មតិយោបល់ឆ្លើយតបនឹងចំណុចសំខាន់ៗ និងផ្តល់ជាព័ត៌មានបន្ថែម ។<br>- ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌដោយសហការជាមួយនឹងអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ធ្វើការសម្របសម្រួល និងផ្ទៀងផ្ទាត់សារឡើងវិញនូវដំណើរការនេះ ។<br>- ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌផ្តល់នូវមតិយោបល់ជាក់លាក់ និងគាំទ្រនូវសំណូមពរ និងធ្វើការផ្លាស់ប្តូរតាមដំណើរការ ។ |
| ទីកន្លែង | សកម្មភាពនៃការផ្ទៀងផ្ទាត់ធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់ |
| រយៈពេល | - ត្រៀមរៀបចំការងារផ្ទៀងផ្ទាត់ : ២ថ្ងៃ<br>- ប្រជុំផ្ទៀងផ្ទាត់ : កន្លះថ្ងៃ (១/២) ដល់ ១ថ្ងៃ<br>- កន្លះថ្ងៃ(១/២) សំរាប់ធ្វើបច្ចុប្បន្នភាពផែនទី ដោយផ្អែកលើការផ្តល់មតិយោបល់ឆ្លើយតបពីឃុំ សង្កាត់ |
| សម្ភារៈ | - ផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញឃុំ សង្កាត់<br>- ក្រដាសប្លាស្ទិកថ្លា និងហ្វឺត<br>- របៀបវារៈ កម្មវិធី និងគោលការណ៍នៃសិក្ខាសាលា<br>- គោលបំណងអភិវឌ្ឍដែលបានមកពីផែនការដែលបានអនុម័តរួច ( សូមមើលឧបសម្ព័ន្ធ ១០ ទម្រង់២ សំរាប់ធ្វើជាគំរូ) |
| លទ្ធផល | - ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ដែលបានធ្វើបច្ចុប្បន្នភាពរួច ផែនទីបញ្ហា មូលហេតុនិងដំណោះស្រាយ<br>- បញ្ជីសំណើនៃជំរើសនានាក្នុងការប្រើប្រាស់ដីពេលអនាគត<br>- បញ្ជីនៃគោលបំណងអភិវឌ្ឍន៍ដែលបានមកពីបណ្តាំផែនការដែលបានអនុម័តរួច ។ |


លទ្ធផលនៃ ផបដឃ
ការងារ B: ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពបណ្តា គោលបំណងអភិវឌ្ឍន៍
ធ្វើបច្ចុប្បន្នភាព ផែនទីប្រើប្រាស់ដី (គំនូសព្រាង)
ធ្វើបច្ចុប្បន្នភាព ផែនទី "តំបន់សើប"
បញ្ជីនៃជំរើសក្នុង ការប្រើប្រាស់ដី ពេលអនាគត
ផអឃ ជំហាន ១ : សេចក្តីព្រាង ក្របខណ្ឌអភិវឌ្ឍន៍ និងថវិកា
ផែនទី បញ្ហា មូលហេតុ និងដំណោះស្រាយ (គំនូសព្រាង)

| សកម្មភាព ១.១: គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការពិនិត្យសារឡើងវិញនូវផែនទីប្រើប្រាស់ដី នៅក្នុងឃុំ សង្កាត់ |
|---|
| **បរិយាយ សកម្មភាព ១.១** |
| ទីកន្លែង: ថ្នាក់ឃុំ សង្កាត់ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យមើលផែនទីប្រើប្រាស់ដីបច្ចុប្បន្ន ដែលទទួលបានពីក្រុម GIS ហើយធ្វើការផ្ទៀងផ្ទាត់ទិន្នន័យនៃការប្រើប្រាស់ដី គំរបដី និងព្រំប្រទល់ តាមស្ថានភាពជាក់ស្តែងដែលមាននៅក្នុងពេលបច្ចុប្បន្នដោយផ្អែកទៅលើចំណេះដឹងមូលដ្ឋានរបស់គេ។ នៅទីតាំងណាដែលមិនត្រឹមត្រូវ ឬជាទិន្នន័យចាស់ដែលមិនទាន់បានធ្វើបច្ចុប្បន្នភាព គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវកែសម្រួលជាគំនូសព្រាង នៅលើប្លាស្ទិកថ្លាដែលផ្ទាប់គ្របពីលើផែនទីប្រើប្រាស់ដីសាមញ្ញ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ស្រុក ជាអ្នកសម្របសម្រួលដំណើរការនេះ។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | ការពិនិត្យសារឡើងវិញលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន ដោយគណៈកម្មាធិការកសាងផែនការ និងថវិកា |
| លទ្ធផល ២ | ការលើកជាសំណើកែប្រែលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន ដោយគណៈកម្មាធិការកសាងផែនការ និង ថវិកា (ដោយគូរកែតម្រូវលើប្លាស្ទិចថ្លាដែលគ្របផ្ទាប់ពីលើផែនទីនោះ)។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ១.១.១ | សូមឱ្យមាន : គ្រូបណ្តុះបណ្តាលមកពីខាងក្រៅដើម្បី "បណ្តុះបណ្តាលគ្រូបង្គោល" ដល់អ្នកសម្របសម្រួលថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ អំពីតម្រូវការនៃកិច្ចការពារសង្គម និងបរិស្ថាន (សំរាប់បណ្តុះបណ្តាលបន្តដល់គណៈកម្មាធិការកសាងផែនការ និងថវិកា)។ |
| សកម្មភាព ១.១.២ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ពិនិត្យសារឡើងវិញនូវផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ជាមួយនឹងគណៈកម្មាធិការកសាងផែនការ និងថវិកា ហើយពន្យល់អំពីលេខកូដនៃទិន្នន័យ និងព័ត៌មានផ្សេងៗក្នុងការគូរផែនទីក៏ដូចជាគោលបំណង និងវិធីសាស្ត្រសំរាប់ការងារពិនិត្យផែនទីសារឡើងវិញនេះ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ធ្វើការសង្ខេបជូនត្រួសៗ អំពីតម្រូវការក្នុងការការពារសង្គម និងបរិស្ថានដល់គណៈកម្មាធិការកសាងផែនការ និងថវិកា ដោយមានជំនួយពីក្រុមសម្របសម្រួលថ្នាក់រាជធានី ខេត្ត។ |
| សកម្មភាព ១.១.៣ | គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការពិនិត្យសារឡើងវិញ និងពិភាក្សាលើផែនទីប្រើប្រាស់ ដីបច្ចុប្បន្ន។ |
| សកម្មភាព ១.១.៤ | គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការគូសព្រាង ជាសំណើក្នុងការកែប្រែ នៅលើប្លាស្ទិចថ្លាដែលគ្របផ្ទាប់ពីលើផែនទី ប្រើប្រាស់ដីសាមញ្ញ។ |

## ប្រតិបត្តិករ និងការទទួលខុសត្រូវ

| | |
|---|---|
| គ្រូបណ្តុះបណ្តាលមកពីខាងក្រៅ | ធ្វើការ "បណ្តុះបណ្តាលគ្រូបង្គោល" ដល់អ្នកសម្របសម្រួលថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដោយមានរួមបញ្ចូលនូវតម្រូវការក្នុងកិច្ចការពារសង្គមបរិស្ថាន និងការកំណត់យុទ្ធសាស្ត្រនៅក្នុងនោះផង ។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត/ក្រុមសម្របសម្រួលរាជធានី ខេត្ត | ជួយដល់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/ក្រុមសម្របសម្រួលក្រុង ស្រុក ខណ្ឌក្នុងការសង្ខេបជូនត្រួសៗ អំពីតម្រូវការក្នុងកិច្ចការពារ សង្គម-បរិស្ថាន ដល់គណៈកម្មាធិការកសាងផែនការ និងថវិកា ។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ ក្រុង ស្រុក ខណ្ឌ/ក្រុមសម្របសម្រួលក្រុង ស្រុក ខណ្ឌ | ធ្វើការសម្របសម្រួលដំណើរការនៃការពិនិត្យផែនទីសារឡើងវិញ : ពន្យល់នូវដំណើរការក្នុងការគូរផែនទីក៏ដូចជាការប្រើប្រាស់លេខកូដ ព្រមទាំងគោលបំណង និងវិធីសាស្ត្រក្នុងការពិនិត្យផែនទីសារឡើងវិញ ។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ធ្វើការពិនិត្យសារឡើងវិញលើកឡើងនូវសំណើ និងការកែប្រែ (នៅកន្លែងណាដែល ចាំបាច់) |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *រយៈពេលប៉ាន់ស្មានសំរាប់ធ្វើការបណ្តុះបណ្តាលអំពីការការពារ សង្គម-បរិស្ថាន ដល់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត , ក្រុមសម្របសម្រួលរាជធានី ខេត្ត, ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ស្រុក : កន្លះ(១/២) ថ្ងៃ*<br>*រយៈពេលប៉ាន់ស្មានសំរាប់ការពិនិត្យសារឡើងវិញ នូវផែនទីប្រើប្រាស់ដីឃុំ និងការបង្ហាញត្រួសៗអំពីការការពារសង្គម-បរិស្ថាន : កន្លះ(១/២) ថ្ងៃ* |
| តម្រូវការសម្ភារៈ | ប្លាស្ទិកថ្លា សំរាប់គ្របផ្ទាប់ពីលើផែនទីដើម្បីធ្វើការគូសគំនូសព្រាង ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | ផែនទីប្រើប្រាស់ដីលំអិត និង សាមញ្ញ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុកខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវការនូវវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីអំពីការពិនិត្យផែនទីសារឡើងវិញ និងការការពារសង្គម-បរិស្ថាន ។ |
| តម្រូវការផ្សេងៗទៀត | សូមឱ្យមានវគ្គបណ្តុះបណ្តាល ស្តីពីការការពារ សង្គម-បរិស្ថាន ដើម្បីធានាថាគណៈកម្មការផែនការ និងថវិកា និង អ្នកភូមិយល់បាននូវតំបន់ដែលងាយរងគ្រោះផ្នែកខាង សង្គម និង បរិស្ថាន ហើយនឹងមាន ការយកចិត្តទុកដាក់ដល់កិច្ចការពារ សង្គម-បរិស្ថាននៅពេលដែលធ្វើផែនការយុទ្ធសាស្ត្រឃុំ សង្កាត់ហើយនឹងអាចធ្វើការចាត់អាទិភាពតាមដំណាក់កាលនៃការធ្វើផែនការ ។ |

## សកម្មភាព ១.២ : ការវិភាគ និងការគូសផែនទី បញ្ហា មូលហេតុ និង ដំណោះស្រាយ

**បរិយាយ សកម្មភាព ១.២**

ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការ "វិភាគនិន្នាការ" ហើយធ្វើការសង្ខេប បញ្ហា មូលហេតុ និង ដំណោះស្រាយ ជាចម្បងៗនៅក្នុងឃុំ សង្កាត់ ដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី។ ក្នុងដំណើរការនេះ គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការគូសផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ដែលជាគំនូសព្រាងបង្ហាញអំពីទីតាំងនៃបញ្ហាមូលហេតុ និងដំណោះស្រាយ។ ផែនទីនេះ គឺជាឧបករណ៍មួយសំរាប់ការចាត់អាទិភាពគំរោង (ការងារ D)។

អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលដំណើរការនេះ ដោយមានការគាំទ្រពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | តារាងសង្ខេបអំពី *បញ្ហា មូលហេតុ និងដំណោះស្រាយ* ដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លីសំខាន់ៗនៅក្នុងឃុំ សង្កាត់។ |
| លទ្ធផល ២ | ផែនទី*បញ្ហា មូលហេតុ និងដំណោះស្រាយ*<br>ត្រូវបានគូសព្រាងនៅនៅលើប្លាស្ទិកថ្លាដែលគ្រប ផ្ទាប់ពីលើផែនទីប្រើប្រាស់ដីសាមញ្ញ ដោយកំណត់នូវទីតាំងនៃបញ្ហា និងលើកឡើងសំណើសំរាប់ ធ្វើការដោះស្រាយបញ្ហាទាំងនោះ ហើយត្រូវភ្ជាប់មកជាមួយនូវតារាងសង្ខេបផងដែរ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ១.២.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌធ្វើការពន្យល់អំពីគោលការណ៍ជាមូលដ្ឋានសំរាប់ការគូរផែនទី និងណែនាំអំពីវិធីសាស្ត្រជាគោលការណ៍ក្នុងការធ្វើតារាងសង្ខេប និងផែនទី ជូនដល់គណៈកម្មាធិការកសាងផែនការ និងថវិកា ។ |
| សកម្មភាព ១.២.២ | គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការវិភាគនិន្នាការ ដើម្បីកំណត់បញ្ហាសំខាន់ៗ មូលហេតុ និងសំណើនៃដំណោះស្រាយក្នុងឃុំ សង្កាត់របស់ខ្លួន។ |
| សកម្មភាព ១.២.៣ | គណៈកម្មាធិការកសាងផែនការ និងថវិកា គូសព្រាងផែនទី*បញ្ហា មូលហេតុ និងដំណោះស្រាយ* នៅលើផ្ទាំងប្លាស្ទិកថ្លា ដែលគ្របផ្ទាប់ពីលើផែនទីប្រើប្រាស់ដីសាមញ្ញដោយបង្ហាញនូវបញ្ហាចម្បងៗ និងសំណើសំរាប់ដោះស្រាយ។ |

## ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/ អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ | ពន្យល់អំពីវិធីសាស្ត្រនៃការវិភាគនិន្នាការ និងជួយដល់គណៈកម្មាធិការកសាងផែនការ និងថវិកាក្នុងការបំពេញតារាងសង្ខេប និង គូសព្រាងផែនទី ឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ធ្វើការវិភាគនិន្នាការ និងគូសព្រាងផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ។ |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *រយៈពេលប៉ាន់ស្មានសំរាប់ការវិភាគនិន្នាការៈ មួយ(១) ថ្ងៃ*<br>*រយៈពេលប៉ាន់ស្មានសំរាប់ការគូសព្រាងផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយៈកន្លះ(១/២) ថ្ងៃ* |
| តម្រូវការសម្ភារៈ | ក្រដាសផ្ទាំងធំ សំរាប់ធ្វើការវិភាគនិន្នាការ ផ្ទាំងប្លាស្ទិកថ្លាសំរាប់ផ្ទាប់គូសគំនូសព្រាង ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | ផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ / អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌជួយសម្របសម្រួលការវិភាគនិន្នាការ និងការគូសព្រាងផែនទី ។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## សកម្មភាព ១.៣: គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យសារឡើងវិញនិងធ្វើបច្ចុប្បន្នភាពបញ្ជីគោលបំណងអភិវឌ្ឍន៍

| បរិយាយ សកម្មភាព ១.៣ |
|---|
| ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា នឹងធ្វើការពិនិត្យសារឡើងវិញ និងធ្វើបច្ចុប្បន្នភាពបញ្ជីគោលបំណងអភិវឌ្ឍន៍ទាំងអស់ ពីឯកសារផ្សេងៗគ្នា។ បញ្ជីនេះនឹងបង្ហាញអំពីគោលបំណងអភិវឌ្ឍន៍ ប្រភពនៃគម្រោងអភិវឌ្ឍន៍និងប្រភពថវិកា (ប្រសិនបើមាន) ព្រមទាំងបង្ហាញទីតាំងនៃគម្រោងទាំងនោះឱ្យបានច្បាស់លាស់។ |

### លទ្ធផល

| | |
|---|---|
| លទ្ធផល ១ | ពិនិត្យសារឡើងវិញ និងធ្វើបច្ចុប្បន្នភាពបញ្ជីនៃគោលបំណងអភិវឌ្ឍន៍។ |
| លទ្ធផល ២ | សេចក្តីព្រាងផែនទីប្រើប្រាស់ដីពេលអនាគត (ជាគំនូសព្រាងលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន) |

### សកម្មភាព

| | |
|---|---|
| សកម្មភាព ១.៣.១ | គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យសារឡើងវិញ និងធ្វើបច្ចុប្បន្នភាពបញ្ជីគោលបំណងអភិវឌ្ឍន៍។ |
| សកម្មភាព ១.៣.២ | គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការសំរេចលើបញ្ជីគោលបំណងអភិវឌ្ឍហើយប្រសិន បើយល់ឃើញថា គោលបំណងនៃការអភិវឌ្ឍន៍ណា មួយមានផលប៉ះពាល់ដល់កិច្ចការពារ សង្គម ឬបរិស្ថាន ត្រូវបង្ហាញអំពីហេតុផលប៉ះពាល់ទាំងនេះ។ |

### ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត / ក្រុមសម្របសម្រួលរាជធានី ខេត្ត | ជំរាបជូនជាសង្ខេបអំពីកិច្ចការពារសង្គម-បរិស្ថាន ដល់គណៈកម្មាធិការកសាងផែនការ និងថវិកា។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ ក្រុង ស្រុក ខណ្ឌ/ ក្រុម សម្របសម្រួលក្រុង ស្រុក ខណ្ឌ | ធ្វើការសម្របសម្រួលដំណើរការពិនិត្យសារឡើងវិញនូវបញ្ជីគោលបំណងអភិវឌ្ឍន៍ និងគូរផែនទី។ ពន្យល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាអំពីការគូរផែនទី និងការប្រើប្រាស់ លេខកូដ និងវិធីសាស្ត្រនៃការគូរផែនទី ព្រមទាំងការពិនិត្យបញ្ជីគោលបំណងអភិវឌ្ឍន៍សារឡើងវិញ។ |
| គណៈកម្មាធិការកសាងផែនការនិង ថវិកា | ពិនិត្យសារឡើងវិញ លើកឡើងនូវអនុសាសន៍ និងធ្វើការកែប្រែបញ្ជីគោលបំណងអភិវឌ្ឍន៍ (ប្រសិនបើមានការចាំបាច់)។ |

### តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *រយៈពេលចាំន់ស្មានសំរាប់ការពិនិត្យសារឡើងវិញនូវគោលបំណងអភិវឌ្ឍន៍ និងការធ្វើបច្ចុប្បន្នភាព : ពីរ(២) ម៉ោង* |

| | |
|---|---|
| តម្រូវការសម្ភារៈ | - ផ្ទាំងប្លាស្ទិកថ្លាសំរាប់គ្របផ្ទាប់ពីលើផែនទីក្នុងការគូរគំនូសព្រាង<br>- ប៊ិចហ្វឺត<br>- បញ្ជីនៃគោលបំណងអភិវឌ្ឍន៍ បានមកពីបណ្តុំផែនការដែលបានអនុម័តរួចហើយ |
| តម្រូវការទិន្នន័យ | គ្មាន |
| តម្រូវការបណ្តុះបណ្តាល | វគ្គបណ្តុះបណ្តាល "គ្រូបង្គោល" សំរាប់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក និងអ្នកសម្របសម្រួលថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការសង្ខេបជូនត្រួស១ដល់គណៈកម្មាធិការកសាងផែនការ និងថវិកា ។ |
| តម្រូវការផ្សេង១ទៀតដើម្បីអនុវត្តក្នុងសកម្មភាពនេះ | សូមឱ្យមានវគ្គបណ្តុះបណ្តាលស្តីពីការការពារសង្គម-បរិស្ថាន ដើម្បីធានាថា គណៈកម្មាធិការកសាងផែនការ និងថវិកា និងអ្នកភូមិយល់បាននូវតំបន់ដែលងាយរងគ្រោះផ្នែកសង្គម និងបរិស្ថាន ហើយនឹងមានការយកចិត្តទុកដាក់ដល់កិច្ចការពារសង្គម-បរិស្ថាន នៅពេលធ្វើផែនការយុទ្ធសាស្ត្រឃុំ សង្កាត់ហើយនឹងអាចធ្វើការចាត់អាទិភាពតាមដំណាក់កាលនៃការធ្វើផែនការ ។ |

## សកម្មភាព ១.៤ : ការធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ

**បរិយាយ សកម្មភាព ១.៤**

ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់

ធ្វើការវិភាគ*ភាពសមស្របនៃដីជាលក្ខណៈទូទៅ* ដើម្បីជាមូលដ្ឋានសំរាប់កំណត់យុទ្ធសាស្ត្ររបស់ឃុំ សង្កាត់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងសំរាប់កំណត់ជំរើសនានាក្នុងការប្រើប្រាស់ដីពេលអនាគត ។ ភាពសមស្របនៃដីជាលក្ខណៈទូទៅនេះ គឺជាការវាយតម្លៃរហ័សដោយវិភាគទៅលើ ១) កំរិតជីជាតិដី ២) គម្របរុក្ខជាតិ និងដំណាំ និង ៣) ប្រភពធនធានទឹកក្នុងឃុំ សង្កាត់ ។ ការវាយតម្លៃគឺផ្អែកតែទៅលើមូលដ្ឋាននៃចំណេះដឹងមូលដ្ឋានដែលមានស្រាប់ពីសំណាក់គណៈកម្មាធិការកសាងផែនការ និងថវិកា និងអ្នកភូមិ ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ថ្នាក់ក្រុង ស្រុក ខណ្ឌ/ក្រុមសម្របសម្រួលក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលសកម្មភាពនេះ ។

**ទំនាក់ទំនងទៅនឹងការវាយតម្លៃភាពសមស្របនៃដី**

*ការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅនេះ គឺជាចំណែកមួយនៃដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ក្នុងអំឡុងពេលរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ ការវិភាគភាពសមស្របនៃដីនេះ មិនមែនជាការបំពេញបន្ថែមសំរាប់ការវាយតម្លៃភាពសមស្របនៃដីលំអិតនៃកម្មវិធីដទៃទៀតនោះទេ ។ គោលបំណងនៃការវិភាគនេះ គឺគ្រាន់តែជាការចងក្រងឯកសារអំពីចំណេះដឹងមូលដ្ឋានដែលមានស្រាប់ទៅលើចំណោតសំខាន់ៗក្នុងការប្រើប្រាស់ធនធានធម្មជាតិដែលមាននៅក្នុងឃុំ សង្កាត់ (ដី ទឹក គម្របរុក្ខជាតិ និងដំណាំ) ដោយប្រជាពលរដ្ឋដែលបានធ្វើកសិកម្ម និងបានប្រើប្រាស់ធនធានទាំងនេះជាប្រចាំថ្ងៃ ។ ការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅនេះអាចផ្តល់នូវព័ត៌មានមូលដ្ឋានសំខាន់ៗ សំរាប់ដំណើរការវិភាគភាពសមស្របនៃដីបន្តបន្ទាប់នៅពេលក្រោយទៀត ។*

*ឧទាហរណ៍ : ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់មានបំណងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនៅមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់អាចយកលទ្ធផលវិភាគភាពសមស្របនៃដីនេះ ធ្វើជាសំណើសុំការសំរេចពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដី រាជធានី ខេត្ត ហើយអាចធ្វើការវិភាគភាពសមស្របនៃដីកាន់តែលំអិតថែមទៀត ។*

*ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់មានបំណងស្នើឡើងដើម្បីបង្កើតប្រព័ន្ធស្រោចស្រពខ្នាតធំនោះ ការវិភាគភាពសមស្របនៃដីលំអិតគួរធ្វើឡើងដោយមន្ត្រីជំនាញបច្ចេកទេសនៃមន្ទីរធនធានទឹក និងឧតុនិយម ។*

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | របាយការណ៍អំពីការវិភាគភាពសមស្របនៃដី ជាមួយនឹងផែនទីប្រើប្រាស់ដីពេលអនាគត ដែលគូសព្រាងដោយ គណៈកម្មាធិការកសាងផែនការ និងថវិកាសំរាប់យកជាមូលដ្ឋាន ក្នុងការបង្ហាញ និងពិពណ៌នា :<br>១) តំបន់ដែលជាដីមានជីជាតិ<br>២) ប្រភពធនធានទឹកដែលអាចមាន<br>៣) តំបន់ដែលមានគម្របរុក្ខជាតិ និងគម្របដំណាំផ្សេងៗគ្នា<br>៤) កំរិតជំរាល និងរយៈកំពស់ និង<br>៥) ទិន្នន័យអំពីទីផ្សារ និងតម្លៃកសិផល ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ១.៤.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ពន្យល់ជូនគណៈកម្មាធិការកសាងផែនការ និងថវិកា នូវគោលបំណង និងវិធីសាស្ត្រ សំរាប់ធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ ។ |
| សកម្មភាព ១.៤.២ | គណៈកម្មាធិការកសាងផែនការ និងថវិកា ដោយមានជំនួយពីអ្នកភូមិ ធ្វើការចងក្រងឯកសារអំពីតំបន់ដែលជាដីមានជីជាតិ ប្រភពធនធានទឹក តំបន់ដែលមានគម្របរុក្ខជាតិ និងគម្របដំណាំផ្សេងៗគ្នា នៅទូទាំងឃុំ សង្កាត់ (ហើយអាចមានជំនួយបន្ថែមពីផែនទីផ្សេងៗ ដូចជា "ផែនទីប្រភេទដី រយៈកំពស់/កំរិតជំរាល ជលសាស្ត្រ ការប្រើប្រាស់ដី ...") ។ |
| សកម្មភាព ១.៤.៣ | គណៈកម្មាធិការកសាងផែនការ និងថវិកា សរសេររបាយការណ៍សង្ខេបអំពីការវិភាគភាពសមស្របនៃដី ជាមួយនឹងរបកគំហើញថ្មីៗ ព្រមជាមួយនឹងរូបភាពផែនទីគំនូសព្រាង ដែលបង្ហាញឱ្យឃើញអំពីតំបន់ដីមានជីជាតិ ប្រភពធនធានទឹក តំបន់ដែលមានគម្របរុក្ខជាតិ និង គម្របដំណាំផ្សេងៗគ្នានៅទូទាំងឃុំ សង្កាត់ ។ |

**ប្រតិបត្តិករ និងការទទួលខុសត្រូវ**

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការ ប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ | ពន្យល់អំពីវិធីសាស្ត្រក្នុងការធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ (ឧបសម្ព័ន្ធ៧)។<br>ធ្វើការសម្របសម្រួលដំណើរការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ ។ |

| | |
|---|---|
| គ្រូឧទ្ទេសមកពីខាងក្រៅ | ផ្ដល់នូវការបណ្ដុះបណ្ដាល "គ្រូបង្គោល" ដល់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត(និងក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ ក្រុង ស្រុក ខណ្ឌ) សំដៅដល់ការធ្វើការវិភាគភាពសមស្របនៃដីដោយមានរំលេចនូវវិធីសាស្ត្រដែលមានភាពសមស្របបំផុត។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | វិភាគ និងចងក្រងរបាយការណ៍ស្ដីពីភាពសមស្របនៃដីជាលក្ខណៈទូទៅ ។ |
| អ្នកភូមិ | ចូលរួមចំណែកក្នុងការផ្ដល់នូវចំណេះដឹងមូលដ្ឋានជូនដល់គណៈកម្មាធិការកសាងផែនការ និងថវិកា |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | ការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ : កន្លះ(១/២)ថ្ងៃ |
| តម្រូវការសម្ភារៈ | ក្រដាសផ្ទាំងធំ សៀវភៅសរសេរ ប៊ិចហ្វឺត និងប៊ិចសរសេរធម្មតា |
| តម្រូវការទិន្នន័យ | ចំណេះដឹងមូលដ្ឋានរបស់អ្នកភូមិ និងកសិករទូទាំងឃុំ សង្កាត់ |
| តម្រូវការបណ្ដុះបណ្ដាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ពន្យល់ និងធ្វើការសម្របសម្រួលដំណើរការវិភាគភាពសមស្របនៃដី និងពន្យល់អំពីតំបន់ដែលតម្រូវឱ្យមានកិច្ចការពារសង្គម-បរិស្ថាន ដោយផ្អែកលើផែនទី "តំបន់រសើប" ។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

| សកម្មភាព ១.៥ : ការរៀបចំផែនការបឋមប្រើប្រាស់ដីពេលអនាគត |
|---|
| **បរិយាយ សកម្មភាព ១.៥** |
| ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់ |
| ផ្អែកតាមលទ្ធផលនៃសកម្មភាព ១.១ដល់១.៤ គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវធ្វើការវិភាគអំពីតំបន់ដែលមានដីសមស្របក្នុងការប្រើប្រាស់សំរាប់រយៈពេល១០ទៅ១៥ឆ្នាំទៅមុខទៀត ដែលគួរតែធ្វើការផ្លាស់ប្តូរ (ការវិភាគនិន្នាការ)។ គណៈកម្មាធិការកសាងផែនការ និងថវិកាត្រូវធ្វើការរៀបចំ "ផែនការក្នុងការប្រើប្រាស់ដីបឋម" (តារាង និងផែនទី) ដែលត្រូវធ្វើបទ បង្ហាញជូនតំណាងឃុំ សង្កាត់សំរាប់ធ្វើការ "អនុម័តជាបណ្តោះអាសន្ន" និងបញ្ចូលទៅក្នុងសេចក្តីព្រាងនៃផែនការប្រើប្រាស់ដី ។ សកម្មភាពការងារនេះត្រូវមានការគាំទ្រពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | បញ្ជីជំរើសនៃសក្តានុពលក្នុងការប្រើប្រាស់ដីពេលអនាគត (ពីជំហាន ១.៤) ។ |
| លទ្ធផល ២ | ផ្តល់ចម្លើយដល់សំណួរមួយថា : តើនៅក្នុងឃុំរបស់អ្នកមានដីសមស្របប្រកបដោយសក្តានុពលសំរាប់អនុវត្តការប្រើប្រាស់ដីពេលអនាគតជាជំរើសផ្សេងៗដែរឬទេ ?<br>ប្រសិនបើជាចម្លើយវិជ្ជមាន គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវបង្កើតផែនការបឋមសំរាប់ការ ប្រើប្រាស់ដីពេលអនាគត ។ |
| លទ្ធផល ៣ | <u>**បញ្ជីផ្ទៀងផ្ទាត់**</u> : ការកំណត់ជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត ត្រូវពិនិត្យលើធាតុមួយចំនួនដូចខាងក្រោម :<br>១) ពិពណ៌នាអំពីតំបន់ដែលត្រូវលើកសំណើរួមមាន : ទីតាំង ព្រំប្រទល់ប្រហាក់ប្រហែល ទំហំ និងចំណាត់ថ្នាក់ជីជាតិដី ។<br>២) ព័ត៌មានស្តីពីកម្មសិទ្ធិ និងស្ថានភាពក្នុងការកាន់កាប់នៃតំបន់ដែលលើកសំណើ ។<br>៣) ការកំណត់ជាបឋមនូវក្រុមគោលដៅដែលត្រូវបានទទួលអត្ថប្រយោជន៍ពីជំរើសនៃការប្រើប្រាស់ ដីតាមរយៈការលើកសំណើនេះ ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ១.៥.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌពន្យល់ជូនគណៈកម្មាធិការកសាងផែនការ និងថវិកាអំពីទំហំការងារគោលបំណង និងគោលការណ៍ជាមូលដ្ឋានសំរាប់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។ |
| សកម្មភាព ១.៥.២ | គណៈកម្មាធិការកសាងផែនការនិងថវិកាពាក់ព័ន្ធ ត្រូវធ្វើការពិនិត្យលើសេចក្តីព្រាងនៃផែនទីប្រើប្រាស់ដីពេលអនាគត (សកម្មភាព ០.៦) និងបន្ថែមជំរើសថ្មីៗ ដោយផ្អែកលើការវិភាគភាពសមស្របនៃដី ។ |

| | |
|---|---|
| សកម្មភាព ១.៥.៣ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ប្រគល់ទិន្នន័យ និងព័ត៌មានដល់ក្រុម GIS ដើម្បីធ្វើការរៀបចំ និងគូសផែនទីប្រើប្រាស់ដីពេលអនាគតឱ្យបានរួចរាល់។ |

## ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ | សម្របសម្រួលដំណើការវិភាគភាពសមស្របនៃដី ដែលជាលទ្ធផលបានមកពីសកម្មភាព ១.៥។ ធ្វើការបណ្តុះបណ្តាលដល់គណៈកម្មាធិការកសាងផែនការ និងថវិកាប្រមូលផ្តុំលើគោលបំណង គោលការណ៍ជាមូលដ្ឋាន និងតម្រូវការសំរាប់ការធ្វើកម្មវិធីសម្បទានដីសង្គមកិច្ច។ |
| គណៈកម្មាធិការកសាងផែនការ និង ថវិកា | រៀបចំតារាង និងផែនទីប្រើប្រាស់ដីសំរាប់ពេលអនាគត (ផែនទីគំនូសព្រាង ដែលគូសពីលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន) ដោយផ្អែកលើការវិភាគភាពសមស្របនៃដី។ |
| ក្រុម GIS | ទទួលទិន្នន័យនិងព័ត៌មានពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងធ្វើការរៀបចំផែនទីប្រើប្រាស់ដីពេលអនាគត និងធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដី នៅកន្លែងណាដែលមានការចាំបាច់។ |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *ការធ្វើផែនការបឋមសំរាប់ជំរើសក្នុងការប្រើប្រាស់ដីធ្លីពេលអនាគត : កន្លះថ្ងៃដល់មួយថ្ងៃ (១/២ថ្ងៃ ដល់ ១ថ្ងៃ)* |
| តម្រូវការសម្ភារៈ | ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | - ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់<br>- ផែនទី *បញ្ហា មូលហេតុ និងដំណោះស្រាយ* និងតារាង *បញ្ហា មូលហេតុ និងដំណោះស្រាយ*<br>- ការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ<br>- ទិន្នន័យឃុំ សង្កាត់<br>- តម្លៃទីផ្សារនៃកសិផល និងអនុផលព្រៃឈើ |
| តម្រូវការធនធានមនុស្ស និងការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ផ្តល់នូវការបង្ហាញត្រួសៗ និងជួយគណៈកម្មាធិការកសាងផែនការ និងថវិកាអំពីជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

| ការងារ C : ការកសាងផែនទីសំរេច (ផអឃ ជំហាន៣) | |
|---|---|
| គោលបំណង | ដើម្បីជាជំនួយដល់ការវិភាគលទ្ធផលនៃការវាយតម្លៃ បញ្ហា មូលហេតុ និង ដំណោះស្រាយនៅថ្នាក់ ភូមិ និងថ្នាក់ឃុំ សង្កាត់។ ផ្តល់នូវគំហើញជារូបវ័ន្ត អំពីលទ្ធផលនៃ*បញ្ហា មូលហេតុ និងដំណោះស្រាយ* នៅថ្នាក់ឃុំ សង្កាត់។ ផ្តល់នូវមូលដ្ឋានសំរាប់ធ្វើអត្តសញ្ញាណកម្ម និងការតាងជារូបវ័ន្តនៃគំរោងនានា។ |
| សកម្មភាព | **សកម្មភាព ៣.១ :** គណៈកម្មាធិការកសាងផែនការ និងថវិកាពិនិត្យ (ការកែសម្រួលពីអ្នកភូមិប្រសិនជាមាន) ផែនទីប្រើប្រាស់ដីបច្ចុប្បន្នសារឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនទីទាំង២ប្រភេទនេះ (ផែនទីលំអិត និង ផែនទីសាមញ្ញ)។<br>**សកម្មភាព ៣.២ :** គណៈកម្មាធិការកសាងផែនការ និងថវិកាដោយមានការគាំទ្រពីក្រុមសម្របសម្រួលរៀបចំ ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុកខណ្ឌ និងរៀបចំផែនទី *បញ្ហា មូលហេតុ និង ដំណោះស្រាយ*ឱ្យបាន ចប់សព្វគ្រប់។ |
| អ្នកចូលរួម | គណៈកម្មាធិការកសាងផែនការនិងថវិកា និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអញ្ជើញឱ្យចូលរួមជាបុគ្គល គន្លឹះក្នុងការផ្តល់ព័ត៌មាន និងមតិយោបល់បន្ថែម។<br>ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលដោយសហការជាមួយនឹងក្រុមសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំផែនទីទាំងនេះឱ្យបានសំរេច។ |
| ទីកន្លែង | សកម្មភាពក្នុងការធ្វើផែនទី បញ្ហា មូលហេតុ និងដំណោះស្រាយនេះប្រព្រឹត្តិទៅ នៅភូមិនិមួយៗនៃឃុំ សង្កាត់គោលដៅ រួចហើយទើបធ្វើការបូកសរុបនៅឃុំ សង្កាត់ ។ |
| រយៈពេល | បញ្ហា មូលហេតុ និងដំណោះស្រាយប្រព្រឹត្តិទៅនៅភូមិនិមួយៗចំនួន ១ថ្ងៃ ហើយបូកសរុបនៅថ្នាក់ ឃុំ សង្កាត់ចំនួន១ថ្ងៃ។ ត្រូវការពេល២ថ្ងៃទៀតសំរាប់រៀបចំផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ។ |
| សម្ភារៈ | - ផែនទីប្រើប្រាស់ដីសាមញ្ញ (សំរាប់ធ្វើជាគោល)<br>- ផែនទីប្រើប្រាស់ដីលំអិត (សំរាប់ជាឯកសារយោង)<br>- ផែនទីតំបន់រសើបរាជធានី ខេត្ត សំរាប់ជាឯកសារយោង និងធ្វើបច្ចុប្បន្នភាព<br>- ផ្ទាំងប្លាស្ទិកថ្លា សំរាប់ផ្ទាប់គូសគំនូសព្រាង<br>- ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ |
| លទ្ធផល | - សេចក្តីព្រាងផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ដែលបង្ហាញអំពីទីតាំងនៃបញ្ហា<br>- គំនិតផ្តើមដំបូងនៃការកំណត់ផ្ទៃដីដែលធ្វើអាជីវកម្មផ្សេងៗទៀត។ |

លទ្ធផលនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ជំហាននៃផែនការ អភិវឌ្ឍន៍ឃុំ សង្កាត់

ការងារ C : កសាងផែនទីសំរេច

ធ្វើបច្ចុប្បន្នភាព ផែនទី ប.ម.ដ (គំនូសព្រាង)

ផែនទីគំរោង (មាត្រដ្ឋាន)

ផែនទីប្រើប្រាស់ដី ឃុំ សង្កាត់ អនាគត

ផ.អ.ឃ ជំហាន ៣ : សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

| សកម្មភាព ៣.១ : គណៈកម្មការផែនការនិងថវិកា ពិនិត្យសារឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដី |
|---|
| **បរិយាយ សកម្មភាព ៣.១** |
| ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់ |
| គណៈកម្មាធិការកសាងផែនការ និងថវិកាពិនិត្យសារឡើងវិញនូវអនុសាសន៍លើផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលទទួលបានពីសំណាក់អ្នកភូមិ ហើយធ្វើបច្ចុប្បន្នភាពផែនទីទាំងនេះនៅត្រង់ណាដែលមានការចាំបាច់។ គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការគូសព្រាងការកែប្រែនៅលើផ្ទាំងប្លាស្ទិចដែលផ្ទាប់គ្របពីលើផែនទីប្រើប្រាស់ដី។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ និងក្រុមសម្របសម្រួលថ្នាក់ ក្រុង ស្រុក ខណ្ឌ នឹងធ្វើការសម្របសម្រួលដំណើរការនេះ។ ផែនទីប្រើប្រាស់ដី ត្រូវបានធ្វើបច្ចុប្បន្នភាពកែប្រែដោយក្រុម GIS (ក្នុងករណីដែលមានការកែប្រែ)។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់បច្ចុប្បន្នដែលបានធ្វើការពិនិត្យសារឡើងវិញនិងធ្វើការពិភាក្សាដោយគណៈកម្មាធិការកសាងផែនការ និងថវិកា។ |
| លទ្ធផល ២ | គណៈកម្មាធិការកសាងផែនការ និងថវិកា លើកឡើងនូវសំណើកែសម្រួលលើផែនទីប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់ដោយគូសជាគំនូសព្រាងនៅលើផ្ទាំងប្លាស្ទិកថ្លាផ្ទាប់គ្របពីលើផែនទីប្រើប្រាស់ដីសាមញ្ញ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ៣.១.១ | សូមឱ្យមានអ្នកបណ្តុះបណ្តាលមកពីខាងក្រៅផ្តល់នូវការបណ្តុះបណ្តាល "គ្រូបង្គោល" ដល់ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ក្រុង ស្រុក និង អ្នកសម្របសម្រួលថ្នាក់រាជធានី ខេត្ត ស្រុក ដោយមានរួមបញ្ចូលនូវតម្រូវការក្នុងកិច្ចការពារសង្គម-បរិស្ថានសំរាប់បណ្តុះបណ្តាលបន្តដល់ទៅគណៈកម្មាធិការកសាងផែនការ និងថវិកា។ |
| សកម្មភាព ៣.១.២ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ពិនិត្យសារឡើងវិញនូវផែនទីប្រើប្រាស់ដីជាមួយនឹងគណៈកម្មាធិការកសាងផែនការ និងថវិកា ហើយធ្វើការពន្យល់អំពីលេខកូដនៃទិន្នន័យ និងព័ត៌មានផ្សេងៗទៀត ព្រមទាំងអំពីគោលបំណង និងវិធីសាស្ត្រនៃការងារពិនិត្យសារឡើងវិញនេះ។ |
| សកម្មភាព ៣.១.៣ | គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការពិនិត្យសារឡើងវិញ និងធ្វើការពិភាក្សាលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន ដោយផ្អែកលើការផ្តល់អនុសាសន៍ពីអ្នកភូមិ។ |
| សកម្មភាព ៣.១.៤ | គណៈកម្មាធិការកសាងផែនការនិងថវិកា គូសជាគំនូសព្រាងលើសំណើក្នុងការកែប្រែនៅលើផ្ទាំងប្លាស្ទិកថ្លា ដែលគ្របផ្ទាប់ពីលើផែនទីប្រើប្រាស់ដី។ |

**ប្រតិបត្តិករ និង ការទទួលខុសត្រូវ**

| | |
|---|---|
| អ្នកបណ្តុះបណ្តាលមកពីខាងក្រៅ | ផ្តល់នូវការបណ្តុះបណ្តាល "គ្រូបង្គោល" ដល់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ អំពីការសហការក្នុងកិច្ចការពារសង្គម បរិស្ថាន ក្នុងការកំណត់យុទ្ធសាស្ត្រ។ |
| ក្រុមសម្របសម្រួលរៀបចំ | ជួយដល់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នក |

| | |
|---|---|
| ផែនការប្រើប្រាស់ដី ថ្នាក់រាជធានី ខេត្ត /អ្នកសម្របសម្រួលថ្នាក់រាជធានី ខេត្ត | សម្របសម្រួលថ្នាក់ ក្រុង ស្រុក ខណ្ឌក្នុងការសង្ខេបជូនត្រួស១នូវកិច្ចការពារសង្គម-បរិស្ថាន ដល់ទៅគណៈកម្មាធិការកសាងផែនការ និងថវិកា។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ថ្នាក់ក្រុង ស្រុក ខណ្ឌ/ អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ | ធ្វើការសម្របសម្រួលដំណើរការពិនិត្យផែនទីសារឡើងវិញ : ពន្យល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកា អំពីដំណើរការនៃការគូរផែនទីព្រមទាំងការប្រើប្រាស់លេខកូដ និង អំពីគោលបំណងនិងវិធីសាស្ត្រក្នុងការពិនិត្យសារឡើងវិញ។ ប្រគល់ទិន្នន័យនៃការធ្វើបច្ចុប្បន្នភាពផែនទីនេះទៅឱ្យក្រុម GIS ដើម្បី គូសចូលកុំព្យូទ័រ។ |
| ក្រុម GIS | ទទួលទិន្នន័យក្នុងការធ្វើបច្ចុប្បន្នភាព (គំនូសព្រាង) នៃផែនទីប្រើប្រាស់ដី រួចគូសបញ្ចូលទៅក្នុងកុំព្យូទ័រ (ប្រសិនបើចាំបាច់)។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ធ្វើការពិនិត្យសារឡើងវិញ និងលើកឡើងជាសំណើដើម្បីកែប្រែ (នៅកន្លែងណាដែលមានការចាំបាច់)។ |
| អ្នកភូមិ | ចូលរួមផ្តល់យោបល់ និងលើកឡើងនូវសំណើកែសម្រួលផែនទីប្រើប្រាស់ដី។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *ការពិនិត្យសារឡើងវិញផែនទីប្រើប្រាស់ដីឃុំ សង្កាត់: កន្លះថ្ងៃ (១/២ថ្ងៃ)* |
| តម្រូវការសម្ភារៈ | ផ្ទាំងប្លាស្ទិកថ្លាសំរាប់ផ្ទាប់គូសគំនូសព្រាង ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | ផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវការនូវការបណ្តុះបណ្តាល "គ្រូបង្គោល" ដែលស្នើឱ្យមានសំរាប់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អំពីកិច្ចការពារសង្គម-បរិស្ថាន ដើម្បីការបង្ហាញត្រួស១ដល់គណៈកម្មាធិការកសាងផែនការ និងថវិកា។ |
| តម្រូវការផ្សេង១ទៀត | សូមឱ្យមាន "វគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារសង្គម បរិស្ថាន" ដើម្បីធានាដល់គណៈកម្មការផែនការនិងថវិកា និងអ្នកភូមិយល់បាននូវតំបន់ដែលងាយរងគ្រោះផ្នែកខាងសង្គម និងបរិស្ថាន ហើយត្រូវមានការយកចិត្តទុកដាក់ដល់កិច្ចការពារសង្គម បរិស្ថាន នៅពេលដែលធ្វើផែនការយុទ្ធសាស្ត្រឃុំ សង្កាត់ហើយនឹងអាចធ្វើការចាត់អាទិភាពតាមដំណាក់កាលនៃការធ្វើផែនការ។ |

| |
|---|
| **សកម្មភាព ៣.២ : គណៈកម្មាធិការកសាងផែនការ និងថវិការៀបចំផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ** |
| **បរិយាយ សកម្មភាព ៣.២** |
| ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការពិនិត្យសារឡើងវិញ និងផ្តល់ជាអនុសាសន៍លើផែនទីបញ្ហាមូលហេតុ និងដំណោះស្រាយដែលបានទទួលមកពីអ្នកភូមិ ហើយធ្វើបច្ចុប្បន្នភាពផែនទីនេះនៅពេលណាដែលមានតម្រូវការ ។ គណៈកម្មាធិការកសាងផែនការ និងថវិកា គូសជាគំនូសព្រាងកែសម្រួលនៅលើផ្ទាំងប្លាស្ទិកថ្លាដែលផ្ទាប់គ្របពីលើផែនទីប្រើប្រាស់ដី។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/ អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលក្នុងដំណើរការនេះ ។ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងកុំព្យូទ័រដោយក្រុម GIS (ក្នុងករណីមានការកែប្រែ) ។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | តារាងសង្ខេបអំពីបញ្ហា មូលហេតុ និងដំណោះស្រាយ ក្នុងឃុំ ដែលរួមមានបញ្ហាដីធ្លីសំខាន់ៗផងដែរ |
| លទ្ធផល ២ | ធ្វើបច្ចុប្បន្នភាពផែនទីបញ្ហា ក្នុងទម្រង់ជាផែនទីគំនូសព្រាងនៅលើផ្ទាំងប្លាស្ទិចថ្លាផ្ទាប់គ្របនៅពីលើផែនទីប្រើប្រាស់ដីសាមញ្ញដែលបានកំណត់ទីតាំងនៃបញ្ហាចំបងៗ និងលើកឡើងជាសំណើសំរាប់ដោះស្រាយ ដោយភ្ជាប់ជាមួយនឹងតារាងសង្ខេប ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ៣.២.១ | គណៈកម្មាធិការកសាងផែនការនិងថវិកា ធ្វើការពិនិត្យសារឡើងវិញ និងពិភាក្សាលើផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ដោយផ្អែកលើអនុសាសន៍ពីអ្នកភូមិ ។ |
| សកម្មភាព ៣.២.២ | គណៈកម្មាធិការកសាងផែនការ និងថវិកាគូសគំនូសព្រាងលើផ្ទាំងប្លាស្ទិកថ្លាដែលគ្របផ្ទាប់ពីលើផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ។ |

**ប្រតិបត្តិករ និង ការទទួលខុសត្រូវ**

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/ អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ | ធ្វើការសម្របសម្រួលដំណើរការពិនិត្យផែនទីសារឡើងវិញ : ពន្យល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកា នូវដំណើរការនៃការគូផែនទីព្រមទាំងអំពីការប្រើប្រាស់លេខកូដអំពីគោលបំណង និងវិធីសាស្ត្រក្នុងការពិនិត្យសារឡើងវិញ។ ប្រគល់ទិន្នន័យនៃការធ្វើបច្ចុប្បន្នភាពផែនទីនេះទៅឱ្យក្រុម GIS ដើម្បីគូសចូលកុំព្យូទ័រ ។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ធ្វើការពិនិត្យសារឡើងវិញ លើកឡើងនូវអនុសាសន៍ និងការកែសម្រួល (នៅកន្លែងណាដែល មានការចាំបាច់) ។ |

**តម្រូវការចនចាន**

| | |
|---|---|
| តម្រូវការពេលវេលា | *ការធ្វើបច្ចុប្បន្នភាព ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ : កន្លះ(១/២) ថ្ងៃ* |
| តម្រូវការសម្ភារៈ | - កំណត់ត្រាពីអ្នកភូមិ<br>- ក្រដាសផ្ទាំងធំសំរាប់ការវិភាគទិន្នាការ<br>- ផ្ទាំងប្លាស្ទិកថ្លាសំរាប់ការគូសគំនូសព្រាង<br>- ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | ផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ |
| តម្រូវបណ្តុះបណ្តាល | តម្រូវឱ្យក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ /អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌសម្របសម្រួលការគូសផែនទីគំនូសព្រាង។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## ការងារ D : ការគាំទ្រដល់ការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ (កទឃ ជំហាន១)

| | |
|---|---|
| គោលបំណង | ដើម្បីជ្រើសរើស និងតាក់តែងសំណើគំរោង ដែលក្នុងនោះរួមមានតម្រូវការក្នុងការធ្វើផែនការប្រើប្រាស់ដី និងដើម្បីកំណត់ និងជ្រើសរើសអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។ |
| សកម្មភាព | **សកម្មភាព ១.១ :** គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការពិនិត្យផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សារឡើងវិញ។ |
| | **សកម្មភាព ១.២ :** វិភាគ និងគូរផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ។ |
| | **សកម្មភាព ១.៣ :** វិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ។ |
| | **សកម្មភាព ១.៤ :** វិភាគនិងគូរផែនទីជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត។ |
| | **សកម្មភាព ១.៥ :** ជ្រើសរើសគំរោងសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់។ |
| | **សកម្មភាព ១.៦ :** ធ្វើបច្ចុប្បន្នភាពផែនទីគំរោង។ |
| អ្នកចូលរួម | គណៈកម្មាធិការកសាងផែនការ និងថវិកា និងក្រុមប្រឹក្សាឃុំ គឺជាប្រតិបត្តិករសំខាន់ក្នុងការងារនេះ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលដំណើរការនេះនិងគាំទ្រផ្នែកបច្ចេកទេស។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ជាអ្នកផលិតផែនទីដែលបានធ្វើបច្ចុប្បន្នភាព។ |
| ទីកន្លែង | ការងារនេះធ្វើនៅថ្នាក់ឃុំ ជាមួយនឹងការផលិតផែនទីធ្វើនៅថ្នាក់រាជធានី ខេត្ត។ |
| រយៈពេល | ត្រៀមរៀបចំការងារ : ០១ថ្ងៃ<br>ដំណើរការតាក់តែងគំរោង : ០១ថ្ងៃ<br>ផលិត និងធ្វើបច្ចុប្បន្នភាពផែនទី : ០២ថ្ងៃ<br>ផ្ទៀងវាយតម្លៃភាពសមស្របនៃដី : ០១ថ្ងៃ (ក្នុងករណីមានតម្រូវការ) |
| សម្ភារៈ | ផែនទីគំរោងកន្លងមក (ដែលមានកន្លងមក) ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ផែនទីគោល ទិន្នន័យឃុំ សង្កាត់ និងទម្រង់ (ស្នើថវិកា កវឃ)ពីគំរោង និងសៀវភៅណែនាំអនុវត្តន៍ |
| លទ្ធផល | សេចក្តីព្រាងក្របខណ្ឌការងារនៃផែនការប្រើប្រាស់ដីពេលអនាគត។<br>សេចក្តីព្រាងផែនទីគំរោងដែលបានធ្វើបច្ចុប្បន្នភាព។ |

## លទ្ធផលនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

**ការងារ D: ការគាំទ្រដល់ការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់**

- ធ្វើបច្ចុប្បន្នភាពផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ (គំនូសព្រាង និងមាត្រដ្ឋាន)
- ផែនទី ប.ម.ដ (គំនូសព្រាង និងមាត្រដ្ឋាន)
- របាយការណ៍អំពីភាពសមស្របនៃដី

**ករណី ជំហាន ១ ការពិនិត្យសារឡើងវិញនូវបញ្ហា ឬតម្រូវការជាមួយនឹងប្រជាពលរដ្ឋ**

- បញ្ជីគោលបំណងនៃការអភិវឌ្ឍន៍ធ្វើបច្ចុប្បន្នភាពរួច
- ធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដីឃុំ សង្កាត់ពេលអនាគត (ព្រាង និង មាត្រដ្ឋាន)
- បញ្ជីនៃគំរោងដីធ្លីសំរាប់សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក

| សកម្មភាព ១.១ : គណៈកម្មាធិការកសាងផែនការ និងថវិកាពិនិត្យផែនទីប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់សារឡើងវិញ |
|---|
| **បរិយាយ សកម្មភាព ១.១ ( ករ/ឃ)** |
| ទីកន្លែង : នៅថ្នាក់ឃុំ សង្កាត់ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការពិនិត្យសារឡើងវិញនូវផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលទទួលបានពីក្រុម GIS ដើម្បីពិនិត្យមើលទៅលើទិន្នន័យ និងព័ត៌មានអំពីការប្រើប្រាស់ដី គម្របដី និងព្រំប្រទល់ តើមានភាពត្រឹមត្រូវដែរឬទេ? ដោយផ្អែកលើចំណេះដឹងមូលដ្ឋានរបស់គេ។ នៅកន្លែងណាដែលព័ត៌មានមានភាពមិនត្រឹមត្រូវ ឬព័ត៌មានមិនស្របតាមភាពជាក់ស្តែង គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវធ្វើការគូរជាគំនូសព្រាងនៅលើផ្ទាំងប្លាស្ទិកថ្លាដែលគ្របផ្ទាប់ពីលើផែនទីប្រើប្រាស់ដីសាមញ្ញ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលដំណើរការនេះ។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលបានពិនិត្យសារឡើងវិញនិងបានពិភាក្សាដោយគណៈកម្មាធិការកសាងផែនការ និងថវិកា។ |
| លទ្ធផល ២ | គណៈកម្មាធិការកសាងផែនការ និងថវិកា លើកជាសំណើក្នុងការកែសម្រួលផែនទីប្រើប្រាស់ដីដោយគូសជាគំនូសព្រាងនៅលើផ្ទាំងប្លាស្ទិកថ្លាដែលផ្ទាប់គ្របពីលើផែនទីប្រើប្រាស់ដីធ្លីសាមញ្ញ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ១.១.១ | សូមឱ្យមាន : គ្រូបណ្តុះបណ្តាលមកពីខាងក្រៅដើម្បី "បណ្តុះបណ្តាលគ្រូបង្គោល" ដល់អ្នកសម្របសម្រួលថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ អំពីតម្រូវការនៃកិច្ចការពារសង្គម និងបរិស្ថាន (សំរាប់បន្តដល់គណៈកម្មាធិការកសាងផែនការ និងថវិកា)។ |
| សកម្មភាព ១.១.២ | គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការពិនិត្យ និងគូសព្រាងផែនទីប្រើប្រាស់ដីសារឡើងវិញ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/ក្រុមសម្របសម្រួលស្រុកសង្ខេបជូនត្រួសៗ អំពីតម្រូវការក្នុងកិច្ចការពារសង្គម បរិស្ថានដល់គណៈកម្មាធិការកសាងផែនការ និងថវិកាដោយមានការជួយគាំទ្រពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត។ |
| សកម្មភាព ១.១.៣ | គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការពិនិត្យសារឡើងវិញ និងពិភាក្សាលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន។ |
| សកម្មភាព ១.១.៤ | គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការគូសព្រាងជាសំណើក្នុងការកែប្រែនៅលើប្លាស្ទិចថ្លាដែលគ្របផ្ទាប់ពីលើផែនទីប្រើប្រាស់ដីសាមញ្ញ។ |

## ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| គ្រូបណ្តុះបណ្តាល មកពីខាងក្រៅ | ផ្តល់នូវវគ្គ "បណ្តុះបណ្តាលគ្រូបង្គោល" ដល់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ អ្នកសម្របសម្រួលថ្នាក់រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌអំពីតម្រូវការក្នុងកិច្ចការពារសង្គម បរិស្ថាន។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ក្រុមសម្របសម្រួលរាជធានី ខេត្ត | ជួយដល់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/ក្រុមសម្របសម្រួលក្រុង ស្រុក ខណ្ឌ ក្នុងការសង្ខេបជូនត្រួសៗអំពីតម្រូវការក្នុងកិច្ចការពារសង្គម បរិស្ថាន ជូនគណៈកម្មាធិការកសាងផែនការ និងថវិកា។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/ ក្រុមសម្របសម្រួលក្រុង ស្រុក ខណ្ឌ | ធ្វើការសម្របសម្រួលដំណើរការនៃការពិនិត្យផែនទីសារឡើងវិញ : ពន្យល់នូវដំណើរការនៃការគូរផែនទី ដូចជាការប្រើប្រាស់លេខកូដ គោលបំណង និងវិធីសាស្ត្រក្នុងការពិនិត្យផែនទីសារឡើងវិញ។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ធ្វើការពិនិត្យសារឡើងវិញ លើកឡើងនូវសំណើ និងការកែប្រែ (នៅកន្លែងណាដែលចាំ បាច់)។ |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | - *ធ្វើការបណ្តុះបណ្តាលអំពីការការពារសង្គម បរិស្ថាន ដល់ក្រុម P-LUP, D-LUP និង DFT : កន្លះថ្ងៃ (១/២)*<br>- *ពិនិត្យសារឡើងវិញនូវផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងការបង្ហាញត្រួសៗអំពីការការពារ សង្គម-បរិស្ថាន : កន្លះថ្ងៃ (១/២)* |
| តម្រូវការសម្ភារៈ | ប្លាស្ទិកថ្លាសំរាប់គ្របផ្ទាប់ពីលើផែនទីដើម្បីធ្វើការគូសគំនូសព្រាងប៊ិចហ្វឺត។ |
| តម្រូវការទិន្នន័យ | ផែនទីប្រើប្រាស់ដីលំអិត និង សាមញ្ញ។ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវការនូវវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការពិនិត្យផែនទីសារឡើងវិញ និងកិច្ចការពារសង្គម បរិស្ថាន។ |
| តម្រូវការផ្សេងៗទៀត | សូមឱ្យមាន វគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារសង្គម បរិស្ថាន ដើម្បីធានាថា គណៈកម្មាធិការកសាងផែនការ និងថវិកា និងអ្នកភូមិយល់បាននូវតំបន់ដែលងាយរងគ្រោះផ្នែកសង្គម និងបរិស្ថាន ហើយត្រូវយកចិត្តទុកដាក់ដល់កិច្ចការពារសង្គម បរិស្ថាន នៅពេលធ្វើផែនការយុទ្ធសាស្ត្រ ឃុំ សង្កាត់ ហើយត្រូវធ្វើការចាត់អាទិភាពតាមដំណាក់កាលនៃការធ្វើផែនការនោះ។ |

## សកម្មភាព ១.២ : ការវិភាគ និងការគូសផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ

| **បរិយាយ សកម្មភាព សង្កាត់ ១.២** |
|---|
| ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការ "វិភាគនិន្នាការ" ដែលលទ្ធផលនេះគឺជាសេចក្ដីសង្ខេបនៃបញ្ហាមូលហេតុ និង ដំណោះស្រាយសំខាន់ៗនៅក្នុងឃុំ សង្កាត់ ដែលក្នុងនោះរួមមានបញ្ហាដីធ្លីផងដែរ ។ នៅក្នុងការងារនេះគណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវផលិតនូវផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ដែលជាផែនទីគំនូសព្រាងបង្ហាញឱ្យឃើញទីតាំងចម្បងៗនៃបញ្ហា មូលហេតុ និងដំណោះស្រាយ ។ ផែនទីនេះគឺជាឧបករណ៍ មួយសំរាប់ចាត់អាទិភាពគំរោង។ អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានការគាំទ្រពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលដំណើរការនេះ ។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | តារាងសង្ខេបអំពីបញ្ហា មូលហេតុ និងដំណោះស្រាយនៅក្នុងឃុំ ដែលក្នុងនោះរួមមានបញ្ហាដីសំខាន់ៗ ផងដែរ ។ |
| លទ្ធផល ២ | ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយជាទម្រង់ជាគំនូសព្រាងនៅលើប្លាស្ទិកថ្លាដែលគ្របផ្ទាប់ពីលើផែនទីប្រើប្រាស់ដីសាមញ្ញ ដោយកំណត់នូវទីកន្លែងនៃបញ្ហា និងលើកឡើងនូវសំណើដំណោះស្រាយបញ្ហាចំបងៗទាំងនោះ ដោយភ្ជាប់មកជាមួយនូវតារាងសង្ខេប ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ១.២.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលថ្នាក់ស្រុក ធ្វើការពន្យល់អំពីគោលការណ៍ជាមូលដ្ឋានសំរាប់ការគូរផែនទី និងណែនាំក្នុងវិធីសាស្ត្រជាគោលការណ៍ក្នុងការធ្វើតារាងសង្ខេប និងការគូរផែនទីបញ្ហា ។ |
| សកម្មភាព ១.២.២ | គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការវិភាគនិន្នាការដើម្បីកំណត់បញ្ហាសំខាន់ៗ មូលហេតុ និងសំណើនៃដំណោះស្រាយក្នុងឃុំរបស់ខ្លួន ។ |
| សកម្មភាព ១.២.៣ | គណៈកម្មាធិការកសាងផែនការ និងថវិកា គូសព្រាងផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយនៅលើផែនទីប្រើប្រាស់ដីសាមញ្ញ ដោយបង្ហាញនូវបញ្ហាចម្បងៗ និងសំណើនៃដំណោះស្រាយ ។ |

**ប្រតិបត្តិករ និង ការទទួលខុសត្រូវ**

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ ក្រុង ស្រុក ខណ្ឌ / អ្នកសម្របសម្រួលថ្នាក់ ក្រុង ស្រុក ខណ្ឌ | ពន្យល់នូវវិធីសាស្ត្រនៃការវិភាគនិន្នាការ ព្រមទាំងធ្វើការសម្របសម្រួលការងារនេះជួយដល់គណៈកម្មាធិការកសាងផែនការ និងថវិកា ដើម្បីបំពេញឱ្យបានចប់សព្វគ្រប់នូវតារាងសង្ខេប និងការគូសគំនូសព្រាងផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ ។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ធ្វើការវិភាគនិន្នាការ និងគូសគំនូសព្រាងផែនទី បញ្ហា មូលហេតុ និង ដំណោះស្រាយ ។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *-ការវិភាគនិន្នាការៈ មួយថ្ងៃ (១)*<br>*-ការគូសព្រាងផែនទី បញ្ហា មូលហេតុ និងដំណោះស្រាយ : កន្លះថ្ងៃ (១/២)* |
| តម្រូវការសម្ភារៈ | ក្រដាសផ្ទាំងធំ សំរាប់ការវិភាគនិន្នាការ<br>ផ្ទាំងប្លាស្ទិកថ្លា សំរាប់គូសគំនូសព្រាង<br>ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | ផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ ក្រុង ស្រុក ខណ្ឌ/អ្នកសម្របសម្រួល ថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលការវិភាគនិន្នាការនិងការគូសព្រាងផែនទី។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## សកម្មភាព ១.៣ : ការធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ

| **បរិយាយ សកម្មភាព** ***សង្កាត់ ១.៣*** |
|---|
| ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់ |
| ធ្វើការវិភាគ*ភាពសមស្របនៃដីជាលក្ខណៈទូទៅ* ដើម្បីជាមូលដ្ឋានសំរាប់កំណត់យុទ្ធសាស្ត្ររបស់ឃុំ សង្កាត់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងសំរាប់កំណត់ជំរើសនានាក្នុងការប្រើប្រាស់ដីពេលអនាគត។ ភាពសមស្របនៃដីជាលក្ខណៈទូទៅនេះ គឺជាការវាយតម្លៃរហ័សដោយវិភាគទៅលើ ១) គំរិតដីជាតិដី ២) គម្របរុក្ខជាតិ និងដំណាំ និង ៣) ប្រភពធនធានទឹកក្នុងឃុំ សង្កាត់។ ការវាយតម្លៃគឺផ្អែកតែទៅលើមូលដ្ឋាននៃចំណេះដឹងមូលដ្ឋានដែលមានស្រាប់ពីសំណាក់គណៈកម្មាធិការកសាងផែនការ និងថវិកា និងអ្នកភូមិ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ថ្នាក់ក្រុង ស្រុក ខណ្ឌ/ក្រុមសម្របសម្រួលក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលសកម្មភាពនេះ។ |

**ទំនាក់ទំនងទៅនឹងការវាយតម្លៃភាពសមស្របនៃដី**

*ការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅនេះ គឺជាចំណែកមួយនៃដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ក្នុងអំឡុងពេលរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ ការវិភាគភាពសមស្របនៃដីនេះ មិនមែនជាការបំពេញបន្ថែមសំរាប់ការវាយតម្លៃភាពសមស្របនៃដីលំអិតនៃកម្មវិធីដទៃទៀតនោះទេ។ គោលបំណងនៃការវិភាគនេះ គឺគ្រាន់តែជាការចងក្រងឯកសារអំពីចំណេះដឹងមូលដ្ឋានដែលមានស្រាប់ទៅលើចំណោតសំខាន់ៗក្នុងការប្រើប្រាស់ធនធានធម្មជាតិដែលមាននៅក្នុងឃុំ សង្កាត់ (ដី ទឹក គម្របរុក្ខជាតិ និងដំណាំ) ដោយប្រជាពលរដ្ឋដែលបានធ្វើកសិកម្ម និងបានប្រើប្រាស់ធនធានទាំងនេះជាប្រចាំថ្ងៃ។ ការវិភាគភាពសមស្របនៃដីជាទូទៅនេះអាចផ្តល់នូវព័ត៌មានមូលដ្ឋាន សំខាន់ៗ សំរាប់ដំណើរការវិភាគភាពសមស្របនៃដីបន្តបន្ទាប់នៅពេលក្រោយទៀត។*

*ឧទាហរណ៍ : ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់មានបំណងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចនៅមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់អាចយកលទ្ធផលវិភាគភាពសមស្របនៃដីនេះ ធ្វើជាសំណើសុំការសំរេចពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដី រាជធានី ខេត្ត ហើយអាចធ្វើការវិភាគភាពសមស្របនៃដីកាន់តែលំអិតថែមទៀត។*

*ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់មានបំណងស្នើឡើងដើម្បីបង្កើតប្រព័ន្ធស្រោចស្រពខ្នាតធំនោះ ការវិភាគភាពសមស្របនៃដីលំអិតគួរធ្វើឡើងដោយមន្ត្រីជំនាញបច្ចេកទេសនៃមន្ទីរធនធានទឹក និងឧតុនិយម។*

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | របាយការណ៍អំពីការវិភាគភាពសមស្របនៃដី ជាមួយនឹងផែនទីប្រើប្រាស់ដីពេលអនាគតដែលគូសព្រាងដោយគណៈកម្មាធិការកសាងផែនការ និងថវិកា សំរាប់យកជាមូលដ្ឋានក្នុងការបង្ហាញ និងពិពណ៌នា :<br>១) តំបន់ដែលជាដីមានជីជាតិ<br>២) ប្រភពធនធានទឹកដែលអាចមាន<br>៣) តំបន់ដែលមានគម្របរុក្ខជាតិ និងគម្របដំណាំផ្សេងៗគ្នា<br>៤) គំរិតជំរាល និងរយៈកំពស់ និង<br>៥) ទិន្នន័យអំពីទីផ្សារ និងតម្លៃកសិផល។ |

## សកម្មភាព

| | |
|---|---|
| សកម្មភាព ១.៣.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ពន្យល់ជូនគណៈកម្មាធិការកសាងផែនការ និងថវិកាអំពីគោលបំណង និងវិធីសាស្ត្រ សំរាប់ធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ ។ |
| សកម្មភាព ១.៣.២ | គណៈកម្មាធិការកសាងផែនការ និងថវិកា ដោយមានជំនួយពីអ្នកភូមិ ធ្វើការចងក្រងឯកសារអំពីតំបន់ដែលជាដីមានជីជាតិ ប្រភពធនធានទឹក តំបន់ដែលមានតម្រូវការក្កជាតិ និងតម្រូវដំណាំផ្សេងៗគ្នានៅទូទាំងឃុំ សង្កាត់ (ហើយអាចមានជំនួយបន្ថែមពីផែនទីផ្សេងៗ ដូចជា "ផែនទីប្រភេទដីវយៈកំពស់ /ករិតជំរាល ជលសាស្ត្រ ការប្រើប្រាស់ដី ...") ។ |
| សកម្មភាព ១.៣.៣ | គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសង្កាត់ សរសេររបាយការណ៍សង្ខេបអំពីការវិភាគភាពសមស្របនៃដីជាមួយ នឹងរបកគំហើញថ្មីៗ ព្រមជាមួយនឹងរូបភាពផែនទីគំនូសព្រាងដែលបង្ហាញឱ្យឃើញអំពីតំបន់ដីមានជីជាតិ ប្រភពធនធានទឹក តំបន់ដែលមានតម្រូវក្កជាតិ និងតម្រូវដំណាំផ្សេងៗគ្នានៅទូទាំង ឃុំ សង្កាត់ ។ |

## ប្រតិបត្តិករ និងការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ | ពន្យល់អំពីវិធីសាស្ត្រក្នុងការធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ (ឧបសម្ព័ន្ធ៧) ។<br>ធ្វើការសម្របសម្រួលដំណើរការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ ។ |
| គ្រូឧទ្ទេសមកពីខាងក្រៅ | ផ្តល់នូវការបណ្តុះបណ្តាល "គ្រូបង្គោល" ដល់ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត (និងក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ) សំដៅដល់ការធ្វើការវិភាគភាពសមស្របនៃដី ដោយមានរំលេចនូវវិធីសាស្ត្រដែលមានភាពសមស្របបំផុត ។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | វិភាគ និងចងក្រងរបាយការណ៍ស្តីពីភាពសមស្របនៃដីជាលក្ខណៈទូទៅ ។ |
| អ្នកភូមិ | ចូលរួមចំណែកក្នុងការផ្តល់នូវចំណេះដឹងមូលដ្ឋានជូនដល់គណៈកម្មាធិការកសាងផែនការ និងថវិកា ។ |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | ប៉ាន់ស្មានរយៈពេលសំរាប់ធ្វើការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ: កន្លះថ្ងៃ (១/២ថ្ងៃ) ។ |
| តម្រូវការសម្ភារៈ | ក្រដាសផ្ទាំងធំ សៀវភៅសរសេរ ប៊ិចហ្វឺត និងប៊ិចសរសេរធម្មតា |
| តម្រូវការទិន្នន័យ | ចំណេះដឹងមូលដ្ឋានរបស់អ្នកភូមិ និងកសិករទូទាំងឃុំ សង្កាត់ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ពន្យល់ និងធ្វើការសម្របសម្រួលដំណើរការវិភាគភាពសមស្របនៃដី និងពន្យល់អំពីតំបន់ដែលតម្រូវឱ្យមានកិច្ចការពារសង្គម-បរិស្ថាន ដោយផ្អែកលើផែនទី "តំបន់រសើប" ។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## សកម្មភាព ១.៤ : ការរៀបចំផែនការបឋមប្រើប្រាស់ដីពេលអនាគត

| **បរិយាយ សកម្មភាព ១.៤** |
|---|
| ទីកន្លែង: ថ្នាក់ឃុំ សង្កាត់ |
| ផ្អែកតាមលទ្ធផលនៃសកម្មភាព ១.១ដល់១.៤ គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវធ្វើការវិភាគអំពីតំបន់ដែលមានដី សមស្របក្នុងការប្រើប្រាស់សំរាប់រយៈពេល១០ទៅ១៥ឆ្នាំទៅមុខទៀត ដែលគួរតែធ្វើការផ្លាស់ប្តូរ ( ការវិភាគនិន្នាការ) ។ គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវធ្វើការរៀបចំ "ផែនការក្នុងការប្រើប្រាស់ដីបឋម" ដែលត្រូវធ្វើបទបង្ហាញជូនតំណាងឃុំ សង្កាត់សំរាប់ធ្វើការ "អនុម័តជាបណ្តោះអាសន្ន" និងបញ្ចូលទៅក្នុងសេចក្តីព្រាងនៃផែនការប្រើប្រាស់ដី ។ សកម្មភាពការងារនេះត្រូវមានការគាំទ្រពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុកខណ្ឌ ។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | បញ្ជីជំរើសនៃសក្តានុពលក្នុងការប្រើប្រាស់ដីពេលអនាគត ( ពីជំហាន ១.៤) ។ |
| លទ្ធផល ២ | ផ្តល់ចម្លើយដល់សំណួរមួយថា : តើនៅក្នុងឃុំរបស់អ្នកមានដីសមស្របប្រកបដោយសក្តានុពលសំរាប់អនុវត្តការប្រើប្រាស់ដីពេលអនាគតជាជំរើសផ្សេងៗដែរឬទេ ?<br>ប្រសិនបើជាចម្លើយវិជ្ជមាន គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវបង្កើតផែនការបឋមសំរាប់ការប្រើប្រាស់ដីពេលអនាគត ។ |
| លទ្ធផល ៣ | <u>**បញ្ជីផ្ទៀងផ្ទាត់**</u> : ការកំណត់ជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត ត្រូវពិនិត្យលើធាតុមួយចំនួនដូចខាងក្រោម :<br>១) ពិពណ៌នាអំពីតំបន់ដែលត្រូវលើកសំណើរួមមាន : ទីតាំង ព្រំប្រទល់ប្រហាក់ប្រហែល ទំហំ និងចំណាត់ថ្នាក់ដីជាតិដី ។<br>២) ព័ត៌មានស្តីពីកម្មសិទ្ធិ និងស្ថានភាពក្នុងការកាន់កាប់នៃតំបន់ដែលលើកសំណើ ។<br>៣) ការកំណត់ជាបឋមនូវក្រុមគោលដៅដែលត្រូវបានទទួលអត្ថប្រយោជន៍ពីជំរើសនៃការប្រើបាស់ដីតាមរយៈការលើកសំណើនេះ ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ១.៤.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ពន្យល់ជូនគណៈកម្មាធិការកសាងផែនការ និងថវិកាអំពីទំហំការងារ គោលបំណង និងគោលការណ៍ជាមូលដ្ឋានសំរាប់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។ |
| សកម្មភាព ១.៤.២ | គណៈកម្មាធិការកសាងផែនការ និងថវិកាពាក់ព័ន្ធ ត្រូវធ្វើការពិនិត្យលើសេចក្តីព្រាងនៃផែនទីប្រើប្រាស់ដីពេលអនាគត( សកម្មភាព ០.៦) និងបន្ថែមជំរើសថ្មីៗ ដោយផ្អែកលើការវិភាគភាពសមស្របនៃដី ។ |
| សកម្មភាព ១.៤.៣ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ប្រគល់ទិន្នន័យ និង ព័ត៌មានដល់ក្រុម GIS ដើម្បីធ្វើការរៀបចំ និងគូសផែនទីប្រើប្រាស់ដីពេលអនាគតឱ្យបានរួចរាល់ ។ |

## ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ | សម្របសម្រួលដំណើការវិភាគភាពសមស្របនៃដី ដែលជាលទ្ធផលបានមកពីសកម្មភាព ១.៥។ ធ្វើការបណ្តុះបណ្តាលដល់ គណៈកម្មាធិការកសាងផែនការ និងថវិកាប្រមូលផ្តុំលើគោលបំណង គោលការណ៍ជាមូលដ្ឋាន និងតម្រូវការសំរាប់ការធ្វើកម្មវិធីសម្បទានដីសង្គមកិច្ច។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | រៀបចំតារាង និងផែនទីប្រើប្រាស់ដីសំរាប់ពេលអនាគត (ផែនទីគំនូសព្រាង ដែលគូសពីលើផែនទីប្រើប្រាស់ដីបច្ចុប្បន្ន) ដោយផ្អែកលើការវិភាគភាពសមស្របនៃដី។ |
| ក្រុម GIS | ទទួលទិន្នន័យនិងព័ត៌មានពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងធ្វើការរៀបចំផែនទីប្រើប្រាស់ដីពេលអនាគត និង ធ្វើបច្ចុប្បន្នភាពផែនទីប្រើប្រាស់ដីនៅកន្លែងណាដែលមានការចាំបាច់។ |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *រយៈពេលប៉ាន់ស្មានសំរាប់ធ្វើផែនការបឋមសំរាប់ជំរើសក្នុងការប្រើប្រាស់ដីថ្មី ពេលអនាគតៈ កន្លះថ្ងៃដល់មួយថ្ងៃ (១/២ថ្ងៃ ដល់ ១ថ្ងៃ)* |
| តម្រូវការសម្ភារៈ | ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | - ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់<br>- ផែនទី*បញ្ហា មូលហេតុ និងដំណោះស្រាយ* និងតារាង*បញ្ហា មូលហេតុ និងដំណោះស្រាយ*<br>- ការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ<br>- ទិន្នន័យឃុំ សង្កាត់<br>- តម្លៃទីផ្សារនៃកសិផល និងអនុផលព្រៃឈើ |
| តម្រូវការធនធានមនុស្ស និងការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ផ្តល់នូវការបង្ហាញត្រួសៗ និងជួយគណៈកម្មាធិការកសាងផែនការ និងថវិកាអំពីជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## សកម្មភាព ១.៥ ៖ ការជ្រើសរើសគំរោងដីធ្លីសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់

| បរិយាយ សកម្មភាព ១.៥ |
|---|
| ទីកន្លែង: ថ្នាក់ឃុំ សង្កាត់ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើបញ្ជីជ្រើសរើសគំរោងដីធ្លី ដែលនឹងលើកនៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ក្នុងឆ្នាំ។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | បញ្ជីនៃគំរោងដីធ្លីដែលនឹងលើកឡើងនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ១.៥.១ | គណៈកម្មាធិការកសាងផែនការ និងថវិកា ពិភាក្សាអំពីគំរោងណាខ្លះ ដែលនឹងត្រូវវាយជាគំរោងអាទិភាព។ ការពិភាក្សានេះគឺត្រូវបានផ្សាភ្ជាប់ទៅនឹងជំហាននៃការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ អំពីការសិក្សាវាយតម្លៃគំរោង និងការបែងចែកថវិកាសំរាប់គំរោង។ |

**ប្រតិបត្តិករ និង ការទទួលខុសត្រូវ**

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ / អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ | សម្របសម្រួលដំណើរការកសាងសេចក្តីព្រាងផែនទីគំរោង។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ពិភាក្សាក្នុងការចាត់អាទិភាពគំរោង និងធ្វើការគូសព្រាងផែនទីជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *រយៈពេលប៉ាន់ស្មានសំរាប់ការចាត់អាទិភាពគំរោង : កន្លះ(១៦២) ថ្ងៃ* |
| តម្រូវការសម្ភារៈ | ក្រដាសផ្ទាំងធំ សំរាប់កំណត់ត្រាក្នុងកិច្ចពិភាក្សា<br>ផ្ទាំងប្លាស្ទិកថ្លា សំរាប់គូសគំនូសព្រាង<br>ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | - បញ្ជីវាយជំរើសនានាក្នុងការប្រើប្រាស់ដីពេលអនាគត<br>- ផែនទីប្រើប្រាស់ដីសាមញ្ញប្រើជាផែនទីគោល<br>- ផែនទី បញ្ហា មូលហេតុ និងដំណោះស្រាយ និងតារាងសង្ខេបអំពីបញ្ហា មូលហេតុ និងដំណោះស្រាយ<br>- លទ្ធផលនៃការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ<br>- ផែនទីប្រើប្រាស់ដីពេលអនាគត។ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ផ្តល់នូវការសម្របសម្រួល និងផ្តល់នូវចំណេះដឹងអំពីការប្រើប្រាស់ដីរដ្ឋ។ |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## សកម្មភាព ១.៦ : ការធ្វើបច្ចុប្បន្នភាពផែនទីតំរោង

### បរិយាយ សកម្មភាព ១.៦

ទីកន្លែង : ថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការកសាងផែនការ និងថវិកា គូសព្រាងផែនទីតំរោងដោយគូសព្រាងនៅលើផ្ទាំងប្លាស្ទិកថ្លាផ្ទាប់គ្របពីលើផែនទីប្រើ ប្រាស់ដីសាមញ្ញ ដោយគូសបង្ហាញអំពីតំរោងអាទិភាពនានាក្នុងឃុំ សង្កាត់។ គំនូសព្រាង ផែនទីតំរោងត្រូវធ្វើការសំរេចជា ចុងក្រោយ បន្ទាប់ពីធ្វើសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ហើយត្រូវបានធ្វើបច្ចុប្បន្នភាពជារៀង រាល់ឆ្នាំ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ/អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួលសកម្មភាពនេះ។

### លទ្ធផល

| | |
|---|---|
| លទ្ធផល ១ | គំនូសព្រាងផែនទីតំរោងបង្ហាញអំពីតំរោងអាទិភាពនៅក្នុងឃុំ សង្កាត់ ដែលស្វែងរកការគាំទ្រថវិកា ហើយត្រូវបានដាក់បង្ហាញនៅសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ។ តំរោងអាទិភាពនេះ ត្រូវបានធ្វើការជ្រើសរើសនៅសកម្មភាព ១.៥។ |
| លទ្ធផល ២ | ផែនទីតំរោងដែលបានធ្វើបច្ចុប្បន្នភាពរួច (មាត្រដ្ឋាន)។ |

### សកម្មភាព

| | |
|---|---|
| សកម្មភាព ១.៦.១ | គណៈកម្មាធិការកសាងផែនការ និងថវិកា ពិភាក្សាថាតំរោងណាខ្លះដែលត្រូវបញ្ចូលទៅក្នុងបញ្ជីតំរោងអាទិភាព។ ការពិភាក្សានេះគឺត្រូវបានផ្សារភ្ជាប់ទៅនឹងជំហាននៃផែនការអភិវឌ្ឍន៍ឃុំសង្កាត់និងកម្មវិធីវិនិយោគឃុំសង្កាត់អំពីការសិក្សាវាយតម្លៃតំរោង និងការបែងចែកថវិកាសំរាប់តំរោង។ |
| សកម្មភាព ១.៦.២ | គណៈកម្មាធិការកសាងផែនការនិងថវិកា គូសព្រាងផែនទីតំរោងនៅលើផែនទីប្រើប្រាស់ដីសាមញ្ញ។ |
| សកម្មភាព ១.៦.៣ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ប្រគល់ដល់ក្រុម GIS នូវទិន្នន័យ/ព័ត៌មានអំពីផែនទីតំរោងឃុំ សង្កាត់។ |
| សកម្មភាព ១.៦.៤ | ក្រុម GIS ផលិតផែនទីតំរោងដែលបានធ្វើបច្ចុប្បន្នភាពរួច។ |

### ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ ក្រុង ស្រុក ខណ្ឌ / អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ | សម្របសម្រួលដំណើរការនៃការរៀបចំគំនូសព្រាងផែនទីតំរោង។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ពិភាក្សាក្នុងការចាត់អាទិភាពតំរោង និង គូសព្រាងផែនទីតំរោង។ |
| ក្រុម GIS | ផលិតផែនទីតំរោងដែលបានធ្វើបច្ចុប្បន្នភាពរួច។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *រយៈពេលប៉ាន់ស្មានសំរាប់ដំណើរការទាំងមូល ( ការឯកភាពលើអាទិភាពគំរោង និង ពង្រាងផែនទីគំរោង)៖ ពីរ (២) ថ្ងៃ* |
| តម្រូវការសម្ភារៈ | - ក្រដាសផ្ទាំងធំ សំរាប់កំណត់ត្រាក្នុងកិច្ចពិភាក្សា<br>- ផ្ទាំងប្លាស្ទិកថ្លា សំរាប់គូសគំនូសព្រាង<br>- ប៊ិចហ្វឺត |
| តម្រូវការទិន្នន័យ | - ផែនទីប្រើប្រាស់ដីសាមញ្ញប្រើជាផែនទីគោល ផែនទី *បញ្ហា មូលហេតុ និងដំណោះស្រាយ* និងតារាងសង្ខេបអំពី *បញ្ហា មូលហេតុ និង ដំណោះស្រាយ*<br>- លទ្ធផលនៃការវិភាគភាពសមស្របនៃដីជាលក្ខណៈទូទៅ<br>- ផែនទីប្រើប្រាស់ដីពេលអនាគត។ |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ /អ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ផ្តល់នូវការសម្របសម្រួល។ |
| តម្រូវការផ្សេងៗទៀត | គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការសិក្សាអំពីការវាយតម្លៃគំរោងទិន្នន័យលំអិតនៃគំរោង និងការប៉ាន់ស្មានតម្លៃ មុននឹងធ្វើការចាត់ទៅជាគំរោងអាទិភាព និងគូសព្រាងចូលទៅក្នុងផែនទីគំរោង។ |

**ការផ្តល់អនុសាសន៍ លើវិធានការសំរាប់កិច្ចការពារ**

| | |
|---|---|
| សង្គម | ក្នុងអំឡុងពេលវាយ "គំរោងអាទិភាព" និងគូសព្រាងជាផែនទីគំរោងនោះ គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវគោរពនូវលក្ខខ័ណ្ឌនៃកិច្ចការពារសង្គមដូចតទៅ៖<br>តំបន់សំរាប់ជនជាតិភាគតិច តំបន់បិតិកភ័ណ្ឌ វប្បធម/ជំនឿ និងតំបន់ដែលនឹងត្រូវតាំងទីលំនៅថ្មី។ ជាក្រិត្យក្រមទូទៅសង្កេតឃើញថាពុំមានគំរោងឃុំ សង្កាត់ណាមួយដែលរៀបចំផែនការសំរាប់កិច្ចការពារសង្គមនោះទេ លើកលែងតែគំរោងនោះមានភ្ជាប់មកជាមួយនូវផែនការ ដែលត្រូវធ្វើការគ្រប់គ្រងប្រភពធនធានសង្គម ឬវប្បធម៌ទាំងនោះ។ |
| បរិស្ថាន | នៅពេលដែលវាយ "គំរោងអាទិភាព" និងគូសព្រាងជាផែនទីគំរោង គណៈកម្មាធិការកសាងផែនការ និងថវិកា គួរតែគោរពតាមវិស័យនៃកិច្ចការពារបរិស្ថានដូចតទៅ៖<br>តំបន់ការពារ ព្រៃការពារ តំបន់ជីវៈចំរុះ និងទីជំរាលដែលមានភាពមិនប្រក្រតី។ ជាក្រិត្យក្រមទូទៅ ពុំមានគំរោងឃុំណាមួយដែលរៀបចំផែនការសំរាប់កិច្ចការពារបរិស្ថាននោះទេ លើកលែងតែវាមានភ្ជាប់មកជាមួយនូវផែនការដែលត្រូវធ្វើការគ្រប់គ្រងប្រភពធនធានបរិស្ថានដែលមានភាពមិនប្រក្រតីទាំងនោះ។ |

| **ការងារ E : ការរៀបចំពង្រាងផែនការប្រើប្រាស់ដី (កវយ ជំហាន២)** | |
|---|---|
| គោលបំណង | ដើម្បីរៀបចំជាសំរេចនូវផែនទី និងក្របខណ្ឌការងារប្រើប្រាស់ដី ដើម្បីធ្វើការបូកសរុប និងការដាក់ស្នើឡើងនូវកម្មវិធីវិនិយោគឃុំ សង្កាត់។ ជាមួយនោះដែរ ក៏ធ្វើការរៀបចំពង្រាងផែនការប្រើប្រាស់ដីសំរាប់ដាក់ស្នើឡើងទៅក្រុមប្រឹក្សាឃុំ សង្កាត់/ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ។ |
| សកម្មភាព | **សកម្មភាព ២.១:** រៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដើម្បីដាក់ជូនដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ /គណៈកម្មាធិការគ្រប់ គ្រងដីរដ្ឋ (ថ្នាក់រាជធានីខេត្ត) ដើម្បីអនុម័ត។ |
| អ្នកចូលរួម | គណៈកម្មាធិការកសាងផែនការ និងថវិកា និងជនបង្គោលសម្របសម្រួលរៀបចំធ្វើផែនការប្រើប្រាស់ដីឃុំ គឺជាជនសំខាន់ក្នុងសកម្មភាពនេះ។ អ្នកសម្របសម្រួលការរៀបចំ ផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកសម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដោយធ្វើការសហការជាមួយនឹងអ្នកសម្របសម្រួល ថ្នាក់ក្រុង ស្រុក ខណ្ឌ។ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានីខេត្ត សម្របសម្រួលផលិតគំនូសព្រាងផែនទីគំរោង។ |
| ទីកន្លែង | ការងារនេះត្រូវបានធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់ តែចំណែកការផលិតផែនទីធ្វើនៅថ្នាក់រាជធានី ខេត្ត។ |
| រយៈពេល | ការងាររៀបចំ : ០១ថ្ងៃ<br>ជួយគណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការសំរេចលើអាទិភាព និងជំរើសក្នុងការប្រើប្រាស់ដីពេល អនាគត : ០១ ថ្ងៃ<br>ការងាររៀបចំ និងធ្វើបច្ចុប្បន្នភាពផែនទីគំរោង : ០១ ឬ ០២ថ្ងៃ។ |
| សម្ភារៈ | សេចក្តីព្រាងផែនទីគំរោង<br>ទិន្នន័យឃុំ |
| លទ្ធផល | - ផែនទីគំរោងសំរាប់ដាក់ជូនទៅថ្នាក់រាជធានី ខេត្ត (កវយ)<br>- សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ រួមមានផែនទីប្រើប្រាស់ ដីសំរាប់ពេលអនាគត។ |

**លទ្ធផលនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់**

| | | | | |
|---|---|---|---|---|
| ការងារ E : រៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ | ផែនទីគំរោង (គំនូសព្រាង/ មាត្រដ្ឋាន) | សេចក្តីព្រាងផែនទីប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់ | សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក | ក.វ.យ ជំហាន២ ការត្រៀមរៀបចំ ក.វ.យ |

## សកម្មភាព ២.១ : ការរៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដើម្បីសុំការអនុម័ត

| |
|---|
| **បរិយាយ សកម្មភាព ២.១ ( ករយ)** |
| ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា ដោយមានការគាំទ្រពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបំពេញទម្រង់គំរូនៃការប្រើប្រាស់ដីឃុំ សង្កាត់នូវទិន្នន័យ/ព័ត៌មានដែលប្រមូលបានក្នុងរយៈពេលរៀបចំ ផែនការ អភិវឌ្ឍន៍ឃុំ សង្កាត់ និង/ឬកម្មវិធីវិនិយោគឃុំ សង្កាត់។ ផែនការនេះរួមមានផែនទីដែលមានមាត្រដ្ឋានមួយចំនួន ដូចខាងក្រោម : ផែនទីប្រើប្រាស់ដីលំអិត ផែនទីប្រើប្រាស់ដីសាមញ្ញ ផែនទី "*បញ្ហា មូលហេតុ និងដំណោះស្រាយ*" និងផែនទីប្រើប្រាស់ដីពេលអនាគត ព្រមទាំងទិន្នន័យលំអិតផ្សេងៗទៀតអំពីវិស័យផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងទិន្នន័យរូបសាស្ត្រ។ ពេលបានរៀបចំរួចហើយ ផែនការនេះត្រូវចុះហត្ថលេខាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយផ្ញើជូនទៅក្រុម ការងារជីវឌ្ឍថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការពិនិត្យ ឯកភាពផ្ញើជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីអនុម័ត។ |

### លទ្ធផល

| | |
|---|---|
| លទ្ធផល ១ | រៀបចំសេចក្តីព្រាងផែនការប្រើប្រាស់ដី ទៅតាមទម្រង់គំរូ (ឧបសម្ព័ន្ធ ១០)។ |
| លទ្ធផល ២ | ក្រុមប្រឹក្សាឃុំ សង្កាត់ចុះហត្ថលេខាលើផែនការប្រើប្រាស់ដីឃុំ សង្កាត់ រួចផ្ញើជូនទៅក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការពិនិត្យ ឯកភាព រួចស្នើសុំការអនុម័តពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ រាជធានី ខេត្ត។ |

### សកម្មភាព

| | |
|---|---|
| សកម្មភាព ២.១.១ | គណៈកម្មាធិការកសាងផែនការ និងថវិកាដោយមានការគាំទ្រពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវធ្វើការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដោយយោងទៅតាមទម្រង់ផែនការគំរូ។ |
| សកម្មភាព ២.១.២ | ក្រុម GIS ប្រគល់ផែនទី និងទិន្នន័យទាំងអស់ដែលត្រូវការសំរាប់ការរៀបចំផែនការប្រើប្រាស់ដីឃុំ សង្កាត់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ (តាមរយៈក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ)។ |
| សកម្មភាព ២.១.៣ | ក្រោយពីមានការឯកភាពលើខ្លឹមសារនៃផែនការប្រើប្រាស់ដីឃុំ សង្កាត់រួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ជូនផែនការនេះ ទៅក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌដើម្បីពិនិត្យនិងឯកភាព។ |

### ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| គណៈកម្មាធិការកសាងផែនការ និងថវិកា | ទទួលទិន្នន័យ/ផែនទីទាំងអស់ ដើម្បីបំពេញក្នុងទម្រង់គំរូផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ បញ្ជូលផែនការនេះទៅជូនក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ក្រោយពីបានចុះហត្ថលេខាក្រុមប្រឹក្សាឃុំ សង្កាត់រួច។ |

| | |
|---|---|
| ក្រុមប្រឹក្សាឃុំ សង្កាត់ | ទទួលសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ហើយអនុម័តដោយចុះហត្ថលេខា នៅពេលដែលបានឯកភាពទៅតាមខ្លឹមសារនៃផែនការនេះ។ |
| ក្រុម GIS | ប្រគល់ផែនទីនានា ដូចជាផែនទីប្រើប្រាស់ដី ផែនទី *"បញ្ហា មូលហេតុ និងដំណោះស្រាយ"* (ខ្នាត A3) ផែនទីប្រើប្រាស់ដីពេលអនាគត (A0) ទិន្នន័យ(តួលេខទំហំ)នៃការប្រើប្រាស់ដី តារាងស្តីពី *"បញ្ហា មូលហេតុ និងដំណោះស្រាយ"* និងគំរោងនានាពាក់ព័ន្ធនឹងប្រើប្រាស់ដី ។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ | គាំទ្រគណៈកម្មាធិការកសាងផែនការ និងថវិកាក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ឱ្យបានចប់សព្វគ្រប់ ដើម្បីដាក់ជូនទៅក្រុមការងារជីវជ្ជថ្នាក់ក្រុង ស្រុក ខណ្ឌ។ |
| ក្រុមការងារជីវជ្ជថ្នាក់ក្រុង ស្រុក ខណ្ឌ | ទទួលសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ហើយធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ជំរើសទាំងនោះឱ្យត្រឹមត្រូវទៅតាមសង្គម/បរិស្ថាន។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *ប៉ាន់ស្មានរយៈពេលសំរាប់រៀបចំពង្រាងផែនការប្រើប្រាស់ដីៈ ពីរថ្ងៃ (២ថ្ងៃ)* |
| តម្រូវការសម្ភារៈ | ទម្រង់គំរូ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ |
| តម្រូវការទិន្នន័យ | - ផែនទីប្រើប្រាស់ដីសាមញ្ញថ្នាក់ឃុំ សង្កាត់ សំរាប់ប្រើជាផែនទីគោល<br>- គំនូសព្រាងផែនទី ឬ ផែនទីសំរេចនៃការប្រើប្រាស់ដីពេលអនាគត<br>- គំនូសព្រាងផែនទីគំរោង បង្ហាញនូវទីតាំងគំរោងអាទិភាពក្នុងឃុំ សង្កាត់<br>- បញ្ជីនៃគំរោងអាទិភាព (លើក្រដាសផ្ទាំងធំ)។ |
| តម្រូវការបណ្តុះបណ្តាល | គ្មាន |
| តម្រូវការផ្សេងៗទៀត | គ្មាន |

**ការផ្តល់អនុសាសន៍ លើវិធានការសំរាប់កិច្ចការពារ**

| | |
|---|---|
| សង្គម និងបរិស្ថាន | នៅពេលដែលធ្វើបទបង្ហាញអំពីបញ្ជីជំរើសជាអាទិភាពក្នុងការប្រើប្រាស់ដីឃុំ សង្កាត់ ត្រូវតែគោរពតាមកិច្ចការពារសង្គមដូចតទៅ : តំបន់សំរាប់ជនជាតិភាគតិច តំបន់បិតិកភ័ណ្ឌវប្បធម៌/ ជំនឿ និងតំបន់ដែលនឹងត្រូវតាំងទីលំនៅថ្មី។ ជាក្រឹត្យក្រមទូទៅ ពុំមានគំរោងឃុំ សង្កាត់ណាមួយដែលរៀបចំផែនការ សំរាប់កិច្ចការពារសង្គមនេះដាច់តែឯងដោយឡែកនោះទេ លើកលែងតែការធ្វើផែនការគ្រប់គ្រងប្រភពធនធាន សង្គម ឬវប្បធម៌ទាំងនោះដោយឡែក។ |

## ការងារ F: ការគាំទ្រឃុំ សង្កាត់ក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ (កវយ ជំហាន៣)

| | |
|---|---|
| គោលបំណង | ដើម្បីជួយគាំទ្រដល់តំណាងឃុំ ក្នុងការរៀបចំធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ។ |
| សកម្មភាព | **សកម្មភាព ៣.១:** ជួយដល់តំណាងឃុំ សង្កាត់ ក្នុងការធ្វើបទបង្ហាញអំពីជំរើសក្នុងការប្រើប្រាស់ដីពេលអនាគត និងគំរោងដែលពាក់ព័ន្ធ ។ |
| អ្នកចូលរួម | តំណាងឃុំ សង្កាត់ ដែលមានការជួយគាំទ្រពីក្រុមសម្របសម្រួលការធ្វើផែនការប្រើប្រាស់ដីថ្នាក់ ក្រុង ស្រុក ខណ្ឌ ។ |
| ទីកន្លែង | រៀបចំការងារនៅសាលាឃុំ សង្កាត់ និងធ្វើបទបង្ហាញនៅសាលាក្រុង ស្រុក ខណ្ឌ ។ |
| រយៈពេល | កន្លះថ្ងៃសំរាប់ការងាររៀបចំជាមួយអ្នកតំណាងឃុំ សង្កាត់ និងមួយថ្ងៃសំរាប់ការចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ។ |
| សម្ភារៈ | ផែនទីគំរោងដែលរួមមាន ព័ត៌មានអំពីសំណើសកម្មភាពអនុវត្តគំរោងនៅលើដីរដ្ឋ ។ |
| លទ្ធផល | កម្មវិធីវិនិយោគឃុំ សង្កាត់ ដែលទទួលការឯកភាព និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងគាំទ្រជាបណ្ដោះអាសន្ន ។ |

### លទ្ធផល នៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ការងារ F : ជួយគាំទ្រដល់សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ

គំរោងអំពីដីធ្លី ត្រូវបានធ្វើការបង្ហាញ

កវយ ជំហាន ៣: សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក

## សកម្មភាព ៣.១ : ការធ្វើបទបង្ហាញអំពីសេចក្តីព្រាងផែនទីគំរោង និងផែនទីប្រើប្រាស់ដីខេត្ត

| បរិយាយ សកម្មភាព ៣.១ ( ករុំយ) |
| --- |
| ទីកន្លែង: នៅថ្នាក់ឃុំ សង្កាត់ |
| ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើបទបង្ហាញអំពីសេចក្តីព្រាងនៃផែនទីគំរោង និងបញ្ជីនៃគំរោងអាទិភាពនៅសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការចរចាជាមួយនឹងមន្ទីរជំនាញជុំវិញរាជធានី ខេត្ត អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារជាតិ-អន្តរជាតិ ដើម្បីសុំការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជំនួយផ្នែកបច្ចេកទេសសំរាប់សំណើគំរោងរបស់ឃុំ សង្កាត់ និងឈានទៅដល់ការចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នជាមួយនឹងទីភ្នាក់ងារដែលបានជ្រើសយកគំរោងទាំងនោះ។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និង/ឬ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋគួរចាត់តំណាងចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ នៅក្នុងរាជធានី ខេត្តរបស់គេ ដើម្បីធ្វើការលើកទឹកចិត្តដល់គំរោងប្រើប្រាស់ដី។ |

### លទ្ធផល

| | |
| --- | --- |
| លទ្ធផល ១ | ធ្វើបទបង្ហាញអំពីសេចក្តីព្រាងផែនទីប្រើប្រាស់ដី ឬ ផែនទីប្រើប្រាស់ដីដែលបានអនុម័តហើយ និងបង្ហាញនូវគោលបំណងប្រាថ្នាក្នុងការប្រើប្រាស់ដីសំរាប់ ១០ ទៅ១៥ឆ្នាំខាងមុខ។ |
| លទ្ធផល ២ | ធ្វើបទបង្ហាញសេចក្តីព្រាងផែនទីគំរោងដែលបង្ហាញទីតាំងអាទិភាពនៃគំរោងឃុំ សង្កាត់ និង បញ្ជីគំរោងអាទិភាពនៅលើក្រដាសផ្ទាំងធំ។ |

### សកម្មភាព

| | |
| --- | --- |
| សកម្មភាព ៣.១.១ | តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ (សេចក្តី ព្រាង/អនុម័ត) បង្ហាញអំពីបំណងប្រាថ្នារបស់ឃុំក្នុងរយៈ១០និង១៥ឆ្នាំខាងមុខ។ |
| សកម្មភាព ៣.១.២ | តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើបទបង្ហាញដល់សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ អំពីផែនទី គំរោង ដែលបង្ហាញអំពីទីតាំងនៃបណ្តាគំរោងអាទិភាពក្នុងឃុំ សង្កាត់។ |
| សកម្មភាព ៣.១.៣ | តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការចរចាជាមួយនឹងទីភ្នាក់ងារសាធារណៈ និងឯកជន ហើយឈានទៅដល់ការចុះ កិច្ចព្រមព្រៀងបណ្តោះអាសន្នសំរាប់ជាកិច្ចគាំទ្រដល់គំរោង។ |

### ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
| --- | --- |
| អភិបាលស្រុក | ជាប្រធាននៃអង្គសិក្ខាសាលា |
| មន្ទីរជំនាញ ជុំវិញរាជធានី ខេត្ត | ជាអ្នកចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ និងអាចចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នជាមួយឃុំ សង្កាត់ ដើម្បីធ្វើការគាំទ្រគំរោង។ |
| អ្នកផ្តល់ជំនួយ | ជាអ្នកចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ។ អាចនឹងចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នជាមួយឃុំ សង្កាត់ដើម្បីធ្វើការគាំទ្រគំរោង។ |
| អង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ-អន្តរជាតិ | ជាអ្នកចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ និងអាចចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នជាមួយឃុំ សង្កាត់ដើម្បីធ្វើការគាំទ្រគំរោង។ |

| | |
|---|---|
| អ្នកវិនិយោគឯកជន | ជាអ្នកចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ និងអាចចុះកិច្ចព្រមព្រៀងបណ្ដោះអាសន្នជាមួយឃុំ សង្កាត់ដើម្បីធ្វើការគាំទ្រគំរោង។ |
| តំណាងឃុំ សង្កាត់ | តំណាង២នាក់ មកពីឃុំ សង្កាត់នីមួយៗ ដើម្បីចូលរួមសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ និងធ្វើបទបង្ហាញសេចក្ដីព្រាងគំរោងរបស់ឃុំ សង្កាត់។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *ប៉ាន់ស្មានរយៈពេល : ពីរថ្ងៃ (២ថ្ងៃ)* |
| តម្រូវការសម្ភារៈ | កិច្ចព្រមព្រៀងបណ្ដោះអាសន្ន |
| តម្រូវការទិន្នន័យ | - ផែនទីប្រើប្រាស់ដីលំអិតប្រើជាផែនទីគោល<br>- គំនូសព្រាង ឬផែនទីប្រើប្រាស់ដីពេលអនាគតដែលបានអនុម័តរួច<br>- គំនូសព្រាងផែនទីគំរោងដែលបង្ហាញនូវទីតាំងនៃគំរោងអាទិភាពរបស់ឃុំ សង្កាត់<br>- បញ្ជីនៃបណ្ដាគំរោងអាទិភាព (លើក្រដាសផ្ទាំងធំ)។ |
| តម្រូវការបណ្ដុះបណ្ដាល | គ្មាន |
| តម្រូវការផ្សេងៗទៀត | គ្មាន |

**ការផ្ដល់អនុសាសន៍ លើវិធានការសំរាប់កិច្ចការពារ**

| | |
|---|---|
| សង្គម និងបរិស្ថាន | នៅពេលដែលធ្វើបទបង្ហាញអំពីបញ្ជីជំរើសជាអាទិភាពក្នុងការប្រើប្រាស់ដីឃុំ សង្កាត់ត្រូវតែគោរពតាមកិច្ចការពារសង្គមដូចតទៅ : តំបន់សំរាប់ជនជាតិភាគតិចតំបន់បិតិកភ័ណ្ឌវប្បធម៌/ ជំនឿ និងតំបន់ដែលនឹងត្រូវតាំងទីលំនៅថ្មី។ ជាក្រឹត្យក្រមទូទៅពុំមានគំរោងឃុំសង្កាត់ណាមួយដែលរៀបចំផែនការសំរាប់កិច្ចការពារសង្គមនេះដាច់តែឯងដោយឡែកនោះទេលើកលែងតែការធ្វើផែនការគ្រប់គ្រងប្រភពធនធាន សង្គម ឬវប្បធម៌ទាំងនោះដោយឡែក។ |

| ការងារ G : ការកសាងផែនទីសំរេចសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់ (កវយ ជំហាន៤) | |
|---|---|
| គោលបំណង | ធ្វើការបូកសរុបផែនទី និងព័ត៌មានសំរាប់ធ្វើបទបង្ហាញដល់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីធ្វើការអនុម័ត ។ |
| សកម្មភាព | **ការងារ ៤.១:** ផ្ទៀងផ្ទាត់ផែនទីគំរោងសារឡើងវិញនៅទីណាដែលចាំបាច់ ។ |
| អ្នកចូលរួម | ក្រុមសម្របសម្រួលការធ្វើផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ផ្តល់ជូនព័ត៌មានអំពីតម្រូវការនៃការផ្លាស់ប្តូរ ។ ក្រុម GIS ថ្នាក់រាជធានី ខេត្ត រៀបចំផែនទី និងព័ត៌មានអំពីគំរោងដើម្បីធ្វើបទបង្ហាញជូនក្រុមប្រឹក្សាឃុំ សង្កាត់ ។ |
| ទីកន្លែង | រៀបចំឧបករណ៍សំភារៈនៅថ្នាក់រាជធានី ខេត្ត និងធ្វើបទបង្ហាញជូនក្រុមប្រឹក្សាឃុំ សង្កាត់នៅឃុំ សង្កាត់ ។ |
| រយៈពេល | រៀបចំឧបករណ៍ សំភារៈរយៈពេលមួយអាទិត្យក្រោយសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ និងមួយថ្ងៃសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការពិនិត្យសារឡើងវិញ ។ |
| សម្ភារៈ | - ផែនទីគំរោងសំរេច<br>- ផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញដែលបានធ្វើបច្ចុប្បន្នភាពហើយ<br>- ផែនទី បញ្ហា មូលហេតុ និងដំណោះស្រាយ ។ |
| លទ្ធផល | ផែនទីគំរោងដែលបានធ្វើការផ្ទៀងផ្ទាត់ឡើងវិញ ។ |

**លទ្ធផល ផបដយ**

ការងារ G : ការកសាងផែនទីសំរេចសំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់

ធ្វើបច្ចុប្បន្នភាពផែនទីគំរោង (មាត្រដ្ឋាន)

កវយ ជំហាន ៤ : ការអនុម័ត

| សកម្មភាព ៤.១: ការធ្វើបច្ចុប្បន្នភាពផែនទីគំរោង នៅទីណាដែលមានភាពសមស្រប |
|---|
| **បរិយាយ សកម្មភាព ៤.១ ( កវ៉យ)** |
| ទីកន្លែង: នៅថ្នាក់រាជធានី ខេត្ត |
| ក្រុម GIS ថ្នាក់រាជធានី ខេត្ត ធ្វើការគូសបញ្ចូលទៅក្នុងកុំព្យូទ័រនូវផែនទីគំរោងសំរេចចុងក្រោយរបស់ឃុំ សង្កាត់ ហើយនិងធ្វើការ បោះពុម្ពជូនទៅដល់គណៈកម្មាធិការកសាងផែនការ និងថវិកា ដើម្បីបញ្ចូលទៅក្នុងឯកសារផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និង កម្មវិធីវិនិយោគឃុំ សង្កាត់ ។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | គំនូសព្រាងផែនទីគំរោងចុងក្រោយ (គូសដោយក្រុម GIS) ដែលបង្ហាញអំពីស្ថានភាពនៃសំណើគំរោងអាទិភាពទាំងអស់នៅក្នុង ឃុំ សង្កាត់ក្រោយពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ។ |
| លទ្ធផល ២ | ផែនទីគំរោងបានត្រូវបោះពុម្ពចេញ (មានមាត្រដ្ឋាន) ដែលបង្ហាញអំពីស្ថានភាពនៃសំណើគំរោងអាទិភាពទាំងអស់នៅក្នុងឃុំ បន្ទាប់ពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ ហើយប្រគល់ជូនគណៈកម្មាធិការកសាងផែនការ និងថវិកា ដើម្បីបញ្ចូលទៅក្នុងឯកសារនៃផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ៤.១.១ | ក្រុម GIS ធ្វើការគូសព្រាងផែនទីគំរោងចុងក្រោយទៅក្នុងកុំព្យូទ័រ ។ |
| សកម្មភាព ៤.១.២ | ក្រុម GIS ធ្វើការបោះពុម្ពផែនទីគំរោង (មានមាត្រដ្ឋាន និងត្រូវបានសំរេចរួច) ចេញជូនគណៈកម្មាការកសាងផែនការ និងថវិកា ដើម្បីបញ្ចូលទៅក្នុងឯកសារនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។ |

**ប្រតិបត្តិករ និង ការទទួលខុសត្រូវ**

| | |
|---|---|
| ក្រុម GIS | ធ្វើការគូសបញ្ចូលទៅក្នុងកុំព្យូទ័រ និងធ្វើការបោះពុម្ពចេញផែនទីគំរោង ។ |
| គណៈកម្មការផែនការ និង ថវិកា | ទទួលផែនទី គំរោងសំរេចពីក្រុម GIS និងរៀបចំបញ្ចូលទៅក្នុងឯកសារផែនការអភិវឌ្ឍ ឃុំ សង្កាត់ ។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *ប៉ាន់ស្មានរយៈពេលសំរាប់ដំណើរការគូសបញ្ចូលទៅក្នុងកុំព្យូទ័រ និងការបោះពុម្ពចេញ: កន្លះថ្ងៃ (១/២ថ្ងៃ)* |
| តម្រូវការសម្ភារៈ | ផ្នែករឹង (កុំព្យូទ័រ) សំរាប់ក្រុម GIS ថ្នាក់រាជធានី ខេត្ត |
| តម្រូវការទិន្នន័យ | គំនូសព្រាងផែនទីគំរោងសំរេចចុងក្រោយ ។ |
| តម្រូវការបណ្តុះបណ្តាល | គ្មាន |
| តម្រូវការផ្សេងៗទៀត | គ្មាន |

## ភារកិច្ច H : ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ (កវយ ជំហាន ៥)

| | |
|---|---|
| គោលបំណង | ជួយគាំទ្រដល់ គណៈកម្មាធិការកសាងផែនការ និងថវិកាក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃផែនការប្រើប្រាស់ដី និងគំរោងពាក់ព័ន្ធនឹងបញ្ហាដីធ្លីដទៃទៀត ។<br>ធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ/រក្សាទុកឯកសារ |
| សកម្មភាព | **សកម្មភាព ៥.១ :** លើកកំពស់សមត្ថភាព គណៈកម្មាធិការកសាងផែនការ និងថវិកា/ តំណាង ឃុំ សង្កាត់ |
| | **សកម្មភាព ៥.២:** ធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ |
| អ្នកចូលរួម | អ្នកសម្របសម្រួលផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានជំនួយពីក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ធ្វើការបណ្តុះបណ្តាលគណៈកម្មាធិការកសាងផែនការ និងថវិកា និង/ឬ តំណាង ឃុំ សង្កាត់ដែលបានចាត់តាំង ។ |
| ទីកន្លែង | វគ្គបណ្តុះបណ្តាលនេះអាចនឹងប្រព្រឹត្តិទៅនៅក្រុង ស្រុក ខណ្ឌ ។ |
| រយៈពេល | មួយថ្ងៃសំរាប់ការបណ្តុះបណ្តាល និងការជួយគាំទ្រផ្នែកបច្ចេកទេសទៅតាមសំណូមពរ ។ |
| សម្ភារៈ | - ផែនទី បញ្ហា មូលហេតុ និងដំណោះស្រាយ<br>- ផែនទីគំរោង<br>- ផែនការប្រើប្រាស់ដីឃុំ<br>- សូចនាករសំខាន់ៗសំរាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ។ |
| លទ្ធផល | លើកកំពស់សមត្ថភាពគណៈកម្មាធិការកសាងផែនការ និងថវិកា និង/ឬតំណាងឃុំ សង្កាត់ដែលបានចាត់តាំងដើម្បីធ្វើការត្រួតពិនិត្យ តាមដាន និងវាយតម្លៃផែនការប្រើប្រាស់ដី និងគំរោងពាក់ព័ន្ធនឹងបញ្ហាដីធ្លីដទៃទៀត ។ |

លទ្ធផល នៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

ការងារ H: ការត្រួតពិនិត្យ តាមដាន និង វាយតម្លៃ

បណ្តុះបណ្តាល អំពី ការត្រួតពិនិត្យតាមដាន និងវាយតំលៃ

ធ្វើបច្ចុប្បន្នភាព មូលដ្ឋានទិន្នន័យ និង ការរក្សាទុក

កវយ ជំហាន ៥ : ត្រួតពិនិត្យ តាមដាន និង វាយតម្លៃ

| សកម្មភាព ៥.១ : ការលើកកំពស់សមត្ថភាពគណៈកម្មាធិការកសាងផែនការ និងថវិកា/ តំណាងឃុំ សង្កាត់ |
|---|
| **បរិយាយ សកម្មភាព ៥.១ ( កវិយ)** |
| ទីកន្លែង: នៅថ្នាក់រាជធានី ខេត្ត ឬថ្នាក់ក្រុង ស្រុក ខណ្ឌ |
| ក្រោយពេលដែលផែនការប្រើប្រាស់ដីត្រូវបានអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋរួច គណៈកម្មាធិការកសាងផែនការ និងថវិកា នឹងទទួលនូវវគ្គបណ្តុះបណ្តាលអំពីការត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើផែនការប្រើប្រាស់ដី។ |

**លទ្ធផល**

| | |
|---|---|
| លទ្ធផល ១ | វគ្គបណ្តុះបណ្តាលដល់ថ្នាក់ឃុំ សង្កាត់ត្រូវបានអនុវត្ត។ |
| លទ្ធផល ២ | ឃុំ សង្កាត់អនុវត្តតាមគោលការណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ |

**សកម្មភាព**

| | |
|---|---|
| សកម្មភាព ៥.១.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ រៀបចំវគ្គ បណ្តុះបណ្តាល។ |
| សកម្មភាព ៥.១.២ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ រៀបចំវគ្គបណ្តុះបណ្តាល។ |

**ប្រតិបត្តិករ និង ការទទួលខុសត្រូវ**

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | រៀបចំ និងបើកវគ្គបណ្តុះបណ្តាល អំពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ្នកដឹកនាំក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត | ធ្វើបទបង្ហាញអំពីគោលការណ៍នៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃដល់អ្នកចូលរួម។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា/ឃុំ សង្កាត់ | ចាត់តំណាងឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងតាមដានការងារអនុវត្តលើការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។ |
| ក្រុម GIS | រៀបចំផែនទីប្រើប្រាស់ដី ផែនទី *"បញ្ហា មូលហេតុ និងដំណោះស្រាយ"* ផែនទីគំរោង តាមសំណើរបស់អ្នកដឹកនាំក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត។ |

**តម្រូវការធនធាន**

| | |
|---|---|
| តម្រូវការពេលវេលា | *ប៉ាន់ស្មានរយៈពេលសំរាប់ការងាររៀបចំវគ្គបណ្តុះបណ្តាលៈ ពីរថ្ងៃ (២ថ្ងៃ)*<br>*សំរាប់វគ្គបណ្តុះបណ្តាលៈ មួយថ្ងៃ (១ថ្ងៃ)* |
| តម្រូវការសម្ភារៈ | - លក្ខខណ្ឌ និងសូចនាករ សំរាប់ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ |

| | |
|---|---|
| | - ផែនទី បញ្ហា មូលហេតុ និងដំណោះស្រាយ<br>- ផែនទីគំរោង<br>- ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ |
| តម្រូវការទិន្នន័យ | គ្មាន |
| តម្រូវការបណ្តុះបណ្តាល | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមការងារជីវជ្ជថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវការនូវការបណ្តុះបណ្តាលអំពីបច្ចេកទេសដោយឡែកអំពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃ លើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងការតាមដានគំរោងពាក់ព័ន្ធនឹងបញ្ហាដីធ្លី។ ក្រុមការងារជីវជ្ជថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវការវគ្គបណ្តុះបណ្តាល ដោយឡែកអំពីការដោះស្រាយជម្លោះ។ |
| តម្រូវការផ្សេងៗទៀតដើម្បីអនុវត្តក្នុងសកម្មភាពនេះ | គ្មាន |

## សកម្មភាព ៥.២ : ការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ និងការរក្សាទុកឯកសារ

### បរិយាយ សកម្មភាព ៥.១ ( ករ)

### ទីកន្លែង: រាជធានី ខេត្ត និងឃុំ សង្កាត់

ក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត មានភារៈទទួលខុសត្រូវក្នុងការរក្សាទុកដាក់ព័ត៌មាន ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងឯកសារទាំងអស់នៅទីកន្លែងដែលមានសុវត្ថិភាព។ ជំហានចុងក្រោយនៃសេចក្តីព្រាងផែនការប្រើប្រាស់ដីឃុំ សង្កាត់ ត្រូវបានរក្សាឯកសារទុកនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។ ទិន្នន័យនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវបានរក្សាទុកនៅក្នុងមូលដ្ឋានទិន្នន័យ (ក្រ.មហាផ្ទៃ/ក្រ. ដនស)។

ក្រុម GIS រក្សាទុកនូវទិន្នន័យព័ត៌មានផែនទីដែលបានធ្វើបច្ចុប្បន្នភាពរួចរបស់គ្រប់ឃុំ សង្កាត់ទាំងអស់នៅក្នុងរាជធានី ខេត្ត នៅក្នុងកុំព្យូទ័រ។ ឃុំ សង្កាត់រក្សាទុករាល់ប្រភេទផែនទីនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទាំងអស់ (លើក្រដាសក្នុងខ្នាត A3) និងផែនទីប្រើប្រាស់ដីពេលអនាគត (ខ្នាត A0)។

ឯកសារទាំងអស់នេះអាចរក្សាទុកនៅក្រុង ស្រុក ខណ្ឌ ប្រសិនបើមានការងាយស្រួល ឬមានការចាំបាច់។

### លទ្ធផល

| | |
|---|---|
| លទ្ធផល ១ | ផែនការប្រើប្រាស់ដីជាឯកសារបោះពុម្ព និងជាឯកសារក្នុងកុំព្យូទ័រត្រូវបានរក្សាទុកនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលក្រុង ស្រុក ខណ្ឌ។ |
| លទ្ធផល ២ | មូលដ្ឋានទិន្នន័យត្រូវបានធ្វើបច្ចុប្បន្នភាព |
| លទ្ធផល ៣ | ផែនទីនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវបានរក្សាទុកនៅក្នុងកុំព្យូទ័រ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។ |
| លទ្ធផល ៤ | ផែនទីសំរេចទាំងអស់នៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ រួមទាំងឯកសារផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវបានរក្សាទុកនៅសាលាឃុំ សង្កាត់។ រួមមានផែនទីចំនួន ៥ :<br>១. ផែនទី "តំបន់រសើប" រាជធានី ខេត្ត<br>២. ផែនទីប្រើប្រាស់ដីលំអិត<br>៣. ផែនទីប្រើប្រាស់ដីសាមញ្ញ<br>៤. ផែនទីបញ្ហា<br>៥. ផែនទីប្រើប្រាស់ដីពេលអនាគត<br>៦. ផែនទីគំរោង។ |

### សកម្មភាព

| | |
|---|---|
| សកម្មភាព ៥.១.១ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ រក្សាទុកទិន្នន័យផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់នៅក្នុងប្រព័ន្ធ GIS ទុកជាឯកសារ។ |
| សកម្មភាព ៥.១.២ | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ទទួលខុសត្រូវក្នុងការប្រមូល និងបញ្ចូលទិន្នន័យនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់ទៅក្នុងមូលដ្ឋានទិន្នន័យ (Databases)។ |

| | |
|---|---|
| សកម្មភាព ៥.១.៣ | ក្រុម GIS ថ្នាក់រាជធានី ខេត្តរក្សាទុកដាក់ទិន្នន័យនៅក្នុងកុំព្យូទ័រនូវផែនទី និងទិន្នន័យរបស់ឃុំ សង្កាត់ទាំងអស់ ។ ធ្វើការចម្លងដើម្បីរក្សាទុក រួចផ្ញើទៅអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ |
| សកម្មភាព ៥.១.៤ | គណៈកម្មាធិការកសាងផែនការ និងថវិការក្សាទុកផែនទី (លើក្រដាស) នៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទាំងអស់ និងឯកសារផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់របស់ខ្លួន ។ |

## ប្រតិបត្តិករ និង ការទទួលខុសត្រូវ

| | |
|---|---|
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ | រក្សាទុកផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ (រួមទាំង ឧបសម្ព័ន្ធ) ជាការតំកល់ទុកឯកសារ ។ |
| ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត | ប្រមូល និងបញ្ចូលទិន្នន័យនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅក្នុងទិន្នន័យមូលដ្ឋាន (Databases) ។ |
| ក្រុម GIS | គ្រប់គ្រង ទិន្នន័យផែនទីប្រើប្រាស់ដីសំរាប់គ្រប់ឃុំ សង្កាត់ទាំង អស់នៅក្នុងរាជធានី ខេត្ត ។ |
| គណៈកម្មាធិការកសាងផែនការ និងថវិកា | គណៈកម្មាធិការកសាងផែនការ និងថវិការក្សាទុកនូវគ្រប់ផែនទី (ក្រដាស)នៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទាំងអស់ និងឯកសារផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់របស់ខ្លួន ។ |

## តម្រូវការធនធាន

| | |
|---|---|
| តម្រូវការពេលវេលា | *ប៉ាន់ស្មានរយៈពេលសំរាប់រក្សាទុកផែនការ : កន្លះថ្ងៃ (១/២ថ្ងៃ)*<br>*សំរាប់ធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ: មួយថ្ងៃ (១ថ្ងៃ)* |
| តម្រូវការសម្ភារៈ | សំភារៈ បរិក្ខា សំរាប់ GIS |
| តម្រូវការទិន្នន័យ | រួមមានផែនទី *ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់* សំរាប់ឃុំ សង្កាត់នីមួយៗ :<br>១. ផែនទីប្រើប្រាស់ដីលំអិត<br>២. ផែនទីប្រើប្រាស់ដីសាមញ្ញ<br>៣. ផែនទីបញ្ហា<br>៤. ផែនទីប្រើប្រាស់ដីពេលអនាគត<br>៥. ផែនទីគំរោង ។ |
| តម្រូវការបណ្តុះបណ្តាល | គ្មាន |
| តម្រូវការផ្សេងៗទៀត | គ្មាន |

# ឧបសម្ព័ន្ធ

## ឯកសារណែនាំអនុវត្ត

## ស្តីពី

## ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

## ដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់

## និងកម្មវិធីវិនិយោគឃុំ សង្កាត់

# ឧបសម្ព័ន្ធ ១: ក្របខ័ណ្ឌច្បាប់សំរាប់រៀបចំដែនដី និងផែនការប្រើប្រាស់ដី

## ១.១. ទិដ្ឋភាពរួមនៃច្បាប់សំរាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

| ដែនទទួលខុសត្រូវ | ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | អាណត្តិនៃច្បាប់ មាត្រា | អាណត្តិនៃច្បាប់ ឯកសារច្បាប់ |
|---|---|---|---|
| " ផែនការមេ សំរាប់ការប្រើប្រាស់ដី" ( Land Use "Master Plan") | ប្លង់ប្រើប្រាស់ដី និងសំណង់ ត្រូវរៀបចំឡើងសំរាប់រាជធានី ខេត្ត។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។ | មាត្រា ០៦ | **ច្បាប់** ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ **១៩៩៤** ( ស្ថិតក្រោមការធ្វើវិសោធនកម្មដោយ ដ.ន.ស) |
| | ប្លង់ប្រើប្រាស់ដី និងសំណង់ត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាល និងបរិក្ខាសាធារណៈ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់ ។ | មាត្រា ០៧ | |
| ព្រំប្រទល់ឃុំ សង្កាត់ (Commune/Sangkat Boundary) | ការបង្កើត ការលុបចោល **ការកែប្រែព្រំប្រទល់** និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់រាជធានី ខេត្តពាក់ព័ន្ធត្រូវសំរេចដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់រាជធានី ខេត្តពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវសំរេច | មាត្រា ០៦ | **ច្បាប់** ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**ឆ្នាំ២០០១** |

| | | |
|---|---|---|
| | ដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រីផ្អែកលើ សំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ | |
| **តួនាទីនិងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់** (Responsibilities of the C/S Administration) | **ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចដូចខាងក្រោម :**<br>- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ<br>- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់នានា និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ ។<br>- លើកទឹកចិត្តឱ្យមានការបង្កើតផាសុខភាព និង សុខុមាលភាពរបស់ប្រជាពលរដ្ឋ ។<br>- ការពារ ថែរក្សា បរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភ័ណ្ឌជាតិ<br>- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក<br>- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ | **មាត្រា ៤៣** |
| **តួនាទីជាភ្នាក់ងារតំណាងរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់** | ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសំរាប់អនុវត្ត។<br>ប្រតិភូកម្មខាងលើនេះត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំសង្កាត់តែប៉ុណ្ណោះ។ | **មាត្រា ៤៤** |

| | | |
|---|---|---|
| **ការដាក់កំរិតកំណត់ចំពោះរដ្ឋបាល ឃុំ សង្កាត់** (The Limitation of C/S administration) | រដ្ឋបាលឃុំ សង្កាត់ គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :<br>- **ព្រៃឈើ**<br>- ប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ការពារប្រទេស<br>- សន្តិសុខជាតិ រូបិយវត្ថុ<br>- នយោបាយក្រៅប្រទេស និង<br>- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ | **មាត្រា ៥៩** |
| **ផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់** (Commune Development Plan and Commune Investment Plan) | ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍឃុំ សង្កាត់ ក្នុងគោលបំណងផ្តល់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍឃុំ សង្កាត់ របស់ខ្លួន ។ | **មាត្រា ៦០** |
| | ផែនការអភិវឌ្ឍឃុំ សង្កាត់ ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ ។ | **មាត្រា ៦១** |
| | ផែនការអភិវឌ្ឍឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឆ្នាំទី១នៃអាណត្តិរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ហើយត្រូតពិនិត្យឡើងវិញ ដើម្បីផ្តល់ទិន្នន័យថ្មីៗ ជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួន។ | **មាត្រា ៦២** |
| | ក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :<br>- វាយតម្លៃអំពីកំរិតអាទិភាព នៃការអភិវឌ្ឍ និងសកម្មភាពអភិវឌ្ឍ នៅក្នុងឃុំ សង្កាត់ របស់ខ្លួន ។ | **មាត្រា ៦៣** |

- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់ និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។
- ផ្តល់សេវា និងការអភិវឌ្ឍ អនុលោមទៅតាមថវិការបស់ខ្លួន ។
- ពិនិត្យ តាមដាន និងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តន៍ផែនការអភិវឌ្ឍ ។
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកិរិតនៃការអភិវឌ្ឍថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន ។
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តន៍ផែនការអភិវឌ្ឍឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របនឹងផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។

**មាត្រា ៦៤**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍឃុំ សង្កាត់ ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។

**មាត្រា ៦៦**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតំលៃរាល់ការអនុវត្តន៍ផែនការ កម្មវិធី គំរោងផ្តល់សេវានានាប្រកបដោយតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធី និងគំរោងនានា ទោះជាការងារ

| | | | |
|---|---|---|---|
| | នោះ ត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។ | | |
| | ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកំរៃសេវាផ្សេងៗ។ ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដី ពន្ធលើអចលនទ្រព្យ និងពន្ធនៃការជួល ។<br>ក្នុងករណីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រមូលចំណូលសារពើពន្ធ និងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំរិត និងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសាពើពន្ធ និងកំរេសេវាកម្មផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។ | **មាត្រា ៧៤** | |
| **រដ្ឋបាលសុរិយោដី** (Cadastral Administration) | រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវធ្វើច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ឃុំ សង្កាត់ ដែលពាក់ព័ន្ធ ។ មេឃុំ ចៅសង្កាត់ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបពិគ្រោះយោបល់ ហើយត្រូវរាយការណ៍ទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ នូវរាល់ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃកម្មសិទ្ធិ និងកម្មសិទ្ធិករ ក្នុងមូលដ្ឋានរបស់ខ្លួន ។ | **មាត្រា ២៣៣** | **ច្បាប់** ភូមិបាល **ឆ្នាំ ២០០១** |
| **ដំណើរការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់** (The C/S Development Planning Process) | ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវប្រើប្រាស់ជាមូលដ្ឋានសំរាប់ណែនាំរាល់ការសំរេចចិត្តក្នុងការអភិវឌ្ឍឃុំ សង្កាត់ និងសំរាប់កសាងកម្មវិធីវិនិយោគឃុំ សង្កាត់ និងការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។ | **ប្រការ ០២** | **ប្រកាសអន្តរក្រសួង** ( ក្រសួងមហាផ្ទៃ និងក្រសួងផែនការ) អំពី ការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ (ខែ កក្កដា **ឆ្នាំ ២០០៧**) |
| | មេឃុំ ចៅសង្កាត់ ត្រូវបង្កើតគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំសង្កាត់របស់ខ្លួន (គ.ផ.ថ)។ គណៈកម្មាធិការកសាងផែនការ និងថវិកា ទទួលខុសត្រូវជួយមេឃុំ ចៅ សង្កាត់ ក្នុងការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ | **ប្រការ ០៦** | |

និងរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។

**មេឃុំ ចៅសង្កាត់ត្រូវទទួលខុសត្រូវចំពោះ:** **ប្រការ ០៨**

- អនុម័តផែនការអភិវឌ្ឍឃុំ សង្កាត់ នៅឆ្នាំ ទីមួយនៃអាណត្តិរបស់ខ្លួន
- អនុម័តរាល់ការកែតម្រូវផែនការអភិវឌ្ឍឃុំ សង្កាត់ក្នុងករណីចាំបាច់
- អនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់
- ត្រួតពិនិត្យ តាមដាន និងវាយតំលៃ អំពីផលប៉ះពាល់នៃការអនុវត្តន៍ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

**វដ្តនៃការកសាងផែនការអភិវឌ្ឍ ឃុំ សង្កាត់ មាន ០៥ ជំហាន:** **ប្រការ ១១**

- ជំហានទី១ : សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍ និងថវិកា
- ជំហានទី២ : កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការអភិវឌ្ឍឃុំ សង្កាត់
- ជំហានទី៣ : សេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់
- ជំហានទី៤ : ការអនុម័តផែនការអភិវឌ្ឍឃុំ សង្កាត់
- ជំហានទី៥ : ការវាយតម្លៃ អំពីការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់

**វដ្តនៃការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់ មាន ០៥ជំហាន:** **ប្រការ ១២**

- ជំហានទី១ : ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ
- ជំហានទី២ : ការរៀបចំគម្រោងវិនិយោគឃុំ សង្កាត់
- ជំហានទី៣ : សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង ស្រុក ខណ្ឌ
- ជំហានទី៤ : ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់
- ជំហានទី៥ : ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍កម្មវិធី

វិនិយោគឃុំ សង្កាត់ ។

**ប្រការ ១៦** ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើតយន្តការសមស្របនានា សំរាប់សម្របសម្រួលរាល់ការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងគំរោងលំអិតនានា និងត្រួតពិនិត្យណែនាំការអនុវត្តន៏ គំរោងទាំងអស់ដែលមានក្នុងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

**ប្រការ ១៩** ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតាមដានការរីកចំរើននៃការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងបណ្តាសកម្មភាពដែលបានអនុវត្តនៅក្នុងដែនដីឃុំ សង្កាត់ របស់ខ្លួនដោយអង្គភាពរដ្ឋាភិបាល អង្គភាពមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិនានា និងវិស័យឯកជន ។

**ប្រការ ២០** ការវាយតំលៃគ្រប់ជ្រុងជ្រោយទៅលើលទ្ធផល និងផលប៉ះពាល់ពីការអនុវត្តន៏ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវធ្វើឡើងក្នុងរយៈពេល០៦ ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ប្រការ ២១** នៅចុងឆ្នាំសារពើពន្ធនីមួយៗ មេឃុំ ចៅសង្កាត់ត្រូវរៀបចំរបាយការណ៏ប្រចាំឆ្នាំ ស្តីពីការអនុវត្តន៏កម្មវិធីវិនិយោគឃុំ សង្កាត់ ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ។ របាយការណ៏ប្រចាំឆ្នាំត្រូវមាន :

- សេវាកម្មអាទិភាពដែលបានផ្តល់ និងសកម្មភាពអភិវឌ្ឍឃុំ សង្កាត់ ទាំងឡាយក្នុងឆ្នាំកន្លងមក ។
- លទ្ធផល និងសមិទ្ធិផលដែលបានមកពីការផ្តល់សេវាកម្ម និងការអនុវត្តសកម្មភាពអភិវឌ្ឍឃុំ សង្កាត់ ។

| | | | |
|---|---|---|---|
| | - បញ្ហាប្រឈម និងអនុសាសន៍សំរាប់ការផ្តល់សេវាកម្ម ឬការអនុវត្តន៍សកម្មភាពអភិវឌ្ឍនានា ។<br>- ស្ថានភាពចំណូលថវិកា និងចំណាយរបស់ឃុំ សង្កាត់ ក្នុងឆ្នាំកន្លងមក<br>- សេវាកម្មជាអាទិភាព និងសកម្មភាពអភិវឌ្ឍឃុំ សង្កាត់ ដែលគ្រោងធ្វើនៅឆ្នាំក្រោយ ។ | | |
| | ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តន៍កម្មវិធីវិនិយោគ ឃុំ សង្កាត់ ក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ។ របាយការណ៍ប្រចាំឆ្នាំនេះត្រូវផ្ញើជូនអភិបាលខេត្ត ក្រុង តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។ | **ប្រការ ២២** | |
| **កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន** (Local Social Land Concession Programs) | - ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាមលក្ខខណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច ដូចមានចែងក្នុងជំពូកទី៤នៃអនុក្រឹត្យនេះ ។<br>- ប្រជាពលរដ្ឋម្នាក់ ឬច្រើននាក់ ឬអង្គការដែលធ្វើការជាមួយប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋនៃឃុំ សង្កាត់ នោះក៏អាចផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានបានដែរ ប៉ុន្តែត្រូវធ្វើតាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់នៃឃុំ សង្កាត់ ដែលដីសម្បទានសង្គមកិច្ចនោះឋិតនៅ ដោយរៀបចំផែនការសម្បទានដីសង្គមកិច្ចស្របតាមលក្ខខណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច ដូចមានចែងក្នុងជំពូកទី៤នៃអនុក្រឹត្យនេះ ។ | **មាត្រា ០៩** | **អនុក្រឹត្យ** ស្តីពីសម្បទានដីសង្គមកិច្ច ( ខែ មិនា **ឆ្នាំ ២០០៣**) |

- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិនិត្យផែនការសម្បទានដីសង្គមកិច្ចប្រចាំឆ្នាំ ដោយអនុលោមតាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ដូចមានចែងក្នុងជំពូកទី ៦នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ០៦**

- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន តាមរយៈក្រុមការងារថ្នាក់ស្រុក ខណ្ឌ ទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ដើម្បីសុំការសម្រេចយល់ព្រម
- បន្ទាប់ពីបានការយល់ព្រម ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយបច្ចេកទេស ពីក្រុមការងារថ្នាក់ ស្រុក ខណ្ឌ ជាអ្នកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកចំហជាសាធារណៈនៅសាលាឃុំ សង្កាត់ពាក់ព័ន្ធ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់រាជធានី ខេត្ត និងនៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងអំឡុងពេលម៉ោងធ្វើការ ។

**មាត្រា ០៩**

**លក្ខខណ្ឌចាំបាច់ ដើម្បីធ្វើផែនការសម្បទានដីសង្គមកិច្ច រួមមាន :**

**ក-** ការពិពណ៌នា អំពីដី និងផែនការប្រើប្រាស់ដី ដែលត្រូវបំពេញតាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**ខ-** ព័ត៌មាន អំពីអត្តសញ្ញាណកម្មដី កម្មសិទ្ធិដី និងការបញ្ជាក់ អំពីដីដែលនៅទំនេរ ដែលអាចប្រើប្រាស់បានសម្រាប់សម្បទានដីសង្គមកិច្ច ឬសមស្រប

សម្រាប់ប្រើប្រាស់ក្នុងផែនការសម្បទានដីសង្គមកិច្ច ។

គ- ព័ត៌មានលំអិត អំពីការជ្រើសរើសមុខសញ្ញាអ្នកទទួលដីរួមមាន :

- ភាពអនុគ្រោះនានាសម្រាប់ក្រុមជនងាយរងគ្រោះ ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ។
- មធ្យោបាយដែលបានប្រើសម្រាប់ធ្វើការត្រួតពិនិត្យឡើងវិញ អំពីការបំពេញលក្ខណវិនិច្ឆ័យនៃភាពអាចជ្រើសរើសបាន និងភាពអនុគ្រោះរបស់មុខសញ្ញាអ្នកទទួលដី ។

ឃ- ផែនការលំអិតសម្រាប់ការបែងចែកដី ដល់មុខសញ្ញាអ្នកទទួលដី រួមទាំងលក្ខខណ្ឌពិសេសនានានៃការកាន់កាប់ និងប្រើប្រាស់ដី ។

ង- ព័ត៌មានលំអិតអំពីដំណើរការដាក់ពាក្យសុំ រួមមាន ទីកន្លែងដាក់ពាក្យ អ្នកទទួលខុសត្រូវក្នុងការផ្សព្វផ្សាយ អំពីដំណើរការដាក់ពាក្យ និងអ្នកទទួលខុសត្រូវ ក្នុងការបិទផ្សាយឈ្មោះអ្នកដាក់ពាក្យសុំកន្លែង បិទផ្សាយសេចក្តីជូនដំណឹង ព្រមទាំងព័ត៌មានលំអិតផ្នែករដ្ឋបាលផ្សេងៗទៀត ។

ច- ការវាយតម្លៃអំពីលទ្ធភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីអនុវត្តផែនការនេះ ដែលរួមមានផ្លូវថ្នល់ ទឹក អគ្គិសនី សាលារៀន ទីផ្សារ មណ្ឌលសុខភាព ព្រមទាំងឧបករណ៍សម្ភារៈសម្រាប់អភិវឌ្ឍដី សេវាផ្សេងទៀត ព័ត៌មានអំពីរបៀប និងពេលវេលាដែលត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សេវាសាធារណៈទាំងនោះ ។

ឆ- ការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាននៃកម្មវិធី និងការពិពណ៌នា

| | | | |
|---|---|---|---|
| | អំពីវិធានការសមស្រប ។<br>**ជ-** តម្រូវការផ្សេងទៀត ត្រូវកំណត់ដោយគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។ | | |
| | **ក្រុមប្រឹក្សាឃុំ សង្កាត់ មានមុខងារ និងភារកិច្ចដូចតទៅៈ**<br>- ផ្តួចផ្តើម និងពិចារណាផែនការសម្បទានដីសង្គមកិច្ចឱ្យស្របតាមនីតិវិធីនៃការអភិវឌ្ឍឃុំ សង្កាត់ ។<br>- អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយមានការគាំទ្របច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ ។<br>- ទទួលខុសត្រូវក្នុងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ក្នុងចំណោមអ្នកដាក់ពាក្យសុំដី ។<br>- ទទួលខុសត្រូវក្នុងការបែងចែកដីដោយត្រឹមត្រូវ និងដោយប្រសិទ្ធភាព ។ | **មាត្រា ២៨** | |
| **ការចែកដី និងការរៀបចំផែនការប្រើប្រាស់ដីលើដីឯកជនរបស់រដ្ឋ** (Allocation and Land Use Planning of State Private Land) | ដីឯកជនរបស់រដ្ឋអាចត្រូវបានចែកអោយប្រើប្រាស់ ដោយថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឬឃុំ សង្កាត់ យោងតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | **មាត្រា ២០** | **អនុក្រឹត្យ** អំពីការគ្រប់គ្រងដីរដ្ឋ ( ខែ តុលា **ឆ្នាំ ២០០៥**) |
| **ការគ្រប់គ្រង និងការអនុវត្តន៍នៃ ការធ្វើផែនទី និងអត្តសញ្ញាណកម្មដីរដ្ឋ** | មុខងារ និងភារកិច្ចរបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌមានដូចតទៅ :<br>- ប្រមូល និងចងក្រងឯកសារ ពត៌មាន ដើម្បីធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋ ។ | **មាត្រា ២៨** | |

| | | | |
|---|---|---|---|
| (Administration and Implementation of State Land Mapping and Identification) | - សម្របសម្រួលជាមួយស្ថាប័ន អាជ្ញាធរ ឬអ្នកកាន់កាប់ដីរដ្ឋអំពីអាណត្តិកាន់កាប់ដីរដ្ឋ ។<br>- ស្វែងរកការឯកភាពលើព្រំប្រទល់ប្រហាក់ប្រហែល ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ ។<br>- ធ្វើការបិទផ្សាយជាសាធារណៈនូវសំណៅពតិមាន និងផែនទីដីរដ្ឋនៅតាមទីប្រជុំជន និងតាម ឃុំ សង្កាត់ ពាក់ព័ន្ធ និងទទួលមតិយោបល់ពីសាធារណៈតាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់ ។<br>- សង្ខេបមតិយោបល់សាធារណៈដែលបានទទួល និងរៀបចំទិន្នន័យ និងឯកសារចាំបាច់រួមទាំងផែនទីដីរដ្ឋ ដែលមានបញ្ជាក់ពតិមានទាំងអស់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ។<br>- **ចូលរួមធ្វើផែនការប្រើប្រាស់ដី និងផ្តល់មតិយោបល់ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ ។**<br>- រៀបចំការពិគ្រោះយោបល់ និងចូលរួមផ្តល់មតិយោបល់លើគំរោងសម្បទានដី ព្រមទាំងសហការតាមដានអនុវត្តគំរោងសម្បទានដី ។<br>- បំពេញភារកិច្ចផ្សេងៗទៀតដូចមានចែងក្នុងអនុក្រិត្យនេះ ។ | | |
| ការចុះបញ្ជីដីជំហានដំបូង (First Land Registration) | **មេឃុំ ចៅសង្កាត់ត្រូវបញ្ជាក់ អំពីភាពត្រឹមត្រូវនៃក្បាលដី និងម្ចាស់កម្មសិទ្ធិ នៅក្នុងដែនព្រំប្រទល់ឃុំ សង្កាត់ របស់ខ្លួនៈ**<br>- ក្បាលដីៈ មេឃុំ ចៅសង្កាត់ ត្រូវបញ្ជាក់ អំពីព្រំប្រទល់នៅលើទំរង់ក្បាលដី<br>- ម្ចាស់កម្មសិទ្ធិៈ មេឃុំ ចៅសង្កាត់ ត្រូវបញ្ជាក់ អំពីឈ្មោះ ពតិមានគ្រួសារ | **ប្រការ ០៣** | **ប្រកាសអន្តរក្រសួង** រវាងក្រសួងមហាផ្ទៃ និងដ.ន.ស អំពីភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ |

| | | | |
|---|---|---|---|
| | ស្ថានភាពគ្រួសារ និងអាស័យដ្ឋានបច្ចុប្បន្នរបស់ម្ចាស់កម្មសិទ្ធិ ។ | | លើការងារចុះបញ្ជីដី ( ខែ កក្កដា **ឆ្នាំ ២០០៥**) |
| | មេឃុំ ចៅសង្កាត់ត្រូវបញ្ជាក់ អំពីភាពត្រឹមត្រូវនៃឯកសាររណប រួមមានការបញ្ជាក់អំពីប្រភព កាលបរិច្ឆេទនៃការកាន់កាប់ដី អំពីស្ថានភាពដី អំពីប្រវត្តិដី | **ប្រការ ០៤** | |
| | មេឃុំ ចៅសង្កាត់ត្រូវទប់ស្កាត់នូវរាល់ការរានដីតាមទំនើងចិត្ត និងការចូលកាន់កាប់ដីដោយគ្មានការអនុញ្ញាត្ត នៅក្នុងមូលដ្ឋានរបស់ខ្លួន ឬត្រូវរាយកាណ៍ជាបន្ទាន់ដល់អភិបាលស្រុក ខណ្ឌ ដើម្បីមានវិធានការដោះស្រាយ ប្រសិនបើទប់ស្កាត់មិនបាន ។ | **ប្រការ ០៥** | |
| | **មេឃុំ ចៅសង្កាត់ ត្រូវគូសគំនូសព្រាងផែនទីប្រើប្រាស់ដីក្នុងឃុំ សង្កាត់របស់ខ្លួន ជាមូលដ្ឋានសំរាប់ការអភិវឌ្ឍ ដោយកំណត់ អំពី:**<br>- ដីឯកជន<br>- ដីរដ្ឋ<br>- ដីសមស្របសំរាប់សម្បទានសង្គមកិច្ច និងសម្បទានសេដ្ឋកិច្ច ។ | **ប្រការ ០៦** | |
| **ការចុះបញ្ជីដីបន្ត** (Subsequent land registration) | អភិបាលស្រុក ខណ្ឌ ឬមេឃុំ ចៅសង្កាត់ ជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗ ដូចជាលិខិតលក់ផ្តាច់ អំណោយផ្តាច់ កិច្ចសន្យាប្រចាំ ដាក់ធានា ហ៊ីប៉ូតែក កិច្ចសន្យារយៈពេលវែង កិច្ចសន្យាបង្កើតសេវភាព ផលុបភោគ អាស្រ័យលើការព្រមព្រៀងរបស់គូភាគី ។ ក្នុងការបញ្ជាក់ អភិបាលស្រុក ខណ្ឌ ឬមេឃុំ ចៅសង្កាត់ ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើៈ<br>- អត្តសញ្ញាណអចលនវត្ថុ ដែលជាកម្មវត្ថុនៃលិខិតកិច្ចសន្យា និង<br>- អត្តសញ្ញាណគូភាគីនៃកិច្ចសន្យា | **ប្រការ ០៩** | **ប្រកាសអន្តរក្រសួង** រវាងក្រសួងមហាផ្ទៃ និងដ.ន.ស អំពីភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ លើការងារចុះបញ្ជីដី ( ខែ កក្កដា **ឆ្នាំ ២០០៥**) |

| | | | |
|---|---|---|---|
| | មេឃុំ ចៅសង្កាត់ ត្រូវផ្សព្វផ្សាយអោយប្រជាពលរដ្ឋក្នុងរង្វង់ដែនដីរបស់ខ្លួនយល់ដឹង អំពីអានុភាពនៃការចុះបញ្ជីដី អំពីភាពចាំបាច់នៃការចូលរួមចុះបញ្ជី ដី និងអំពីផលវិបាកដែលកើតឡើងអំពីការមិនបានចុះបញ្ជី នូវរាល់ការប្រែប្រួលសិទ្ធិតាមរយៈការលក់ ទិញ ការអោយ ឬប្រទានកម្ម ការដូរ ការជំរះមរតក ការបង្កើតសិទ្ធិតាមរយៈការបញ្ចាំ ការដាក់ធានា ការដាក់ហ៊ីប៉ូតែក ការជួលរយៈពេលវែង ការបង្កើតសេវភាព និងការរលត់សិទ្ធិលើក្បាលដីតាមរយៈការលើកលែងបញ្ចាំ ការលើកលែងការដាក់ធានា ការលើកលែងហ៊ីប៉ូតែក ក៏ដូចជាការប្រែប្រួលលក្ខណៈរូបនៃក្បាលដីតាមរយៈការកែតម្រូវព្រំដី ការបំបែកក្បាលដី ឬការបង្រួមក្បាលដី ។ | **ប្រការ ១១** | |
| **ការផ្តល់ពត៌មានពាក់ព័ន្ធទៅនឹងការចុះបញ្ជីដី** (Information provision related to land registration) | បន្ទាប់ពីបញ្ជាក់លើលិខិតសញ្ញារួចហើយ បើលិខិតនោះបញ្ជាក់នៅឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ត្រូវយកលិខិតនោះទៅចុះក្នុងបញ្ជីមួយហៅថា សៀវភៅចុះលិខិតបញ្ជាក់។ ការចុះក្នុងសៀវភៅចុះលិខិតបញ្ជាក់ គឺត្រូវចុះលេខរៀង និងកាលបរិច្ឆេទនៃប្រតិបត្តិការ រួចស្រង់លេខរៀង និងថ្ងៃ ខែ ឆ្នាំ ដាក់ក្នុងលិខិតដើមគ្រប់លិខិតបញ្ជាក់ដែលត្រូវប្រគល់អោយទៅភាគីម្នាក់ៗ។ បន្ទាប់មកត្រូវចុះថ្ងៃ ខែ ឆ្នាំ នៃលិខិត ចុះឈ្មោះ ព្រមទាំងទីលំនៅនៃភាគី ចុះប្រភេទនៃលិខិត និងកម្មវត្ថុនៃលិខិត។ បើលិខិតនោះទាក់ទងនឹងអចលនវត្ថុ សេចក្តីនៃលិខិតត្រូវចំលងចូលដោយសង្ខេបដាក់ចូលក្នុងបញ្ជិការមួយទៀត ហៅថា បញ្ជិការនៃលិខិតបញ្ជាក់អចលនវត្ថុ សំរាប់ឃុំ សង្កាត់ នីមួយៗ ។ | **ប្រការ ១២** | **ប្រកាសអន្តរក្រសួង** រវាងក្រសួងមហាផ្ទៃ និងដ.ន.ស អំពីភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ លើការងារចុះបញ្ជីដី (ខែកក្កដា **ឆ្នាំ ២០០៥**) |
| | លិខិតបញ្ជាក់អចលនវត្ថុដោយអភិបាលស្រុក ខណ្ឌ ត្រូវបញ្ជូនទៅ មេឃុំ ចៅ | **ប្រការ ១៣** | |

សង្កាត់ អចលនវត្ថុនោះស្ថិតនៅ ដើម្បីមេឃុំ ចៅសង្កាត់ ចុះសេចក្ដីបញ្ជាក់ ក្នុងសៀវភៅចុះលិខិតបញ្ជាក់ ។ ទន្ទឹមនេះ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះសេចក្ដីនៃលិខិតបញ្ជាក់ចូលក្នុងបញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុបន្ថែមទៀត ។

បញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុត្រូវមាននៅក្នុងសាលាឃុំ សង្កាត់ សាលាក្រុង ស្រុក ខណ្ឌ និងនៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ។

**ប្រការ ១៤**

បញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុ ត្រូវប្រើប្រាស់សំរាប់ការផ្សព្វផ្សាយ បញ្ជាក់អចលនវត្ថុក្នុងឃុំ សង្កាត់នីមួយៗ ។ ចំពោះលិខិតបញ្ជាក់ដែលមេឃុំ ចៅសង្កាត់ ឬអភិបាលក្រុង ស្រុក ខណ្ឌជាអ្នកបញ្ជាក់ តែមិនបានចុះក្នុងបញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុ មេឃុំ ចៅសង្កាត់ ឬអភិបាលក្រុង ស្រុក ខណ្ឌនោះត្រូវទទួលខុសត្រូវចំពោះភាគី ឬតតិយជនដែលមានប្រយោជន៍ក្នុងរឿងនេះ ។

**ប្រការ ១៥**

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើច្បាប់ចំលងនៃសម្រង់ឯកសារសុរិយោដីដល់មេឃុំ ចៅសង្កាត់ដែលពាក់ព័ន្ធ ។ សម្រង់ឯកសារសុរិយោដីទាំងនោះត្រូវមាន :

១. ចំពោះតំបន់ដែលធ្វើការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ:
   - ប្លង់សុរិយោដី
   - បញ្ជីឈ្មោះកម្មសិទ្ធិករ
   - ពត៌មាន ពីការទប់ស្កាត់ផ្សេងៗ ប្រសិនបើមាន ។

២. ចំពោះតំបន់ដែលធ្វើការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ:

- បញ្ជីឈ្មោះម្ចាស់ដី ប្រសិនបើមាន
- ផែនទីក្បាលដី ប្រសិនបើមាន
- ពត៌មាន ពីការទប់ស្កាត់ផ្សេងៗ ប្រសិនបើមាន ។

**ប្រការ ១៦**

មេឃុំ ចៅសង្កាត់ត្រូវទទួលខុសត្រូវក្នុងការកាន់កាប់ច្បាប់ចំលងនៃសម្រង់សុរិយោដីដែលបានទទួល ហើយអាចធ្វើចរន្តការលើឯកសារនូវរាល់ការផ្លាស់ប្តូរប្រែប្រួលសិទ្ធិ ឬបន្ទុកផ្សេងៗលើក្បាលដីនីមួយៗ ដើម្បីជាការកត់សំគាល់របស់ខ្លួន និងជាមូលដ្ឋានបញ្ជាក់ទៅថ្ងៃក្រោយ ។

លើមូលដ្ឋាននៃសម្រង់សុរិយោដី មេឃុំ ចៅសង្កាត់ត្រូវអនុញ្ញាតអោយជនគ្រប់រូបពិគ្រោះយោបល់ ហើយត្រូវរាយការណ៍ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ នូវរាល់ការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃកម្មសិទ្ធិ និងកម្មសិទ្ធិករក្នុងមូលដ្ឋានរបស់ខ្លួន ។

**ប្រការ ១៧**

ក្នុងការចុះបញ្ជីដី រដ្ឋបាលឃុំ សង្កាត់ ត្រូវទទួលបាននូវកម្រៃតាមការកំណត់រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងទទួលបាននូវការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងសំភារៈផ្សេងៗទៀតដែលចាំបាច់ ។

**ប្រការ ១៨**

ក្នុងការអនុវត្តនីអំណាចប្រតិភូកម្មនេះ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសុរិយោដី ដែលមានសមត្ថកិច្ចទទួលខុសត្រូវទាំងស្រុងចំពោះដំណើរការនៃការចុះបញ្ជីដី។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញភារកិច្ចខាងលើនេះ អោយបានសមស្របតាមច្បាប់ភូមិបាលនិងលិខិតបទដ្ឋានពាក់ព័ន្ធនានា។

## ១.២. អនុក្រឹត្យស្តីពីនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់នៅក្នុងដីឃុំ សង្កាត់

បានទទួលការយល់ព្រមពីទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០០៩ និងបានដាក់ប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## នីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៥ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៩

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

**មាត្រា ២ ._**

អនុក្រឹត្យនេះមានគោលបំណង ៖

- ផ្ដល់សមត្ថកិច្ចឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំផែនការគ្រប់គ្រងនិងប្រើប្រាស់ធនធានដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព
- គាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយនិរន្តរភាព និងសមធម៌
- រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- ជួយឱ្យសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំ សង្កាត់ ស្របតាមស្ថានភាពដីជាក់ស្ដែង និងសក្ដានុពលធម្មជាតិនៃដី
- ឆ្លើយតបចំពោះសេចក្ដីត្រូវការដីរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់
- ជួយការពារធនធានដី និងធនធានធម្មជាតិផ្សេងៗទៀតមិនឱ្យបាត់បង់គុណភាព និងមិនឱ្យប្រើប្រាស់ខុសទិសដៅ
- រួមចំណែកក្នុងការកំណត់ និងគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ សង្កាត់ ឱ្យបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាងរដ្ឋរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ស្វែងរកការគាំទ្រផ្នែកបច្ចេកទេសពីស្ថាប័ន អង្គភាពនានា និងពីផ្នែកឯកជន ដើម្បីបំពេញបន្ថែមចំពោះការរៀបចំកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

**មាត្រា ៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ព្រមទាំងដីឯកជនរបស់បុគ្គលឯកជនដែលស្ថិតនៅក្នុងឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤ .-**

វាក្យសព្ទខាងក្រោមប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ÷

- **ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជនរបស់បុគ្គលឯកជន ។
- **ផែនការអភិវឌ្ឍឃុំ សង្កាត់** សំដៅដល់ផែនការអភិវឌ្ឍនានាដែលបានអនុម័តជាផ្លូវការរួចហើយសម្រាប់ ឃុំ សង្កាត់ទាំងមូល ដើម្បីឱ្យឃុំ សង្កាត់នោះមានការរីកចម្រើនជាទូទៅ ជាពិសេសផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នោះបានល្អប្រសើរជាលំដាប់ ។
- **កម្មវិធីវិនិយោគនៅឃុំ សង្កាត់** សំដៅដល់កម្មវិធីវិនិយោគសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំ ដែលជាឧបករណ៍ចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចបាននូវចក្ខុវិស័យ ទិសដៅ និងយុទ្ធសាស្ត្រនានាដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ ។
- **ផែនទីរដ្ឋបាលឃុំ សង្កាត់** សំដៅដល់ផែនទីរដ្ឋបាលដែលចេញផ្សាយដោយនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។
- **ផែនទីប្រើប្រាស់ដីឃុំសង្កាត់** សំដៅដល់ផែនទីដែលមានព័ត៌មានស្តីពីប្រភេទនៃការប្រើប្រាស់ដី គម្របដី ព្រំប្រទល់ និងទីតាំងរដ្ឋបាលឃុំសង្កាត់ដែលមានកន្លងមក ។

## ជំពូកទី២
## គោលការណ៍សម្រាប់រៀបចំផែនការ

**មាត្រា ៥ .-**

ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ÷

១. ត្រូវធ្វើតាមវិធីសាស្ត្រដែលមានលក្ខណៈចូលរួម ដោយឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធពីគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់នីមួយៗ ព្រមទាំងពីក្រុមសង្គមស៊ីវិលដែលមានការពាក់ព័ន្ធនឹងការងារដីធ្លី ។

២. ត្រូវស្របតាមគម្រោងផែនការអភិវឌ្ឍដែលមានជាផ្លូវការនៅថ្នាក់ឃុំ សង្កាត់ ដែលអាចជាប្រភេទនៃការអភិវឌ្ឍចម្រុះ ឬជាប្រភេទនៃការអភិវឌ្ឍផ្អែកតាមប្រភពធនធានជាក់លាក់នីមួយៗតាមទស្សនៈភូមិមួយផលិតផលមួយ ឬតាមលក្ខណៈពិសេសជាក់លាក់របស់តំបន់នីមួយៗ ។

៣. ត្រូវយកផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ។

៤. ត្រូវតែបើកចំហរាល់ព័ត៌មានទាំងអស់ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។

៥. ត្រូវផ្តល់អាទិភាពខ្ពស់ដល់តម្រូវការដីនៅមូលដ្ឋាន ឃុំ សង្កាត់សាមី នាពេលបច្ចុប្បន្ន និងទៅអនាគតសម្រាប់រយៈពេលពី ១០ (ដប់) ទៅ ១៥ (ដប់ប្រាំ) ឆ្នាំខាងមុខ សម្រាប់សេវា និងការប្រើប្រាស់ជាសាធារណៈសម្រាប់ការដោះស្រាយការតាំងទីលំនៅថ្មីដែលបណ្តាលមកពីគម្រោងអភិវឌ្ឍរបស់រដ្ឋ គម្រោងអភិវឌ្ឍរបស់មូលដ្ឋាន គ្រោះធម្មជាតិផ្សេងៗ ឬកំណើនប្រជាពលរដ្ឋ តាមរយៈការបម្រុងដីទុកសម្រាប់គោលដៅជាក់លាក់នីមួយៗស្របតាមបញ្ញត្តិច្បាប់ទាំងឡាយដូចជា ការផ្តល់ដីតាមរយៈសម្បទានដីសង្គមកិច្ចជាដើម ។

៦. ធ្វើផែនការប្រើប្រាស់ដីមិនមែនជាការផ្តល់ដីឬបែងចែកដីជាក់ស្តែងនោះទេ ។

## ជំពូកទី៣

## យន្តការ និងភារកិច្ច

**មាត្រា ៦ .-**

យន្តការសម្រាប់ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ មានដូចតទៅ ÷

១. ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការសិក្សា និងបង្ហាញអំពីសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន ផ្តល់ព័ត៌មានជាក់លាក់នានា រៀបចំកិច្ចពិភាក្សា ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ជាមួយប្រជាជនក្នុងភូមិ ដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីជាលក្ខណៈផែនការលំអិតនិងជាម្ចាស់នៃផែនការប្រើប្រាស់ដីឃុំ សង្កាត់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់តាំងជនបង្គោលមួយ ឬច្រើនរូបឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល និងធ្វើទំនាក់ទំនងជាប្រចាំជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ លើការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

២. ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពតាមការកំណត់ដោយមាត្រា ២៧ នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មានភារកិច្ចសំខាន់ក្នុងការសម្របសម្រួលផ្តល់ការគាំទ្រផ្នែកបច្ចេកទេសចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងជួយកៀរគរការគាំទ្រពីភាគីពាក់ព័ន្ធនានា ។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

ដើម្បីធ្វើការជាប្រចាំជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ។

៣. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តដែលមានសមាសភាពតាមការកំណត់ដោយមាត្រា ២៤ នៃអនុក្រឹត្យលេខ ១១៨ អនក្រ ប.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មានភារកិច្ចពិនិត្យឡើងវិញ ផ្តល់យោបល់កែសម្រួល សម្រេច និងត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

**មាត្រា ៧ .-**

ក្រុមប្រឹក្សាឃុំ សង្កាត់ មានភារកិច្ចដូចតទៅ ÷

- ស្រង់ និងផ្តល់ទិន្នន័យនៃការប្រើប្រាស់ដីជាក់ស្តែងកន្លងមក
- ធ្វើការសិក្សា និងបង្ហាញអំពីសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន និងពិចារណាអំពីការរៀបចំគម្រោងផែនការអភិវឌ្ឍឃុំ សង្កាត់ ព្រមទាំងកិច្ចសហការចាំបាច់ផ្សេងទៀតក្នុងដំណើរការរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ជូនដំណឹង និងបិទផ្សាយជាសាធារណៈនូវលទ្ធផលនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត បានផ្តល់យោបល់កែសម្រួលរួច
- ប្រមូល និងសង្ខេបមតិយោបល់សាធារណៈជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ក្រោយការបិទផ្សាយជាសាធារណៈ
- លើកសំណើសុំកែប្រែផែនការទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ
- តាមដាន និងវាយតម្លៃការអនុវត្តផែនការ និងធ្វើរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ មេឃុំ ចៅសង្កាត់មានភារកិច្ចដឹកនាំកិច្ចប្រជុំនានាពាក់ព័ន្ធដល់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងទទួលខុសត្រូវលើការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ដែលបានអនុម័តរួចហើយ ។

**មាត្រា ៨ .-**

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចតទៅ ÷

- ដឹកនាំការប្រជុំដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- រួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការវាយតម្លៃសេចក្តីត្រូវការដី ស្ថានភាពជាក់ស្តែងនៃដី និងសក្តានុពល ដីដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ

- រួមសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ លើកសំណើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដោយមានសេចក្តីអធិប្បាយអំពីសេចក្តីត្រូវការដីរបស់មូលដ្ឋាន ស្ថានភាពជាក់ស្តែងនៃដីនិងសក្តានុពលដី និងគម្រោងរៀបចំផែនការអភិវឌ្ឍផ្សេងៗទៅអនាគតរបស់ឃុំ សង្កាត់
- ជួយធ្វើការកែតម្រូវគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ តាមការសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត
- ជំរុញការអនុវត្តផែនការប្រើប្រាស់ដី ដែលបានសម្រេចជាផ្លូវការ និងជួយរៀបចំរបាយការណ៍បូកសរុបប្រចាំឆមាស និងឆ្នាំ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អំពីការអនុវត្តផែនការប្រើប្រាស់ដី ជាពិសេសដីដែលបានផ្តល់ ឬចែកឱ្យបុគ្គលឯកជន សមូហភាព ឬអង្គភាពរដ្ឋនានា នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងដីដែលនៅសល់ក្នុងផែនការមិនទាន់បានបែងចែក ព្រមទាំងដីដែលស្ថិតនៅក្រោមការគ្រប់គ្រងកាន់កាប់របស់អាជ្ញាធរកាន់កាប់ដីរដ្ឋដែលមានក្នុងឃុំ សង្កាត់នោះ
- ដោះស្រាយទំនាស់ពាក់ព័ន្ធនឹងការប្រើប្រាស់ដីរវាងឃុំ សង្កាត់ និងឃុំ សង្កាត់
- ចាត់តាំងបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។ សមាសភាពក្រុមនេះអាចមានពី ៣ (បី)ទៅ ៥ (ប្រាំ) នាក់ ដែលជាមន្ត្រីបច្ចេកទេសពីការិយាល័យជំនាញជុំវិញក្រុង ស្រុក ខណ្ឌ។

**មាត្រា ៩ ._**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានភារកិច្ចដូចតទៅ ÷

- ដឹកនាំពិគ្រោះយោបល់សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ផ្តល់យោបល់ដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកែសម្រួលផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដោយពិចារណាជាមួយប្លង់មេ ផែនការអភិវឌ្ឍផ្សេងៗ និងការកំណត់តំបន់ប្រើប្រាស់ដីទាំងឡាយដែលបានសម្រេចជាផ្លូវការរួចហើយ
- សម្រេច និងត្រួតពិនិត្យលើការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ចាត់តាំងបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ដែលសមាសភាពក្រុមនេះអាចមានពីបី (៣) ទៅប្រាំ (៥) នាក់ ជាមន្ត្រីបច្ចេកទេសពីមន្ទីរជំនាញជុំវិញរាជធានី ខេត្ត ហើយមានភារកិច្ចសំខាន់ ជួយសម្របសម្រួលការងារអង្គភាពពាក់ព័ន្ធនៅជុំវិញរាជធានី ខេត្ត និងធ្វើជាគ្រូបណ្តុះបណ្តាលការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

- បូកសរុប និងលើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៤
## នីតិវិធីនៃការរៀបចំផែនការ

**មាត្រា ១០ .-**

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវអនុវត្តដូចខាងក្រោម ÷

១. ក្រុមប្រឹក្សាឃុំ សង្កាត់ លើកសំណើសុំគោលការណ៍រៀបចំផែនការប្រើប្រាស់ដីទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណើសុំរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវធ្វើការសម្រេច និងឆ្លើយតបក្នុងរយៈពេលមិនលើសពី ២១ (ម្ភៃមួយ) ថ្ងៃ។

២. បន្ទាប់ពីមានការយល់ព្រមពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំសំណើថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណើថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃយ៉ាងយូរ ដើម្បីឱ្យគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត រៀបចំថវិកាស្របតាមបញ្ញត្តិដែលមានចែងក្នុងមាត្រា ១៩ នៃអនុក្រឹត្យនេះ។

៣. ក្រោយពីទទួលបានការឯកភាពថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមានការគាំទ្រពីដៃគូអភិវឌ្ឍ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងដោយមេឃុំ ចៅសង្កាត់ និងសមាជិកម្នាក់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលបន្ទុកការងារដី ត្រូវប្រជុំដើម្បីរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ អង្គប្រជុំត្រូវចាត់តាំងក្រុមការងារសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមានមេឃុំឬចៅសង្កាត់សាមី ចុះស្រង់ព័ត៌មានពី

ស្ថានភាពជាក់ស្តែងនៃការប្រើប្រាស់ដីកន្លងមក ហើយគូសលើផែនទីរដ្ឋបាល និង/ឬ ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ប្រសិនបើមាន។

៤. ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំលើកទី ២ ដើម្បីពិចារណាអំពី :

- ការរៀបចំផែនការប្រើប្រាស់ដី ដោយប្រើប្រាស់ផែនទីដែលមានទិន្នន័យ ឬព័ត៌មានពីស្ថានភាពប្រើប្រាស់ដីជាក់ស្តែងដែលមានកន្លងមក
- ផែនការមេ ឬផែនការអភិវឌ្ឍឃុំ សង្កាត់ ឬផែនការអភិវឌ្ឍរបស់រដ្ឋផ្សេងទៀតដែលបានអនុម័តជាផ្លូវការរួចហើយ ឬមិនទាន់អនុម័ត ប្រសិនបើមាន
- ការគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ សង្កាត់នោះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព
- សេចក្តីត្រូវការដីរបស់ស្ថាប័ន អាជ្ញាធរផ្សេងៗ និងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់។

៥. ពេលបានសម្រេចធ្វើផែនការនេះរួចហើយ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសេចក្តីព្រាងផែនការនេះទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីពិនិត្យ និងកែសម្រួល។

៦. ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃ តាមទីកន្លែងជាក់ស្តែងនូវផែនការដែលបានពិនិត្យ និងកែសម្រួលរួចហើយដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនឯកភាពនឹងទិន្នន័យដែលបានបិទផ្សាយជាសាធារណៈមានសិទ្ធិតវ៉ាទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

៧. ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រមូលសរុបមតិសាធារណៈ ពិនិត្យ និងលើកអនុសាសន៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យសម្រេចចុងក្រោយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។

៨. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ប្រជុំលើកទីពីរដើម្បីពិនិត្យមតិយោបល់សាធារណៈ និងអនុសាសន៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អាចចាត់បញ្ជូនក្រុមស៊ើបអង្កេតមួយទៅពិនិត្យ និងស្រង់យកព័ត៌មានបន្ថែមទៀតប្រសិនបើយល់ឃើញថាជាការចាំបាច់។ ក្រុមស៊ើបអង្កេតអាចប្រើពេលវេលាមិនឱ្យហួសពី ៣០ (សាមសិប) ថ្ងៃទេ។

៩. ការសម្រេចលើផែនការប្រើប្រាស់ដី ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃអង្គប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដែលមានសមាជិកចូលរួមប្រជុំយ៉ាងតិច ២/៣

(ពីរភាគបី) នៃសមាជិកទាំងអស់។ ក្រោយពីគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវបានសម្រេចរួចហើយ លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវចម្លងឯកសារអំពីផែនការប្រើប្រាស់ដីនេះជូនគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឃុំ សង្កាត់សាមី។

១០. ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំការប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដី និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ជារៀងរាល់ឆមាស និងប្រចាំឆ្នាំ។

**មាត្រា ១១ ._**

ការរៀបចំ និងការអនុវត្តផែនការប្រើប្រាស់ដីលំអិតនៅក្នុងឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងផែនការ។

**មាត្រា ១២ ._**

ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើការផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យនេះឱ្យបានទូលំទូលាយដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលជាអ្នកអនុវត្តផ្ទាល់។

## ជំពូកទី៥
## ការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

**មាត្រា ១៣ ._**

ដើម្បីធានាប្រសិទ្ធភាពនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តតាមផែនការដែលបានសម្រេចជាផ្លូវការរួចហើយ តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយពីក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវដំណើរការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ដែលបានសម្រេចរួចហើយ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយតម្លាភាព។

**មាត្រា ១៤ ._**

ដីដែលមានចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ មួយចំណែកអាចត្រូវបានផ្តល់ ឬបែងចែកឱ្យអង្គភាពរដ្ឋ ឬរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ស្របតាមផែនការប្រើប្រាស់ដីនោះ និងមួយចំណែក

ទៀតអាចផ្តល់ជាសម្បទានដីសង្គមកិច្ច ដោះស្រាយការតាំងទីលំនៅថ្មី ជាសម្បទានដីសេដ្ឋកិច្ច អាចលក់ ដូរ ជួល ឬអាចអនុញ្ញាតឱ្យប្រើប្រាស់រយៈពេលខ្លី ឬក៏សម្រាប់គម្រោងវិនិយោគផ្សេងៗរបស់រដ្ឋ និងរបស់មូលដ្ឋានដោយត្រូវគោរពតាមនីតិវិធីច្បាប់ជាធរមាន។

ចំណែកដីដែលមានចំណាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ដីនោះត្រូវរក្សាទុកសម្រាប់បម្រើសេវាសាធារណៈ ឬសម្រាប់គ្រប់គ្រង និងប្រើប្រាស់ប្រកបដោយសមធម៌ និងនិរន្តរភាព។

## មាត្រា ១៥ .-

ការអនុញ្ញាតឱ្យប្រើប្រាស់ដីរយៈពេលខ្លីគឺមិនលើសពី ០១ (មួយ) ឆ្នាំអាចបន្តជាថ្មីបានតែម្តងគត់ ហើយអាចដកហូតវិញបានគ្រប់ពេលវេលា។ ការអនុញ្ញាតនេះសម្រាប់ជូនប្រជាពលរដ្ឋក្រីក្រនៅមូលដ្ឋានឃុំ សង្កាត់ ដែលត្រូវការដីចាំបាច់ ឬខ្វះដីសម្រាប់ធ្វើជម្រកស្នាក់នៅបណ្តោះអាសន្ន ឬធ្វើកសិកម្មចិញ្ចឹមជីវិតជាបណ្តោះអាសន្ន ក្នុងពេលរង់ចាំការបែងចែកដីក្នុងក្របខណ្ឌសម្បទានដីសង្គមកិច្ច ឬការតាំងទីលំនៅថ្មី។

ការអនុញ្ញាតនេះត្រូវមានការចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរច្បាស់លាស់ជាមួយមេឃុំ ចៅសង្កាត់។ ប្រជាពលរដ្ឋក្រីក្រដែលត្រូវការដី ឬខ្វះដី ត្រូវដាក់សំណើសុំការអនុញ្ញាតប្រើប្រាស់ដីរយៈពេលខ្លីជាបណ្តោះអាសន្ន តាមរយៈមេភូមិទៅមេឃុំ ចៅសង្កាត់ ដោយមានបញ្ជាក់ទីតាំងដី និងគោលបំណងប្រើប្រាស់ដីជាក់លាក់។ កិច្ចសន្យាដែលមានកំណត់លក្ខខណ្ឌនៃការអនុញ្ញាតឱ្យប្រើប្រាស់ដីនោះ ត្រូវទុកជាឯកសារសាធារណៈនៅសាលាឃុំ សង្កាត់ និងត្រូវចម្លងជូនក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការអនុញ្ញាតឱ្យប្រើប្រាស់ដីរបស់រដ្ឋ ឬការការពារជនប្រើប្រាស់ដីរបស់រដ្ឋដោយគ្មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរត្រឹមត្រូវ ឬដោយបំពានសិទ្ធិអំណាចរបស់អាជ្ញាធរ ត្រូវបានហាមឃាត់។

## មាត្រា ១៦ .-

ការប្រើប្រាស់ដីដែលមិនស្របតាមផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវដកហូតយកមកវិញ ឬត្រូវបញ្ឈប់ការប្រើប្រាស់ចំពោះដីរដ្ឋ ឬត្រូវបញ្ឈប់ការប្រើប្រាស់ដីជាបណ្តោះអាសន្នចំពោះដីឯកជនរបស់បុគ្គលឯកជន ក្នុងរយៈពេលពីរខែយ៉ាងយូរ។ ការដកហូត ឬការបញ្ឈប់ការប្រើប្រាស់ដី ត្រូវសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមសំណើរបស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ លើកលែងតែគម្រោងថ្នាក់ជាតិដែលត្រូវសម្រេចដកហូត ឬបញ្ឈប់ការប្រើប្រាស់ដីដោយថ្នាក់ជាតិ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ឱ្យបានជាប់ជាប្រចាំ។

រូបវន្តបុគ្គល ឬនីតិបុគ្គលមានសិទ្ធិប្តឹងតវ៉ាអំពីការសម្រេចបញ្ឈប់ការប្រើប្រាស់ដីឯកជនដែលសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ទៅស្ថាប័នមានសមត្ថកិច្ច ឬទៅតុលាការ។

**មាត្រា ១៧ .-**

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវកត់ត្រាអំពីការកំណត់ និងការសម្រេចលើរបៀបប្រើប្រាស់ ឬការបែងចែកដីដែលបានធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច តាមនីតិវិធីជាធរមានចំពោះក្បាលដីនីមួយៗ របស់រដ្ឋ។

## ជំពូកទី៦
## ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

**មាត្រា ១៨ .-**

ក្រោយពីទទួលបានការឯកភាពពីក្រុមប្រឹក្សាឃុំសង្កាត់ និង/ឬក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ អាចស្នើទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីកែប្រែផែនការប្រើប្រាស់ដីនៅក្នុង ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវសេចក្ដីពន្យល់ពីមូលហេតុផ្សេងៗក្នុងការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈចូលរួម ដូច ដំណើរការធ្វើផែនការប្រើប្រាស់ដីពីដំបូងដែរ។

ក្នុងករណីចាំបាច់ដែលមានការតម្រូវពីរាជរដ្ឋាភិបាល ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ មិនចាំបាច់គោរពតាមនីតិវិធីទូទៅឡើយ។ ការសម្រេចលើការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់នេះ ត្រូវជូនដំណឹងដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងភាគីពាក់ព័ន្ធ យ៉ាងតិច ៣០ (សាមសិប) ថ្ងៃជាមុន។

ក្រោយពីផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវបានកែប្រែរួចហើយ លេខាធិការដ្ឋាននៃគណៈកម្មាធិការ គ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវចម្លងឯកសារកែសម្រួលនេះជូនគ្រប់ស្ថាប័នពាក់ព័ន្ធ និងឃុំ សង្កាត់សាមី ដើម្បីអនុវត្ត។

## ជំពូកទី៧
## ថវិកាចំណាយសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

**មាត្រា ១៩ .-**

ថវិកាសម្រាប់ការងាររៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ បានមកពី :

- ថវិកាជាតិ ។
- បរិវច្ចាប្បទានបានមកពីក្នុងនិងក្រៅប្រទេស ឬពីដៃគូអភិវឌ្ឍ ។

នីតិវិធីនៃការស្នើសុំ និងប្រើប្រាស់ថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា ២០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី និងអភិបាលខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា ២១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ ២ : ឃុំ សង្កាត់ដែលបានអនុវត្តការចូលរួមរៀបចំផែនការប្រើប្រាស់ដី (PLUP)

| ខេត្ត ក្រុង | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | ភូមិ |
|---|---|---|---|
| ១- ក្រុង កែប | ដំណាក់ចង្អើរ | អង្កោល | |
| ២- ក្រុង ព្រះសីហនុ | ព្រៃនប់ | អូរជ្រៅ | |
| | | បិតត្រាំង | |
| | | សំរោង | |
| | ស្ទឹងហាវ | អូរ ត្រេស | |
| | | ទំនប់រលក | |
| ៣- ខេត្ត កោះកុង | កោះកុង | ត្រពាំងរូង | |
| | បុទមសាគរ | កណ្តោល | |
| | ស្មាច់មានជ័យ | ស្ទឹងវែង | |
| ៤- ខេត្ត ពោធិសាត់ | ក្រគរ | អូរសណ្តាន់ | |
| | | ស្នាអន្សា | |
| | បាកាន | បឹងបាត់កណ្តោល | |
| | ភ្នំក្រវាញ | សំរោង | |
| ៥- ខេត្ត សៀមរាប | ប្រាសាទបាគង | បល័ង្គ | |
| | សូទ្រនិគម | ខ្នារពោធិ៍ | |
| | | ព្រៃនប់ | |
| | អង្គរជុំ | គោក ដូង | |
| ៦- ខេត្ត ក្រចេះ | ព្រែកប្រសប់ | ព្រែកប្រសប់ | |
| | ស្នួល | ឃ្សឹម | |
| | ឆ្លូង | កញ្ជោរ | |

បណ្តាឃុំ សង្កាត់ទាំងនេះមានផែនការប្រើប្រាស់ដីដោយមានការចូលរួមចំពោះភូមិមួយចំនួន (ត្រូវបានរៀបចំក្នុងអំឡុងពេលនៃការអនុវត្តគំរោង CCB-NREM/DANIDA ឆ្នាំ២០០៤-២០០៦)។ សូមសាកសួរមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីថតចំលងផែនការទាំងនេះ ហើយសួរបន្ថែមទៀត ថាតើនៅមានភូមិ ឃុំ សង្កាត់ ណាផ្សេងទៀតក្នុងខេត្តដែលបានបញ្ចប់ផែនការបែបនេះ។

# ឧបសម្ព័ន្ធ ៣: ទិដ្ឋភាពរួមនៃឃុំ សង្កាត់ដែលមានការវិភាគក្បេរត្រួបរិស្ថាន

កិច្ចសន្យានៃការងារ វិភាគប្រព័ន្ធក្បេត្រ-បរិស្ថានឃុំ សង្កាត់ ( មន្ទីរកសិកម្មខេត្ត) - កែសំរួល ០២-០៤-០៨

| លេខ | ចុះកិច្ចសន្យា | លេខ កិច្ចសន្យា | ខេត្ត ក្រុង | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | កូដ ឃុំ សង្កាត់ |
|---|---|---|---|---|---|---|
| | | | កំពង់ចាម | | ១៦ | |
| 1 | 24-06-04 | KCM_AEA_02 | | ចំការលើ | តាអុង | 30207 |
| 2 | 24-06-04 | KCM_AEA_01 | | អូររាំងឪ | មៀន | 31105 |
| 3 | 09-08-04 | KCM_AEA_03 | | ពញាក្រែក | វាលមូ | 31209 |
| 4 | 09-08-04 | KCM_AEA_04 | | បាធាយ | សំបូរ | 30107 |
| 5 | 21-12-04 | KCM_AEA_05 | | ត្បូងឃ្មុំ | ថ្មពេជ្រ | 31621 |
| 6 | 21-12-04 | KCM_AEA_06 | | ស្ទឹងត្រង់ | មេសរជ្រៃ | 31505 |
| 7 | 20-01-05 | KCM_AEA_07 | | ស្រីសន្ធរ | ទងត្រឡាច | 31414 |
| 8 | 20-01-05 | KCM_AEA_08 | | អូររាំងឪ | ដីវល | 31103 |
| 9 | 14-06-05 | KCM_AEA_09 | | ស្រីសន្ធរ | ព្រែកដំបូក | 31408 |
| 10 | 14-06-05 | KCM_AEA_10 | | ត្បូងឃ្មុំ | ពាមជីលាំង | 31615 |
| 11 | 08-05-05 | KCM_AEA_11 | | ចំការលើ | ស្វាយទាប | 30206 |
| 12 | 08-05-05 | KCM_AEA_12 | | បាធាយ | សណ្តែក | 30108 |
| 13 | 02-02-06 | KCM_AEA_13 | | ពញាក្រែក | កណ្តោលជ្រុំ | 31204 |
| 14 | 02-02-06 | KCM_AEA_14 | | អូររាំងឪ | គងជ័យ | 31104 |
| 15 | 07-10-06 | KCM_AEA_15 | | ត្បូងឃ្មុំ | ដីគរ | 31604 |
| 16 | 28-09-06 | KCM_AEA_16 | | មេមត់ | ជាំក្រវៀន | 31003 |
| | | | តាកែវ | | ៤៥ | |
| 17 | 14-06-04 | TKE_AEA_05 | | ទ្រាំង | ស្រង៉ែ | 211012 |
| 18 | 14-06-04 | TKE_AEA_02 | | សំរោង | ទ្រា | 210711 |
| 19 | 14-06-04 | TKE_AEA_01 | | ត្រាំកក់ | ត្រពាំងធំខាងជើង | 210914 |
| 20 | 07-03-04 | TKE_AEA_04 | | ព្រៃកប្បាស | ចំប៉ា | 210603 |
| 21 | 07-03-04 | TKE_AEA_03 | | សំរោង | រវៀង | 210707 |
| 22 | 08-01-04 | TKE_AEA_06 | | ត្រាំកក់ | ត្រាំកក់ | 210913 |
| 23 | 24-08-04 | TKE_AEA_07 | | បាទី | លំពង់ | 210208 |
| 24 | 24-08-04 | TKE_AEA_08 | | ទ្រាំង | អង្គកែវ | 211006 |
| 25 | 11-06-04 | TKE_AEA_09 | | ត្រាំកក់ | ឧត្តមសុរិយា | 210908 |
| 26 | 11-08-04 | TKE_AEA_10 | | បាទី | ចំបក់ | 210201 |
| 27 | 08-11-04 | TKE_AEA_11 | | សំរោង | បឹងត្រាញ់ខាងត្បូង | 210702 |
| 28 | 20-12-04 | TKE_AEA_12 | | ទ្រាំង | ព្រៃស្លឹក | 211007 |
| 29 | 20-12-04 | TKE_AEA_13 | | ព្រៃកប្បាស | ព្រៃកប្បាស | 210609 |
| 30 | 20-12-04 | TKE_AEA_14 | | កោះអណ្តែត | ធ្លាប្រជុំ | 210506 |
| 31 | 02-07-05 | TKE_AEA_15 | | ត្រាំកក់ | គុស | 210903 |
| 32 | 02-07-05 | TKE_AEA_16 | | សំរោង | ជើងគួន | 210703 |
| 33 | 02-07-05 | TKE_AEA_17 | | បាទី | ពត់សរ | 210210 |
| 34 | 02-07-05 | TKE_AEA_18 | | អង្គរបុរី | ពន្លៃ | 210104 |
| 35 | 02-07-05 | TKE_AEA_19 | | ត្រាំកក់ | សំរោង | 210910 |
| 36 | 04-07-05 | TKE_AEA_20 | | ទ្រាំង | អង្គខ្នុរ | 211002 |
| 37 | 04-07-05 | TKE_AEA_21 | | អង្គរបុរី | ព្រៃផ្គាំ | 210106 |
| 38 | 04-07-05 | TKE_AEA_22 | | ព្រៃកប្បាស | ព្រៃផ្តៅ | 210611 |

| លេខ | ចុះកិច្ចសន្យា | លេខ កិច្ចសន្យា | ខេត្ត ក្រុង | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | កូដ ឃុំ សង្កាត់ |
|---|---|---|---|---|---|---|
| 39 | 04-07-05 | TKE_AEA_23 | | សំរោង | ជំរះពេន | 210704 |
| 40 | 04-07-05 | TKE_AEA_24 | | បាទី | ក្រាំងលាវ | 210206 |
| 41 | 06-07-05 | TKE_AEA_25 | | បាទី | ដូង | 210203 |
| 42 | 06-07-05 | TKE_AEA_26 | | សំរោង | លំចង់ | 210706 |
| 43 | 06-07-05 | TKE_AEA_27 | | ត្រាំកក់ | ជាងទង | 210902 |
| 44 | 16-06-05 | TKE_AEA_28 | | កោះអណ្តែត | រមេញ | 210505 |
| 45 | 16-06-05 | TKE_AEA_29 | | ទ្រាំង | រនាម | 211008 |
| 46 | 08-07-05 | TKE_AEA_30 | | ព្រៃកប្បាស | ព្រៃល្វា | 210610 |
| 47 | 15-07-05 | TKE_AEA_31 | | ព្រៃកប្បាស | ចារ | 210604 |
| 48 | 15-07-05 | TKE_AEA_32 | | កោះអណ្តែត | ព្រៃខ្លា | 210503 |
| 49 | 15-07-05 | TKE_AEA_33 | | បាទី | ចំប៉ី | 210202 |
| 50 | 14-08-05 | TKE_AEA_34 | | អង្គរបុរី | អង្គរបុរី | 210101 |
| 51 | 14-08-05 | TKE_AEA_35 | | ព្រៃកប្បាស | កំពែង | 210605 |
| 52 | 14-08-05 | TKE_AEA_36 | | កោះអណ្តែត | ពេជសារ | 210502 |
| 53 | 09-07-05 | TKE_AEA_37 | | សំរោង | ខ្វាវ | 210705 |
| 54 | 09-07-05 | TKE_AEA_39 | | ទ្រាំង | ជីខ្មារ | 211003 |
| 55 | 09-07-05 | TKE_AEA_40 | | បាទី | ពារាម | 210209 |
| 56 | 24-02-06 | TKE_AEA_38 | | ត្រាំកក់ | ពពេល | 210909 |
| 57 | 05-05-06 | TKE_AEA_41 | | បាទី | កុមាររាជា | 210205 |
| 58 | 23-06-06 | TKE_AEA_42 | | គីរីវង់ | អង្គប្រាសាទ | 210401 |
| 59 | 08-04-06 | TKE_AEA_43 | | ដូនកែវ | បារាយណ៍ | 210801 |
| 60 | 30-10-06 | TKE-ISAEA-44 | | បូរីជលសារ | ដូងខ្ពស់ | 210303 |
| 61 | 04-12-06 | TKE-ISAEA-01 | | សំរោង | សឹង្ហ | 210709 |
| | | | កំពង់ស្ពឺ | | ២០ | |
| 62 | 15-06-04 | KSP_AEA_05 | | សំរោងទង | កាហែង | 50702 |
| 63 | 07-01-04 | KSP_AEA_06 | | គងពិសី | រកាកោះ | 50308 |
| 64 | 07-01-04 | KSP_AEA_04 | | សំរោងទង | ក្រាំងអំពិល | 50704 |
| 65 | 07-01-04 | KSP_AEA_03 | | ភ្នំស្រួច | គីរីវ័ណ្ណ | 50604 |
| 66 | 07-01-04 | KSP_AEA_02 | | សំរោងទង | រលាំងចក | 50701 |
| 67 | 07-01-04 | KSP_AEA_01 | | គងពិសី | វាល | 50313 |
| 68 | 17-03-05 | KSP_AEA_10 | | ភ្នំស្រួច | អូរ | 50607 |
| 69 | 12-01-04 | KSP_AEA_08 | | សំរោងទង | ត្រពាំងគង | 50713 |
| 70 | 04-05-05 | KSP_AEA_12 | | គងពិសី | ពេជ្រមុនី | 50304 |
| 71 | 12-01-04 | KSP_AEA_07 | | គងពិសី | ព្រះនិពាន | 50305 |
| 72 | 22-02-05 | KSP_AEA_09 | | សំរោងទង | សែនដី | 50709 |
| 73 | 17-03-05 | KSP_AEA_11 | | គងពិសី | ព្រៃញាតិ | 50306 |
| 74 | 27-06-05 | KSP_AEA_13 | | សំរោងទង | សំបូរ | 50708 |
| 75 | 27-06-05 | KSP_AEA_14 | | ភ្នំស្រួច | ព្រៃក្មេង | 50609 |
| 76 | 06-07-05 | KSP_AEA_15 | | គងពិសី | ជង្រុក | 50302 |
| 77 | 23-09-05 | KSP_AEA_16 | | ភ្នំស្រួច | ព្រៃរំដួល | 50608 |
| 78 | 02-01-06 | KSP_AEA_17 | | សំរោងទង | ទំព័រមាស | 50714 |
| 79 | 26-04-06 | KSP_AEA_18 | | គងពិសី | ស្តុក | 50309 |
| 80 | 10-07-06 | KSP_AEA_19 | | ភ្នំស្រួច | មហាសាំង | 50606 |
| 81 | 19-09-06 | KSP_AEA_20 | | គងពិសី | ស្នំក្រពើ | 50310 |
| | | | ស្វាយរៀង | | ២៥ | |

| លេខ | ចុះកិច្ចសន្យា | លេខ កិច្ចសន្យា | ខេត្ត ក្រុង | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | កូដ ឃុំ សង្កាត់ |
|---|---|---|---|---|---|---|
| 82 | 19-08-04 | SVR_AEA_07 | | ចន្ទ្រា | ច្រេស | 200104 |
| 83 | 14-12-04 | SVR_AEA_16 | | ចន្ទ្រា | ជាទី | 200101 |
| 84 | 14-12-04 | SVR_AEA_17 | | រមាសហែក | អង្គប្រស្រែ | 200404 |
| 85 | 19-08-04 | SVR_AEA_09 | | ស្វាយទៀប | ប្រសូត្រ | 200707 |
| 86 | 19-08-04 | SVR_AEA_08 | | រំដួល | ស្វាយចេក | 200309 |
| 87 | 19-08-04 | SVR_AEA_10 | | ស្វាយជ្រំ | គោកព្រីង | 200509 |
| 88 | 19-08-04 | SVR_AEA_06 | | រមាសហែក | មុខដា | 200411 |
| 89 | 02-06-04 | SVR_AEA_04 | | ស្វាយទៀប | ស្វាយរំពា | 200711 |
| 90 | 02-06-04 | SVR_AEA_05 | | ស្វាយជ្រំ | តាសួស | 200505 |
| 91 | 02-06-04 | SVR_AEA_02 | | ចន្ទ្រា | ចន្ទ្រា | 200103 |
| 92 | 02-06-04 | SVR_AEA_03 | | រំដួល | ថ្នាធ្នង់ | 200310 |
| 93 | 02-06-04 | SVR_AEA_01 | | រមាសហែក | ដូង | 200407 |
| 94 | 14-03-05 | SVR_AEA_15 | | រមាសហែក | កំពង់ត្រាច | 200408 |
| 95 | 14-03-05 | SVR_AEA_13 | | រំដួល | បុសមន | 200301 |
| 96 | 19-04-05 | SVR_AEA_14 | | រំដួល | កំពង់អំពិល | 200305 |
| 97 | 19-04-05 | SVR_AEA_18 | | ស្វាយទៀប | គគីរសោម | 200702 |
| 98 | 20-05-05 | SVR_AEA_12 | | ស្វាយជ្រំ | ពោធិរាជ | 200512 |
| 99 | 20-05-05 | SVR_AEA_11 | | ស្វាយជ្រំ | ចំបក់ | 200503 |
| 100 | 04-08-05 | SVR_AEA_19 | | ស្វាយជ្រំ | ចំលង | 200504 |
| 101 | 04-08-05 | SVR_AEA_20 | | រំដួល | ធ្នា | 200302 |
| 102 | 10-07-05 | SVR_AEA_21 | | ស្វាយជ្រំ | អង្គតាសូ | 200501 |
| 103 | 12-08-05 | SVR_AEA_22 | | រំដួល | មឺនជ័យ | 200306 |
| 104 | 31-03-06 | SVR_AEA_23 | | កំពង់រោទិ៍ | សំយ៉ោង | 200208 |
| 105 | 17-07-06 | SVR_AEA_24 | | ចន្ទ្រា | ទួលស្ដី | 200109 |
| 106 | 19-09-06 | SVR_AEA_25 | | កំពង់រោទិ៍ | ក្សេត្រ | 200203 |
| 107 | 20-11-06 | SVR_AEA_26 | | ស្វាយទៀប | សំបួរ | 200709 |
| | | | ព្រៃវែង | | ៣២ | |
| 108 | 21-06-04 | PRV_AEA_01 | | ពារាំង | ព្រៃស្រឡិត | 140809 |
| 109 | 02-07-04 | PRV_AEA_02 | | ស៊ីធរកណ្ដាល | អំពិលក្រៅ | 141201 |
| 110 | 22-11-04 | PRV_AEA_12 | | ស៊ីធរកណ្ដាល | ឬស្សីសាញ់ | 141211 |
| 111 | 02-07-04 | PRV_AEA_04 | | បាភ្នំ | ស្ដី ខ | 140108 |
| 112 | 22-11-04 | PRV_AEA_14 | | បាភ្នំ | ធាយ | 140109 |
| 113 | 02-07-04 | PRV_AEA_03 | | កញ្ជ្រៀច | គោកគង់កើត | 140404 |
| 114 | 17-08-04 | PRV_AEA_10 | | កញ្ជ្រៀច | ចុងអំពិល | 140401 |
| 115 | 22-11-04 | PRV_AEA_11 | | កញ្ជ្រៀច | ក្ងៀងរាយ | 140403 |
| 116 | 02-07-04 | PRV_AEA_05 | | មេសាង | ត្រពាំងស្រែ | 140508 |
| 117 | 02-07-04 | PRV_AEA_06 | | កំពង់ត្របែក | ព្រៃឈរ | 140311 |
| 118 | 22-11-04 | PRV_AEA_15 | | កំពង់ត្របែក | ប្រធាតុ | 140310 |
| 119 | 02-07-04 | PRV_AEA_07 | | បាភ្នំ | បឹងព្រះ | 140101 |
| 120 | 02-07-04 | PRV_AEA_08 | | ពារាំង | ព្រៃស្នៀត | 140808 |
| 121 | 02-07-04 | PRV_AEA_09 | | ពារាំង | រកា | 140811 |
| 122 | 08-02-05 | PRV_AEA_16 | | ព្រៃវែង | ពានរោង | 141006 |
| 123 | 22-11-04 | PRV_AEA_13 | | កំចាយមារ | ដូនកឹង | 140202 |
| 124 | 08-02-05 | PRV_AEA_17 | | មេសាង | អង្គរសរ | 140501 |
| 125 | 22-02-05 | PRV_AEA_18 | | កញ្ជ្រៀច | ព្រាល | 140406 |

| លេខ | ចុះកិច្ចសន្យា | លេខ កិច្ចសន្យា | ខេត្ត ក្រុង | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | កូដ ឃុំ សង្កាត់ |
|---|---|---|---|---|---|---|
| 126 | 22-02-05 | PRV_AEA_19 | | ស៊ីធរកណ្ដាល | ពោធិ៍ទី | 141206 |
| 127 | 04-05-05 | PRV_AEA_20 | | កំពង់ត្របែក | ចាម | 140302 |
| 128 | 04-05-05 | PRV_AEA_21 | | មេសាង | ស្វាយជ្រំ | 140507 |
| 129 | 04-05-05 | PRV_AEA_23 | | ពាមរាំង | ព្រៃខ្លៅ | 140807 |
| 130 | 07-11-05 | PRV_AEA_22 | | កញ្ជ្រៀច | កញ្ជ្រៀច | 140402 |
| 131 | 07-11-05 | PRV_AEA_24 | | កំចាយមារ | ត្របែក | 140208 |
| 132 | 07-11-05 | PRV_AEA_25 | | ស៊ីធរកណ្ដាល | ព្រៅទី ១ | 141204 |
| 133 | 09-09-05 | PRV_AEA_26 | | មេសាង | ព្រៃឃ្នេស | 140504 |
| 134 | 09-07-05 | PRV_AEA_27 | | ព្រៃវែង | សំរោង | 141009 |
| 135 | 09-07-05 | PRV_AEA_28 | | ពាមរាំង | កញ្ចំ | 140802 |
| 136 | 12-08-05 | PRV_AEA_31 | | កំចាយមារ | ស្មោងជើង | 140206 |
| 137 | 02-06-06 | PRV_AEA_29 | | កំចាយមារ | ក្រញូង | 140203 |
| 138 | 05-05-06 | PRV_AEA_30 | | ព្រះស្ដេច | ព្រះស្ដេច | 140908 |
| 139 | 23-06-06 | PRV_AEA_32 | | ព្រៃវែង | ដីរិទ្ធន | 141004 |
| | | | **កំពង់ឆ្នាំង** | | ១៥ | |
| 140 | 07-07-04 | KCN_AEA_02 | | ទឹកផុស | ចោងម៉ោង | 40803 |
| 141 | 07-07-04 | KCN_AEA_01 | | កំពង់ត្រឡាច | ពានី | 40507 |
| 142 | 07-07-04 | KCN_AEA_03 | | កំពង់ត្រឡាច | ច្រេស | 40503 |
| 143 | 07-07-04 | KCN_AEA_04 | | ទឹកផុស | ខ្លុងពពក | 40805 |
| 144 | 22-02-05 | KCN_AEA_05 | | បរិបូរ | ពេជចង្វារ | 40108 |
| 145 | 22-02-05 | KCN_AEA_06 | | កំពង់ត្រឡាច | លង្វែក | 40505 |
| 146 | 30-05-05 | KCN_AEA_07 | | ទឹកផុស | ក្បាលទឹក | 40804 |
| 147 | 15-07-05 | KCN_AEA_08 | | បរិបូរ | ផ្សារ | 40107 |
| 148 | 21-07-05 | KCN_AEA_09 | | បរិបូរ | កំពង់ព្រះគគីរ | 40105 |
| 149 | 08-04-05 | KCN_AEA_10 | | កំពង់ត្រឡាច | ឈូកស | 40502 |
| 150 | 12-08-05 | KCN_AEA_11 | | ទឹកផុស | ក្រាំងស្គារ | 40806 |
| 151 | 31-03-06 | KCN_AEA_12 | | សាមគ្គីមានជ័យ | ឈានឡើង | 40701 |
| 152 | 10-07-06 | KCN_AEA_13 | | កំពង់លែង | ពោធិ៍ | 40405 |
| 153 | 29-08-06 | KCN_AEA_14 | | កំពង់លែង | ដារ | 40402 |
| 154 | 24-11-06 | KCN_AEA_15 | | រលាប្អៀរ | ព្រៃមូល | 40609 |
| | | | **កណ្ដាល** | | ២៤ | |
| 155 | 07-07-04 | KDL_AEA_02 | | កណ្ដាលស្ទឹង | ព្រែករកា | 80115 |
| 156 | 07-07-04 | KDL_AEA_01 | | អង្គស្នួល | ម្កាក់ | 80809 |
| 157 | 17-08-04 | KDL_AEA_03 | | ស្អាង | ក្រាំងយ៉ូវ | 81005 |
| 158 | 27-08-04 | KDL_AEA_04 | | កៀនស្វាយ | សំរោងធំ | 80211 |
| 159 | 20-09-04 | KDL_AEA_05 | | ពញាឮ | ទំនប់ធំ | 80913 |
| 160 | 16-09-04 | KDL_AEA_06 | | ខ្សាច់កណ្ដាល | ជ័យធំ | 80302 |
| 161 | 21-12-04 | KDL_AEA_07 | | មុខកំពូល | រកាកោង ២ | 80708 |
| 162 | 21-12-04 | KDL_AEA_08 | | ពញាឮ | កំពង់អុស | 80904 |
| 163 | 14-02-05 | KDL_AEA_09 | | កៀនស្វាយ | ឈើទាល | 80202 |
| 164 | 14-02-05 | KDL_AEA_10 | | អង្គស្នួល | ព្រៃពួច | 80813 |
| 165 | 30-03-05 | KDL_AEA_11 | | កណ្ដាលស្ទឹង | អន្លង់រមៀត | 80102 |
| 166 | 30-03-05 | KDL_AEA_12 | | ស្អាង | ព្រែកគយ | 81008 |
| 167 | 30-05-05 | KDL_AEA_13 | | ខ្សាច់កណ្ដាល | ស៊ីធរ | 80314 |
| 168 | 30-05-05 | KDL_AEA_14 | | មុខកំពូល | សំបួរមាស | 80710 |

| លេខ | ចុះកិច្ចសន្យា | លេខ កិច្ចសន្យា | ខេត្ត ក្រុង | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | កូដ ឃុំ សង្កាត់ |
|---|---|---|---|---|---|---|
| 169 | 12-07-05 | KDL_AEA_15 | | អង្គស្នួល | ទួលព្រេច | 80816 |
| 170 | 12-07-05 | KDL_AEA_16 | | កៀនស្វាយ | កំពង់ស្វាយ | 80204 |
| 171 | 04-08-05 | KDL_AEA_17 | | ស្អាង | ស្វាយប្រទាល | 81012 |
| 172 | 05-08-05 | KDL_AEA_18 | | ពញាឮ | ផ្សារដែក | 80911 |
| 173 | 01-09-05 | KDL_AEA_19 | | លើកដែក | កំពង់ភ្នំ | 80501 |
| 174 | 01-09-05 | KDL_AEA_20 | | កោះធំ | កោះធំ "ខ" | 80405 |
| 175 | 09-03-06 | KDL_AEA_22 | | កណ្ដាលស្ទឹង | រកា | 80117 |
| 176 | 22-05-06 | KDL_AEA_23 | | ល្វាឯម | ទឹកឃ្លាំង | 80615 |
| 177 | 02-07-06 | KDL-AEA_24 | | កោះធំ | ព្រែកស្ដី | 80410 |
| 178 | 29-08-06 | KDL_AEA_25 | | ល្វាឯម | សំបួរ | 80612 |
| | | | **កំពត** | | **២២** | |
| 179 | 12-07-04 | KPT_AEA_02 | | កំពត | កូនសត្វ | 70708 |
| 180 | 02-09-04 | KPT_AEA_04 | | កំពត | កណ្ដោល | 70705 |
| 181 | 12-07-04 | KPT_AEA_01 | | ដងទង់ | ដងទង់ | 70502 |
| 182 | 12-08-04 | KPT_AEA_03 | | ឈូក | សត្វពង | 70312 |
| 183 | 8/11/2004 | KPT_AEA_05 | | ជុំគីរី | ជំពូវ័ន្ត | 70402 |
| 184 | 08-11-04 | KPT_AEA_06 | | កំពង់ត្រាច | កន្ធោរខាងជើង | 70607 |
| 185 | 31-01-05 | KPT_AEA_07 | | បន្ទាយមាស | សំរោងលើ | 70205 |
| 186 | 31-01-05 | KPT_AEA_08 | | អង្គរជ័យ | សំឡាញ់ | 70110 |
| 187 | 30-03-05 | KPT_AEA_09 | | ដងទង់ | អង្គរមាស | 70509 |
| 188 | 30-03-05 | KPT_AEA_10 | | កំពង់ត្រាច | កំពង់ត្រាចខាងកើត | 70605 |
| 189 | 30-03-05 | KPT_AEA_11 | | កំពត | ព្រៃថ្នង | 70713 |
| 190 | 06-07-05 | KPT_AEA_12 | | ជុំគីរី | ច្រេស | 70401 |
| 191 | 06-07-05 | KPT_AEA_13 | | ឈូក | ត្រមែង | 70314 |
| 192 | 07-06-05 | KPT_AEA_14 | | ឈូក | បឹងនិមល | 70303 |
| 193 | 08-04-05 | KPT_AEA_15 | | អង្គរជ័យ | អង្គភ្នំតូច | 70101 |
| 194 | 08-04-05 | KPT_AEA_16 | | បន្ទាយមាស | ស្ដេចគង់ខាងលិច | 70207 |
| 195 | 09-07-05 | KPT_AEA_17 | | កំពង់បាយ | ត្រើយកោះ | 70805 |
| 196 | 09-07-05 | KPT_AEA_18 | | ឈូក | ល្បើក | 70308 |
| 197 | 20-10-05 | KPT_AEA_19 | | កំពង់ត្រាច | ដំណាក់កន្ទួតខាងត្បូង | 70604 |
| 198 | 12-08-05 | KPT_AEA_20 | | ដងទង់ | ល្បាង | 70510 |
| 199 | 03-09-06 | KPT_AEA_21 | | ឈូក | បានៀវ | 70301 |
| 200 | 23-06-06 | KPT_AEA_22 | | កំពង់ត្រាច | ឫស្សីស្រុកខាងកើត | 70613 |
| | | | **កំពង់ធំ** | | **១៦** | |
| 201 | 16-07-04 | KTM_AEA_01 | | បារាយណ៍ | ចុងដូង | 60108 |
| 202 | 16-07-04 | KTM_AEA_02 | | ស្ទឹងសែន | ត្បូងក្រពើ | 60311 |
| 203 | 16-07-04 | KTM_AEA_03 | | កំពង់ស្វាយ | កំពង់ស្វាយ | 60204 |
| 204 | 16-01-04 | KTM_AEA_04 | | បារាយណ៍ | ឈូកខ្សាច់ | 60107 |
| 205 | 17-01-04 | KTM_AEA_05 | | សន្ទុក | កកោះ | 60704 |
| 206 | 31-01-05 | KTM_AEA_06 | | កំពង់ស្វាយ | ត្បែង | 60208 |
| 207 | 02-11-05 | KTM_AEA_07 | | ស្ទោង | រុងរឿង | 60811 |
| 208 | 02-11-05 | KTM_AEA_08 | | ប្រាសាទសំបូរ | គោល | 60502 |
| 209 | 18-05-05 | KTM_AEA_09 | | ស្ទឹងសែន | ក្ដីដូង | 60305 |
| 210 | 18-05-05 | KTM_AEA_10 | | ប្រាសាទបល្ល័ង្ក | ទួលគ្រើល | 60407 |
| 211 | 08-04-05 | KTM_AEA_11 | | សណ្ដាន់ | ដងកាំបិត | 60602 |

| លេខ | ចុះកិច្ចសន្យា | លេខ កិច្ចសន្យា | ខេត្ត ក្រុង | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | កូដ ឃុំ សង្កាត់ |
|---|---|---|---|---|---|---|
| 212 | 12-08-05 | KTM_AEA_12 | | សន្ទុក | ប្រាសាទ | 60707 |
| 213 | 31-03-06 | KTM_AEA_13 | | សណ្ដាន់ | ងន | 60606 |
| 214 | 08-04-06 | KTM_AEA_14 | | បារាយណ៍ | ចើងដើង | 60105 |
| 215 | 29-08-06 | KTM_AEA_15 | | ស្ទោង | ប្រឡាយ | 60809 |
| 216 | 23-11-06 | KTM-AEA-16 | | ប្រាសាទសំបូរ | សំបូរ | 60503 |
| | | | ពោធិសាត់ | | ១៨ | |
| 217 | 03-08-04 | PST_AEA_01 | | កណ្ដៀង | កញ្ជរ | 150204 |
| 218 | 3/8/2004 | PST_AEA_02 | | ភ្នំក្រវាញ | ព្រងិល | 150404 |
| 219 | 25-10-04 | PST_AEA_03 | | ភ្នំក្រវាញ | ផ្ទះរុង | 150403 |
| 220 | 25-10-04 | PST_AEA_04 | | ក្រគរ | កំពង់ពោធិ៍ | 150306 |
| 221 | 12-01-04 | PST_AEA_05 | | កណ្ដៀង | ស្រែស្ដុក | 150206 |
| 222 | 12-01-04 | PST_AEA_06 | | ក្រគរ | អូរសណ្ដាន់ | 150308 |
| 223 | 21-12-04 | PST_AEA_07 | | សំពៅមាស | ស្វាយអាត់ | 150507 |
| 224 | 26-01-05 | PST_AEA_08 | | បាកាន | ស្នាមព្រះ | 150107 |
| 225 | 04-11-05 | PST_AEA_09 | | ភ្នំក្រវាញ | សំរោទ្រ | 150406 |
| 226 | 4/11/2005 | PST_AEA_10 | | ក្រគរ | ស្នាអន្សា | 150309 |
| 227 | 07-06-05 | PST_AEA_11 | | កណ្ដៀង | អន្លង់វិល | 150201 |
| 228 | 07-06-05 | PST_AEA_12 | | បាកាន | បឹងខ្នារ | 150102 |
| 229 | 09-02-05 | PST_AEA_13 | | បាកាន | តាលោ | 150109 |
| 230 | 09-02-05 | PST_AEA_14 | | សំពៅមាស | កោះជុំ | 150502 |
| 231 | 24-02-06 | PST_AEA_15 | | ភ្នំក្រវាញ | បាក់ចិញ្ចៀន | 150401 |
| 232 | 23-06-06 | PST_AEA_16 | | សំពៅមាស | រលាប | 150506 |
| 233 | 08-04-06 | PST_AEA_17 | | កណ្ដៀង | កណ្ដៀង | 150203 |
| 234 | 29-09-06 | PST_ISAEA_18 | | ក្រគរ | ឈើតុំ | 150304 |
| | | | បន្ទាយមានជ័យ | | ១៦ | |
| 235 | 27-07-04 | BMC_AEA_01 | | ស្វាយចេក | រលួស | 10808 |
| 236 | 27-07-04 | BMC_AEA_02 | | ថ្មពួក | បន្ទាយឆ្មារ | 10701 |
| 237 | 27-07-04 | BMC_AEA_03 | | ថ្មពួក | គោកកឋិន | 10705 |
| 238 | 27-07-04 | BMC_AEA_04 | | អូរជ្រៅ | សឹង្ហ | 10507 |
| 239 | 18-02-05 | BMC_AEA_05 | | ម៉ាឡៃ | បឹងបេង | 10901 |
| 240 | 18-02-05 | BMC_AEA_06 | | អូរជ្រៅ | កូប | 10502 |
| 241 | 18-02-05 | BMC_AEA_07 | | មង្គលបុរី | គោកបល្ល័ង្គ | 10204 |
| 242 | 05-05-05 | BMC_AEA_08 | | មង្គលបុរី | សឿ | 10211 |
| 243 | 16-06-05 | BMC_AEA_09 | | ថ្មពួក | គោករមៀត | 10702 |
| 244 | 14-07-05 | BMC_AEA_10 | | ម៉ាឡៃ | តាគង់ | 10906 |
| 245 | 14-07-05 | BMC_AEA_11 | | ភ្នំស្រុក | ប៉ោយចារ | 10302 |
| 246 | 09-01-05 | BMC_AEA_12 | | ព្រះនេត្រព្រះ | ទានកាំ | 10407 |
| 247 | 12-08-05 | BMC_AEA_13 | | ស្វាយចេក | ស្លាក្រាម | 10803 |
| 248 | 03-09-06 | BMC_AEA_14 | | អូរជ្រៅ | គុត្តសត | 10503 |
| 249 | 20-04-06 | BMC_AEA_15 | | ភ្នំស្រុក | ពន្លៃ | 10303 |
| 250 | 29-08-06 | BMC_ISAEA_16 | | សិរីសោភ័ណ | ម្កាក់ | 10604 |
| | | | សៀមរាប | | ១០ | |
| 251 | 05-08-04 | SRP_AEA_01 | | ប្រាសាទបាគង | ត្រពាំងធំ | 170909 |
| 252 | 05-08-04 | SRP_AEA_02 | | បន្ទាយស្រី | ខ្នារសណ្ដាយ | 170301 |
| 253 | 05-08-04 | SRP_AEA_03 | | អង្គរធំ | ស្វាយចេក | 170204 |

| លេខ | ចុះកិច្ចសន្យា | លេខ កិច្ចសន្យា | ខេត្ត ក្រុង | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | កូដ ឃុំ សង្កាត់ |
|---|---|---|---|---|---|---|
| 254 | 21-12-04 | SRP_AEA_04 | | ជីក្រែង | ខ្វាវ | 170404 |
| 255 | 18-03-05 | SRP_AEA_05 | | ជីក្រែង | ឬស្សីលក | 170410 |
| 256 | 07-06-05 | SRP_AEA_06 | | សូទ្រនិគម | កៀនសង្កែ | 171105 |
| 257 | 08-04-05 | SRP_AEA_07 | | សូទ្រនិគម | ចាន់សរ | 171101 |
| 258 | 12-08-05 | SRP_AEA_08 | | ពួក | ក្ដីរុន | 170703 |
| 259 | 29-08-06 | SRP_AEA_09 | | ក្រឡាញ់ | រោងគោ | 170605 |
| 260 | 23-11-06 | SRP_AEA_10 | | ក្រឡាញ់ | សែនសុខ | 170607 |
| | | | **បាត់ដំបង** | | ១៨ | |
| 261 | 02-08-04 | BTB_AEA_01 | | មោងឫស្សី | ព្រៃតូច | 20610 |
| 262 | 02-08-04 | BTB_AEA_02 | | គាស់ក្រឡ | ដូនបា | 21304 |
| 263 | 02-08-04 | BTB_AEA_03 | | គាស់ក្រឡ | ហប់ | 21303 |
| 264 | 02-08-04 | BTB_AEA_04 | | គាស់ក្រឡ | ព្រះផុស | 21304 |
| 265 | 14-12-04 | BTB_AEA_05 | | បវេល | ក្ដុលតាហែន | 20406 |
| 266 | 02-08-05 | BTB_AEA_06 | | មោងឫស្សី | របស់មង្គល | 20609 |
| 267 | 18-02-05 | BTB_AEA_07 | | សំឡូត | តាសាញ | 20907 |
| 268 | 18-02-05 | BTB_AEA_08 | | សំឡូត | ស៊ុង | 20904 |
| 269 | 18-02-05 | BTB_AEA_09 | | កំរៀង | កំរៀង | 21201 |
| 270 | 18-05-05 | BTB_AEA_10 | | មោងឫស្សី | ព្រៃត្រឡាច | 20612 |
| 271 | 18-05-05 | BTB_AEA_11 | | បវេល | អំពិលប្រាំដើម | 20405 |
| 272 | 06-07-05 | BTB_AEA_12 | | កំរៀង | តាសែន | 21205 |
| 273 | 06-07-05 | BTB_AEA_13 | | កំរៀង | តាក្រី | 21206 |
| 274 | 08-04-05 | BTB_AEA_14 | | បវេល | ព្រៃខ្ពស់ | 20404 |
| 275 | 10-04-05 | BTB_AEA_17 | | រតនៈមណ្ឌល | ផ្លូវមាស | 20703 |
| 276 | 12-08-05 | BTB_AEA_18 | | សំពៅលូន | សេរីមានជ័យ | 21005 |
| 277 | 02-01-06 | BTB_AEA_19 | | មោងឫស្សី | តាលាស់ | 20606 |
| 278 | 03-09-06 | BTB_AEA_16 | | គាស់ក្រឡ | ឆ្នាល់មាន់ | 21301 |
| | | | **ប៉ៃលិន** | | ៨ | |
| 279 | 25-08-04 | PLN_AEA_01 | | សាលាក្រៅ | ស្ទឹងត្រង់ | 240202 |
| 280 | 25-08-04 | PLN_AEA_02 | | សាលាក្រៅ | សាលាក្រៅ | 240201 |
| 281 | 17-12-04 | PLN_AEA_03 | | ប៉ៃលិន | អូរតាវៅ | 240102 |
| 282 | 17-12-04 | PLN_AEA_04 | | ប៉ៃលិន | ទួលល្វា | 240103 |
| 283 | 07-06-05 | PLN_AEA_05 | | សាលាក្រៅ | ស្ទឹងកាច់ | 240203 |
| 284 | 07-06-05 | PLN_AEA_06 | | ប៉ៃលិន | ប៉ៃលិន | 240101 |
| 285 | 12-08-05 | PLN_AEA_07 | | ប៉ៃលិន | បរយ៉ាខា | 240104 |
| 286 | 23-06-06 | PLN_AEA_08 | | សាលាក្រៅ | អូរអណ្ដូង | 240204 |
| | | | **ឧត្តរមានជ័យ** | | ២ | |
| 287 | 05-02-06 | OMC_EAE_01 | | សំរោង | បុស្សស្បូវ | 220402 |
| 288 | 28-09-06 | OMC_EAE_02 | | បន្ទាយអំពិល | គោកខ្ពស់ | 220204 |
| | | | **ក្រចេះ** | | ២ | |
| 289 | 05-05-06 | KRT_AEA_01 | | ក្រចេះ | សំបុក | 100212 |
| 290 | 29-08-06 | KRT_AEA_02 | | ស្នួល | ស្វាយជ្រះ | 100505 |
| | | | **ព្រះវិហារ** | | ២ | |
| 291 | 22-05-06 | PVH_AEA_01 | | ត្បែងមានជ័យ | ឈានមុខ | 130703 |
| 291 | 29-08-06 | PVH_AEA_02 | | គូលែន | ថ្មី | 130403 |

## ឧបសម្ព័ន្ធ ៤ : ការពិពណ៌នាអំពីការប្រើប្រាស់ដី/គំរបដី (ផែនទីមាត្រដ្ឋាន)

ផែនទីនេះ គឺជាផែនទីមាត្រដ្ឋាន ដែលបង្ហាញធនធានសំខាន់ៗ និងប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ផែនទីនេះមិនមែនជាផែនទីផ្លូវការនោះទេ គឺជាផែនទីការងារមួយ ដើម្បីអោយក្រុមប្រឹក្សាឃុំ សង្កាត់ ប្រើប្រាស់ក្នុងអំឡុងពេលនៃការរៀបចំផែនការ។ គោលបំណងសំខាន់នៃផែនទីនេះ គឺដើម្បីជួយក្រុមប្រឹក្សាឃុំ សង្កាត់ (និងអ្នកផ្សេងៗទៀតក្នុងសហគមន៍) បានបីយ៉ាង ៖

- ស្វែងយល់ និងវិភាគ អំពីស្ថានភាពធនធានធម្មជាតិ និងការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
- ជួយកំណត់សកម្មភាព ដើម្បីលើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិ រួមទាំងការរៀបចំផែនការប្រើប្រាស់ដី។
- ប្រើជាផែនទីមូលដ្ឋាន (ផែនទីគោល) ដើម្បីបន្ថែមពតិមានអំពីបញ្ហា និងសកម្មភាពនៅក្នុងឃុំ សង្កាត់ នៅពីលើផែនទីនេះ ។

### ៤.១. ពត៌មានមួយចំនួនអាចជួយអ្នកអោយយល់ដឹងអំពីផែនទី

មាត្រដ្ឋាន : នៅលើផែនទីមាត្រដ្ឋានយើងអាចមាន ÷

- វាស់ចំងាយរវាងទីតាំងពីរផ្សេងគ្នា (ឧទាហរណ៍: រវាងភូមិ ០២ ផ្សេងគ្នា)។
- វាស់ប្រវែងផ្លូវ និងស្ទឹង។
- វាស់ក្រឡាផ្ទៃ (ឧទាហរណ៍: ក្រឡាផ្ទៃសហគមន៍នេសាទ)។
- ប្រៀបធៀបទំហំរវាងតំបន់ពីរផ្សេងគ្នា (ឧទាហរណ៍: ផ្ទៃដីព្រៃឈើ និងផ្ទៃដីស្រែ)។
- ប្រសិនបើយើងមានផែនទីពីរ ផលិតក្នុងឆ្នាំពីរផ្សេងគ្នា គឺចាស់មួយ និងថ្មីមួយ អាចរកបំរែបំរួលបាន (ឧទាហរណ៍: តើដីព្រៃក្នុងឆ្នាំ២០០០ និង២០០៥មានប៉ុន្មាន)។ ពេលនោះយើងអាចទស្សន៍ទាយថា តើនឹងមានអ្វីកើតឡើងនាពេលអនាគត ប្រសិនបើបំរែបំរួលនៅតែបន្តបែបនេះ ។

### ៤.២. ព្រំប្រទល់ឃុំ សង្កាត់ :

ព្រំប្រទល់ឃុំ សង្កាត់ដែលបានបង្ហាញនៅលើផែនទី គឺជាព្រំប្រទល់ផ្លូវការ ដែលទទួលបានពីថ្នាក់ជាតិ ។ ប៉ុន្តែព្រំប្រទល់ជាក់ស្តែងនៅមូលដ្ឋានអាចមានភាពខុសគ្នាដោយហេតុថា ៖

- នៅពេលខ្លះអាចមានការឯកភាពគ្នារវាងឃុំ សង្កាត់ និងអាជ្ញាធរក្រុង ស្រុក ខណ្ឌ ដើម្បីរំកិលព្រំប្រទល់ឃុំ សង្កាត់ផ្លូវការដែលផ្តល់ដោយថ្នាក់ជាតិ។

- ជួនកាលខ្សែបន្ទាត់ព្រំប្រទល់ឃុំ សង្កាត់ មិនសូវមានភាពសុក្រិត្យប៉ុន្មានទេ និងមានការប្រែប្រួលបន្តិចបន្តួច ដែលទាមទារនូវការកែសំរួល ។

## ៤.៣. ការប្រើប្រាស់ដី និងធនធានធម្មជាតិ

ទិន្នន័យអំពីការប្រើប្រាស់ដី និងធនធានធម្មជាតិក៏ទទួលបានពីថ្នាក់ជាតិដែរ។ មន្ត្រីរដ្ឋបាលព្រៃឈើ នាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណៈការនិងដឹកជញ្ជូន បានកសាងទិន្នន័យទាំងនេះ ដោយប្រើរូបថតពីលើអាកាស រូបភាពពីផ្កាយរណបនៅឆ្នាំ១៩៩៧ និងឆ្នាំ២០០២។ យោងតាមទិន្នន័យនេះ ការប្រើប្រាស់ដី និងធនធានធម្មជាតិមាន ៦៧ចំណាត់ថ្នាក់ ដែលក្នុងនោះចំណាត់ថ្នាក់សំខាន់ៗ/ចំណាត់ថ្នាក់សាមញ្ញមាន :

- ដីព្រៃ ( បង្ហាញប្រភេទព្រៃឈើ)
- ព្រៃគុម្ពោធ និងវាលស្មៅ
- ដីកសិកម្ម ( រួមទាំងដីស្រែ និងចំការដំណាំ)
- ដីលំនៅដ្ឋាន
- ផ្ទៃទឹក ( បឹងបួ និងផ្លូវទឹក)

ជួនកាលអ្នកអាចសង្កេតឃើញទិន្នន័យមិនត្រឹមត្រូវមួយចំនួននៅលើផែនទី ដែលអាចបណ្តាលមកពីមូលហេតុសំខាន់ៗពីរយ៉ាង :

- នៅពេលផលិតផែនទី អ្នកជំនាញមើលតែលើរូបថតពីលើអាកាស និងរូបភាពពីផ្កាយរណប ហើយមិនអាចចុះអង្កេតដល់ឃុំ សង្កាត់ និងដល់ទីវាល ។
- ការប្រើបាស់ដីមានការផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងរយៈពេល ០៥ឆ្នាំចុងក្រោយ (ឧទាហរណ៍: ការរានព្រៃសំរាប់ធ្វើស្រែ និងការពង្រីកដីភូមិជាដើម ) ។

មានឃុំ សង្កាត់មួយចំនួននៅក្នុងខេត្តចំនួន ១០នៃប្រទេសកម្ពុជាធ្លាប់បានធ្វើការជាមួយក្រុមការងារ GIS នៃសមាសភាគរៀបចំដែនដី/គំរោងគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ឃុំ សង្កាត់ ដើម្បីរៀបចំផែនទីខាងលើអោយមានភាពកាន់តែសុក្រិត្យ។ ចំពោះឃុំ សង្កាត់ផ្សេងៗទៀត ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខ័ណ្ឌ (D-LUP)នឹងជួយគាំទ្រដល់អ្នកសម្របសម្រួលក្រុង ស្រុក ខណ្ឌ (DFT) ដើម្បីរៀបចំផែនទីដូចគ្នានេះដែរក្នុងអំឡុង ពេលនៃដំណើរការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីនេះ ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី និងក្រុមពត៌មានភូមិសាស្ត្រ (D-LUP/GIS) ត្រូវចំណាយពេលពី ០៣-០៤ថ្ងៃ ធ្វើការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ។

## ៤.៤. ទិន្នន័យផ្សេងៗទៀត

ផែនទីប្រើប្រាស់ដី និងធនធានធម្មជាតិបង្ហាញនូវព័ត៌មានជាច្រើនទៀត អំពីឃុំ សង្កាត់នីមួយៗ ដែលក្នុង នោះមាន ៖

- បណ្តាញផ្លូវថ្នល់
- បណ្តាញធនធានទឹក (ទន្លេ ស្ទឹង ព្រែក និងបឹងបួ)
- បណ្តាញផ្លូវរថភ្លើង
- ទីតាំងសាលាឃុំ សង្កាត់
- ទីតាំងភូមិ
- មណ្ឌលសុខភាព
- ទីតាំងសាលារៀន
- ទីតាំងវត្តព្រះពុទ្ធសាសនា និងសាសនាផ្សេងៗទៀត
- តំបន់ការពារ
- តំបន់សម្បទាន (បើអាចមាន)
- សហគមន៍ព្រៃឈើ (បើអាចមាន)
- សហគមន៍នេសាទ (បើអាចមាន)

នៅលើទិន្នន័យអំពីការប្រើប្រាស់ដី និងធនធានធម្មជាតិ មានទិន្នន័យមួយចំនួនដែលមិនត្រឹមត្រូវ។ ទិន្នន័យទាំងនោះរួមមាន ៖

- ផ្លូវថ្មីៗមិនត្រូវបានបង្ហាញ ឬផ្លូវដែលបានធ្វើបច្ចុប្បន្នភាពហើយនៅបង្ហាញជាលក្ខណៈដាច់ៗនៅឡើយ
- ប្រឡាយតូចៗមិនត្រូវបានបង្ហាញឡើយ
- ស្ទឹងអាចស្ថិតនៅខុសទីតាំង
- អាគារថ្មីៗ (ទីតាំងសាលារៀនថ្មីៗ) អាចមិនត្រូវបានបង្ហាញ

ក្រុមប្រឹក្សាឃុំ សង្កាត់អាចគូសបញ្ចូលនូវពត៌មានថ្មីៗនៅលើផែនទីនេះបាន។ ពត៌មានទាំងអស់នឹងត្រូវបញ្ចូលទៅលើផែនទីអោយមានមាត្រដ្ឋាននៅពេលក្រោយ។

# ៤.៥. កំណត់សំគាល់ និងរូបថតនៃការប្រើប្រាស់ដី

| Code | ខ្មែរ | English | Photo | Code | ខ្មែរ | English | Photo |
|---|---|---|---|---|---|---|---|
| 1100 | ដីលំនៅដ្ឋាន ទីប្រជុំជន | Urban settlement |  | 1200 | ដីភូមិ | Village Settlement |  |
| 1210 | ភូមិបណ្ដែត ទឹក | Floating Village |  | 1300 | ផ្លូវក្រាលកៅ ស៊ូ | Infrastructure |  |
| 1310 | អាកាសយាន ដ្ឋាន | Airfield |  | 1320 | កន្លែងកប់ ខ្មោច | Cemetery |  |
| 2110 | ដីស្រែវស្សា | Wet season rice |  | 2111 | ដីភូមិលាយ វាលស្រែ | Rice with villages |  |
| 2112 | ដីស្រែនៅក្នុង បឹង/ស្ទឹង | Rice in lake or stream |  | 2113 | ដីស្រែគ្មានជី ជាតិ | Rice with poor soil |  |

# កំណត់សំគាល់ និងរូបថតនៃការប្រើប្រាស់ដី (ត.១)

**2120**

ដីស្រែឡើងទឹក

Flooded Rice



**2121**

ដីស្រែប្រដេញទឹក

Receding Rice



**2122**

ដីស្រែឡើងទឹក/ស្រូវព្រួស

Direct seeding (flooded) rice



**2140**

ដីស្រែលើ/ស្រូវព្រួស

Direct seeding (upland) rice



**2130**

ដីស្រែប្រាំង

Dry season (irrigated) rice



**2150**

ដីស្រែប្រាំង និង ស្រែវស្សា

Dry and wet season rice



**2200**

ដីចំការ

Cropland



**2210**

ដីចំការស្រោចស្រព

Irrigated Cropland



**2310**

ចំការឈើហូបផ្លែ

Orchard



**2311**

ចំការឈើហូបផ្លែក្នុងភូមិ

Fruit trees on old village land



## កំណត់សំគាល់ និងរូបថតនៃការប្រើប្រាស់ដី (ត-២)

| Code | Symbol | Khmer | English | Photo |
|---|---|---|---|---|
| 2321 |  | ចំការកៅស៊ូ | Rubber Plantation |  |
| 2322 |  | ចំការកាហ្វេ | Coffee Plantation |  |
| 2323 |  | ចំការស្វាយចន្ទី | Cashew Plantation |  |
| 2324 |  | ព្រៃដាំ | Timber/forest Plantation |  |
| 2325 | | ចំការដូង | Coconut Plantation |  |
| 2400 |  | ចំការពនេចរ | Swidden |  |
| 2410 | | ចំការពនេ្ទចរទុកអោយនៅទំនេរ | Fallow swidden |  |
| 3110 |  | ព្រៃស្រោង (សើម) | Moist Evergreen broad leaf forest (SW) |  |
| 3120 |  | ព្រៃស្រោង (ស្ងួត) | Dry Evergreen broad leafed forest (NE) |  |
| 3130 |  | ព្រៃស្រល់ | Coniferous forest |  |

## កំណត់សំគាល់ និងរូបថតនៃការប្រើប្រាស់ដី (ត-៣)

| | | | |
|---|---|---|---|
| 3210<br>ព្រៃរល្បោះ<br>Deciduous forest |  | 3220<br>ព្រៃរល្បោះស្ដើង (ស្ងួត)<br>Dry Deciduous (open) forest |  |
| 3300<br>ព្រៃពាក់កណ្ដាលស្រោង<br>Mixed forest (evergreen and deciduous) |  | 3310<br>ព្រៃតាមដងស្ទឹង<br>Riparian forest |  |
| 3400<br>ព្រៃដុះឡើងវិញ<br>Secondary forest |  | 3410<br>ព្រៃឫស្សី<br>Bamboo forest |  |
| 3500<br>ព្រៃលិចទឹក<br>Flooded forest |  | 3510<br>ព្រៃលិចទឹក (ក្រាស់)<br>Flooded forest (Dense) |  |
| 3600<br>ព្រៃកោងកាង<br>Mangrove forest |  | 3610<br>ព្រៃកោងកាង (ស្ដើង)<br>Rear mangrove forest |  |

# កំណត់សំគាល់ និងរូបថតនៃការប្រើប្រាស់ដី (ត-៤)

**3800**

ព្រៃជាមួយដីកសិកម្ម

Forest with patches of agriculture



**3810**

ព្រៃជាមួយដីស្រែ

Forest with patches of rice field



**3820**

ព្រៃជាមួយចំការ

Forest with patches of field crops



**4100**

ដីវាលស្មៅ

Grassland



**4110**

ដីវាលបោះបង់

Abandoned field covered by grass



**4120**

វាលស្មៅសំរាប់ចំណីសត្វ

Grazing area in grassland



**4200**

វាលស្មៅលិចទឹក

Flooded grass



**4500**

ព្រៃគុម្ពោធ

Shrubland



**4510**

វាលស្រែបោះបង់

Abandoned field covered by shrub



**4600**

ព្រៃគុម្ពោធនិងដើមឈើដុះរាយប៉ាយ

Shrubland and scattered trees



# កំណត់សំគាល់ និងរូបថតនៃការប្រើប្រាស់ដី (ត-៥)

| Code | ខ្មែរ | English | |
|---|---|---|---|
| 5110 | បឹង | Lake |  |
| 5111 | បឹងមានទឹកជាអចិន្ត្រៃយ៍ | Permanent lake |  |
| 5112 | បឹងមានទឹកតាមរដូវ | Seasonal lake |  |
| 5120 | អាងស្តុកទឹក | Reservoir |  |
| 5130 | ស្រះ | Pond |  |
| 5210 | ទន្លេ | River |  |
| 5211 | ទន្លេមានទឹកជាអចិន្ត្រៃយ៍ | Permanent river |  |
| 5212 | ស្ទឹងមានទឹកតាមរដូវ | Seasonal river |  |
| 5220 | សមុទ្រ | Sea |  |
| 5300 | វាលភក់ | Marsh |  |

## កំណត់សំគាល់ និងរូបថតនៃការប្រើប្រាស់ដី (ត-៦)

| Code | Khmer | English | Photo |
|---|---|---|---|
| 5400 | ស្រែបង្គា ចិញ្ចឹមត្រី | Shrimp/fish farming |  |
| 5410 | ស្រែអំបិល | Salt pond |  |
| 6100 | ដីអត់ជីជាតិ | Barren land |  |
| 6200 | វាលខ្សាច់ | Sand bank |  |
| 6300 | ថ្មផុស | Rock outcrop |  |
| 6410 | កន្លែង អាជីវកម្មថ្ម | Quarry |  |
| 6420 | ព្រៃកាប់អស់ | Cleared forest |  |
| 6430 | ដីដោះមីន | Land recently cleared of landmines |   |

# ឧបសម្ព័ន្ធ ៥ ៖ ការរៀបចំផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ

## ៥.១. ការកំណត់ និងវិភាគបញ្ហា

សាកសួរក្រុមសហគមន៍ និងពិភាក្សាអំពីបញ្ហាដែលពួកគាត់កំពុងប្រឈមមុខនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ បញ្ហាទាំងឡាយបានលើកឡើងក្នុងអំឡុងពេលពិភាក្សា ចាំបាច់ត្រូវសរសេរចូលក្នុងក្រដាសផ្ទាំងធំ (Ao) ដើម្បីអោយអាចទទួលបាននូវការបញ្ជាក់ឡើងវិញពីប្រជាជន។ បញ្ជីត្រួតពិនិត្យសំរាប់ការវិភាគបញ្ហា (ក្នុងតារាងខាងក្រោម) អាចជួយដើម្បីពិនិត្យ និងបញ្ជាក់ថា តើចំណាត់ថ្នាក់នៃបញ្ហាទាំងឡាយត្រូវបានលើកឡើងសំរាប់ការវាយតំលៃចុងក្រោយហើយឬនៅ ។

ប្រការយ៉ាងសំខាន់នៅក្នុងដំណើរការនៃការពិភាក្សាបែបនេះ គឺត្រូវធ្វើយ៉ាងណាឱ្យមានការចូលរួមមតិពីក្រុមស្ត្រី។ វិធីប្រសើរបំផុត ដើម្បីសំរេចនូវគោលបំណងនេះ គឺត្រូវប្រើក្រុមយេនឌ័រតូចៗ ក្នុងអំឡុងពេលនៃការពិភាក្សាបញ្ហា។ ទស្សនៈផ្សេងៗគ្នាក្នុងចំណោមបុរស និងស្ត្រីអាចត្រូវបានដោះស្រាយនៅពេលក្រោយនៅក្នុងក្រុមធំដោយប្រៀបធៀប និងពិភាក្សានូវការយល់ឃើញផ្សេងៗគ្នារវាងបុរស និងស្ត្រី ។ ការពិភាក្សាបែបនេះនឹងជួយលើកឡើងនូវការយល់ដឹងរបស់សហគមន៍ទាក់ទងទៅនឹងបញ្ហាពិសេសៗរបស់ស្ត្រី ហើយធានាថាក្រុមស្ត្រីនឹងទទួលបានការយកចិត្តទុកដាក់យ៉ាងគ្រប់គ្រាន់ ។

នៅពេលដែលបញ្ហាទាំងឡាយត្រូវបានរកឃើញគ្រប់គ្រាន់ហើយ នៅជំហានបន្តគឺកំណត់នូវបណ្តាបញ្ហាទាំងឡាយណាដែលសហគមន៍ចាត់ទុកថា សំខាន់បំផុត ។ បន្ទាប់មក ស្នើសុំសហគមន៍មូលដ្ឋានអោយចាត់ថ្នាក់បណ្តាបញ្ហាទាំងនោះតាមលំដាប់នៃសារៈសំខាន់ ដោយបញ្ជាក់ពីទំហំនៃផលប៉ះពាល់ (តូច មធ្យម ឬធំ)។ ជាចុងក្រោយដាក់លេខរៀងនៃបញ្ហា និងដៅលើផ្ទាំងប្លាស្ទិកដែលគ្របពីលើផែនទីប្រើប្រាស់ដីសាមញ្ញ ។

បញ្ហាដែលជាអាទិភាពទាំងឡាយ អាចត្រូវបានវិភាគ ហើយមូលហេតុចំបងៗក៏ត្រូវបានរកឃើញ ដើម្បីកំណត់នូវដំណោះស្រាយសមស្របសំរាប់បណ្តាបញ្ហាទាំងនោះ។ ការអនុវត្តន៍ការវិភាគបញ្ហាបែបការចូលរួម នឹងផ្តល់នូវផលប្រយោជន៍សំខាន់ៗដូចខាងក្រោម៖

- សហគមន៍ស្វែងយល់បានកាន់តែប្រសើរ អំពីមូលហេតុនៃបញ្ហារបស់ខ្លួន ហើយចាប់ផ្តើមយល់ដឹងអំពីដំណោះស្រាយចំពោះបណ្តាបញ្ហានីមួយៗ។
- ជួយគាំទ្រ ដើម្បីបង្ហាញអោយឃើញថា បញ្ហាជាច្រើនដែលពួកគាត់កំពុងតែប្រឈមមុខជាមួយ ជារៀងរាល់ថ្ងៃ គឺមានពាក់ព័ន្ធទៅនឹងការរិចរិលនៃធនធានធម្មជាតិ។

- ការចូលរួមនឹងផ្តល់ដល់សហគមន៍នូវការទទួលស្គាល់ភាពជាម្ចាស់លើដំណោះស្រាយបញ្ហា ដែលនឹងអាចកើត ចេញពីដំណើរការជាយថាហេតុ ។
- ការធ្វើបែបនេះនឹងពង្រឹងសហគមន៍អោយជួយគ្នាទៅវិញទៅមក ដើម្បីស្វែងយល់ពីមូលហេតុនៃបញ្ហា ដែលពួកគាត់កំពុងតែប្រឈមមុខជាមួយ ហើយនឹងចាប់ផ្តើមរកនូវដំណោះស្រាយចំពោះបញ្ហាទាំងនោះ ។

**បញ្ជីត្រួតពិនិត្យក្រុមចំណាត់ថ្នាក់បញ្ហាសំរាប់ការវិភាគបញ្ហា**

- សុវត្ថិភាពស្បៀង និងកសិកម្ម
- ទឹកប្រើប្រាស់ប្រចាំថ្ងៃ និងសំរាប់កសិកម្ម
- សុខាភាព និងចំណីអាហារ
- ទំហំគ្រួសារ និងកំណើនប្រជាសាស្ត្រ
- ហេដ្ឋារចនាសម្ពន្ធ
- ការសិក្សាអប់រំ និងសាលារៀន
- កំរិតប្រាក់ចំណូល និងភាពក្រីក្រ
- ការទំនាក់ទំនងព័ត៌មាន និងទីផ្សារ

ចំពោះបណ្តាដំណោះស្រាយដែលបានលើកឡើង ចាំបាច់ត្រូវបញ្ជាក់ អំពីពេលវេលាអោយច្បាស់លាស់ ថាតើនៅពេលណាដែលអាចអនុវត្តបាន (រយៈពេលខ្លី <១ឆ្នាំ មធ្យម= ១-៣ឆ្នាំ ឬវែង= ៣-៥ឆ្នាំ) ។ ខាងក្រោមនេះ គឺជាតារាងដែលប្រើប្រាស់សំរាប់វិភាគអាទិភាពនៃបញ្ហាៈ

| អាទិភាព | បញ្ហា | ទំហំនៃបញ្ហា (តូច មធ្យម ធំ) | មូលហេតុ | សំណើដំណោះស្រាយ | សំណើ គំរោង | រយៈពេល (ខ្លី មធ្យម វែង) |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## ៥.២. ជំហានសំរាប់ការវិភាគបញ្ហា



## ៥.៣. ឧទាហរណ៍នៃបញ្ហា និងដំណោះស្រាយ

### បញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់ដី

បញ្ហាកង្វះខាតទឹកស្អាត



បញ្ហាកាប់ និងដុតបំផ្លាញព្រៃឈើ



បញ្ហាគ្មានប្រព័ន្ធបង្ហូរ



បញ្ហាធនធានព្រៃឈើរិចរិល



បញ្ហារាំងស្ងួត/ទិន្នផលស្រូវទាប



បញ្ហាបំពុលបរិស្ថាន



## សំណើដំណោះស្រាយ

ផ្តល់នូវប្រព័ន្ធបង្ហូរ



ផ្តល់នូវប្រព័ន្ធស្រោចស្រព



បង្កើតតំបន់ព្រៃការពារ



បង្កើតមុខរបរចិញ្ចឹមសត្វ



ការចាក់ថ្នាំបង្ការជម្ងឺសត្វ



បង្កើតមុខរបរចិញ្ចឹមសត្វ



បង្កើនការដាំព្រៃឡើងវិញ



បង្កើនការចិញ្ចឹមត្រី



## ឧបសម្ព័ន្ធ ៦ : ការរៀបចំផែនទីបង្ហាញតំបន់មានបញ្ហាចោទ (តំបន់រសើប)

**ដូចម្តេចដែលហៅថា តំបន់មានបញ្ហាចោទ?** គឺជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេស ដោយផ្អែកលើសារៈសំខាន់ ឬជីវចំរុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តំលៃខាងផ្លូវចិត្តដែលមានលក្ខណៈ ដូចជា តំបន់ប្រពៃណីសំរាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងៗទៀត។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ និងធ្វើផែនទី ដើម្បីធានាថា ឃុំ សង្កាត់ត្រូវការដឹងឮ នូវតម្រូវការ និងប្រធានបទពិសេសទាំងនោះ ។

ដូច្នេះ "**ផែនទីបង្ហាញតំបន់មានបញ្ហាចោទ**" គឺអាស្រ័យលើតំបន់ទាំងឡាយដែលទាមទារនូវកិច្ចការពារ និងគ្រប់គ្រងពិសេស នៅពេលណាដែលមានការប្រើប្រាស់តំបន់នេះជាតំបន់អភិវឌ្ឍ សំរាប់ជាជំរើសនៃការប្រើប្រាស់ដីអនាគត ប៉ុន្តែមិនមានន័យថា តំបន់បែបនេះអាចត្រូវបានប្រើសំរាប់ការអភិវឌ្ឍនៅពេលអនាគតទាំងអស់បានឡើយ ដោយសារតែស្ថានភាពរបស់តំបន់ទាំងនោះ។ ផែនទីនេះ អាចបង្ហាញអំពីស្ថានភាពដែលពាក់ព័ន្ធនឹងតំបន់ដូចបានរៀបរាប់ខាងលើ និងបង្ហាញនូវដែនកំណត់ និងលទ្ធភាពនៃការអភិវឌ្ឍសំរាប់ពេលអនាគត។

**ឧទាហរណ៍នៃតំបន់បង្ហាញបញ្ហាចោទមួយចំនួន:** តំបន់ការពារ តំបន់អភិរក្សជីវចំរុះ ព្រៃសំរាប់ការសិក្សាស្រាវជ្រាវ តំបន់សំរាប់ស្តារ ឬដាំព្រៃឡើងវិញ តំបន់ដែលជាប្រភពគ្រាប់ពូជសំរាប់ព្រៃឈើ សហគមន៍ព្រៃឈើ សហគមន៍នេសាទ តំបន់អភិរក្សជំរកត្រី តំបន់សំរាប់ត្រីរស់នៅ និងធ្វើចលនា តំបន់ទីជំរាល តំបន់ព្រៃការពាររបស់សហគមន៍ តំបន់ព្រៃសម្បទាន តំបន់ធ្វើអាជីវកម្មរ៉ែ តំបន់សម្បទានសេដ្ឋកិច្ច តំបន់ឡូត៍នេសាទ ភូមិរបស់ជនជាតិដើមភាគតិច តំបន់បង្ហាញពីគុណភាពទឹករបស់អណ្តូងខួង តំបន់គ្របដណ្តប់គ្រាប់មិនទាន់ផ្ទុះ និងដោយមីន ( UXO[១] ) និងតំបន់កំពុងធ្វើសកម្មភាពដោះមីន និងគ្រាប់មិនទាន់ផ្ទុះ គុណភាពដី តំបន់រងគ្រោះដោយទឹកជំនន់ និងតំបន់ដែលមានជំរាលខ្លាំង ។

**តើផែនទីបង្ហាញតំបន់មានបញ្ហាចោទត្រូវរៀបចំនៅពេលណាក្នុងដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីឃុំ សង្កាត់?** ការរៀបចំផែនទីនេះ ចែកចេញជាពីរដំណាក់កាលៈ ទី១- រៀបចំនៅថ្នាក់ខេត្ត ក្រោមការគាំទ្រពីមន្ទីរពាក់ព័ន្ធទាំងអស់ អង្គការ NGOs មន្ត្រីឯកទេស (ការិយាល័យពតិមានភូមិសាស្ត្រ) និងទី២- ក្នុងអំឡុងពេលនៃការវិភាគបញ្ហា/មូលហេតុ/ដំណោះស្រាយ (ដោយផ្អែកលើទិន្នន័យថ្នាក់ជាតិ និងធ្វើបច្ចុប្បន្នភាពជាមួយចំណេះដឹងមូលដ្ឋាន) ។

**តើត្រូវរៀបចំផែនទីបង្ហាញតំបន់មានបញ្ហាចោទដោយរបៀបណា?** ផែនទីបង្ហាញតំបន់មានបញ្ហាចោទត្រូវបានរៀបចំឡើងនៅក្នុងការងារ-0: ការងាររៀបចំ ។ ផ្អែកលើបទពិសោធន៍ពីគំរោងបែងចែកដី/LASED ដែលបានរៀបចំឡើងក្នុងខែ ឧសភា ឆ្នាំ ២០០៨ ក្នុងខេត្តកំពង់ធំ ដំណើរការនៃការរៀបចំផែនទីបង្ហាញតំបន់មានបញ្ហាចោទអាចត្រូវបានរៀបចំដូចខាងក្រោម:

- ប្រមូលទិន្នន័យស្ថាប័នរដ្ឋាភិបាលមួយចំនួន អង្គការ/ស្ថាប័នពាក់ព័ន្ធ NGOs អង្គការសហប្រតិបត្តិការអន្តរជាតិ (រយៈពេល ០២សប្តាហ៍) ។

(១) Un-Exploided Ordnance

- រៀបចំផែនទីបង្ហាញតំបន់មានបញ្ហាចោទ (ប្រើប្រព័ន្ធពត៌មានភូមិសាស្ត្រ) សំរាប់សិក្ខាសាលាប្រើរយៈពេលប្រហែល ០១ សប្តាហ៍ ។
- រៀបចំសិក្ខាសាលា ធ្វើបទបង្ហាញទិន្នន័យដល់ស្ថាប័នពាក់ព័ន្ធ អង្គការ/ស្ថាប័នពាក់ព័ន្ធ NGOs និងវិស័យឯកជន ប្រើរយៈពេល ០១ ថ្ងៃ លើប្រធានបទមួយចំនួនដូចខាងក្រោម:
  - ដូចម្តេចដែលហៅថា តំបន់មានបញ្ហាចោទ?
  - ហេតុអ្វីបានជាចាំបាច់ត្រូវរៀបចំផែនទីបង្ហាញតំបន់មានបញ្ហាចោទ?
  - ការងាររៀបចំសំរាប់សិក្ខាសាលា (ធ្វើការជាក្រុម) រួមមាន ការកំណត់កាលបរិច្ឆេទ រៀបចំលិខិតអញ្ជើញ ប្រើរយៈពេលប្រហែល ០២សប្តាហ៍ ។
  - **ខ្លឹមសារនៃការពិភាក្សាក្នុងសិក្ខាសាលា:**
    - តើតំបន់ដែលមានបញ្ហាចោទ មានទីតាំងនៅលើផែនទីត្រង់ចំណុចណា ?
    - តើនៅមានតំបន់មានបញ្ហាចោទផ្សេងៗទៀតទេដែលមិនបានបង្ហាញនៅលើផែនទីនេះ?
    - តើនៅកន្លែងណាដែលមានទំនាស់រវាងតំបន់មានបញ្ហាចោទនានា (កន្លែងត្រួតស៊ីគ្នា) ?
    - តើត្រូវដោះស្រាយតំបន់ត្រួតស៊ីគ្នាទាំងនេះដោយរបៀបណា?
    - ពិនិត្យលើតំបន់មានបញ្ហាចោទផ្នែកបរិស្ថានទាំងអស់(តំបន់ការពារ សហគមន៍ព្រៃឈើ សហគមន៍នេសាទតំបន់ការពាររបស់សហគមន៍(CPA[២]) និងព្រៃការពារផ្សេងៗទៀត តំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប និងតំបន់ធ្វើកសិកម្មចំរុះ និងជីវចំរុះ (IFBA[3]) ដែលមាននៅលើផែនទី និងពិភាក្សាលំអិតអំពីព្រំប្រទល់ និងស្ថានភាពផ្សេងៗទៀត ដើម្បីបញ្ជាក់ថា ការបង្ហាញនេះត្រឹមត្រូវ ឬអត់ ។
    - ពិនិត្យលើតំបន់មានបញ្ហាចោទផ្នែកសេដ្ឋកិច្ច (តំបន់សម្បទានសេដ្ឋកិច្ច ព្រៃសម្បទាន តំបន់រុករក ឬធ្វើអាជីវកម្មរ៉ែ តំបន់ឡូត៍នេសាទ) ដែលមាននៅលើផែនទី និងពិភាក្សាលំអិត អំពីព្រំប្រទល់ និងស្ថានភាព ផ្សេងៗទៀត ដើម្បីបញ្ជាក់ថា ការបង្ហាញនេះត្រឹមត្រូវ ឬអត់ ។
    - កែសំរួល និងគូរឡើងវិញនៅលើច្បាប់ចំលងនៃផែនទីនេះនូវ ទីតាំង ព្រំប្រទល់ និងផ្នែកផ្សេងៗទៀត ដែលបានកែប្រែ (ប្រើពេលប្រហែល ០២សប្តាហ៍)
    - រៀបចំសិក្ខាសាលាបញ្ចប់ ដើម្បីបង្ហាញលទ្ធផលនៃផែនទីបង្ហាញតំបន់មានបញ្ហាចោទដែលបានកែសំរួលរួច (ប្រើរយៈពេល ១/២ថ្ងៃ)
    - បោះពុម្ពផែនទីបង្ហាញតំបន់មានបញ្ហាចោទក្នុងទំរង់ A0 សំរាប់មន្ទីរពាក់ព័ន្ធ អង្គការ/ស្ថាប័ន និង NGOs ដែលបានចូលរួមក្នុងសិក្ខាសាលា។ រក្សាទិន្នន័យ និងឯកសារទាំងអស់នៅក្នុងការិយាល័យ GIS/សមាសភាគរៀបចំផែនដីខេត្ត ។

---

(២) CPA- Community Protected Areas

(៣) IFBA- Itergrated Farming and Biodiversity Areas

## ផែនទីបង្ហាញតំបន់មានបញ្ហាចោទ (តំបន់រសើប)តាមវិស័យរបស់ខេត្តកំពង់ធំ

### បញ្ហាចោទផ្នែកសេដ្ឋកិច្ច




### បញ្ហាចោទផ្នែកបរិស្ថាន




### បញ្ហាចោទផ្នែកធារាសាស្ត្រ/ជលសាស្ត្រ




### បញ្ហាចោទផ្នែកគំរបដី




### បញ្ហាចោទផ្នែកសង្គម និងវប្បធម៌




### បញ្ហាចោទផ្នែកទីជំរាល



បញ្ហាចោទផ្នែកធនធានដី




បញ្ហាចោទផ្នែកគ្រាប់មិនទានផ្ទុះ និងមីន




ផែនទីបង្ហាញតំបន់មានបញ្ហាចោទរួម(តំបន់រសើប)របស់ខេត្តកំពង់ធំ



## ឧបសម្ព័ន្ធ ៧ : ការវិភាគដីសមស្រប និងជំរើសនៃការប្រើប្រាស់ដីពេលអនាគត

ការវិភាគដីសមស្របបឋម នឹងត្រូវធ្វើឡើងក្នុងការងារ (**Task-B**) និង (**Task-D**) គឺជាការវាយតំលៃបែបសាមញ្ញ (បែបរហ័ស) ដោយផ្អែកលើធនធានដី រយៈកំពស់ ជំរាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីពេលអនាគត អាស្រ័យលើចំណេះដឹងមូលដ្ឋាន និងបច្ចេកទេសមួយចំនួនដែលអាចមាននៅលើផែនទីថ្នាក់រាជធានី ខេត្ត។

ការវិភាគដីសមស្របនេះ នឹងប្រើសំរាប់រៀបចំផែនទីប្រើប្រាស់ដីពេលអនាគតក្នុងឃុំ សង្កាត់ ដែលបង្ហាញពីជំរើសនៃការប្រើប្រាស់ដីពេលអនាគត។ ការវិភាគនេះ នឹងត្រូវដឹកនាំសម្របសម្រួលដោយថ្នាក់ឃុំ សង្កាត់ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ការទ្រទ្រង់បច្ចេកទេសមួយចំនួនគួរតែត្រូវបានគាំទ្រដោយអ្នកឯកទេសមកពីមន្ទីរកសិកម្ម។ ការវិភាគដីសមស្របបែបស៊ីជំរៅនឹងត្រូវធ្វើនៅពេលក្រោយ ជាពិសេសចំពោះតំបន់ដែលមានបញ្ហាចោទ និងសំរាប់តំបន់សម្បទានសេដ្ឋកិច្ច ។

### ៧.១. ហេតុអ្វីចាំបាច់ត្រូវវិភាគដីសមស្រប?

ការវិភាគដីសមស្រប អាចផ្តល់ដល់អ្នកប្រើប្រាស់ដី និងអ្នករៀបចំផែនការប្រើប្រាស់ដី នូវឱកាសដើម្បីធ្វើការគ្រប់គ្រងដីបានប្រសើរបំផុត សំរាប់គោលបំណងនានា ឬធ្វើអោយសមស្របសំរាប់គោលបំណងជាក់លាក់ណាមួយ ។ ការវិភាគដីសមស្រប ទាមទារនូវការផ្គូរផ្គងរវាងលក្ខខ័ណ្ឌរបស់ដី (អាកាសធាតុ ដី និងគំរបរុក្ខជាតិ ។ល។) ជាមួយ នឹងតម្រូវការនៃគោលបំណង។ ជំរើសមួយចំនួនដែលត្រូវបានគិតគូរក្នុងការវាយតំលៃដីសមស្រប អាចត្រូវបានកំរិត ដោយកត្តារូបវ័ន្ត និងកត្តាសេដ្ឋកិច្ច-សង្គម ឬត្រូវបានបន្ថែមដោយកត្តាផ្សេងទៀតដូចជាលទ្ធភាពរបស់ប្រព័ន្ធ ស្រោចស្រព/ប្រព័ន្ធបង្ហូរទឹក ។ល។ ការដឹងពីការកំរិត និងជំរើសមួយចំនួនខាងលើអាចធ្វើអោយអ្នកប្រើប្រាស់ដី ឬ អ្នករៀបចំផែនការប៉ាន់ប្រមាណ អំពីផលប្រយោជន៍ក្នុងរយៈពេលខ្លី និងវែងបាន។ សេចក្តីសំរេចចិត្តថាតើនឹងត្រូវធ្វើអ្វីនៅលើដីនោះត្រូវតែស្ថិតក្នុងក្របខ័ណ្ឌនៃការរៀបចំផែនការប្រើប្រាស់ និងគ្រប់គ្រងដីប្រកបដោយនិរន្តភាព តែមិនមែនជានិច្ចកាលតម្រូវទៅតាមការដែលត្រូវទទួលបានតែផលិតភាពខ្ពស់មួយមុខនោះទេ។

ការវាយតំលៃដីសមស្រប មានសារៈសំខាន់ណាស់ចំពោះដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅថ្នាក់មូលដ្ឋាន។ ការគាំទ្របច្ចេកទេសពីថ្នាក់រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ គឺជាការចាំបាច់ណាស់ ដើម្បីផ្តល់ដល់សហគមន៍មូលដ្ឋាននូវជំរើសមួយចំនួន ដូចជាភាពសំបូរបែបនៃដំណាំធញ្ញជាតិ ឬដំណាំឈើហូបផ្លែ លទ្ធភាពទឹក (តាមរយៈការស្រោចស្រព) ការប្រើប្រាស់ស្រះរបស់សហគមន៍ (ការបង្កើតគណៈកម្មាធិការសហគមន៍នេសាទ)។

ទិដ្ឋភាពរួមនៃដីសមស្របបែបសាមញ្ញមួយរបស់ឃុំ សង្កាត់ត្រូវបានរៀបចំបង្ហាញជាផែនទីបាន ដូច្នេះធ្វើអោយសហគមន៍មូលដ្ឋាន ឃុំ សង្កាត់ និង ស្រុក ខណ្ឌអាចចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តបាន ។

## ៧.២. មុនពេលវិភាគដីសមស្របត្រូវគិតគូរដូចខាងក្រោមៈ

- ចំណេះដឹងរបស់ប្រជាជននៅក្នុងតំបន់ជនបទ អំពីសក្តានុពលនៃភាពសមស្របរបស់ដី គឺមានកំរិតបំផុត ។
